# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ១




វត្តនិគ្រោធវ័ន "គល់ទទឹង"

# អភិធម្មត្ថសង្គហៈ

# បរិច្ឆេទទី ១

*រៀបរៀងដោយ*

**ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

*ព.ស. ២៥៥៥*

ឈ្មោះសៀវភៅ **អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ១**

រៀបរៀងដោយ ភិក្ខុ **អគ្គធីរោ គង់ សុមិត្ត**

ផ្ទៀងផ្ទាត់ដោយ ភិក្ខុ ធម្មបាលោ សាន សប្បាយ

ភិក្ខុ វជិរប្បញ្ញោ គូ សុភាព

ភិក្ខុ ធម្មជោតោ អ៊ុម សុទ្ធា

សាមណេរ ញ៉ិប យ៉ន្ត

សាមណេរ នៅ ហៃឡុន

ឧបាសិកា អ៊ុង គឹមសេ៉

កាលបរិច្ឆេទ ព.ស. ២៥៥៥

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន

"គល់ទទឹង" សង្កាត់ព្រែកថ្មី

ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

# សម្ដែងព្រះអភិធម្ម នៅឋានតាវត្តិង្ស

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ចាំព្រះវស្សាទី៧ នៅឋានតាវត្តិង្សទេវលោក ក្នុងគ្រាដែលបានសំដែងយមកបាដិហារ្យផ្ចាញ់ពួកតិរ្ថិយរួចហើយ បានគង់លើសិលាសនៈ ឈ្មោះបណ្ឌុកម្ពល ក្រោមដើមបារិឆត្ត ទ្រង់ព្រះសិរីសោភា ដូចព្រះអាទិត្យឧទ័យឡើងលើភ្នំយុគន្ធរ ដែលពួកនៃទេវតាទាំងឡាយក្នុងម៉ឺនចក្រវាឡបានមកប្រជុំគ្នា ហែហមសម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់ធ្វើសន្ទុសិតទេវបុត្រដែលធ្លាប់ជាពុទ្ធមាតា ឱ្យជាប្រធាននៃពួកទេវតាទាំងឡាយ ហើយត្រាស់កថាមគ្គព្រះអភិធម្មថា "**កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា**"ជាដើម ទ្រង់សម្ដែងដោយន័យនេះ ជាប់តរហូតអស់មួយព្រះវស្សា ដោយតេជៈនៃព្រះសព្វញ្ញុតញ្ញាណនោះ ។ ក៏កាលដែលទ្រង់សម្ដែងធម៌នោះ ក្នុងវេលាភិក្ខាចារទ្រង់និម្មិតព្រះពុទ្ធនិមិត្តដោយទ្រង់អធិដ្ឋានថា "ព្រះពុទ្ធនិមិត្ត

នេះ ចូរសម្តែងធម៌ ឈ្មោះប៉ុណ្ណោះ ដរាបដល់តថាគតមក” ហើយក៏ស្តេចយាងទៅព្រៃហេមពាន្ត ទ្រង់ទំពាឈើស្ទន់ ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋក្នុងស្រះអនោតត្ត នាំបិណ្ឌបាត អំពីឧត្តរកុរុទ្វីប បានធ្វើភត្តកិច្ចក្នុងរោងជំទូលាយហើយ ។ ព្រះសារីបុត្រទៅធ្វើវត្តចំពោះព្រះសាស្តាក្នុងទីនោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជាទេវតារបស់ទេវតា ជាអ្នកនាំវិសេសអង្គនោះ កាលទ្រង់សំដែងអភិធម្មណា ដល់ទេវតាទាំងឡាយហើយ ក៏បានត្រាស់ប្រាប់ដល់ព្រះសារីបុត្តត្ថេរ អ្នកឧបដ្ឋាកព្រះមហេសីជាម្ចាស់ ក្នុងអនោតត្តស្រះ ដោយន័យ (សង្ខេប)ទៀតថា “ម្នាលសារីបុត្រ ថ្ងៃនេះតថាគតបានសម្តែងធម៌ឈ្មោះប៉ុណ្ណោះ អ្នកចូរប្រាប់ដល់(ភិក្ខុ ៥០០) ជាកូនសិស្សរបស់អ្នក” ព្រះថេរៈបានស្តាប់ហើយ ក៏បាននិមន្តមកកាន់លំនៅឋាន ហើយប្រាប់ដល់ភិក្ខុទាំងឡាយ, ព្រះអភិធម្មនោះ ដែលភិក្ខុទាំងឡាយបានទ្រទ្រង់ចាំទុកហើយ ដោយប្រការយ៉ាងនេះ ។

# ជីវប្រវត្តិសង្ខេប

ភិក្ខុ **គង់-សុមិត្ត** គង់នៅពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន គល់ទទឹង

ញោមប្រុស ឈ្មោះ គង់-តិក(ស្លាប់) ញោមស្រី ឈ្មោះ ហុក-តាង រស់នៅក្នុងភូមិខ្វិត ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

កើតនៅថ្ងៃព្រហស្បតិ៍ ៩ កើត ខែមិគសិរ ឆ្នាំ ថោះ ព.ស. ២៥១៩ - គ.ស. ១៩៧៦ ។ មានបងប្អូន ៧ នាក់ គឺ ប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ

ក្នុងកុមារ បានចូលរៀនសាលារដ្ឋ (ក្តាំងផា និង ព្រែកហ្លួង)ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរ ក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡយ-លឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។

ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទាជាភិក្ខុភាវៈ ។ ព.ស. ២៥៣៩ មកគង់នៅវត្តសមសាន្ត (ខេត្តបាត់ដំបង) រៀនវិន័យ-អភិធម្ម ។ ព.ស. ២៥៤០ មកនៅវត្តនិគ្រោធវ័ន ខេត្តកណ្ដាល រៀនធម៌វិន័យបន្ត ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន (ខេត្តកំបាម) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌-វិន័យ ។ ព.ស. ២៥៤៦ បានបួសជាសាមណេរវិញទៀត ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម ឃី-ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្ដាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។ ព.ស. ២៥៤៧ បានឧបសម្បទាជាភិក្ខុ បានបង្រៀនព្រះវិន័យដល់ព្រះសង្ឃ បង្រៀនអភិធម្មដល់ដូនជី ក្នុងវត្តនិគ្រោធវ័ន និងខិតខំរៀបចំសៀវភៅធម៌-វិន័យរហូតមក ។

# អភិធម្មត្ថសង្គហកថា

គម្ពីរអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ព្រះអនុរុទ្ធាចារ្យ បានចងក្រងឡើង ។

អភិធម្មត្ថសង្គហៈ មាន ៩ បរិច្ឆេទ គឺ

បរិច្ឆេទទី១ ចិត្តសង្គហវិភាគ ការសម្តែងសង្គ្រោះនិង
ចែកចិត្ត ៨៩ ឬ១២១

បរិច្ឆេទទី២ ចេតសិកសង្គហវិភាគ ការសម្តែងសង្គ្រោះនិង
ចែកចេតសិក ៥២

បរិច្ឆេទទី៣ បកិណ្ណកសង្គហៈ ការសម្តែងសង្គ្រោះនិង
ចែកបកិណ្ណក ៦ ពួក

បរិច្ឆេទទី៤ វិថីសង្គហវិភាគ ការសម្តែងសង្គ្រោះនិង
ចែកវិថីចិត្ត

បរិច្ឆេទទី៥ វិថីវិមុត្តសង្គហវិភាគ ការសម្តែងសង្គ្រោះនិង
ចែកវិថីវិមុត្ត

បរិច្ឆេទទី៦ រូបសង្គហវិភាគ-និព្វានបរមត្ថ ការសម្ដែងសង្គ្រោះ
និងចែករូបនិងនិព្វាន

បរិច្ឆេទទី៧ សមុច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិង
ចែកពួកធម៌ជាក្រុម ៗ

បរិច្ឆេទទី៨ បច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិង
ចែកបច្ច័យ១២ និង២៤

បរិច្ឆេទទី៩ កម្មដ្ឋានវិភាគ ការសម្ដែងចែកកម្មដ្ឋាន
៤០ និងវិបស្សនា ។

សៀវភៅអភិធម្មនេះ ព្រះអនុរុទ្ធាចារ្យបានប្រមូលចង
ក្រងអំពីបិដក និងអដ្ឋកថា ហើយបានចែកជាបរិច្ឆេទតាម
ប្រភេទនៃបរមត្ថធម៌ ដើម្បីងាយស្រួលក្នុងការសិក្សា គឺ
បរិច្ឆេទទី១ សម្ដែងចិត្តបរមត្ថ, បរិច្ឆេទទី២ សម្ដែងចេតសិក
បរមត្ថ, បរិច្ឆេទទី៣, ៤, ៥ សម្ដែងចិត្តបរមត្ថ និងចេតសិក
បរមត្ថរួមគ្នា, បរិច្ឆេទទី ៦ សម្ដែងរូបបរមត្ថ, និងនិព្វាន
បរមត្ថ, បរិច្ឆេទទី៧, ៨, ៩ សម្ដែងបរមត្ថទាំង ៤ រួមគ្នា ។

# បុព្វកថា

សៀវភៅអភិធម្មនេះ ខ្ញុំបានសរសេរក្នុងព.ស. ២៥៤៥ ចប់នៅក្នុងព.ស. ២៥៤៧ ។ ព.ស. ២៥៥២ បានរៀបចំជាសៀវភៅធំ ឈ្មោះថា អភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ។ ព.ស. ២៥៥៥ ដោយសេចក្តីត្រូវរបស់អ្នកសិក្សា ក៏បានចែកតាមបរិច្ឆេទនីមួយ ៗវិញ ដើម្បីងាយកាន់សិក្សា ។

ការរៀបចំសៀវភៅអភិធម្មត្ថសង្គហៈនេះ បានចប់សព្វគ្រប់ ហើយ បើមានពាក្យឬសេចក្តីណានៅខុស ក៏សូមអភ័យទោស និងសូមមេត្តាកែ សម្រួលផងចុះ ។

គម្ពីរព្រះអភិធម្ម ជាគម្ពីរដែលសម្តែងឡើងនូវធម៌ពិត គឺ សច្ចធម៌ បរមត្ថធម៌ និងបង្ហាញនូវផ្លូវបដិបត្តិឆ្ពោះទៅរកទីរំលត់ទុក្ខ គឺ ព្រះនិព្វាន ។ សត្វលោកដែលកើតមកសុទ្ធតែមានអវិជ្ជា និងតណ្ហាគ្រប់គ្នា មានតែព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធទេ ដែលអាចត្រាស់ដឹងនូវធម៌ពិត កម្ចាត់អវិជ្ជាបានដោយខ្លួន

ព្រះអង្គឯង ក្រៅពីនោះ ត្រូវតែអាស្រ័យព្រះពុទ្ធ ដែលទ្រង់មានព្រះទ័យមហាករុណាសម្តែងប្រាប់ ទើបអាចយល់ដឹងស្គាល់ធម៌ពិត និងបានឃើញផ្លូវបដិបត្តិដល់ព្រះនិព្វានជាទីរំលត់ទុក្ខបាន ។

កាលបើពុទ្ធបរិស័ទទាំងអស់ សិក្សានូវព្រះអភិធម្មបានយល់ដឹងហើយ បញ្ញាក៏កើតឡើង បានឃើញនូវសភាវធម៌ពិតទាំងដែលយើងសព្វថ្ងៃបានជួប បានទាន់ព្រះធម៌កំពុងឋិតនៅសម្រាប់ក្រេបជញ្ជក់ធម្មរស ហើយធ្វើឱ្យយើងមានសម្រស់ក្នុងជីវិត មិនឋិតនៅក្នុងភាពស្ងិតស្រពោន និងសម្រេចមគ្គផលតាមឧបនិស្ស័យដែលយើងបានសន្សំមក, ព្រោះហេតុដូច្នេះទើបខ្ញុំព្យាយាមរៀបចំសៀវភៅនេះឡើង ។ ម្យ៉ាងទៀត សៀវភៅនេះ ក៏ដូចជាសាវកមួយអង្គដែលឈ្លាសវៃនាំយកព្រះពុទ្ធដីកាមកប្រាប់ ហើយពន្យល់សេចក្តីនោះ ឱ្យយើងបានយល់ដឹងឬចាត់ថា ជាគ្រូក៏បាន ។

ការរៀបចំសៀវភៅធម៌នេះ ជាបុណ្យកុសលមួយយ៉ាងល្អប្រសើរ ដែលខ្ញុំព្រះករុណា អាត្មាភាព និងពុទ្ធបរិស័ទទាំងឡាយ បានរួបរួមសាមគ្គីជួយឧបត្ថម្ភ ដោយកម្លាំងកាយចិត្ត និងថវិកា ជាចេតនាមហាកុសលថ្នាក់ធម្មទាន និងធម្មបូជា យ៉ាងពេញចិត្តគ្រប់ ៗគ្នា ។ ដោយអំណាចនៃបុណ្យនេះ នឹងនាំឱ្យបានទទួលនូវសេចក្តីសុខ ជាពិសេស គឺបាននូវបញ្ញាដែលជាពន្លឺញាំងជីវិតឱ្យរុងរឿងគ្រប់ ៗ ជាតិរហូតដល់បានលះបង់នូវមន្ទិលគឺ កិលេស ដែលយើងគ្រប់ ៗ គ្នាចង់បាននូវ ការត្រាស់ដឹងនូវសច្ចធម៌ ឃើញច្បាស់នូវព្រះនិព្វាន ដែលជាទីបំផុតទុក្ខ ។ ម្យ៉ាងទៀតបញ្ញានេះឯង អាចឱ្យសម្រេចតាមសេចក្តីប្រាថ្នានោះបាន ។

ខ្ញុំព្រះករុណាអាត្មាភាព សូមអនុមោទនានូវបុណ្យកុសលរបស់ពុទ្ធបរិស័ទ ទាំងអស់ ដែលបានឧបត្ថម្ភថវិកាជាធម្មទាន និងការខិតខំសិក្សានេះ ។ ម្យ៉ាងទៀត សូមពុទ្ធ

បរិស័ទទាំងអស់ អនុមោទនាយកនូវបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានរៀបចំបោះពុម្ពព្រះអភិធម្មនេះផងចុះ ។ សូមឱ្យពុទ្ធបរិស័ទទាំងអស់ មានបញ្ញា ភ្លឺថ្លាមោះមុត ជាគ្រឿងត្រាស់ដឹងនូវសច្ចធម៌ សូមបានសម្រេចនូវសម្បត្តិលោកិយៈ និងលោកុត្តរៈ មានចិត្តល្អបរិសុទ្ធរួចផុតចាកទុក្ខ ដល់ព្រះនិព្វានគ្រប់ ៗ គ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអនុមោទនា !!!

ថ្ងៃ១៥កើត ខែស្រាពណ៍ ឆ្នាំថោះ ត្រីស័ក ព.ស.២៥៥៥

# ឯកសារវិគ្រោះ

| អក្សរកាត់ | អក្សរពេញ | ភាគគម្ពីរ |
|---|---|---|
| ទីឃ. មហា. | ទីឃនិកាយ មហាវគ្គ | បិដកភាគ ១៦. ១៧. |
| មជ្ឈិ. មូល. | មជ្ឈិមនិកាយ មូលបណ្ណាសក | បិដកភាគ ២០. ២១. |
| មជ្ឈិ. មជ្ឈិ. | មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក | បិដកភាគ ២៣. |
| មជ្ឈិ. ឧប. | មជ្ឈិមនិកាយ ឧបរិបណ្ណាសក | បិដកភាគ ២៦. ២៨. |
| សំយុ. និទា. | សំយុត្តនិកាយ និទានវគ្គ | បិដកភាគ ៣២ |
| សំយុ. ខន្ធ. | សំយុត្តនិកាយ ខន្ធវារវគ្គ | បិដកភាគ ៣៣ |
| សំយុ. មហា. | សំយុត្តនិកាយ មហាវារវគ្គ | បិដកភាគ ៣៧. ៣៨. ៣៩. |
| អង្គុ. តិក. | អង្គុត្តរនិកាយ តិកនិបាត | បិដកភាគ ៤១ |
| អង្គុ. ចក្ក. | អង្គុត្តរនិកាយ ចតុក្កនិបាត | បិដកភាគ ៤២ |
| អង្គុ. បញ្ច. | អង្គុត្តរនិកាយ បញ្ចកនិបាត | បិដកភាគ ៤៥ |
| អង្គុ. ឆក្ក. | អង្គុត្តរនិកាយ ឆក្កនិបាត | បិដកភាគ ៤៦ |
| អង្គុ. អដ្ឋ. | អង្គុត្តរនិកាយ អដ្ឋកនិបាត | បិដកភាគ ៤៨ |
| ខុទ្ទ. ធម្ម. | ខុទ្ទកនិកាយ ធម្មបទ | បិដកភាគ ៥២ |
| ខុទ្ទ. សុត្ត. | ខុទ្ទកនិកាយ សុត្តនិបាត | បិដកភាគ ៥៤ |
| ខុទ្ទ. មហា. | ខុទ្ទកនិកាយ មហានិទ្ទេស | បិដកភាគ ៦៤. ៦៦. |

| អក្សរកាត់ | អក្សរពេញ | ភាគគម្ពីរ |
|---|---|---|
| អភិ. សង្គ. | អភិធម្ម ធម្មសង្គណី | បិដកភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្ម វិភង្គ | បិដកភាគ ៨០. ៨១. ៨២. |

សុមង្គលវិលាសិនី អដ្ឋកថានៃទីឃនិកាយ សីលក្ខន្ធវគ្គ

បបញ្ចសូទនី អដ្ឋកថានៃមជ្ឈិមនិកាយ មូលបណ្ណាសក, ឧបរិបណ្ណាសក,

សារត្ថប្បកាសិនី អដ្ឋកថានៃសំយុត្តនិកាយ មហាវារវគ្គ

មនោរថបូរណី អដ្ឋកថានៃអង្គុត្តរនិកាយឯកនិបាត ទុកនិបាត អដ្ឋកនិបាត

សទ្ធម្មប្បកាសិនី អដ្ឋកថានៃខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

អដ្ឋសាលិនី អដ្ឋកថានៃអភិធម្ម ធម្មសង្គណី

សម្មោហវិនោទនី អដ្ឋកថានៃអភិធម្ម វិភង្គ

បញ្ចបករណៈ អដ្ឋកថានៃអភិធម្ម បុគ្គលបញ្ញត្តិ

សុពោធាលង្ការ,

វិភាវិនីដីកា, មូលដីកា,

លេខដែលនៅបន្ទាប់គឺ ខាងដើមជាភាគគម្ពីរ កណ្តាលជាលេខឃ្នាប ខាងចុងជាលេខទំព័រ ឧទាហរណ៍ : ៣១. ៦៦/៦១ គឺ បិដកភាគ ៣១ លេខឃ្នាប ៦៦ ទំព័រ ៦១ ។

# បញ្ជីមាតិកា អភិធម្មត្ថសង្គហៈ

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


សម្ដេចព្រះអភិធម្ម នៅឋានតាវត្តិង្ស ... ... ... ... ... ... ... ក

ជីវប្រវត្តិសង្ខេបគ ... ... ... ... ... ... ... ... ... ... ... ... ... គ

អភិធម្មត្ថសង្គហកថា ... ... ... ... ... ... ... ... ... ... ... ... ... ង

បុព្វកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ឆ

ឯកសារយោគ្រោះ ... ... ... ... ... ... ... ... ... ... ... ... ... ... ដ

បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ឌ


**អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ១ ចិត្តសង្គហវិភាគ**


គាថាបករណ៍ អភិធម្ម ១៧ គាថា ... ... ... ... ... ... ... ... ១

អធិប្បាយ គាថាបករណ៍ អភិធម្ម ១៧ គាថា ... ... ... ... ១៩

ទី១ គាថាផ្ដើមបករណ៍ ... ... ... ... ... ... ... ... ... ១៩

គាថាផ្ដើមបករណ៍ មាន ៦ បទ ... ... ... ... ២០

សេចក្ដីពន្យល់ក្នុងគាថា ... ... ... ... ... ... ... ២១

អធិប្បាយផលសម្បទា ៤ យ៉ាង ... ... ... ... ២៥

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

សង្គហគាថាទី២ បរមត្ថធម៌៤ ... ... ... ... ... ... ... ២៩
ពណ៌នាសេចក្ដីក្នុងគាថាទី២ ... ... ... ... ... ២៩
អធិប្បាយពាក្យថា បរមត្ថ ... ... ... ... ... ... ៣០
បរមត្ថធម៌ មាន ២ យ៉ាង ... ... ... ... ... ... ៣១
សច្ចៈ សេចក្ដីពិត ២ យ៉ាង ... ... ... ... ... ៣២
ហេតុដែលនាំឱ្យទ្រង់ត្រាស់សម្មុតិសច្ចៈ ... ... ៣៣
ចិត្តបរមត្ថ ... ... ... ... ... ... ... ... ... ... ... ... ៣៤
លក្ខណៈរបស់ចិត្ត ... ... ... ... ... ... ... ... ៣៦
លក្ខណាទិចតុក្កៈរបស់ចិត្ត ... ... ... ... ... ... ៣៦
អំណាចចិត្ត ... ... ... ... ... ... ... ... ... ... ... ៣៧
ចែកចិត្ត ៨៩ ដោយន័យផ្សេង ៗ ... ... ... ៤២
ចេតសិកបរមត្ថ ... ... ... ... ... ... ... ... ... ... ... ៤៣
រូបបរមត្ថ ... ... ... ... ... ... ... ... ... ... ... ... ... ... ៤៦
និព្វានបរមត្ថ ... ... ... ... ... ... ... ... ... ... ... ... ៥២

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

អធិប្បាយចិត្តបរមត្ថ … … … … … … … … … … ៥៤
សម្តែងចិត្ត ៤ យ៉ាង … … … … … … … … … ៥៤
គាថាសម្តែងអត្ថរបស់កាមាវចរចិត្ត … … … … ៥៨
ចិត្តមានប្រភេទទាបខ្ពស់ជាងគ្នា ៤ យ៉ាង … ៦០
ចែកកាមាវចរចិត្តជា ៣ ប្រភេទ … … … … ៦១
កាមាវចរចិត្ត … … … … … … … … … … … … … … … ៦៣
១, អកុសលចិត្ត ១២ … … … … … … … … … … … ៦៣
សង្គហគាថាទី៣ … … … … … … … … … … … … ៦៣
អធិប្បាយ … … … … … … … … … … … … … … ៦៣
លោភមូលចិត្ត ៨ … … … … … … … … … … … ៦៤
ទោសរបស់លោភសហគតចិត្ត … … … … … ៦៦
អធិប្បាយ បាលីលោភមូលចិត្តទី ១, ២, … ៦៨
អធិប្បាយ លោភមូលចិត្តទី ៣. ៤. … … … ៧១
អធិប្បាយ លោភមូលចិត្តទី ៥. ៦. ៧. ៨. ៧២

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


លក្ខណាទិចតុក្កៈរបស់លោភៈ ... ... ... ... ... ៧៦
ហេតុឱ្យកើតលោភមូលចិត្ត មាន ៤ ... ... ៧៧
ហេតុឱ្យកើតលោភៈសោមនស្ស មាន ៤ ... ៨២
ព្យសនៈ ការវិនាស ៥ យ៉ាង ... ... ... ... ៨៥
ហេតុឱ្យកើតឧបេក្ខា ៤ យ៉ាង ... ... ... ... ... ៨៦
ហេតុឱ្យកើតទិដ្ឋិគតសម្បយុត្តចិត្ត ៥ ... ... ៨៨
អកុសលវិតក្កៈ មាន ៣ ... ... ... ... ... ... ៩៥
ហេតុឱ្យកើតទិដ្ឋិវិប្បយុត្តចិត្ត ៥ យ៉ាង ... ... ៩៧
ហេតុឱ្យកើតអសង្ខារិកចិត្ត ៦ យ៉ាង ... ... ៩៨
ហេតុឱ្យកើតសសង្ខារិកចិត្ត ៦ ... ... ... ... ១០៣
ចែកលោភមូលចិត្ត ៨ ដោយន័យផ្សេង ៗ ១០៦
វិបាកចិត្តដែលកើតពីលោភមូលចិត្ត ... ... ... ១០៧
ទោសមូលចិត្ត ២ ... ... ... ... ... ... ... ... ... ... ... ១០៩

**មាតិកា អភិធម្មត្ថសង្គហៈ  ទំព័រ**

អធិប្បាយ ... ... ... ... ... ... ... ... ... ... ... ១១០
អធិប្បាយលក្ខណៈនៃទោសចេតសិក ... ... ១១៣
លក្ខណាទិចតុក្កៈរបស់ទោសចេតសិក ... ... ១១៣
អាឃាតវត្ថុ ១០ ... ... ... ... ... ... ... ... ... ១១៤
ប្រភេទរបស់ទោសៈ ... ... ... ... ... ... ... ... ១១៦
ហេតុឱ្យកើតទោសមូលចិត្ត មាន ៤ យ៉ាង ១១៧
ចែកទោសមូលចិត្ត ២ ដោយន័យផ្សេង ៗ ១២១
ផលដែលកើតពីទោសមូលចិត្ត ... ... ... ... ១២២
ធម៌ដែលជាហេតុលះទោសៈ មាន ៦ យ៉ាង ១២៣
មោហមូលចិត្ត ២ ... ... ... ... ... ... ... ... ... ... ... ១២៤
មោហមូលចិត្ត ២ ... ... ... ... ... ... ... ... ... ១២៤
អធិប្បាយ ... ... ... ... ... ... ... ... ... ... ... ១២៥
គាថាសម្តែងសរុបឧទ្ធច្ចៈ ... ... ... ... ... ... ១២៦
គាថាសម្តែងសេចក្តីសង្ខេប ... ... ... ... ... ១២៨

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


ហេតុឱ្យកើតមោហមូលចិត្ត ២ យ៉ាង … … ១២៩

មោហៈ មិនដឹងក្នុងធម៌ ៨ យ៉ាង … … … ១៣២

លក្ខណាទិចតុក្កៈរបស់មោហៈ … … … … … ១៣៣

លក្ខណាទិចតុក្កៈរបស់វិចិកិច្ឆា … … … … … ១៣៣

សេចក្តីសង្ស័យ ៨ យ៉ាង … … … … … … ១៣៤

អធិប្បាយវិចិកិច្ឆា៨ … … … … … … … … ១៣៥

សេចក្តីសង្ស័យក្នុងព្រះសូត្រ ១៦ យ៉ាង … ១៤៣

សង្ស័យក្នុងអតីត ៥ … … … … … … … … ១៤៣

សង្ស័យក្នុងអនាគត ៥ … … … … … … … ១៤៤

សង្ស័យក្នុងបច្ចុប្បន្ន ៦ … … … … … … … ១៤៥

លក្ខណាទិចតុក្កៈរបស់ឧទ្ធច្ចៈ … … … … … ១៤៦

ធម៌ដែលជាហេតុលះវិចិកិច្ឆា ៦ … … … … ១៤៧

ធម៌ដែលជាហេតុលះឧទ្ធច្ចៈ ៦ … … … … ១៤៧

ចែកមោហមូលចិត្ត ២ ដោយន័យផ្សេង ៗ ១៤៨

**មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ**

ផលវិបាកដែលកើតអំពីមោហមូលចិត្ត ... ... ១៤៩
សម្តែងសម្បយុត្ត ក្នុងអកុសលចិត្ត១២ ... ... ... ... ១៥១
ហេតុឱ្យកើតអកុសលចិត្ត មាន ៤ យ៉ាង ... ១៥១
អកុសលកម្មបថ ... ... ... ... ... ... ... ... ... ... ... ១៥២
អកុសលកម្មបថ ១០ ចែកជា ៣ ទ្វារ ... ១៥២
អកុសលកម្មបថ ១០ មានអាការ ៥ ... ... ១៥៣
អធិប្បាយ ... ... ... ... ... ... ... ... ... ... ... ... ... ១៥៤
១- បាណាតិបាត ... ... ... ... ... ... ... ... ... ១៥៤
២- អទិន្នាទាន ... ... ... ... ... ... ... ... ... ... ១៥៧
៣- កាមេសុមិច្ឆាចារៈ ... ... ... ... ... ... ... ១៦០
៤- មុសាវាទ ... ... ... ... ... ... ... ... ... ... ១៦៣
៥- បិសុណាវាទ ... ... ... ... ... ... ... ... ... ១៦៧
៦- ផរុសវាទ ... ... ... ... ... ... ... ... ... ... ១៧០
៧- សម្ផប្បលាបៈ ... ... ... ... ... ... ... ... ១៧៣

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


៨- អភិជ្ឈា ... ... ... ... ... ... ... ... ... ... ... ១៧៦
៩- ព្យាបាទ ... ... ... ... ... ... ... ... ... ... ... ១៧៩
១០- មិច្ឆាទិដ្ឋិ ... ... ... ... ... ... ... ... ... ... ១៨២
អកុសលមូល ៣ ជាហេតុកើតអកុសលកម្មបថ
១០ ... ... ... ... ... ... ... ... ... ... ... ១៨៥
ពាក្យនិគម ... ... ... ... ... ... ... ... ... ... ... ... ១៩៤
សរុបអកុសលចិត្ត ១២ ... ... ... ... ... ... ... ... ... ១៩៦
សំនួរ-ចម្លើយ ក្នុងគាថាបករណ៍ ... ... ... ... ... ... ១៩៧
សំនួរ-ចម្លើយក្នុងអកុសលចិត្ត១២ ... ... ... ... ... ២០៦
អហេតុកចិត្ត ១៨ ... ... ... ... ... ... ... ... ... ... ... ២១៨
សង្គហគាថាទី៤ ... ... ... ... ... ... ... ... ... ... ២១៨
អធិប្បាយ ... ... ... ... ... ... ... ... ... ... ... ២១៨
អហេតុកចិត្ត ៣ ប្រភេទ ... ... ... ... ... ... ... ២១៩
១.អកុសលវិបាកចិត្ត ៧ ... ... ... ... ... ... ២១៩

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

២.អហេតុកកុសលវិបាកចិត្ត ៨ ... ... ... ២៣២
៣.អហេតុកកិរិយាចិត្ត ៣ ... ... ... ... ... ... ២៣៩
សង្ខារភេទនៃអហេតុកៈ ... ... ... ... ... ... ... ... ២៥០
ឧប្បត្តិហេតុនៃអហេតុកចិត្ត ១៨ ... ... ... ... ... ២៥២
កិច្ច ១៤ របស់អហេតុកចិត្ត ១៨ ... ... ... ... ២៥៩
ទ្វាររបស់អហេតុកចិត្ត ១៨ ... ... ... ... ... ... ... ២៦១
វត្ថុរបស់អហេតុកចិត្ត ១៨ ... ... ... ... ... ... ... ២៦២
អហេតុកចិត្ត ១៨ ជាវិញ្ញាណធាតុ ៧ ... ... ... ២៦២
ចែកអហេតុកចិត្ត ១៨ ដោយន័យផ្សេង ៗ ... ២៦៣
បាលីពាក្យនិគម ... ... ... ... ... ... ... ... ... ... ២៦៤
សំនួរ-ចម្លើយក្នុងអហេតុកចិត្ត ១៨ ... ... ... ... ... ២៦៦
សោភណចិត្ត ... ... ... ... ... ... ... ... ... ... ... ... ... ... ... ២៨២
សង្គហគាថាទី៥ ... ... ... ... ... ... ... ... ... ... ២៨២
សោភណចិត្ត ៤ ប្រភេទ ... ... ... ... ... ... ... ... ២៨៣

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


កាមាវចរសោភណ ... ... ... ... ... ... ... ... ... ... ... ... ២៨៣

សង្គហគាថាទី៦ ... ... ... ... ... ... ... ... ... ... ២៨៣

អធិប្បាយ សង្គហគាថា ... ... ... ... ... ... ... ... ២៨៤

កាមាវចរសោភណចិត្ត ២៤ ... ... ... ... ... ... ... ... ២៨៤

មហាកុសលចិត្ត ៨ ... ... ... ... ... ... ... ... ... ២៨៦

អធិប្បាយ មហាកុសលចិត្ត ៨ ... ... ... ... ... ២៨៨

កុសលចិត្តកើតព្រមដោយឧបេក្ខា ៤ ... ... ... ២៩០

វិធីរាប់កុសលចិត្ត ដោយពិស្តារ ... ... ... ... ... ២៩១

អធិប្បាយ ពាក្យថា កុសល ... ... ... ... ... ... ២៩៣

កុសល មានអត្ថ ៥ យ៉ាង ... ... ... ... ... ... ២៩៥

អធិប្បាយពាក្យថា បុញ្ញ "បុណ្យ" ... ... ... ... ២៩៦

លក្ខណាទិចតុក្កៈរបស់កុសល ... ... ... ... ... ... ២៩៦

លក្ខណាទិចតុក្កៈរបស់កុសលចិត្ត (ន័យមួយទៀត) ... ... ... ... ... ... ... ... ... ... ... ... ... ... ២៩៨

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

សេចក្តីផ្សេងគ្នារបស់ន័យទាំង ២ ... ... ... ... ... ៣០០
ចក្កៈ ៤ ... ... ... ... ... ... ... ... ... ... ... ... ... ៣០២
ហេតុឱ្យកើតកុសលសោមនស្ស ៦ យ៉ាង ... ... ៣០៥
ហេតុឱ្យកើតកុសលឧបេក្ខា ៦ យ៉ាង ... ... ... ៣០៧
ហេតុឱ្យកើតកុសលញាណសម្បយុត្ត ៤ ... ... ៣០៧
ហេតុឱ្យកើតកុសលញាណសម្បយុត្ត ៧ ... ... ៣០៩
ហេតុឱ្យកើតកុសលញាណវិប្បយុត្ត ៤ ... ... ... ៣១០
ហេតុឱ្យកើតកុសលញាណវិប្បយុត្ត ៧ ... ... ... ៣១០
ហេតុឱ្យកើតអសង្ខារិកចិត្ត ៦ ... ... ... ... ... ... ៣១១
មហាកុសលចិត្ត ២ ប្រភេទ ... ... ... ... ... ... ៣១៣
ហេតុឱ្យកើតបញ្ញា ៣ យ៉ាង ... ... ... ... ... ... ៣១៤
កម្មស្សកតាបញ្ញា ១០ យ៉ាង ... ... ... ... ... ... ៣១៧
ចេតនាក្នុងមហាកុសលចិត្ត ២ ន័យ ... ... ... ៣១៨
អង្គធម៌របស់កុសលកម្មបថ ១០ ... ... ... ... ៣១៩

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


ចែកមហាកុសល ៨ ប្រកបដោយចេតនា ៣ ៣២២
ចែកកុសលដោយឧក្កដ្ឋៈ និងឱមកៈ ជា ៤ ... ៣២៣
ចែកកុសលដោយឧក្កដ្ឋ និងឱមក ៨ ... ... ... ៣២៣
មហាកុសល ៨ ដោយន័យផ្សេង ៗ ... ... ... ៣២៥
សម្ដែងកាមាវចរកុសលចិត្ត ៨ ... ... ... ... ... ៣២៦
កាមាវចរវិបាកចិត្ត ៨ ... ... ... ... ... ... ... ... ... ... ៣២៨
មហាវិបាកផ្សេងពីមហាកុសល ... ... ... ... ... ៣៣២
ឋានដែលឱ្យផលរបស់មហាវិបាក មាន ៤ ... ៣៣៤
មហាវិបាកចែកសត្វឱ្យផ្សេងគ្នា ... ... ... ... ... ... ៣៣៦
កុសលកម្មឱ្យផលផ្សេងគ្នា ៧ យ៉ាងទៀត ... ... ៣៣៨
បុព្វហេតុឱ្យសត្វផ្សេងគ្នា ៨ ... ... ... ... ... ... ៣៣៩
អចិន្តេយ្យមាន ៤ គឺ ... ... ... ... ... ... ... ... ៣៤៣
ចែកមហាវិបាក ៨ ដោយន័យផ្សេង ៗ ... ... ៣៤៥
កាមាវចរវិបាកចិត្ត មាន ២៣ ... ... ... ... ... ... ៣៤៧

**មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ**

សម្តែងមហាវិបាកចិត្ត ៨ ... ... ... ... ... ... ... ៣៤៧
មហាកិរិយា ៨ ... ... ... ... ... ... ... ... ... ... ... ... ៣៤៨
បែកមហាកិរិយា ៨ ដោយន័យផ្សេង ៗ ... ... ៣៥៥
សម្តែងកាមាវចរកិរិយាចិត្ត ៨ ... ... ... ... ... ... ៣៥៦
បាលីពាក្យនិគម ... ... ... ... ... ... ... ... ... ... ... ៣៥៧
សរុបកាមាវចរសោភណចិត្ត ២៤ ... ... ... ... ... ៣៥៧
សង្គហគាថាទី៧ ... ... ... ... ... ... ... ... ... ... ... ៣៥៨
សម្តែងសរុប កាមាវចរចិត្ត ៥៤ ... ... ... ... ... ៣៥៩
សំនួរ-ចម្លើយ ... ... ... ... ... ... ... ... ... ... ... ... ៣៦០
រូបាវចរសោភណចិត្ត ... ... ... ... ... ... ... ... ... ... ... ... ៣៨៤
សង្គហគាថាទី៨ ... ... ... ... ... ... ... ... ... ... ... ៣៩២
រូបាវចរកុសលចិត្ត ៥ ... ... ... ... ... ... ... ... ... ៣៩២
អធិប្បាយ រូបាវចរកុសលចិត្ត ... ... ... ... ៣៩៤
អង្គ ៥ នៃបឋមជ្ឈាន ... ... ... ... ... ... ... ៣៩៤

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


អធិប្បាយ ... ... ... ... ... ... ... ... ... ... ... ៤០១

ឧបមាបីតិ និង សុខ ... ... ... ... ... ... ... ៤០៤

សមាធិ មាន ៣ យ៉ាង ... ... ... ... ... ... ៤០៧

ប្រភេទនៃឈានចិត្ត ... ... ... ... ... ... ... ... ៤០៨

អធិប្បាយពាក្យ បឋមជ្ឈាន ... ... ... ... ... ៤០៩

បឋមជ្ឈានកុសលចិត្ត ... ... ... ... ... ... ... ៤១០

សង្ខារប្បភេទរបស់អប្បនាឈាន ... ... ... ៤១៣

ឈាន ២ យ៉ាង គឺ ... ... ... ... ... ... ... ... ៤១៥

សមថកម្មដ្ឋាន ៤០ យ៉ាង ... ... ... ... ... ៤១៦

អធិប្បាយ អប្បនាវិថី ... ... ... ... ... ... ... ៤២៣

ទុតិយជ្ឈាន ... ... ... ... ... ... ... ... ... ... ... ៤២៤

តតិយជ្ឈាន ... ... ... ... ... ... ... ... ... ... ... ៤២៦

ចតុត្ថជ្ឈាន ... ... ... ... ... ... ... ... ... ... ... ៤២៧

បញ្ចមជ្ឈាន ... ... ... ... ... ... ... ... ... ... ... ៤២៨

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

រូបាវចរវិបាកចិត្ត ៥ ... ... ... ... ... ... ... ... ... ... ៤៣២
អធិប្បាយ រូបាវចរវិបាកចិត្ត ... ... ... ... ... ៤៣៣
អធិប្បាយ ព្រហ្មក្នុងព្រហ្មភូមិ ... ... ... ... ... ៤៣៦
ចែករូបាវចរវិបាកចិត្ត៥ ដោយន័យផ្សេង ៗ ៤៤២
រូបាវចរកិរិយាចិត្ត ៥ ... ... ... ... ... ... ... ... ... ... ៤៤៣
ចែករូបាវចរកិរិយាចិត្ត៥ ដោយន័យផ្សេង ៗ ៤៤៥
ពាក្យនិគម ... ... ... ... ... ... ... ... ... ... ... ... ... ... ៤៤៦
សរុបរូបាវចរសោភណចិត្ត ១៥ ... ... ... ... ... ... ៤៤៧
អរូបាវចរសោភណចិត្ត ១២ ... ... ... ... ... ... ... ... ... ... ៤៤៨
សង្គហគាថាទី៩ ... ... ... ... ... ... ... ... ... ... ៤៤៨
អធិប្បាយសង្គហគាថា ... ... ... ... ... ... ... ... ៤៤៨
អរូបាវចរកុសលចិត្ត ៤ ... ... ... ... ... ... ... ... ... ... ៤៥០
អធិប្បាយ ... ... ... ... ... ... ... ... ... ... ... ... ៤៥០
វិធីចម្រើនអរូបជ្ឈានទី ១ ... ... ... ... ... ... ... ៤៥២

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


អធិប្បាយអប្បនាវិថី ... ... ... ... ... ... ... ... ... ៤៥៦

អធិប្បាយវិញ្ញាណញ្ចាយតនកុសលចិត្ត ... ... ... ... ៤៥៨

អរូបាវចរវិបាកចិត្ត ៤ ... ... ... ... ... ... ... ... ... ... ៤៦៤

អរូបាវចរកិរិយាចិត្ត ៤ ... ... ... ... ... ... ... ... ... ... ៤៦៦

ចែកអរូបាវចរចិត្ត ១២ ដោយន័យផ្សេង ៗ ... ៤៦៨

បាលីពាក្យនិគម ... ... ... ... ... ... ... ... ... ... ... ៤៦៩

សរុបមហគ្គតចិត្ត ២៧ ... ... ... ... ... ... ... ... ៤៧០

លោកុត្តរសោភណចិត្ត ... ... ... ... ... ... ... ... ... ... ... ... ៤៧១

សង្គហគាថាទី១០ លោកុត្តរចិត្ត ៨ ... ... ... ... ៤៧២

លោកុត្តរកុសលចិត្ត ៤ ... ... ... ... ... ... ... ... ... ៤៧២

អធិប្បាយ ... ... ... ... ... ... ... ... ... ... ... ... ៤៧៣

សម្តែងលោកុត្តរកុសលចិត្ត ៤ ឬ ២០ ... ៤៧៨

លោកុត្តរវិបាកចិត្ត ៤ ... ... ... ... ... ... ... ... ... ... ... ៤៨០

សម្តែងលោកុត្តរវិបាកចិត្ត ៤ ឬ ២០ ... ... ៤៨០

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


បាលីពាក្យនិគម ............................... ៤៨២

អកុសលធម៌ ៩ កង ............................... ៤៨៥

មគ្គចិត្តទម្លាយអកុសលធម៌ ៩ កង .................. ៤៨៧

មគ្គចិត្តលះអកុសលកម្មបថ១០ ..................... ៤៨៨

សោតាបន្ន ៣ ប្រភេទ ............................ ៤៨៩

សកទាគាមី មាន ៥ ប្រភេទ ........................ ៤៩១

ព្រះអនាគាមី ៥ ប្រភេទ .......................... ៤៩២

ព្រះអរហន្ត ២ ប្រភេទ ........................... ៤៩៤

សង្គហគាថាទី១១ សម្តែងចិត្ត ដោយជាតិ ............ ៤៩៥

សង្គហគាថាទី១២ សម្តែងចិត្ត ដោយភូមិ ...... ៤៩៥

សង្គហគាថាទី១៣ សម្តែងចិត្ត ៨៩ ឬ១២១ ......... ៤៩៦

សង្គហគាថាទី១៤ សម្តែងលោកុត្តរចិត្ត ៤០

ដោយឈាន ...................................... ៤៩៩

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

សង្គហគាថាទី១៥ សម្ដែងលោកុត្តរចិត្ត ដោយរូបជ្ឈាន
និងអរូបជ្ឈាន … … … … … … … … … … … … … ៥០០
សង្គហគាថាទី១៦ សម្ដែងឈានចិត្តរួម
នឹងលោកុត្តរចិត្ត … … … … … … … … … … … ៥០០
សង្គហគាថាទី១៧ ចែកចិត្តដោយពិស្ដារ១២១ … … ៥០១
កុសលចិត្តដោយពិស្ដារ ៣៧ … … … … … … … … ៥០២
វិបាកចិត្តដោយពិស្ដារ មាន ៥២ … … … … … … … ៥០២
ចែកចិត្ត ១២១ ដោយន័យផ្សេង ៗ … … … … … ៥០៣
សេចក្ដីសំដៅរបស់ភូមិ ២ ន័យ … … … … … … … ៥០៥
សម្ដែងសរុប ចិត្តបរមត្ថ ១២១ … … … … … … … ៥០៩
អវសានគាថា … … … … … … … … … … … … … ៥១១

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ១ ចិត្តសង្គហវិភាគ

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

## គាថាបករណ៍ អភិធម្ម ១៧ គាថា

### គាថាផ្តើមបករណ៍

១. *សម្មាសម្ពុទ្ធមតុលំ សសទ្ធម្មគណុត្តមំ*
*អភិវាទិយភាសិស្សំ អភិធម្មត្ថសង្គហំ ។*

*ខ្ញុំឈ្មោះអនុរុទ្ធាចារ្យ សូមនមស្សការ ថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធ ទ្រង់រកបុគ្គលដទៃស្មើគ្មាន មួយអន្លើដោយព្រះសទ្ធម្ម និងប្រជុំនៃព្រះអរិយសង្ឃទាំង ៨ ពួក ដ៏ប្រសើរខ្ពង់ខ្ពស់ដោយគោរព ហើយនឹងពោលនូវគម្ពីរអភិធម្មត្ថសង្គហៈ គឺ ការបំព្រួញនូវសេចក្តីនៃព្រះអភិធម្ម ។*

២. តត្ថ វុត្តាភិធម្មត្ថា ចតុធា បរមត្ថតោ
ចិត្តំ ចេតសិកំ រូបំ និព្វានមីតិ សព្វថា ។

*វីអត្ថនៃព្រះអភិធម្មទាំងឡាយ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទុកក្នុងអភិធម្មទាំង ៧ គម្ពីរនោះ ដោយសេចក្ដីល្អិតសុខុមក្រៃពេក ដោយចំណែកធម៌ ៤ ប្រការ គឺ ចិត្ត ១ ចេតសិក ១ រូប ១ និងព្រះនិព្វាន ១ ។*

## គាថាសង្គហៈ ក្នុងកាមាវចរចិត្ត ៥៤

៣. អដ្ឋធា លោភមូលានិ ទោសមូលានិ ច ទ្វិធា
មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសលា សិយុំ ។

*អកុសលចិត្ត មាន១២ គឺ លោភមូលចិត្ត៨ ទោសមូលចិត្ត២ មោហមូលចិត្ត២ ។*

៤. សត្តាកុសលបាកានិ បុញ្ញបាកានិ អដ្ឋធា
ក្រិយាចិត្តានិ តីណីតិ អដ្ឋារស អហេតុកា ។

*អកុសលវិបាកចិត្ត៧ កុសលវិបាកចិត្ត៨ កិរិយា*

ចិត្ត៣ រួមជាអហេតុកចិត្ត១៨ ។

៥. បាបាហេតុកមុត្តានិ សោភណានីតិ វុច្ចរេ
ឯកូនសដ្ឋី ចិត្តានិ អថេកនវុតីបិវា ។

ចិត្តទាំងឡាយ ដែលផុតចាកអកុសលចិត្ត១២ និង អហេតុកចិត្ត១៨ នោះ ឈ្មោះថា សោភណចិត្ត មានចំនួន៥៩ ឬ៩១ ។

៦. វេទនាញាណសង្ខារ ភេទេន ចតុវីសតិ
សហេតុកកាមាវចរ បុញ្ញបាកក្រិយាមតា ។

សោភណចិត្ត២៤ គឺ កុសលចិត្ត៨ វិបាកចិត្ត៨ កិរិយាចិត្ត៨ ដែលព្រះសម្មាសម្ពុទ្ធសម្ដែងហើយ ផ្សេងគ្នា ដោយវេទនា ញាណ និងសង្ខារ ។

៧. កាមេ តេវីស បាកានិ បុញ្ញាបុញ្ញានិ វីសតិ
ឯកាទស ក្រិយាចេតិ ចតុបញ្ញាស សព្វថា ។

កាមាវចរចិត្តនោះ បាត់ជាវិបាក ២៣. កុសលចិត្ត និង អកុសលចិត្ត ២០ និងកិរិយាចិត្ត ១១ រួបរួម កាមាវចរចិត្ត ទាំងអស់ត្រូវជា ៥៤ ដូច្នេះ ។

## សង្គហគាថា ក្នុងមហគ្គតចិត្ត ២៧

៨. បញ្ចធា ឈានភេទេន រូបាវចរមានសំ
បុញ្ញបាកក្រិយាភេទា តំ បញ្ចទសធា ភវេ ។

*រូបាវចរចិត្ត១៥ ចែកដោយឈាន មាន៥ គឺ កុសលចិត្ត៥ វិបាកចិត្ត៥ កិរិយាចិត្ត៥ រួមជា១៥យ៉ាង ។*

៩. អាលម្ពនប្បភេទេន ចតុធារុប្បមានសំ
បុញ្ញបាកក្រិយាភេទា បុន ទ្វាទសធា ឋិតំ ។

*អរូបាវចរចិត្ត ចាត់តាមអារម្មណ៍ មាន៤ ប្រការ ចាត់តាមកុសល វិបាក កិរិយា មាន ១២ ប្រការ ។*

## សង្គហគាថាក្នុងលោកុត្តរចិត្ត ៨

១០. ចតុមគ្គប្បភេទេន ចតុធា កុសលន្តថា
បាកន្តស្ស ផលត្តាតិ អដ្ឋធានុត្តរំ មតំ ។

*អនុត្តរ( គឺ លោកុត្តរ )ចិត្ត បណ្ឌិតពោលទុក៨*

ប្រភេទ គឺ កុសលចិត្ត៤ យ៉ាង ដោយប្រភេទនៃមគ្គ. វិបាកចិត្ត ក៏មាន៤ យ៉ាង ព្រោះជាផលរបស់កុសលនោះ ។

## សម្តែងចិត្ត ៨៩ ដោយជាតិ

១១. ទ្វាទសាកុសលានេវ  កុសលានេកវីសតិ
 ឆត្តឹសេវ វិបាកានិ  ក្រិយាចិត្តានិ វីសតិ ។

អកុសលចិត្ត១២ កុសលចិត្ត២១ វិបាកចិត្ត៣៦ និងកិរិយា២០ ( រួមជាចិត្ត ៨៩ ) ។

## សម្តែងចិត្ត ៨៩ ដោយភូមិ

១២. ចតុបញ្ញាសធា កាមេ  រូបេ បណ្ណរសីរិយេ
 ចិត្តានិ ទ្វាទសារូបេ  អដ្ឋធានុត្តរេ តថា ។

បណ្ឌិតពោលថា ចិត្តក្នុងកាមភូមិ មាន៥៤ ចិត្តក្នុងរូបភូមិ មាន១៥ ចិត្តក្នុងអរូបភូមិ មាន១២ និងអនុត្តរចិត្ត មាន៨ ។

## សម្ដែងចិត្ត ៨៩ ឬ ១២១

១៣. ឥត្ថមេកូននវុតិ ប្បភេទំ បន មានសំ
ឯកវីសសតំ វាថ វិភជន្តិ វិចក្ខណា ។

*បណ្ឌិតដែលមានបញ្ញាឃើញច្បាស់ រមែងចែកមានស: (ចិត្ត) ក្នុងទីនេះ ចេញជាចិត្ត៨៩ ឬ១២១ ។*

## សម្ដែងលោកុត្តរចិត្ត ៤០ ដោយឈាន

១៤. ឈានង្គយោគភេទេន កត្វេកេកន្តុ បញ្ចធា
វុច្ចតានុត្តរំ ចិត្តំ ចត្តាឡីសវិធន្តិ ច ។

*បណ្ឌិតធ្វើលោកុត្តរចិត្តមួយ ៗ ជា ៥ យ៉ាង ឱ្យផ្សេងគ្នា ដោយអំណាចនៃអង្គឈាន ហើយពោលថា លោកុត្តរចិត្ត មាន ៤០ ។*

## សម្ដែងលោកុត្តរចិត្ត ដោយរូបជ្ឈាន និងអរូបជ្ឈាន

១៥. យថា ច រូបាវចរំ គយ្ហតានុត្តរំ តថា
បឋមាទិជ្ឈានភេទេ អារុប្បញ្ចាបិ បញ្ចមេ ។

*រូបាវចរចិត្ត ដោយប្រភេទនៃឈាន មានបឋមជ្ឈានជាដើមយ៉ាងណា លោកុត្តរចិត្ត ក៏យ៉ាងនោះ សូម្បីអរូបជ្ឈាន ក៏សង្គ្រោះចូលក្នុងបញ្ចមជ្ឈានហ្នឹងឯង ។*

## សម្ដែងឈានចិត្តរួមនឹងលោកុត្តរចិត្ត

១៦. ឯកាទសវិធំ តស្មា បឋមាទិកមីរិតំ
ឈានមេកេកមន្តេ តុ តេវីសតិវិធំ ភវេ ។

*ព្រោះហេតុនោះ ឈានចិត្តមួយប្រភេទ ៗ ដែលលោកហៅថា បឋមជ្ឈានជាដើម ទើបមាន ១១ ចំណែកឈានចិត្តខាងចុង (បញ្ចមជ្ឈាន) មានចិត្ត ២៣ ។*

## សម្តែងចិត្ត ដោយពិស្តារ ១២១

**១៧.** សត្តតឹសវិធំ បុញ្ញំ ទ្វិបញ្ញាសវិធន្តថា
បាកមិច្ចាហុ ចិត្តានិ ឯកវីសសតម្ពុធាតិ ។

*កុសលចិត្តមាន៣៧ វិបាកចិត្ត៥២ បណ្ឌិតពោល (រួមអកុសលចិត្ត១២ និងកិរិយាចិត្ត២០)[១] ឱ្យពិស្តារថា មាន ១២១ ។*

**បករណ៍ ១៧ គាថា ចប់**

---

*១. បាលីគាថានេះ មិនមានអកុសលចិត្ត ១២ និងកិរិយាចិត្ត ២០, តែព្រោះបាទគាថាចុងក្រោយថា ឯកវីសតំ : ១២១ ដូច្នេះ ទើបថែមកុសលចិត្ត ១២ និងកិរិយាចិត្ត ២០ផង ទើបគ្រប់ ១២១ ។*

## បណាមគាថា

នមោ តស្សារហន្តស្ស ភគវន្តស្ស សត្ថុនោ
សម្មាសម្ពុទ្ធស្ស មារយត្ថោ លោកជេដ្ឋស្ស តាទិនោ ។

*ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ព្រះអង្គជាព្រះបរមសាស្តាដ៏ប្រសើរបំផុតក្នុងលោក ទ្រង់ជាបុគ្គលដ៏នឹងធឹង ។*

## បណាមគាថា មាន ១០ បទ

១. *នមោ ប្រែថា កិរិយានមស្សការ ដោយកាយ វាចា ចិត្ត*

២. *តស្ស ប្រែថា ព្រះអង្គនោះ*

៣. *អរហន្តស្ស ប្រែថា ទ្រង់ជាព្រះអរហន្ត ទ្រង់ព្រះនាមថា អរហន្ត ព្រោះព្រះអង្គឆ្ងាយចាកកិលេស១ ព្រះអង្គកំចាត់សត្រូវ គឺកិលេស១ ទ្រង់កាច់នូវកាំនៃសង្សារ*

ចក្រ១ ទ្រង់គួរដល់ទក្ខិណាវត្ថុ គឺ គួរដល់ទេយ្យធម៌ ដែលគេថ្វាយដល់អ្នកដែលទ្រទ្រង់គុណវិសេស១ ទ្រង់មិនធ្វើបាបក្នុងទីស្ងាត់កំបាំង១

៤. **ភគវន្តស្ស** ប្រែថា ព្រះមានព្រះភាគ (ទ្រង់ចែកធម៌ដោយខន្ធ អាយតនៈ ធាតុជាដើម ជាអនិច្ចំ...)

៥. **សត្ថុនោ** ប្រែថា ព្រះអង្គជាសាស្តា គឺ ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ព្រោះទ្រង់សម្តែងធម៌មានលំអបទដើម បទកណ្តាល និងបទចុង

៦. **សម្មាសម្ពុទ្ធស្ស** ប្រែថា ព្រះអង្គត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង បានដល់ ការត្រាស់ដឹងនូវអរិយសច្ចធម៌៤ ព្រមដោយព្រះញាណទាំងឡាយ ។

**មាយត្ថោ** គឺ **មេ** = **អត្ថុ**

៧. **មេ** ប្រែថា ខ្ញុំព្រះករុណា

៨. **អត្ថុ** ប្រែថា ចូរមាន

៩. *លោកជេដ្ឋស្ស* ប្រែថា ទ្រង់ប្រសើរបំផុតក្នុងលោក

១០. *តាទិនោ* ប្រែថា ព្រះអង្គនឹងធឹង គឺ ព្រោះព្រះអង្គលះកិលេសបានហើយ រមែងមិនកម្រើកឡើងទៀតឡើយ ។

## ចែកដោយព្រះគុណ ៣ យ៉ាង គឺ

ពាក្យថា **អរហន្តស្ស** និង **តាទិនោ** ជាព្រះវិសុទ្ធិគុណ

ពាក្យថា **ភគវន្តស្ស** និង **សត្ថុនោ** ជាព្រះករុណាគុណ

ពាក្យថា **សម្មាសម្ពុទ្ធស្ស** ជាព្រះបញ្ញាគុណ

ពាក្យថា **លោកជេដ្ឋស្ស** សង្គ្រោះចូលក្នុងព្រះគុណទាំង ៣

## ពណ៌នាព្រះគុណ ចាប់ពីផ្តើមតាំងបណិធានមក

ពិតមែន ព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយកាលប្រមូលសរុបមកមានត្រឹមតែ ៣ ប៉ុណ្ណោះ តែកាលពោលដោយពិស្តារ មិនមានអ្នកណា នឹងអាចរាប់ អាចប្រមាណបានឡើយ ព្រោះព្រះអង្គតាំងបណិធាន ប្រាថ្នានឹង

ជួយសត្វទាំងឡាយ ឱ្យផុតចាកសង្សារទុក្ខ ដោយផ្ដើមតាំងក្នុងព្រះទ័យថា អាត្មាអញនឹងបានជាព្រះពុទ្ធ គឺ ត្រឹមតែនឹកក្នុងព្រះទ័យប៉ុណ្ណោះថា **"ពុទ្ធោ ពោធេយ្យំ មុត្តោ មោចេយ្យំ តិណ្ណោ តារេយ្យំ : យើងត្រាស់ដឹងហើយ នឹងឱ្យអ្នកដទៃត្រាស់ដឹងផង, យើងរួចផុតហើយ នឹងឱ្យអ្នកដទៃរួចផុតផង, យើងឆ្លងហើយ នឹងឱ្យអ្នកដទៃ ឆ្លងផង"** យ៉ាងនេះ អស់រយៈពេល ៧ អសង្ខេយ្យ ។ ប្រាថ្នាជាព្រះពុទ្ធដោយថ្លែងវាចាតាមចិត្តដែលគិតនឹងជួយសត្វ (ដូចខាងលើ) អស់ ៩ អសង្ខេយ្យទៀត ។ ទ្រង់ប្រាថ្នានឹងបំពេញបារមីដោយកាយ វាចា ចិត្ត តាំងពីបានទទួលការព្យាករណ៍ពីព្រះពុទ្ធទីបង្ករថា "នឹងបានត្រាស់ជាព្រះពុទ្ធ" អស់រយៈពេល ៤ អសង្ខេយ្យ និង១សែនមហាកប្បទៀត ។ ទ្រង់បំពេញបារមី រួមទាំងអស់ ២០អសង្ខេយ្យ និង ១សែនមហាកប្ប[១] ។

---

១. ២៥៦អន្តរកប្ប = ១មហាកប្ប, មហាកប្បដែលមានលេខ១ សូន្យ

ព្រះសព្វញ្ញុពោធិសត្វរបស់យើងទាំងឡាយ ទ្រង់បាន តាំងប្រាថ្នាជាព្រះពុទ្ធ ក្នុងខណៈចិត្តជាលើកដំបូង ដែលមិន ទាន់បានធ្លាប់ជួបព្រះពុទ្ធអង្គណា ៗឡើយ រាប់ជាតិមិនអស់ មានរឿងពោលទុកថា ៖

រាប់តាំងពីភទ្ទកប្បនេះ ថយក្រោយទៅ ២០ អសង្ខេយ្យ និង ១សែនមហាកប្ប, ព្រះពោធិសត្វកើតជា មនុស្សក្រីក្រនៅក្នុងដែនគន្ធារៈ កាប់ឧស បេះបន្លែអំពីព្រៃ យកទៅលក់បានប្រាក់ចិញ្ចឹមមាតា ។ ថ្ងៃមួយ កំពុងរែក របស់ធ្ងន់ដើរមកហាលក្តៅផង ស្រេកទឹកផង ក៏ចូលសម្រាក

---

១៤០ = ១អសង្ខេយ្យកប្ប ។ ព្រះពុទ្ធបញ្ញាធិក នៅជាអនិយត ពោធិសត្វ ១៦ អសង្ខេយ្យកប្ប, ជានិយតពោធិសត្វ ៤អសង្ខេយ្យ ១សែនមហាកប្ប រួមជា ២០អសង្ខេយ្យ និង ១សែនមហាកប្ប ។ ព្រះពុទ្ធសទ្ធាធិក ៤០អសង្ខេយ្យ និង ១សែនមហាកប្ប ។ ព្រះពុទ្ធ វីរិយាធិក ៨០អសង្ខេយ្យ និង ១សែនមហាកប្ប ។ ទើបបានត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញាណ ។

ក្រោមដើមជ្រៃ ពិចារណាថា “ពេលនេះ អាត្មាអញនៅមានកម្លាំង អាចអត់ធន់ចំពោះសេចក្ដីទុក្ខព្រោះក្ដៅជាដើមបាន, តែកាលយើងចាស់ ឬឈឺ ប្រាកដជាមិនអាចអត់ធន់នឹងសេចក្ដីទុក្ខយ៉ាងនេះបានឡើយ, ណ្ហើយ យើងនឹងទៅកាន់សុវណ្ណភូមិ ជីកយកមាសមកចិញ្ចឹមមាតាឱ្យមានសេចក្ដីសុខចុះ” ។ កាលគិតដូច្នោះហើយ ក៏បាននាំមាតាចុះសំពៅ ទៅកាន់សុវណ្ណភូមិជាមួយនឹងពួកឈ្មួញ ដោយសុំបម្រើជាកូនឈ្នួលប្រចាំសំពៅ, កាលសំពៅចេញទៅបាន ៧ ថ្ងៃ ក៏បែកលិចលង់ទៅ ពួកឈ្មួញក៏ដល់នូវសេចក្ដីស្លាប់ វិនាសទាំងអស់គ្នា ចំណែកព្រះពោធិសត្វលីមាតាផង ហែលទឹកឆ្លងមហាសមុទ្រទៅផង ។

គ្រានោះ ស្ដេចមហាព្រហ្មជាន់សុទ្ធាវាស រំពឹងមើលពួកសត្វលោកទូទៅ ដោយគិតថា “កន្លងទៅ ១ អសង្ខេយ្យមហាកប្បហើយ មិនមានបុរសណាមួយ ដែលត្រាស់ជាព្រះ

ពុទ្ធឡើយ, ចុះអ្នកដែលនឹងបានត្រាស់ដឹងជាព្រះពុទ្ធមានឬទេហ្ន៎ ?" ទើបមើលឃើញព្រះពោធិសត្វដែលកំពុងលះបង់ជីវិតនាំមាតារបស់ខ្លួនហែលឆ្លងមហាសមុទ្រដ៏ធំល្វឹងល្វើយ, ក៏ជ្រាបបានថា "មហាបុរសនេះ មានសេចក្ដីព្យាយាមខ្លាំងក្លាណាស់ នឹងមានអធ្យាស្រ័យជួយអ្នកដទៃ". ព្រះពោធិសត្វនោះ ដោយអានុភាពមហាព្រហ្មបណ្ដាលចិត្ត ក៏កើតសេចក្ដីគិតឡើងថា "យើងត្រាស់ដឹងហើយ នឹងឱ្យអ្នកដទៃត្រាស់ដឹងផង, យើងរួចផុតហើយ នឹងឱ្យអ្នកដទៃរួចផុតផង, យើងឆ្លងហើយ នឹងឱ្យអ្នកដទៃឆ្លងផង" ដូច្នេះ ហែលឆ្លងមហាសមុទ្រ ២-៣ ថ្ងៃ ក៏បានដល់ត្រើយ ព្រមទាំងមាតា ។ តាំងពីនោះមក ព្រះពោធិសត្វចិញ្ចឹមមាតារហូតដល់អស់ជីវិត ហើយទៅកើតក្នុងទេវលោក, ចំណែកមាតាក៏ទៅតាមយថាកម្ម, នេះគឺជាកាលវេលាដែលទ្រង់តាំងសេចក្ដីប្រាថ្នាជាព្រះពុទ្ធឡើងក្នុងចិត្ត ជាគ្រាដំបូង ហៅថា បឋមចិត្តុប្បាទកាល ។

ចាប់ផ្ដើមពីនោះមក ទ្រង់សន្សំបារមី រហូតដល់ភពចុង បំផុតបានតាំងសេចក្ដីព្យាយាមប្រកបដោយអង្គ ៤ ដែលហៅថា ចាតុរង្គប្បធាន ដូចដែលទ្រង់ត្រាស់ថា ៖

កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ យំ តំ បុរិសត្ថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា បុរិសស្ស វីរិយស្ស សណ្ឋានំ ភវិស្សតិ

*ស្បែក១ សសៃ១ ឆ្អឹង១ ចូរសល់នៅចុះ ឯសាច់ ឈាម ក្នុងសរីរៈ ចូររីងស្ងួតចុះ គុណជាតណា ដែលបុគ្គលគប្បីដល់ដោយកម្លាំងរបស់ បុរស ដោយសេចក្ដីព្យាយាមរបស់បុរស ដោយសេចក្ដី ប្រឹងប្រែងរបស់បុរស បើមិនទាន់ដល់គុណជាតនោះ ទេ នឹងមិនបញ្ឈប់នូវសេចក្ដីព្យាយាមរបស់បុរស*

ឡើយ ។[១]

ព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ដែលព្រះអង្គទ្រង់បានមកនោះ រាប់ថា ជាការបានមកដោយសេចក្ដីលំបាកយ៉ាងក្រៃលែង ក្នុងព្រះជាតិចុងក្រោយបំផុត ដោយហេតុនេះឯងទើបព្រះអដ្ឋកថាចារ្យបានប្រព័ន្ធបណាមគាថា ដើម្បីឱ្យរលឹកដល់ព្រះគុណដ៏ធំក្រៃលែង រាប់ប្រមាណមិនបានរបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រទ្រង់ទុកនូវព្រះគុណទាំង ៣ គឺ ព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ និងព្រះករុណាគុណ ដែលមិនមានអ្នកណាប្រៀបផ្ទឹមបាន ។ កាលបើបុគ្គលមានចិត្តជ្រះថ្លាពោលពាក្យនមស្សការដោយរលឹកដល់ព្រះគុណទាំងនោះជានិច្ច ក៏នឹងធ្វើឱ្យចិត្តស្អាតផូរផង់ ប្រាសចាកភ័យ និងអន្តរាយ សូម្បីកិច្ចការដែលគួរធ្វើក៏សម្រេចតាមសេចក្ដីប្រាថ្នានោះឯងហោង ។

---

១. សំយុ. និទា. ទសពលវគ្គ. ៣១. ៦៦/៦១ ។

## ព្រះពុទ្ធសាសនភាសិត

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ

ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

*ធម៌ គឺ ពរទាំងឡាយ ៤ ប្រការ គឺ អាយុ ១ ពណ៌សម្បុរកាយ ១ សេចក្ដីសុខ ១ កម្លាំង ១ រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែលមានសេចក្ដីឱនកាយថ្វាយបង្គំ ដល់ព្រះរតនត្រ័យជាប្រក្រតី និងអ្នកដែលមានសេចក្ដីគោរព កោតក្រែងដល់បុគ្គល ដែលជាអ្នកមានសេចក្ដីចម្រើនដោយគុណ មានសីលគុណជាដើម ឬដែលចម្រើនដោយវ័យ គឺ ចាស់ព្រឹទ្ធាចារ្យ ។*

# អធិប្បាយ គាថាបករណ៍ អភិធម្ម ១៧ គាថា

## គាថាផ្តើមបករណ៍

១. សម្មាសម្ពុទ្ធមតុលំ សសទ្ធម្មគណុត្តមំ
អភិវាទិយ ភាសិស្សំ អភិធម្មត្ថសង្គហំ ។

*ខ្ញុំឈ្មោះអនុរុទ្ធាចារ្យ សូមនមស្ការ ថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធ ទ្រង់រកបុគ្គលដទៃស្មើគ្មាន មួយអន្លើដោយព្រះសទ្ធម្ម និងប្រជុំនៃព្រះអរិយសង្ឃទាំង ៨ ពួក ដ៏ប្រសើរខ្ពង់ខ្ពស់ដោយគោរព ហើយនឹងពោលនូវគម្ពីរអភិធម្មត្ថសង្គហៈ គឺ ការបំព្រួញនូវសេចក្តីនៃព្រះអភិធម្ម ។*

## គាថាផ្ដើមបករណ៍ មាន ៦ បទ គឺ

១. **សម្មាសម្ពុទ្ធ** ប្រែថា ព្រះសម្មាសម្ពុទ្ធ
២. **អតុលំ** ប្រែថា ទ្រង់មិនមានបុគ្គលប្រៀបប្រដូចបាន
៣. **សសទ្ធម្មគណុត្តមំ** ប្រែថា ព្រមទាំងព្រះសទ្ធម្ម និងពួកនៃព្រះអរិយសង្ឃដ៏ឧត្តមហើយ
៤. **អភិវាទិយ** ប្រែថា សូមអភិវាទ ក្រាបថ្វាយបង្គំ
៥. **ភាសិស្សំ** ប្រែថា នឹងពោល
៦. **អភិធម្មត្ថសង្គហំ** ប្រែថា បករណ៍ឈ្មោះ អភិធម្មត្ថសង្គហៈ

គាថានេះសម្ដែងដល់បណាម គឺ ការនមស្សការព្រះរតនត្រ័យ និងបេ្ដជ្ញាតាំងចិត្តពោលទទួលដោយវាចាថា នឹងតែងបករណ៍ឱ្យសម្រេច ដើម្បីមិនឱ្យមានឧបសគ្គ អន្តរាយណា ៗ ដែលធ្វើឱ្យអក្ខរខូចខាត ព្រោះអក្សរនីមួយ ៗ មានតម្លៃថ្លៃណាស់, ដូចជាពន្លឺប្រទីបភ្លឺចិញ្ចាច ញុំាងបញ្ញាឱ្យកើត

ឡើង ទើបព្រះបូរាណាចារ្យប្រព័ន្ធគាថាទុកដូច្នេះថា ៖

អក្ខរំ ឯកមេកញ្ច    ពុទ្ធរូបសមំ សិយា
តស្មា ហិ បណ្ឌិតោ បោសោ លិខេយ្យ បិដកត្តយំ ។

*អក្សរនីមួយ ៗ ស្មើនឹងព្រះពុទ្ធរូបមួយអង្គ ព្រោះ ហេតុនោះឯង បុគ្គលដែលជាបណ្ឌិត យល់ឃើញ យ៉ាងនេះហើយ គប្បីរចនាព្រះត្រៃបិដក ។*

## សេចក្ដីពន្យល់ក្នុងគាថា

*បទថា* ***សម្មាសម្ពុទ្ធំ*** *ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា* ***សម្មាសម្ពុទ្ធ:*** *ព្រោះអត្ថថា ត្រាស់ដឹងក្រៃលែងហើយនូវធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ។*

*ពិតមែន ព្រះអង្គទ្រង់ត្រាស់ដឹងហើយ គឺ ទ្រង់ដឹងនូវធម្មជាតិដែលជាសង្ខត: និងអសង្ខត:ទាំងអស់ដោយប្រពៃ ដោយអំណាចនៃការចាក់ធ្លុះនូវលក្ខណ: ព្រមទាំងកិច្ចតាមសេចក្ដីពិត ដោយសយម្ភូញាណដែលកើតល្អហើយ ពី*

បារមីដែលព្រះអង្គសន្សំកសាងមកដោយព្រះអង្គឯង ។ ដូច
ព្រះតម្រាស់ដែលទ្រង់ត្រាស់ថា ៖

សព្វាភិភូ សព្វវិទូហមស្មិ សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហាក្ខយេ វិមុត្តោ សយំ អភិញ្ញាយ
កមុទ្ទិសេយ្យំ ។

ន មេ អាចរិយោ អត្ថិ សទិសោ មេ ន វិជ្ជតិ
សទេវកស្មឹ លោកស្មឹ នត្ថិ មេ បដិបុគ្គលោ ។
អហញ្ហិ អរហា លោកេ អហំ សត្ថា អនុត្តរោ
ឯកោម្ហិ សម្មាសម្ពុទ្ធោ សីតិភូតោស្មិ និព្វុតោ ។

តថាគតជាអ្នកគ្របសង្កត់ នូវតេភូមិកធម៌ទាំងអស់
ត្រាស់ដឹងនូវចតុព្ភូមិកធម៌ មិនប្រឡាក់ដោយកិលេស
ក្នុងតេភូមិកធម៌ទាំងអស់ បានលះបោលនូវតេភូមិក
ធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះ ព្រោះអស់
ទៅនៃតណ្ហាហើយ ដឹងច្បាស់ចតុព្ភូមិកធម៌ដោយខ្លួន

**ឯង ចាំបាច់ឧទ្ទិសខ្លួនចំពោះគ្រូណា តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលស្មើនឹងតថាគតទេ ក្នុងលោកនេះ ព្រមទាំងទេវលោក មិនមានបុគ្គលណាប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះតថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់បំផុត ជាអ្នកត្រាស់ដឹង ដោយប្រពៃចំពោះព្រះអង្គឯង តថាគតមានសេចក្តីត្រជាក់ មានកិលេសរលត់ហើយ ។**[១]

បទថា **អតុលំ** សូម្បីប្រកបដោយស័ព្ទសម្មាសម្ពុទ្ធ និងដោយអត្ថនៃពាក្យតាមដែលពោលហើយ ទើបសរសើរព្រះមានព្រះភាគឱ្យវិសេស ដោយពាក្យថា **អតុលំ** ព្រោះស័ព្ទថា **សម្មាសម្ពុទ្ធ** ជាព្រះនាមព្រះមានព្រះភាគ ។

ពិតមែន ព្រះមានព្រះភាគ មិនមានបុគ្គលណាមួយប្រៀបផ្ទឹមបានឡើយ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា

---

១. មជ្ឈិ. មូល. បាសិរាសិសូត្រ. ២១. ៦៣/១៥៤ ។

**អតុល** គឺ មិនមានបុគ្គលណា ៗដូចដោយគុណទាំងឡាយមានសីលជាដើម ព្រោះព្រះអង្គជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក មិនមានអ្នកណាផ្ទឹម មិនមានអ្នកណាស្មើ សេចក្ដីនេះសមដូចដែលត្រាស់ទុកថា "**យាវតា ភិក្ខវេ សត្តា អបទា វា ទ្វិបទា វា ចតុប្បទា វា ពហុប្បទា វា រូបិនោ វា អរូបិនោ វា សញ្ញិនោ វា អសញ្ញិនោ វា នេវសញ្ញីនាសញ្ញិនោ វា តថាគតោ តេសំ អគ្គមក្ខាយតិ** : ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ទោះជាសត្វឥតជើងក្ដី មានជើងពីរក្ដី មានជើងបួនក្ដី មានជើងច្រើនក្ដី មានរូបក្ដី ឥតរូបក្ដី មានសញ្ញាក្ដី ឥតសញ្ញាក្ដី មានសញ្ញាក៏មិនមែនមិនមានសញ្ញាក៏មិនមែនក្ដី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ"[១] ដូច្នេះ ។

ដោយបទថា **អតុលំ** តាមដែលពោលមកនេះ ជាពាក្យ

---

១. សំយុ. មហា. អប្បមាទវគ្គ. ៣៧. ២៤៥/១១១ ។

ដែលព្រះអនុរុទ្ធាចារ្យ ធ្វើការពោលសរសើរគុណព្រះមានព្រះភាគដោយសម្បទា ៣ យ៉ាង គឺ ហេតុសម្បទា ១ ផលសម្បទា ១ សត្តូបការសម្បទា ១ ។

ទ្រង់ប្រកបដោយព្រះមហាករុណា និងទ្រង់អប់រំបំពេញពោធិសម្ភារ ឈ្មោះ ថា **ហេតុសម្បទា** ។

ចំណែក**ផលសម្បទា** មាន ៤ យ៉ាង គឺ ញាណសម្បទា១ បហានសម្បទា១ អានុភាវសម្បទា១ និងរូបកាយសម្បទា១ ។

## អធិប្បាយផលសម្បទា ៤ យ៉ាង

១. មគ្គញ្ញាណដែលជាទីតាំងនៃសព្វញ្ញុតញ្ញាណ និងទសពលញ្ញាណជាដើម ឈ្មោះថា **ញាណសម្បទា** ។

២. សង្កិលេសទាំងអស់ ព្រមទាំងវាសនា ដែលព្រះអង្គលះបានហើយ មិនកើតឡើងទៀត ឈ្មោះថា **បហានសម្បទា** ។

៣. អានុភាព គឺ ភាពជាធំក្រៃលែង ក្នុងការធ្វើឱ្យសម្រេចបានតាមសេចក្តីប្រាថ្នា ឈ្មោះថា **អានុភាវសម្បទា** ។

៤. អត្តភាវសម្បត្តិ គឺ ព្រះរូបសម្បត្តិដែលប្រកបដោយមហាបុរិសលក្ខណៈ និងអនុព្យញ្ជនៈ គួរជាទីរីករាយរបស់មនុស្សសត្វទាំងពួងដែលបានឃើញហើយ ឈ្មោះថា **រូបកាយសម្បទា** ។

**សត្តូបការសម្បទា** មាន ២ យ៉ាង គឺ

**អាសយៈ** បានដល់ ព្រះអធ្យាស្រ័យ និង**បយោគ** បានដល់ ព្រះឧស្សាហ៍ ព្រះមានព្រះភាគ ទ្រង់មានអធ្យាស្រ័យអនុគ្រោះជានិច្ច សូម្បីក្នុងពួកសត្វដែលមានកំហុស ដូចភិក្ខុទេវទត្តជាដើម និងទ្រង់រង់ចាំវេលាចាស់ក្លានៃឥន្ទ្រិយរបស់សត្វដែលមិនទាន់ចាស់ក្លា ឈ្មោះថា **អាសយៈ** ។

ព្រះអង្គសម្តែងធម៌ ដើម្បីនាំសត្វឱ្យចេញចាកទុក្ខ មិនមានព្រះទ័យប្រាថ្នាលាភ សក្ការៈជាដើម ឈ្មោះថា

បយោគៈ ។

ទ្រង់ប្រកបដោយសម្បទា ដូចដែលពោលមកនេះ ទើបឈ្មោះថា **អតុលំ** គឺ មិនមានអ្នកណាប្រៀប ។

បទថា **សសទ្ធម្មគណុត្តមំ** "ព្រមដោយព្រះសទ្ធម្ម" ព្រះសទ្ធម្មក្នុងទីនេះ បានដល់ សទ្ធម្ម ៣ យ៉ាង គឺ

១. បរិយត្តិសទ្ធម្ម គឺ ព្រះពុទ្ធវចនៈ ឬព្រះត្រៃបិដក

២. បដិបត្តិសទ្ធម្ម គឺ ការរក្សាសីល កាន់ធុតង្គ ចម្រើនកម្មដ្ឋាន

៣. បដិវេធសទ្ធម្ម គឺ មគ្គ ផល និព្វាន ឈាន អភិញ្ញា ។

ដែលឈ្មោះថា សទ្ធម្ម ព្រោះជាធម៌របស់លោកអ្នកស្ងប់ គឺ សប្បុរសទាំងឡាយ, ព្រះអរិយបុគ្គល ឈ្មោះថា ខ្ពង់ខ្ពស់ ព្រោះប្រកបដោយគុណវិសេស មានការបដិបត្តិល្អហើយដោយប្រពៃជាដើមម្យ៉ាងទៀត ឈ្មោះថា ខ្ពង់ខ្ពស់

ព្រោះខ្ពស់ជាងមនុស្ស និងទេវតាទាំងឡាយ ។

ពាក្យថា **អភិវាទិយ** ប្រែថា សូមថ្វាយអភិវាទ គឺ សូមថ្វាយបង្គំដោយវិសេស ថ្វាយបង្គំដោយគោរព ដោយកាយទ្វារ វចីទ្វារ និងមនោទ្វារ ដោយវៀរចាកការសំពះព្រោះខ្លាច និងព្រោះឃើញដល់ការបាន (លាភ យស...)ជាដើម ។

ពាក្យថា **ភាសិស្សំ** ប្រែថា នឹងពោល នឹងតែង ។

ពាក្យថា **អភិធម្មត្ថសង្គហៈ** បែកជា ៥ ស័ព្ទ គឺ អភិ + ធម្ម + អត្ថ + សំ + គហ ។

**១. អភិ** ប្រែថា ដ៏ប្រសើរ ដ៏ក្រៃលែង, **២. ធម្ម** ប្រែថា សភាវៈដែលទ្រទ្រង់ទុក, **៣. អត្ថ** ប្រែថា អត្ថ ឬ សេចក្តី, **៤. សំ** ប្រែថា ដោយសង្ខេប **៥. គហ** ប្រែថា ការរួបរួម ; **អភិធម្មត្ថសង្គហៈ** ប្រែថា រួបរួមសេចក្តីនៃព្រះអភិធម្ម (៧ គម្ពីរ) ទុកដោយសង្ខេប ។

## សង្គហគាថា

២. តត្ថ វុត្តាភិធម្មត្ថា ចតុធា បរមត្ថតោ

ចិត្តំ ចេតសិកំ រូបំ និព្វានមីតិ សព្វថា ។

*រីអត្ថនៃព្រះអភិធម្មទាំងឡាយ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទុកក្នុងអភិធម្មទាំង ៧ គម្ពីរនោះ ដោយសេចក្ដីល្អិតសុខុមក្រៃពេក ដោយចំណែកធម៌ ៤ ប្រការ គឺ ចិត្ត ១ ចេតសិក ១ រូប ១ និងព្រះនិព្វាន ១ ។*

## ពណ៌នាសេចក្ដីទុតិយគាថា

*ព្រះអនុរុទ្ធាចារ្យ កាលធ្វើការនមស្សការព្រះរតនត្រ័យជាខាងដើម ដែលជានិមិត្តនៃប្រយោជន៍តាមសេចក្ដីប្រាថ្នាយ៉ាងនេះហើយ ឥឡូវនេះ នឹងផ្ដើមបករណ៍ ដោយអំណាចការរួបរួមអត្ថ ក្នុងព្រះអភិធម្មទាំងឡាយណា ដើម្បីនឹងលើកអត្ថក្នុងព្រះអភិធម្មទាំងឡាយនោះឡើង សម្ដែងទុកដោយ*

សង្ខេប ទើបពោលពាក្យថា **តត្ថ វុត្តា** ជាដើម មានសេចក្ដីថា អត្ថក្នុងព្រះអភិធម្មទាំងឡាយ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងគម្ពីរព្រះអភិធម្មដោយពិស្ដារនោះ គឺ ដោយអំណាចនៃធម៌ មានកុសលជាដើម និងដោយអំណាចនៃធម៌មានខន្ធជាដើម, កាលពោលដោយបរមត្ថ (វៀរបញ្ញត្តិ) មានត្រឹម ៤ ប្រការ គឺ **ចិត្ត** បានដល់ វិញ្ញាណក្ខន្ធ, **ចេតសិក** បានដល់ ខន្ធ ៣ មានវេទនាខន្ធជាដើម, **រូប** បានដល់ រូបក្ខន្ធ ដែលផ្សេងគ្នាដោយប្រភេទនៃមហាភូតរូប និងឧបាទាយរូប, ព្រះនិព្វាន បានដល់ អសង្ខតធម៌ ។

## អធិប្បាយពាក្យថា បរមត្ថ

ពាក្យថា បរមត្ថ មាន ២ បទ គឺ **បរម** = **អត្ថ**

**បរម** : ប្រសើរ ខ្ពង់ខ្ពស់ មិនវិបរិត, **អត្ថ** : អត្ថន័យ ឬ សេចក្ដី; រួមពីរបទចូលគ្នា ជា **បរមត្ថ** : អត្ថដ៏ប្រសើរ ។

**បរមត្ថ** មានវចនត្ថៈថា **បរមោ អត្ថោ អវិបរិតោ អត្ថោ បរមស្ស វា ឧត្តមស្ស ញាណស្ស អត្ថោ គោចរោតិ = បរមត្ថោ :** អត្ថដែលមិនវិបរិត ដ៏ប្រសើរ គឺ ខ្ពង់ខ្ពស់ ឬ អត្ថដែលជាអារម្មណ៍របស់ញាណដ៏ប្រសើរ គឺ ខ្ពង់ខ្ពស់ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា បរមត្ថៈ ។

ម្យ៉ាងទៀត មានវចនត្ថៈថា **បរមោ(បធានោ) អត្ថោ = បរមត្ថោ :** អត្ថ (ដែលជាប្រធានក្នុងអត្ថប្បញ្ញត្តិ និង នាមប្បញ្ញត្តិ) ឈ្មោះថា បរមត្ថៈ ។ (បរមត្ថ + ធម៌ = បរមត្ថធម៌) ។

## បរមត្ថធម៌ មាន ២ យ៉ាង

១. **សង្ខតធម៌** ធម៌ដែលមានបច្ច័យតាក់តែង គឺ ចិត្ត ចេតសិក រូប

២. **អសង្ខតធម៌** ធម៌ដែលមិនមានបច្ច័យតាក់តែង គឺ ព្រះនិព្វាន

## សច្ចៈ សេចក្តីពិត ២ យ៉ាង

ព្រះមានព្រះភាគ ទ្រង់ឆ្លាតក្នុងទេសនា បានត្រាស់សច្ចៈ ២ គឺ

**១, បរមត្ថសច្ចៈ** ពិតដោយបរមត្ថ

**២, សម្មតិសច្ចៈ** ពិតដោយការសន្មត

<u>ក្នុងមនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ ឯកនិបាត</u> ពោលថា ៖

ទុវេ សច្ចានិ អក្ខាសិ  សម្ពុទ្ធោ វទតំ វរោ
សម្មុតឹ បរមត្ថញ្ច  តតិយំ នុបលព្ភតិ ។

ព្រះសម្ពុទ្ធដ៏ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់ប្រកាសសច្ចៈ ២ គឺ សម្មតិសច្ចៈ១ បរមត្ថសច្ចៈ១ មិនត្រាស់សច្ចៈទី៣ ។

## ហេតុដែលនាំឱ្យទ្រង់ត្រាស់សម្មតិសច្ចៈ មាន ៨ ប្រការ

១. ដើម្បីទ្រង់សម្ដែងដល់ហិរិ និងឱត្តប្បៈ

២. ដើម្បីទ្រង់សម្ដែងកម្មស្សកតា

៣. ដើម្បីទ្រង់សម្ដែងដល់អ្នកធ្វើអំពើចំពោះខ្លួន

៤. ដើម្បីទ្រង់សម្ដែងដល់អនន្តរិយកម្ម

៥. ដើម្បីទ្រង់សម្ដែងដល់ព្រហ្មវិហារធម៌

៦. ដើម្បីទ្រង់សម្ដែងដល់បុព្វេនិវាសញ្ញាណ

៧. ដើម្បីទ្រង់សម្ដែងដល់ទក្ខិណាវិសុទ្ធិ

៨. ទ្រង់សម្ដែងដើម្បីមិនលះនូវបញ្ញត្តិក្នុងលោក ។[១]

---

១. បបញ្ចសូទនី អដ្ឋកថានៃមជ្ឈិមនិកាយ មូលបណ្ណាសក, អនង្គណសូត្រ ។

# ចិត្តបរមត្ថ

**ចិត្ត** មានវចនត្ថៈថា **អារម្មណំ ចិន្តេតីតិ = ចិត្តំ** ធម្មជាតណា រមែងគិត គឺ ដឹងអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា ចិត្ត ។

ម្យ៉ាងទៀត មានវចនត្ថៈថា **ចិន្តេន្តិ សម្បយុត្តធម្មា ឯតេនាតិ = ចិត្តំ** ធម្មជាត ដែលឈ្មោះថា ចិត្ត ព្រោះអត្ថថា ជាហេតុឱ្យសម្បយុត្តធម៌ដឹងអារម្មណ៍ ។

ម្យ៉ាងទៀត មានវចនត្ថៈថា **ចិន្តនមត្តំ = ចិត្តំ** ធម្មជាត ដែលត្រឹមតែគិត គឺ ដឹង ក៏ឈ្មោះថា ចិត្ត ។

<u>ក្នុងអដ្ឋសាលិនី</u> ពោលទុកថា **យំ ចិត្តំ មនោ ហទយំ មានសំ បណ្ឌរំ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ ចិត្តំ ។**

១. ធម្មជាតិណា រមែងគិត ធម្មជាតិនោះ ឈ្មោះថា **ចិត្ត**

២. ធម្មជាតិណា រមែងបង្អោនទៅ ធម្មជាតិនោះ ឈ្មោះថា

**មនោ**

៣. ធម្មជាតិដែលរួបរួមអារម្មណ៍ទុកខាងក្នុង ឈ្មោះថា **ហទយៈ**

៤. ចិត្តនុ៎ះឯង មានឆន្ទៈ គឺ សេចក្ដីពេញចិត្ត ឈ្មោះថា **មានសៈ**

៥. ចិត្តនោះ ជាធម្មជាតិថ្លាផូរផង់ ឈ្មោះថា **បណ្ឌរៈ**

៦. មនៈ ដែលជាអាយតនៈខាងក្នុង ឈ្មោះថា **មនាយតនៈ**

៧. មនៈ ដែលជាឥន្ទ្រិយ ឈ្មោះថា **មនិន្ទ្រិយ**

៨. ធម្មជាតិ ដែលដឹងច្បាស់នូវអារម្មណ៍ ឈ្មោះថា **វិញ្ញាណ**

៩. ខន្ធ គឺ គំនរនៃវិញ្ញាណ មានវិញ្ញាណជាអតីតជាដើម ឈ្មោះថា **វិញ្ញាណក្ខន្ធ**

១០. មនៈ ដែលជាធាតុ ដឹងច្បាស់នូវអារម្មណ៍ ឈ្មោះថា **មនោវិញ្ញាណធាតុ** ។

## លក្ខណៈរបស់ចិត្ត

ចិត្តជាសង្ខតធម៌ គឺ ធម៌ដែលតាក់តែងដោយបច្ច័យទាំងឡាយ ដូច្នោះ ចិត្តទើបធ្លាក់នៅក្នុងអំណាចសាមញ្ញលក្ខណៈ គឺ អនិច្ចលក្ខណៈ ទុក្ខលក្ខណៈ អនត្តលក្ខណៈ ព្រោះចិត្តមានសភាពជាត្រៃលក្ខណ៍ ដូច្នេះ ចិត្តទើបមានការកើតរលត់បន្តគ្នាទៅមិនដាច់ និងប្រព្រឹត្តទៅយ៉ាងរហ័ស មិនអាចនឹងរាប់ប្រមាណបាន ។ សង្ខតធម៌ដែលជាចេតសិក និងរូប ក៏ធ្លាក់នៅក្នុងអំណាចរបស់ត្រៃលក្ខណ៍ដូចគ្នា ។

## លក្ខណាទិចតុក្កៈរបស់ចិត្ត

១. **វិជាននលក្ខណំ** មានការដឹងអារម្មណ៍ ជាលក្ខណៈ

២. **បុព្វង្គមរសំ** មានភាពជាប្រធាន ជាកិច្ច

៣. **សន្ធានបច្ចុប្បដ្ឋានំ** មានការកើតបន្តគ្នា ជាផល

៤. **នាមរូបបទដ្ឋានំ** មាននាមក្ខន្ធ៣ និងរូប ជាបទដ្ឋាន ។

## អំណាចចិត្ត

អាចារ្យទាំងឡាយ ពណ៌នាអត្ថនៃចិត្តស័ព្ទ ដោយពិស្ដារ សូម្បីដោយអត្ថដែលមានការធ្វើឱ្យវិចិត្រជាដើម ។ ក្នុងចិត្តស័ព្ទនេះ មានសេចក្ដីសង្ខេបដូច្នេះ ៖

**វិចិត្តករណា ចិត្តំ អត្តនោ ចិត្តតាយ វា**
**ចិត្តំ កម្មកិលេសេហិ ចិត្តំ តាយតិ វា តថា**
**ចិនោតិ អត្តសន្តានំ វិចិត្តារម្មណន្តិ វាតិ ។**

**១. វិចិត្តករណា ចិត្តំ** ឈ្មោះថា ចិត្ត ព្រោះធ្វើឱ្យវិចិត្រផ្សេង ៗ និងធ្វើវត្ថុផ្សេង ៗឱ្យវិចិត្រ គឺ ឱ្យមានសេចក្ដីល្អស្អាត ដូចវិចិត្រករ(ជាងគំនូរ) គូររូបភាពល្អស្អាតបានច្រើនយ៉ាង និងវិចិត្រធ្វើកិរិយា មារយាទឱ្យសមរម្យល្អស្អាតគួរមើល គួរសរសើរ ឬធ្វើឱ្យប្លែកចម្លែក គួរឱ្យឆ្ងល់ជាដើម ។ ម្យ៉ាងទៀត សំដៅដល់ការធ្វើដែលកើតអំពីចិត្តទាំងជាកុសល និងជាអកុសល ឱ្យមានភាពវិចិត្រច្រើនបែបច្រើន

យ៉ាង ។

**២. អត្តនោ ចិត្តតាយ វា** ឈ្មោះថា ចិត្ត ព្រោះសភាពរបស់ខ្លួនវិចិត្រ គឺ ចិត្តនុ៎ះឯង ជាកុសលក៏មាន អកុសលក៏មាន វិបាកក៏មាន កិរិយាក៏មាន សេចក្តីនេះសំដៅដល់ ចិត្តនុ៎ះឯង ខណៈខ្លះក៏ជាកុសល ខណៈខ្លះក៏ជាអកុសល ខណៈខ្លះក៏ជាវិបាក ខណៈខ្លះក៏ជាកិរិយា ។

**៣. ចិត្តំ កម្មកិលេសេហិ** ឈ្មោះថា ចិត្ត ព្រោះសន្សំកម្ម និងកិលេស គឺ ចិត្តនុ៎ះឯង ជាអ្នកសន្សំកម្មដែលជាកុសលជាអកុសល និងសន្សំកិលេស មានរាគៈទោសៈ និងមោហៈជាដើម ដូចមានរាគៈ ហើយក៏សន្សំរាគៈនោះ ឱ្យច្រើន ៗឡើងជាដើម ។

**៤. ចិត្តំ តាយតិ វា តថា** ឈ្មោះថា ចិត្ត ព្រោះរក្សាទុកនូវកុសលវិបាក និងអកុសលវិបាករបស់ខ្លួនមិនឱ្យវិនាសកាលមានឱកាសបានបច្ច័យហើយ វិបាកនោះ ៗ រមែងកើត

ឡើង ដូចឱ្យកើតតាមចក្ខុទ្វារជាដើម ។

**៥. ចិនោតិ អត្តសន្តានំ** ឈ្មោះថា ចិត្ត ព្រោះសន្សំសន្តាន គឺ ចិត្តនុ៎ះឯង រមែងសន្សំអំពើល្អខ្លះ អំពើអាក្រក់ខ្លះ ទុកក្នុងសន្តាន មិនឱ្យបាត់ មិនឱ្យវិនាស ធ្វើឱ្យកើតសេចក្តីជំនាញ គឺ ទម្លាប់ក្នុងការធ្វើដរាប ដល់ជានិស្ស័យ ឬជាចរិតជាប់តាមសន្តាន ។

**៦. វិចិត្តារម្មណន្តិ វា** ឈ្មោះថា ចិត្ត ព្រោះអារម្មណ៍វិចិត្រ ដោយប្រការផ្សេង ៗ គឺ ចិត្តនេះ ជាធម្មជាតដឹងអារម្មណ៍ បានតាមទ្វារ ៦ តែដឹងម្តងបានអារម្មណ៍តែមួយ មានរូបារម្មណ៍ជាដើម ។

<u>ក្នុងបរមត្ថទីបនីដីកា</u> ពោលថា ៖

ចិត្តវិចិត្តតាយ សញ្ញាវិចិត្តា

សញ្ញាវិចិត្តតាយ តណ្ហាវិចិត្តា

តណ្ហាវិចិត្តតាយ កម្មានិ វិចិត្តា

កម្មវិចិត្តតាយ យោនិយោ វិចិត្តា
យោនិវិចិត្តតាយ តេសំ
តិរច្ឆានគតានំ វិចិត្តតា វេទិតព្វា ។

*សេចក្តីដែលសត្វទាំងនោះវិចិត្រ ព្រោះកំណើតវិចិត្រ, កំណើតវិចិត្រ ព្រោះការធ្វើវិចិត្រ, ការធ្វើវិចិត្រ ព្រោះតណ្ហាវិចិត្រ, តណ្ហាវិចិត្រ ព្រោះសញ្ញាវិចិត្រ, សញ្ញាវិចិត្រ ព្រោះចិត្តវិចិត្រ ។*

ពាក្យថា **សត្វទាំងនោះវិចិត្រ ព្រោះកំណើតវិចិត្រ** នោះមានសេចក្តីថា សត្វទាំងឡាយដែលកើតក្នុងលោក មានច្រើនប្រភេទ សូម្បីមួយប្រភេទ ៗ ក៏មានច្រើន, សត្វដែលកើតលើគោក មានប្រមាណរាប់មិនបាន ឯសត្វក្នុងទឹក ក៏ច្រើនជាងសត្វដែលនៅលើគោក សត្វដែលកើតក្នុងភូមិដទៃ ៗ មានអបាយភូមិជាដើម ក៏ច្រើនសន្ធឹកសន្ធាប់ ទាំងនេះកើតមាន ព្រោះកំណើតវិចិត្រ ដូច្នោះ ទើបលោកពោលថា សត្វ

ទាំងឡាយវិចិត្រ ព្រោះកំណើតវិចិត្រ គឺ មានប្រភេទច្រើនជាទីបំផុត ។ ពាក្យថា **កំណើតវិចិត្រ ព្រោះការធ្វើវិចិត្រនោះ** គឺថា ជាធម្មតារបស់សត្វដែលកើតមកហើយ តែងតែធ្វើកម្មទុកផ្សេង ៗគ្នា ពួកខ្លះធ្វើកុសល ពួកខ្លះធ្វើអកុសល ហេតុនោះ ទើបលោកពោលថា កំណើតវិចិត្រ ព្រោះការធ្វើវិចិត្រ ។

ពាក្យថា **ការធ្វើវិចិត្រ ព្រោះតណ្ហាវិចិត្រ** មានសេចក្ដីថា តណ្ហា គឺ សេចក្ដីប្រាថ្នា ចង់បានក្នុងវត្ថុផ្សេង ៗ ក្នុងសត្វ ក្នុងបុគ្គល មិនចង់ព្រាត់ប្រាស់ ឬប្រាថ្នាដោយប្រការណា ៗ ក៏ដោយ ខ្លួនឯងទើបត្រូវធ្វើកម្មដោយអំណាចនៃតណ្ហា ដែលមានប្រភេទផ្សេង ៗនោះ ព្រោះហេតុនេះ ទើបលោកពោលថា ការធ្វើវិចិត្រ ព្រោះតណ្ហាវិចិត្រ ។

ពាក្យថា **តណ្ហាវិចិត្រ ព្រោះសញ្ញាវិចិត្រ** មានសេចក្ដីថា សញ្ញា គឺ ការចាំបាន ការចំណាំដឹងបាន ក៏មានច្រើន

យ៉ាង ដូចជាឃើញរូបម្តង ការចាំក៏កើតឡើងម្តង ស្តាប់សំឡេងម្តងការចាំក៏កើតឡើងម្តង យ៉ាងនេះជាដើម កាលណាមានការចាំក្នុងវត្ថុដែលល្អ តណ្ហាក៏កើតការពេញចិត្តក្នុងវត្ថុនោះ ៗ ព្រោះហេតុនេះ ទើបលោកពោលថា តណ្ហាវិចិត្រ ព្រោះសញ្ញាវិចិត្រ ។

ពាក្យថា **សញ្ញាវិចិត្រ ព្រោះចិត្តវិចិត្រ** បានសេចក្តីថា កាលចិត្តមួយកើតឡើង សញ្ញាមួយក៏កើតឡើង ចិត្តកើតមួយរយដង មួយពាន់ដង សញ្ញាក៏កើតមួយរយដង មួយពាន់ដង ស្មើនឹងចិត្តនុ៎ះឯង ព្រោះហេតុនោះ ទើបលោកពោលថា សញ្ញាវិចិត្រ ព្រោះចិត្តវិចិត្រ ។

## ចែកចិត្ត ៨៩ ដោយន័យផ្សេង ៗ

ចិត្តទាំងអស់ មាន ៨៩ ដោយពិស្តារ មាន ១២១ កាលពោលដោយលក្ខណៈហើយ មានតែ១ គឺ "**អារម្មណវិជាននលក្ខណំ** : មានការដឹងអារម្មណ៍ ជា

លក្ខណៈ", កាលចែកដោយប្រភេទរបស់ចិត្ត រមែងបានន័យផ្សេង ៗ ដូច្នេះ គឺ ៖

ដោយជាតិ ដោយភូមិ ដោយវេទនា ដោយហេតុ ដោយសម្បយោគៈ ដោយសង្ខារ ដោយសោភណ ដោយឈាន ដោយលោក ដោយកិច្ច ដោយអារម្មណ៍ ដោយទ្វារ ដោយវត្ថុ និងដោយវិញ្ញាណធាតុ ៧ ។

## ចេតសិកបរមត្ថ

ព្រះដីកាចារ្យ ពោលលក្ខណៈរបស់ចេតសិកទុក ២ ន័យ គឺ

**ចេតសិ ភវំ = ចេតសិកំ :** ធម្មជាតណា ដែលកើតជាមួយនឹងចិត្ត ធម្មជាតនោះ ឈ្មោះថា ចេតសិក ។

**ចេតសិ និយុត្តំ = ចេតសិកំ :** ធម្មជាតប្រកបជាមួយចិត្ត ឈ្មោះថា ចេតសិក ។

ធម្មជាតិដែលកើតជាមួយចិត្តនោះ បានដល់ ធម្មជាតិដែលអាស្រ័យចិត្តកើតឡើង និងកើតរួមជាមួយចិត្ត ចិត្តមិនកើតចេតសិកក៏មិនកើត ។ ចំណែកដែលលោកពោលថា ធម្មជាតិ ប្រកបជាមួយចិត្ត ឈ្មោះថា ចេតសិក បានដល់ការប្រកបដោយអង្គ ៤ គឺ ៖

**១. ឯកុប្បាទ** កើតព្រមជាមួយនឹងចិត្ត
**២. ឯកនិរោធ** រលត់ព្រមជាមួយនឹងចិត្ត
**៣. ឯកាលម្ពន** មានអារម្មណ៍តែមួយជាមួយនឹងចិត្ត
**៤. ឯកវត្ថុក** អាស្រ័យវត្ថុតែមួយជាមួយនឹងចិត្ត

ពិតមែន ចេតសិកនោះ វៀរចាកចិត្តហើយ មិនអាចនឹងកើតឡើងបាន ចំណែកចិត្តវៀរចាកចេតសិកពួកខ្លះ ក៏កើតបាន (ដូចជាទិដ្ឋិ ឬមានះ មិនកើតក្នុងទោសមូលចិត្តជាដើម ពិស្តារមានក្នុងបរិច្ឆេទទី២) ព្រោះដូច្នោះ ចេតសិកនោះ ទើបឈ្មោះថា ប្រព្រឹត្តទៅជាមួយនឹងចិត្ត សមដូចព្រះ

តម្រាស់ថា ៖

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះ វិលតាមជានជើងគោដែលកំពុងអូសទៅ ។[១]

---

១. ខុទ្ទ. ធម្ម. យមកវគ្គ. ៥២. ១១ស/២១ ។

## រូបបរមត្ថ

<u>ក្នុងបរមត្ថទីបនីដីកា</u> ពោលទុកថា ៖

**រុប្បតីតិ = រូបំ :** ធម្មជាតណា រមែងបែកធ្លាយ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា រូប ។

<u>ក្នុងវិភាវិនីដីកា</u> លោកបានអធិប្បាយទុកថា ៖

**សីតុណ្ហាទិវិរោធិប្បច្ចយេហិ រុប្បតីតិ = រូបំ :** ធម្មជាតណា រមែងបែកធ្លាយ (វិនាសទៅ)ដោយបច្ច័យ ដែលជាសត្រូវ មានត្រជាក់ជាដើម ព្រោះដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា រូប ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ របស់ណាវិនាស របស់នោះហៅថា រូប ។ ចុះវិនាសដោយអ្វី ? វិនាសដោយត្រជាក់ក៏មាន វិនាសដោយក្តៅក៏មាន វិនាសដោយគំលានក៏មាន វិនាសដោយសម្រេកក៏មាន វិនាសដោយសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់

តូចពស់ធំក៏មាន”[១] ។

សួរថា បើដូច្នោះ សុម្បីអរូបធម៌ គឺ ធម៌ដែលជានាម ក៏ហៅថា រូបបានឬ ?

ឆ្លើយថា មិនបានទេ ព្រោះលោកសំដៅយកការ ប្រែប្រួលដែលប្រាកដច្បាស់ ដោយបច្ច័យដែលជាសត្រូវ មានត្រជាក់ជាដើម ។

តើប្រាកដច្បាស់ដូចម្តេច ?

<u>ក្នុងសម្មោហវិនោទនី អដ្ឋកថាវិភង្គ</u> ពោលទុកថា ៖

រូបរមែងបែកធ្លាយ គឺ រមែងសាបសូន្យទៅ ព្រោះ ត្រជាក់នោះ ដូចក្នុងលោកន្តរនរក, នរកមួយរណ្តៅ ៗ ប្រមាណ ៨.០០០ យោជន៍ ក្នុងចន្លោះចក្រវាឡទាំង ៣ ខាងក្រោមមិនមានផែនដី ខាងលើមិនមានព្រះចន្ទ ព្រះអាទិត្យ

---

១. សំយុ. ខន្ធ. ខជ្ជនីយវគ្គ. ៣៣. ១៥៩/២០២ ។

មិនមានពន្លឺអ្វីបន្តិចបន្តួចឡើយ ងងឹតជានិច្ច ឈ្មោះថា លោកន្តរនរក, អត្តភាពរបស់សត្វដែលកើតក្នុងទីនោះ មាន ប្រមាណ ៣ គាវុត សត្វទាំងនោះ មានក្រចក-វែងក្រាស់ ៗ តោងថ្កក់ជើងភ្នំចក្រវាឡខាងក្រោម សំយុងក្បាលចុះ ដូច សត្វជ្រីង ឬប្រចៀវ កាលណា វារំកិលទៅប៉ះគ្នា ពួកវាក៏ សំគាល់ថា បានអាហារហើយ ក៏ខ្វល់ខ្វាយក្នុងអាហារនោះ ដេញតាមគ្នាទៅប្រកិត ៗ ហើយក៏ធ្លាក់ចុះទៅក្នុងទឹកទ្រផែនដី ទៅ កាលខ្លះត្រូវខ្យល់ត្រជាក់បក់មក ពួកវាភ័យខ្លាច ក៏ របូតជាប់ធ្លាក់ចុះក្នុងទឹកទៅ ពេលធ្លាក់ទៅដល់ទឹកនោះ ពួក វាត្រូវទឹកដ៏ត្រជាក់ កាត់ទម្លាយជាដុំ ៗ ដូចដុំម្សៅដែល គេដាក់ក្នុងខ្លាញ់ក្ដៅ, ការវិនាសទៅនៃរូបក្នុងលោកន្តរនរក ដោយត្រជាក់យ៉ាងនេះ សូម្បីក្នុងប្រទេសដែលត្រជាក់ខ្លាំង ព្រោះទឹកកក និងព្រិលធ្លាក់ មានដែនឈ្មោះមហិសកៈជាដើម ក៏ដូចគ្នា ព្រោះសត្វទាំងឡាយ ក្នុងប្រទេសនោះ មានរាង

កាយ ត្រូវត្រជាក់ធ្វើឱ្យវិនាស ដរាបដល់អស់ជីវិត ក៏មាន ។

រូបដែលវិនាសទៅ ព្រោះក្ដៅ ដូចសត្វកើតក្នុងអវិចីមហានរក ។

រូបដែលវិនាសទៅ ព្រោះស្រេកទឹក ដូចប្រេត ឈ្មោះកាលកញ្ជិកាសូរ មិនអាចបានតំណក់ទឹក ត្រឹមតែញ៉ាំងបំពង់កឱ្យសើម អស់រយៈកាល ២-៣ ពុទ្ធន្តរ សូម្បីពួកខ្លះទៅដល់ទន្លេដោយគិតថា នឹងផឹកទឹក ទឹកនោះក៏ស្ងួតហួតហែងនៅសល់សុទ្ធតែខ្សាច់ ។

រូបដែលវិនាសទៅ ព្រោះឃ្លាន ដូចពួកប្រេតដែលត្រូវសេចក្ដីឃ្លានគ្របសង្កត់ មិនបានអាហារអ្វីបរិភោគឡើយរហូតអស់រយៈកាល ២-៣ ពុទ្ធន្តរ ខាងក្នុងផ្ទៃពោះ ដូចដើមឈើមានប្រហោងខាងក្នុងត្រូវភ្លើងឆេះ, ឬក្នុងពេលកើតទុព្ភិក្ខភ័យ សត្វទាំងឡាយក៏ដល់នូវសេចក្ដីស្លាប់យ៉ាងច្រើន ព្រោះ

ឃ្លាន ។

រូបដែលវិនាសទៅ ព្រោះសម្ផស្សរបោមមូស រមែងប្រាកដក្នុងទីដែលមានសម្ផស្សរបោមមូសនោះច្រើន ។

រូបដែលវិនាសទៅ ព្រោះខ្យល់ ដូចខ្យល់ដែលទម្លាយដៃ ជើង ខ្នងជាដើម ធ្វើឱ្យជាមនុស្សខ្វិន ខ្វាក់ភ្នែក ពិការអវយវៈ និងគមជាដើម ។

រូបដែលវិនាសទៅ ព្រោះកំដៅនោះ រមែងប្រាកដក្នុងផ្លូវកន្តារ មានវាលខ្សាច់ជាដើម មានរឿងពោលទុកថា មានស្ត្រីម្នាក់ បានបែកគ្នាអំពីពួកឈ្មួញរទេះទៅក្នុងវេលារាត្រី ព្រោះតែខ្លួនយឺតយូរពេក នាកណ្តាលវាលខ្សាច់ធំល្វឹងល្វើយ កាលព្រះអាទិត្យគោចរទៅដល់ថ្ងៃត្រង់ ក៏មិនអាចដាក់ជើងលើខ្សាច់ដ៏ក្តៅបាន ទើបដាក់កញ្ចើចុះពីក្បាលមកជាន់, កាលមិនអាចជាន់លើកញ្ចើបាន ព្រោះក្តៅខ្លាំង ក៏ដាក់សាដកពីលើហើយជាន់ទៀត សូម្បីសាដកក៏នៅតែក្តៅ ទើបចាប់កូនដែល

ពរមកជាមួយឱ្យដេកផ្កាប់ហើយជាន់ មិនយូរប៉ុន្មាន ម្តាយនិងកូនក៏ស្លាប់ទាំងពីរនៅក្នុងទីនោះឯង ។

រូបដែលវិនាសទៅ ព្រោះត្រូវសត្វលួននិងសត្វវារតូចធំចិកឬខាំ រូបនោះ ក៏វិនាសទៅ ព្រោះអាសិរពិសផ្សេង ៗ ចិកឬខាំនុ៎ះឯង ។

សួរថា បើរូបវិនាសទៅ ដោយបច្ច័យខាងលើនេះមែន ចុះក្នុងព្រហ្មលោក ដែលមិនមានទូវបច្ច័យទាំងនេះបៀតបៀនសោះ តើហេតុដូចម្តេច បានជាភូមិនោះ ហៅថា រូបព្រហ្ម "ព្រហ្មមានរូប"បាន ?

ឆ្លើយថា សូម្បីបច្ច័យដែលជាសត្រូវមិនប្រាកដព្រោះមានតែបច្ច័យដែលជួយឧបត្ថម្ភ, ក៏ការប្រែប្រួលវិនាសនៃរូបក្នុងព្រហ្មលោកនោះ នៅតែមានដដែល គឺ ព្រោះបច្ច័យដែលជួយឧបត្ថម្ភនោះឯងអស់ ដូច្នោះ ការបញ្ញត្តិថារូបក្នុងព្រហ្មលោកនោះ ក៏មិនកន្លងនូវការប្រែប្រួល វិនាស

ទៅឡើយ ។

## និព្វានបរមត្ថ

ពាក្យថា **និព្វាន** បែកជាពីរសព្ទ គឺ **និ** + **វាន**
**និ** : ចេញ ឬ ផុត **វាន** : តណ្ហាជាគ្រឿងជោតក្រង ។

ធម្មជាតិ ដែលឈ្មោះថា និព្វាន ព្រោះអត្ថថា ចេញចាកតណ្ហា ដែលហៅថា **វាន** ព្រោះជោតក្រង គឺ ជោតក្រងភ្ជាប់ទុកនូវភពតូចនិងភពធំ ឬថា ឈ្មោះថា និព្វាន ព្រោះអត្ថថា ជាគ្រឿងរំលត់ភ្លើង គឺ ភ្លើងរាគៈ ទោសៈ មោហៈជាដើម ។

- ព្រះនិព្វាន មានលក្ខណៈដូចម្តេច ?

+ ព្រះនិព្វាន មានសេចក្តីស្ងប់ ជាលក្ខណៈ

- ព្រះនិព្វានដែលមានសេចក្តីស្ងប់ ជាលក្ខណៈនោះ តើយ៉ាងណា ?

+ ព្រះនិព្វាន មានសេចក្តីសុខស្ងប់ចាកទុក្ខទាំងពួង

ជាលក្ខណៈ គឺ ជាគ្រឿងសំគាល់ឱ្យដឹងថា ព្រះនិព្វានមាន តែសេចក្តីស្ងប់ សេចក្តីសុខ ប្រាសចាកទុក្ខគ្រប់យ៉ាង ព្រោះហេតុនោះ ទើបលោកពោលថា ព្រះនិព្វានមានសន្តិ ជាលក្ខណៈ មានការដល់ព្រមដោយការមិនបែកធ្លាយ មិនមាននិមិត្ត គឺ ការកើតឡើងនៃនាមរូប មានការរលាស់ចេញចាកភពទាំងពួង ផុតចាកហេតុបច្ច័យតាក់តែង ជាធម៌ដែលមានពិត ហៅថា ព្រះនិព្វាន ។

**និព្វាន** មានវចនត្ថៈថា ៖

***វានតោ និក្ខន្តន្តិ = និព្វានំ. វា និព្វាយន្តិ សព្វេ វដ្តទុក្ខសន្តាបា ឯតស្មិន្តិ = និព្វានំ*** : ធម្មជាតណាចេញចាកតណ្ហាដែលជាគ្រឿងដោតក្រង ព្រោះដូច្នោះ ធម្មជាតនោះ ទើបឈ្មោះថា និព្វាន ។ម្យ៉ាងទៀត វដ្តទុក្ខ និងសេចក្តីក្តៅក្រហាយទាំងអស់ រមែងរលត់ទៅក្នុងទីនេះ ព្រោះហេតុនោះ ទីនេះ ទើបឈ្មោះថា និព្វាន ។

ចប់ ការពណ៌នាគាថាផ្តើមបករណ៍

# អធិប្បាយចិត្តបរមត្ថ

## សម្តែងចិត្ត ៤ យ៉ាង

តត្ថ ចិត្តំ តាវ ចតុព្វិធំ ហោតិ កាមាវចរំ រូបាវចរំ អរូបាវចរំ លោកុត្តរញ្ចេតិ : ក្នុងបណ្តាអត្ថព្រះអភិធម្មទាំង ៤ នោះ ជាបឋមនឹងពណ៌នាអំពីចិត្តបរមត្ថមាន ៤ ប្រភេទ គឺ

**១. កាមាវចរចិត្ត** កាម+អវចរ+ចិត្ត

**២. រូបាវចរចិត្ត** រូប+អវចរ+ចិត្ត

**៣. អរូបាវចរចិត្ត** អរូប+អវចរ+ចិត្ត

**៤. លោកុត្តរចិត្ត** លោក+ឧត្តរ+ចិត្ត

**តត្ថ កតមំ កាមាវចរំ** ប្រែថា ចិត្តទាំង ៤ យ៉ាងនោះ កាមាវចរចិត្ត តើដូចម្តេច ?

ពាក្យថា **កតមំ** គឺ ជាពាក្យដែលទ្រង់សួរ ដើម្បី

ឆ្លើយដោយព្រះអង្គឯង ៗ ពិតមែន ពាក្យសួរនោះមាន ៥ ប្រការ គឺ ៖

១. **អទិដ្ឋជោតនាបុច្ឆា** សួរដើម្បីដឹងក្នុងវត្ថុដែលខ្លួនមិនទាន់ដឹង មិនទាន់យល់

២. **ទិដ្ឋសំសន្ទនាបុច្ឆា** សួរដើម្បីប្រៀបធៀបនឹងវត្ថុដែលខ្លួនដឹង

៣. **វិមតិច្ឆេទនាបុច្ឆា** សួរដើម្បីកាត់នូវសេចក្ដីសង្ស័យ

៤. **អនុមតិបុច្ឆា** សួរដើម្បីការយល់ឃើញប្រពៃ( អនុមតិយល់ស្រប )

៥. **កថេតុកម្យតាបុច្ឆា** សួរដើម្បីឆ្លើយខ្លួនឯង ៗ

**កតមំ** ក្នុងទីនេះ ប្រាថ្នាយកសំនួរទី ៥

ពាក្យថា **កាម** បានដល់ កិលេសកាម និងវត្ថុកាម

ពាក្យថា **អវចរ** បានដល់ ការត្រាច់ទៅ

ពាក្យថា **ចិត្ត** បានដល់ ធម្មជាតិដែលដឹងអារម្មណ៍

បណ្ដាកាមទាំងពីរនោះ គឺ

<u>**កិលេសកាម**</u> មានវិគ្រោះថា **កាមេតីតិ = កាមោ** សភាវៈណា រមែងញុំាងចិត្តឱ្យប្រាថ្នា ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា កាម បានដល់ កាមតណ្ហា ។

**សា ឯត្ថ អវចរតិ អាលម្ពនករណវសេនាតិ = កាមាវចរំ** កាមតណ្ហានោះ រមែងត្រាច់ទៅក្នុងចិត្តនេះ ដោយអំណាចការធ្វើឱ្យជាទីតោង ព្រោះហេតុនោះ ចិត្តនោះ ទើបឈ្មោះថា កាមាវចរ ។

<u>**វត្ថុកាម**</u> មានវិគ្រោះថា **កាមីយតីតិ = កាមោ** សភាវៈណា ដែលចិត្តរមែងប្រាថ្នា ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា កាម បានដល់ កាមភព ១១ ដែលមានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាអារម្មណ៍របស់ចិត្តនោះ ។

**តស្មិំ យេភុយ្យេន អវចរតីតិ = កាមាវចរំ** : ចិត្តដែលឈ្មោះថា កាមាវចរ ព្រោះអត្ថថា រមែងត្រាច់ទៅក្នុង

កាមភព ១១ នោះ ដោយច្រើន ។

ពាក្យថា “**កាមាវចរចិត្ត ឬកាមចិត្ត**” មានច្រើនន័យ គឺ ៖

១. សំដៅដល់ ចិត្តដែលកើតក្នុងកាមភូមិ ១១ ជាន់ ដោយច្រើន ព្រោះកាមភូមិ ១១ នោះ បរិបូណ៌ដោយរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាភូមិរបស់កាមបុគ្គល អ្នកដែលកើតក្នុងកាមភូមិ ១១ នេះ គឺ ទោះជាសត្វនរក ប្រេត អសុរកាយ ជាសត្វតិរច្ឆាន ជាមនុស្ស ជាទេវតា ឬជាព្រះខីណាស្រព ឬ ព្រះមានព្រះភាគ ក៏ចាត់ជាកាមបុគ្គល, ចំណែកចិត្តរបស់បុគ្គលដែលកើតក្នុងកាមភូមិ ១១ នេះ ហៅថា កាមាវចរកុសលចិត្តខ្លះ ហៅថា កាមាវចរវិបាកចិត្តខ្លះ ហៅថា កាមាវចរកិរិយាចិត្តខ្លះ ។

២. សំដៅដល់ ចិត្តរបស់អ្នកទាក់ជាប់នៅក្នុងកាមារម្មណ៍ គឺ ជាប់នៅក្នុងកាមតណ្ហាខ្លះ ក្នុងវត្ថុកាម គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈខ្លះ ឬសំដៅដល់ ចិត្តដែល

ប្រព្រឹត្តទៅក្នុងកាមារម្មណ៍នោះ ៗ ។

៣. សំដៅដល់ ចិត្តដែលទទួលកាមារម្មណ៍ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ គឺ ត្រជាក់ ក្ដៅ ទន់ រឹង តឹង ធូរ, ម្យ៉ាងទៀត កាមចិត្តនេះ មិនថាជាចិត្តរបស់បុគ្គល ណា ៗទេ គេកើតក្នុងភូមិ(ភព)ណា ក៏ដោយ កាលបើមាន រូប សំឡេង ក្លិន រស ត្រជាក់ក្ដៅ ទន់ រឹង តឹង ធូរ ជា អារម្មណ៍ ក្នុងខណៈនោះ ក៏ហៅថា កាមចិត្ត ។ សូម្បីព្រះ សម្មាសម្ពុទ្ធ ក៏មានកាមចិត្ត ព្រោះកាលទ្រង់មិនទាន់បរិនិព្វាន ក៏ទ្រង់មានចិត្តឃើញរូប ឮសំឡេងជាដើម ដែលជាអារម្មណ៍ មកប៉ះខ្ទប់តាមទ្វារនោះ ៗ ។

## គាថាសម្ដែងអត្ថរបស់កាមាវចរចិត្ត

កាមោចរន្តីត្ថេត្ថ   កាមេវចរន្តីតិ វា
ឋានូបចារតោ វាបិ   តំ កាមាវចរំ ភវេ ។

ចិត្ត ឈ្មោះថា កាមាវចរ ព្រោះអត្ថថា ជាទីត្រាច់ទៅ

នៃកាម ឬត្រាច់ទៅក្នុងកាម ឬ សូម្បីដោយឋានូប
ចារន័យ. អ្នកសិក្សា គប្បីឃើញន័យនៃរូបាវចរចិត្ត
និងអរូបាវចរចិត្ត សមគួរតាមន័យដូចគ្នានឹងកាមាវចរ
ចិត្តនោះចុះ ។

លោកុត្តរំ (លោកុត្តរសព្ទ) មានវិគ្រោះថា ៖

**ឧបាទានក្ខន្ធសង្ខាតលោកតោ ឧត្តរតិ អនាសវភាវេនាតិ = លោកុត្តរំ :** មគ្គចិត្ត ឈ្មោះថា លោកុត្តរៈ ព្រោះអត្ថថា រមែងឆ្លងឡើងផុតចាកលោក គឺ ឧបាទានក្ខន្ធដែលមិនមានអាសវៈ ។ ចំណែកផលចិត្ត ឈ្មោះថា លោកុត្តរៈ ព្រោះអត្ថថា ឆ្លងឡើងផុតហើយចាកលោក គឺ ឧបាទានក្ខន្ធ ៥ ។

ន័យមួយទៀត សូម្បីមគ្គចិត្ត ផលចិត្ត និព្វាន ឈ្មោះថា លោកុត្តរៈ ព្រោះអត្ថថា ឧត្តម ខ្ពង់ខ្ពស់ គឺ

ក្រៃលែងជាងលោកិយដោយអំណាចនៃគុណ ។

ចិត្តដែលជាធម្មជាតដឹងច្បាស់នូវអារម្មណ៍នោះ មានត្រឹមតែមួយ តែព្រោះការដឹងអារម្មណ៍មិនដូចគ្នា ទើបត្រូវចែកចិត្តតាមអារម្មណ៍មួយ ៗ ក៏បានចិត្ត៨៩ ឬ១២១ ក្នុងភូមិទាំង៤ គឺ ៖

**១. កាមាវចរភូមិ** ចិត្តដែលត្រាច់ទៅក្នុងកាម មាន៥៤
**២. រូបាវចរភូមិ** ចិត្តដែលត្រាច់ទៅក្នុងរូប មាន១៥
**៣. អរូបាវចរភូមិ** ចិត្តដែលត្រាច់ទៅក្នុងអរូប មាន១២
**៤. លោកុត្តរភូមិ** ចិត្តដែលនៅក្នុងលោកុត្តរ មាន៨ ឬ៤០

## ចិត្តមានប្រភេទទាបខ្ពស់ជាងគ្នា ៤ យ៉ាង

១. កាមាវចរចិត្ត ជាហីនចិត្ត គឺ ចិត្តជាន់ទាប
២. រូបាវចរចិត្ត ជាឧក្កដ្ឋចិត្ត គឺ ចិត្តប្រសើរ
៣. អរូបាវចរចិត្ត ជាឧក្កដ្ឋតរចិត្ត គឺ ចិត្តប្រសើរជាង
៤. លោកុត្តរចិត្ត ជាឧក្កដ្ឋតមចិត្ត គឺ ចិត្តប្រសើរបំផុត ។

## ចែកកាមាវចរចិត្តជា ៣ ប្រភេទ គឺ

១. អកុសលចិត្ត ១២ ២. អហេតុកចិត្ត ១៨

៣. កាមាវចរសោភណចិត្ត ២៤

កាលរួមទាំង ៣ ប្រភេទហើយ កាមាវចរចិត្ត ក៏មាន ៥៤ ។

ពាក្យថា **អកុសលចិត្តំ** ចែកជា **ន + កុសល + ចិត្តំ**

**អកុសលចិត្ត** មានវិគ្រោះថា **កុសលបដិបក្ខានិ អកុសលានិ មិត្តបដិបក្ខោ អមិត្តោ វិយ** : ចិត្តដែលជាបដិបក្ខចំពោះកុសលចិត្ត ឈ្មោះថា អកុសលចិត្ត ដូចជនដែលជាបដិបក្ខ ( ប្រឆាំង ) ចំពោះមិត្ត ឈ្មោះថា អមិត្ត ( គឺសត្រូវ ) ដូច្នោះ ។

កាមាវចរចិត្តដែលចែកជាអកុសលចិត្ត អហេតុកចិត្ត និងកាមាវចរសោភណចិត្តទាំង ៣ ប្រភេទនេះ មានសភាព

ផ្សេងគ្នា គឺ ៖

-អកុសលចិត្ត ជាចិត្តអាក្រក់ ឱ្យផលជាទុក្ខ

-អហេតុកចិត្ត ជាផលរបស់កុសល និងអកុសល និងជាអហេតុកកិរិយាចិត្ត ជាចិត្តដែលមិនប្រកបដោយហេតុ មិនមានវិបាក ។

-កាមាវចរសោភណចិត្ត ជាចិត្តដែលល្អ ឱ្យផលជាសុខ ក្នុងកាមារម្មណ៍ ឬជាចិត្តដែលមានសោភណចេតសិកប្រកបជាមួយ,

សូម្បីចិត្តទាំង ៣ ប្រភេទនេះ មានសភាពផ្សេង ៗគ្នា តែក៏ជាកាមាវចរចិត្តទាំងអស់ ។

# កាមាវចរចិត្ត

កាមាវចរចិត្ត មាន ៥៤ ចែកជា ៣ ពួក គឺ

១.អកុសលចិត្ត ១២ ២.អហេតុកចិត្ត ១៨

៣.កាមាវចរសោភណចិត្ត ២៤

## ១, អកុសលចិត្ត ១២

### សង្គហគាថា

៣. អដ្ឋធា លោភមូលានិ ទោសមូលានិ ច ទ្វិធា

មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសលា សិយុំ ។

*អកុសលចិត្ត មាន១២ គឺ លោភមូលចិត្ត៨ ទោសមូលចិត្ត២ មោហមូលចិត្ត២ ។*

### អធិប្បាយ

អកុសលចិត្ត ជាចិត្តមិនល្អ មិនស្អាត អាក្រក់ ថោកទាប ជាចិត្តដែលប្រកបជាមួយអកុសលចេតសិក ជា

បាប មានទោស ឱ្យផលជាទុក្ខ មាន១២ គឺ លោភមូលចិត្ត៨ ទោសមូលចិត្ត២ មោហមូលចិត្ត២ ។

## លោភមូលចិត្ត ៨ គឺ

១. **សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ លោភមូលចិត្តំ** : លោភមូលចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រកបដោយទិដ្ឋិ មិនមានការបបួលដឹកនាំ

២. **សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ លោភមូលចិត្តំ** : លោភមូលចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រកបដោយទិដ្ឋិ មានការបបួលដឹកនាំ

៣. **សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ លោភមូលចិត្តំ** : លោភមូលចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រាសចាកទិដ្ឋិ មិនមានការបបួលដឹកនាំ

៤. **សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ**

**លោភមូលចិត្តំ** : លោភមូលចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រាសចាកទិដ្ឋិ មានការបបួលដឹកនាំ

៥. **ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ លោភមូលចិត្តំ** : លោភមូលចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មិនមានការបបួលដឹកនាំ

៦. **ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ លោភមូលចិត្តំ** : លោភមូលចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មានការបបួលដឹកនាំ

៧. **ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ លោភមូលចិត្តំ** : លោភមូលចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិ មិនមានការបបួលដឹកនាំ

៨. **ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ លោភមូលចិត្តំ** : លោភមូលចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិ មានការបបួលដឹកនាំ

**ឥមានិ អដ្ឋបិ លោភសហគតចិត្តានិ នាម** : ចិត្តទាំង

៨ នេះ ឈ្មោះថា លោភសហគតចិត្ត ។

## ទោសរបស់លោភសហគតចិត្ត

**លោភសហគតចិត្ត** : ចិត្តកើតព្រមជាមួយនឹងសេចក្តីលោភ, ចិត្តនេះ ហៅថា លោភមូលចិត្តខ្លះ លោភចិត្តខ្លះ តែមានន័យដូចគ្នា គឺ ជាចិត្តដែលពេញចិត្ត ប្រាថ្នា ចង់បាន ទោះបីមានតិច ឬមានច្រើន ក៏ហៅថា លោភមូលចិត្ត ជាហេតុឱ្យកើតសេចក្តីក្តៅក្រហាយ ប្រៀបដូចភ្លើង បើមានច្រើនក៏ក្តៅខ្លាំង បើមានតិចក៏ក្តៅតិច នឹងជាចំណងដ៏មាំ និងជាភ័យខាងក្នុង ធ្វើចិត្តឱ្យងងឹតឈឹង ។

<u>ក្នុងខុទ្ទកនិកាយ មហានិទ្ទេស</u> ថា ៖

អនត្ថជននោ លោភោ លោភោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ ។
លុទ្ធោ អត្ថំ ន ជានាតិ លុទ្ធោ ធម្មំ ន បស្សតិ

អន្ធតមំ តទា ហោតិ យំ លោភោ សហតេ នរំ ។

*លោភៈជាកិលេស ញ៉ាំងសេចក្ដីវិនាសឱ្យកើត លោភៈជាកិលេសញ៉ាំងចិត្តឱ្យកម្រើក ភ័យកើតហើយក្នុងខាងក្នុង ជនរមែងមិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកលោភ រមែងមិនដឹងអត្ថ បុគ្គលអ្នកលោភ រមែងមិនឃើញធម៌. លោភៈគ្របសង្កត់ជនណា សេចក្ដីងងឹតសូន្យឈឹង(នៃជននោះ) ក៏មានក្នុងកាលនោះ ដូច្នេះ ។*[១]

<u>ក្នុងធម្មសង្គណី</u> ពោលធម៌ដែលមានសភាពដូចលោភៈទុកច្រើន ដែលមានពាក្យជាដើមថា ៖

**រាគោ** : សេចក្ដីតម្រេក, **សរាគោ** : តម្រេកខ្លាំង, **អនុនយោ** : បណ្ដោតតាមអារម្មណ៍, **អនុរោធោ** :

---

១. ខុទ្ទ. មហា. កាមសុត្តនិទ្ទេស. ៦៤. ២២/២៧ ។

សេចក្ដីត្រេកអរ ។

## អធិប្បាយ បាលីលោភមូលចិត្តទី ១, ២,

ពាក្យថា **សោមនស្សសហគតំ** ចែកជា២បទ គឺ ៖

**សោមនស្ស** + **សហគតំ** កើតព្រមដោយសោមនស្ស

ពាក្យថា **សោមនស្ស** មកពី **សុ** + **មន** បានដល់វេទនាចេតសិកដែលពេញចិត្ត គឺ សោមនស្សវេទនា ។

សោមនស្ស មានវចនត្ថថា **សុមនស្ស ភាវោ សោមនស្សំ** ភាពនៃបុគ្គលដែលមានចិត្ត ឈ្មោះថាសោមនស្ស ។

ពាក្យថា **សហគតំ** < **សហ** + **គតំ** : កើតព្រម ។

ពាក្យថា **ទិដ្ឋិគតសម្បយុត្តំ** ចែកជាពីរបទ គឺ **ទិដ្ឋិគត** + **សម្បយុត្តំ** : ប្រកបដោយការយល់ខុស

**ទិដ្ឋិគត** : ការយល់ខុស, **សម្បយុត្តំ** : ប្រកប

ដោយ ។

ពាក្យថា **អសង្ខារិកំ** បែកចេញជា ២ គឺ **ន + សង្ខារិកំ** : មិនមានការបបួល

ពាក្យថា សង្ខារ បានដល់ រូបនាម ម្យ៉ាង, បានដល់ ចេតនា ម្យ៉ាង, តែក្នុងទីនេះ បានដល់ កាយបយោគៈ និងវចីបយោគ គឺ ការបបួលឱ្យកើតឡើង ដោយកាយនិងវាចា ។

លោភមូលចិត្តទី ២ ដូចនឹងចិត្តទី ១ ប្លែកត្រង់សង្ខារ គឺ ទី ២ នេះ ជាសសង្ខារិក ប្រែថា មានការបបួលដឹកនាំ ។

**ការបបួលអ្នកដទៃមាន ២ យ៉ាង គឺ**

១. **កាយបយោគៈ** បបួលដោយកាយ គឺធ្វើកិរិយាអាការ ដឹកដៃ លើកដៃចង្អុល បក់ដៃ ញាក់មុខ ព្រិចភ្នែកជាដើម ។

២. **វចីបយោគៈ** បបួលដោយវាចា គឺ ពោលវាចា ប្រាប់ ណែនាំ បញ្ជា ប្រើ ។

**ការបបួលខ្លួនឯងមាន ១ គឺ មនោបយោគៈ** បបួលដោយចិត្តខ្លួនឯង គឺ បង្អោនទឹកកំណាត់ឱ្យកើតឡើងដោយខ្លួនឯង សំដៅដល់ មហាកុសល ឬ មហាកិរិយា ដែលជាបរិកម្ម ឧបចារ អនុលោម គោត្រភូ ឬវោទាន នាំមុខមហគ្គតចិត្ត ៦៧ ( រូបជ្ឈាន ១៥ អរូបជ្ឈាន ១២ និងលោកុត្តរ ៤០ ) ។

<u>ក្នុងវិភាវិនីដីកា</u> អធិប្បាយលោភមូលចិត្តទាំង ២ នេះថា ៖

- កាលណា បុគ្គលមានមិច្ឆាទិដ្ឋិកើតជាខាងដើមថា "ទោសក្នុងកាមទាំងឡាយ មិនមាន" ដូច្នេះ ហើយរីករាយត្រេកអរនឹងការបរិភោគកាម ឬប្រកាន់ជឿ ទិដ្ឋិមង្គលជាដើមថា ជាសារៈ ដោយចិត្តក្លៀវក្លាដោយខ្លួនឯង មិនមានអ្នក

ណាជាស់តឿន បបែរបបួល កាលនោះ លោភមូលចិត្តទី ១ ក៏កើតឡើង ។

- កាលណា បុគ្គលមានមិច្ឆាទិដ្ឋិកើតជាខាងដើមថា ទោសក្នុងកាមទាំងឡាយ មិនមាន ។ល ។ ដោយចិត្តទន់ខ្សោយ ទាល់តែមានអ្នកជាស់តឿនបបួល ទើបត្រេកអរ កាលនោះ លោភមូលចិត្តទី ២ ក៏កើតឡើង ។

## អធិប្បាយ លោភមូលចិត្តទី ៣. ៤.

លោភមូលចិត្តទី ៣ នេះ មានពាក្យបាលីផ្សេងពីទី ១ ត្រឹមតែមួយបទ គឺ **ទិដ្ឋិគតវិប្បយុត្តំ** ។

**ទិដ្ឋិគត + វិប្បយុត្តំ** ប្រែថា មិនប្រកបដោយសេចក្ដីយល់ខុស ក្រៅពីនេះ ដូចគ្នាទាំងអស់ ។

សម្រាប់លោភទី ៤ ក៏មានពាក្យបាលីផ្សេងពីទី ២ ត្រឹមតែមួយបទ គឺ **ទិដ្ឋិគតវិប្បយុត្តំ** ដែរ ។

**ក្នុងវិភាវិនីដីកា** អធិប្បាយលោភមូលចិត្តទាំង ២ នេះ

ថា ៖

កាលណាបុគ្គលមិនមានមិច្ឆាទិដ្ឋិជាខាងដើមទេ រីករាយត្រេកអរតែម្យ៉ាង សេពមេថុនខ្លះ គិតប្រាថ្នាចង់បានទ្រព្យអ្នកដទៃខ្លះ លួចទ្រព្យអ្នកដទៃខ្លះ ដោយចិត្តក្លៀវក្លាដោយខ្លួនឯងតាមសភាពតែម្យ៉ាង មិនមានអ្នកណាបបួល ដាស់តឿនកាលនោះ លោភមូលចិត្តទី ៣ នេះក៏កើតឡើង ។

កាលណា បុគ្គលមិនមានមិច្ឆាទិដ្ឋិជាខាងដើមទេ ។ល ។ ដោយចិត្តទន់ខ្សោយ ទាល់តែមានអ្នកដាស់តឿន បបែរបបួលទើបប្រព្រឹត្ត កាលនោះ លោភមូលចិត្តទី ៤ ក៏កើតឡើង ។

## អធិប្បាយ លោភមូលចិត្តទី ៥. ៦. ៧. ៨.

លោភមូលចិត្ត ៤ ក្រោយផ្សេងពី ៤ ខាងដើមត្រង់ **ឧបេក្ខាសហគតំ, ឧបេក្ខា** គឺ **ឧប + ឥក្ខា** ការចូលទៅសម្លឹង ឬការសម្លឹងព្រងើយ ៗ ក្នុងលក្ខណៈដែលជា

កណ្តាល បានដល់ ឧបេក្ខាវេទនាទុំះឯង, ក្រៅពីនេះ ដូចគ្នាទាំងអស់ គឺ ទី ៥ ដូចគ្នានឹងទី ១, ទី ៦ ដូចគ្នានឹងទី ២, ទី ៧ ដូចគ្នានឹងទី ៣, ទី ៨ ដូចគ្នានឹងទី ៤ ។

<u>ក្នុងវិភាវនីដីកា</u> អធិប្បាយលោភមូលចិត្តទាំង ៤ ក្រោយនេះថា ៖

មួយទៀត បុគ្គលណា វៀរចាកសោមនស្សវេទនាទាំង ៤ ព្រោះតែមិនបរិបូរណ៍ដោយកាមទាំងឡាយ ឬព្រោះមិនមានហេតុឱ្យសោមនស្សកើតឡើង កាលនោះលោភមូលចិត្ត ៤ ដែលជាឧបេក្ខាសហគត រមែងកើតឡើង ។

ពាក្យថា **លោភ** មានវិគ្រោះថា ៖

**លុព្ភតីតិ + លោភោ** ឈ្មោះថា លោភៈ ព្រោះអត្ថថាចង់បាន ។

មួយទៀត ការដែលដឹង ឬយល់ចូលចិត្តក្នុងសភាវៈធម៌នោះ ៗ បានត្រឹមត្រូវ មិនសេមសោម ក៏ចាំបាច់ត្រូវដឹង

ត្រូវតែស្គាល់នូវគ្រឿងសំគាល់របស់សភាវៈធម៌នោះ ៗ ដែលហៅថា លក្ខណៈ ។ ឯលក្ខណៈប្រចាំសភាវធម៌នោះ មាន ២ គឺ ៖

១. វិសេសលក្ខណៈ លក្ខណៈដែលផ្សេងគ្នានៃបរមត្ថធម៌ កំណត់បានដោយអត្ថ ៤ យ៉ាង មានពាក្យថា លក្ខណៈជាដើម ដែលហៅថា លក្ខណាទិចតុក្កៈ គឺ

ក. លក្ខណៈ គឺ លក្ខណៈមានជាប្រចាំរបស់សភាវៈធម៌នោះ ៗ

ខ. រសៈ គឺ កិច្ច នាទី ហៅថា កិច្ចរស និងការដល់ព្រម ហៅថា សម្បត្តិរស

គ. បច្ចុប្បដ្ឋាន គឺ អាការប្រាកដ ឬផលធម៌

ឃ. បទដ្ឋាន គឺ ហេតុជិត ឬ ហេតុនាំឱ្យកើតឡើង ។

២. សាមញ្ញលក្ខណៈ គឺ លក្ខណៈដែលស្មើគ្នា

របស់បរមត្ថធម៌ទាំងឡាយ គឺ ចិត្ត ចេតសិក និងរូបទាំងនេះឯង ប្រកបដោយលក្ខណៈ ៣ គឺ អនិច្ចតា (ភាពមិនទៀង) ទុក្ខតា (ភាពជាទុក្ខ) អនត្តតា (ភាពជារបស់មិនមែនខ្លួន), ឯនិព្វាន ប្រកបដោយលក្ខណៈ ១ គឺ អនត្តតា ។

<u>ក្នុងអដ្ឋកថា អដ្ឋសាលិនី</u> ពោលទុកថា ៖

**លក្ខណាទីសុ ហិ តេសំ ធម្មានំ សភាវោ វា សាមញ្ញំ វា លក្ខណំ នាម** : មែនពិត បណ្ដាអត្ថ ៤ យ៉ាង មានលក្ខណៈជាដើម សភាវៈ ឬ ភាពស្មើគ្នានៃធម៌នោះ ៗ ឈ្មោះថា លក្ខណៈ ។

**កិច្ចំ វា សម្បត្តិ វា រសោ នាម** កិច្ច ឬសម្បត្តិ (នៃធម៌ទាំងនោះ) ឈ្មោះថា រស ។

**ឧបដ្ឋាកាកោ វា ផលំ វា បច្ចុប្បដ្ឋានំ នាម** អាការប្រាកដ ឬផល (នៃធម៌ទាំងនោះ) ឈ្មោះថា បច្ចុប្បដ្ឋាន ។

**អាសន្នការណំ បទដ្ឋានំ នាម** ហេតុជិត (គឺ ហេតុនាំឱ្យកើតឡើងនៃធម៌ទាំងនោះ) ឈ្មោះថា បទដ្ឋាន ។

ដូច្នោះ ដើម្បីឱ្យស្គាល់លោភៈ គឺ សេចក្ដីត្រេកអរនេះ ទើបត្រូវសិក្សាអត្ថ ៤ យ៉ាង ដែលហៅថា លក្ខណាទិចតុក្កៈរបស់លោភៈ ដូចតទៅ ៖

## លក្ខណាទិចតុក្កៈរបស់លោភៈ

១. **អារម្មណគ្គហណលក្ខណោ** មានការកាន់យកអារម្មណ៍ជាលក្ខណៈ ដូចស្វាជាប់ជ័រ

២. **អភិសង្គរសោ** មានការទាក់ជាប់ក្នុងអារម្មណ៍ ជាកិច្ច

៣. **អបរិច្ចាគបច្ចុប្បដ្ឋានោ** មានការមិនលះបង់ ជាផល

៤. **សញ្ញោជនីយធម្មេសុ អស្សាទទស្សនបទដ្ឋានោ** : មានការឃើញដោយពេញចិត្តក្នុងធម៌ដែលជាអារម្មណ៍របស់

សញ្ញោជនៈ[១] ជាហេតុជិត ។

លោភមូលចិត្តនេះ ជាបរមត្ថធម៌ ដែលមិននៅក្នុងអំណាចនៃការបង្គាប់បញ្ជារបស់អ្នកណា កាលបើមានហេតុបច្ច័យ ក៏កើតឡើង កើតហើយកើតទៀតទាំងនេះ ព្រោះនៅមានហេតុឱ្យកើត ។

**ហេតុឱ្យកើតលោភមូលចិត្ត មាន ៤ យ៉ាង គឺ**

១. **លោភបរិវារកម្មបដិសន្ធិកតា** បដិសន្ធិដោយកម្មដែលមានលោភៈជាបរិវារ

២. **លោភឧស្សន្នភវតោចវនតា** ចុតិចាកភពដែលច្រើនដោយលោភៈ

៣. **ឥដ្ឋារម្មណសមាយោគោ** ប្រកបជាមួយនឹង

---

១. គឺ ចិត្ត៨១ ចេតសិក៥២ រូប២៨ (វៀរលោកុត្តរចិត្តប្បាទនិងនិព្វាន) ។ លោភនេះ ឱ្យទោស សូម្បីសត្វតិរច្ឆាន ដូចរឿងកាកប្រេតដែលត្រូវភ្លើងឆេះនៅលើភ្នំគិជ្ឈកូដ ក្នុងធម្មបទ ។

អារម្មណ៍ដែលគួរប្រាថ្នា

៤. **អស្សាទទស្សនំ** ឃើញវត្ថុដែលពេញចិត្ត

ពាក្យថា **លោភបរិវារកម្មបដិសន្ធិកតា** គឺ **លោភ + បរិវារ + កម្ម + បដិសន្ធិក + តា**

បានសេចក្តីថា បុគ្គលខ្លះ បដិសន្ធិក្នុងសុគតិភូមិ ដោយអាស្រ័យការធ្វើកុសលយ៉ាងណាមួយ ដោយអំណាចនៃលោភៈ ដូចជាចង់បានរូបល្អ មានទ្រព្យច្រើន មានអាយុវែងជាដើម ក៏ធ្វើកុសលមានការឱ្យទាន រក្សាសីលជាដើម មិនមែនធ្វើដើម្បីជុសខាត់កិលេសទេ គឺ គិតតែរកវត្ថុដែលពេញចិត្តមកបន្ថែមឱ្យច្រើន ៗឡើង យ៉ាងនេះហៅថា មានលោភៈជាបរិវារ គឺ លោភៈនោះឯង ហែហមកុសល កាលស្លាប់ទៅក៏នឹងកើតក្នុងសុគតិភូមិ ព្រោះគេបានសាងកុសល ដោយអំណាចនៃលោភៈ គឺ មុនធ្វើ ក៏មានលោភៈមានសេចក្តីប្រាថ្នាចង់បានផ្សេង ៗ កាលធ្វើកុសលហើយ

លោភៈក៏កើតឡើងទៀត គឺ ប្រាថ្នារបស់នេះ ប្រាថ្នារបស់នោះឱ្យក្រៃលែងជាងមុន ឬឱ្យជាប់គេ គឺថា លោភៈមានទាំងខាងមុខ (មុនពេលធ្វើ) ទាំងខាងក្រោយ (ធ្វើរួចហើយ) ដូចអ្នកមានបរិវារច្រើន ហែហមពីមុខពីក្រោយដូច្នោះ កាលបដិសន្ធិមក ដោយចិត្តដែលមានលោភៈជាបរិវារ ដូច្នេះ លោភៈនោះ កាលបានបច្ច័យគ្រប់គ្រាន់ ក៏កើតឡើងក្នុងភពថ្មីទៀត ។

ពាក្យថា **លោភឧស្សន្នភវតោចវនតា** គឺ **លោភ** + **ឧស្សន្ន** + **ភវតោ** + **ចវនតា**

**លោភ** : ការចង់បាន, **ឧស្សន្ន** : ក្រាស ឬច្រើន, **ភវតោ** : ចាកពីភព, **ចវនតា** : ការចុតិ,

បានសេចក្តីថា អ្នកដែលចុតិចាកភពដែលច្រើនដោយអារម្មណ៍របស់លោភៈ កាលកើតមកក្នុងជាតិថ្មីនេះ លោភៈក៏ជាប់តាមសន្តានមកជានិស្ស័យ ដែលហៅថា **រាគចរិត** ធ្វើឱ្យស្រឡាញ់តែស្អាត តែល្អ ចង់បានរូប សំឡេងជាដើម

នឹងក្នុងវត្ថុដែលល្អ ៗ ទើបជាហេតុឱ្យកើតលោភៈតទៅ ។

បទថា **ឥដ្ឋារម្មណសមាយោគោ** គឺ **ឥដ្ឋ** + **អារម្មណ** + **សមាយោគោ**

**ឥដ្ឋ** : ល្អ ឬគួរប្រាថ្នា, **អារម្មណ** : អារម្មណ៍ គឺ វត្ថុដែលចិត្តចាប់តោង, **សមាយោគោ** : ប្រកប ឬ ប្រសព្វ ។

បានសេចក្តីថា ក្នុងជាតិដែលខ្លួនកើតមកនេះ ប្រកប ឬជួបប្រសព្វនឹងអារម្មណ៍ដែលល្អ ៗ ដែលគួរប្រាថ្នា មិនមែនប្រកបនឹងអារម្មណ៍មិនល្អ; បើប្រកបដោយអារម្មណ៍ដែលមិនល្អ មិនពេញចិត្ត ទោសៈក៏កើត, បើប្រកបនឹងអារម្មណ៍ល្អ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលគួរប្រាថ្នាហើយ លោភៈក៏បានឱកាសកើតឡើង កាលឃើញអារម្មណ៍ដែលពេញចិត្ត ក៏ចង់បានអារម្មណ៍នោះ ឱ្យប្រណីតឡើងទៀត, ដែលឈ្មោះថា លោភៈ គឺ កាមគុណនេះ

រមែងខ្វះខាតជានិច្ច ចង់ចិត្តទុកធ្វើឱ្យមិនឆ្អែត មិនពេញ មិនគ្រប់ ដូចកាមរបស់ព្រះបាទមន្ធាតុចក្កពត្តិរាជដែលមានអំណាចធំ បានសោយសម្បត្តិទិព្វក្នុងឋានតាវត្តិង្សពាក់កណ្ដាល ដរាបសក្កទេវរាជទ្រង់ឧប្បត្តិហើយចុតិអស់ទៅដល់ ៣៦ ព្រះអង្គ ក៏នៅមិនឆ្អែតដោយកាម ព្រោះដូច្នោះ ការប្រកប ឬជួបប្រសព្វអារម្មណ៍ដែលល្អនោះ ទើបជាហេតុឱ្យលោភចិត្តកើតឡើងទៀត ។

ពាក្យថា **អសោមនស្សំ គឺ អសោមនស + ទស្សនំ**

**អសោមនស : ពេញចិត្ត ឬសប្បាយចិត្ត, ទស្សនំ :** ការឃើញ ( ឃើញអារម្មណ៍ )

បានសេចក្ដីថា លោភមូលចិត្តដែលនឹងកើតឡើងត្រូវតែមានការឃើញរូបដែលពេញចិត្តជាដើម ឧបមាដូចបុគ្គលដែលទិញអ៊ីវ៉ាន់ ដើរមើលទំនិញគ្រប់ប្រភេទ កាលឃើញរបស់ដែលពេញចិត្ត ក៏ប្រាថ្នាចង់បាន យ៉ាងនេះជា

ដើម ទើបឈ្មោះថា ការឃើញវត្ថុដែលពេញចិត្តនេះ ជាហេតុឱ្យលោភចិត្តកើត ។

ម្យ៉ាងទៀត លោភមូលចិត្តដែលកើតព្រមនឹងសោមនស្សនោះ ៗ សូម្បីសោមនស្សនោះ ក៏មានហេតុដែលនាំឱ្យកើតឡើង ព្រោះសង្ខារធម៌ទាំងពួង មានហេតុជាដែនកើត ។

**ហេតុឱ្យកើតលោភៈសោមនស្ស មាន ៤ យ៉ាង គឺ**

១. ***សោមនស្សបដិសន្ធិកតា*** *ភាពជាអ្នកបដិសន្ធិដោយសោមនស្ស*

២. ***អគម្ភីរបកតិតា*** *ភាពជាអ្នកមានប្រក្រតីមិនហ្មត់ចត់*

៣. ***ឥដ្ឋារម្មណសមាយោគោ*** *ប្រកបជាមួយនឹងឥដ្ឋារម្មណ៍*

៤. ***ព្យសនវិមុត្តិ*** *ផុតចាកការវិនាស ៥ យ៉ាង*

*ពាក្យថា* ***សោមនស្សបដិសន្ធិកតា*** *គឺ* ***សោមនស្ស*** *+ បដិសន្ធិក + តា*

***សោមនស្ស*** *: សេចក្ដីសប្បាយចិត្ត ការរីករាយ,* ***បដិសន្ធិ***

**ក** : ការបន្ត គឺការកើតថ្មី, **តា** : ភាពជា ។

បានសេចក្តីថា សភាពរបស់បដិសន្ធិចិត្ត កើតព្រមដោយសោមនស្សវេទនា គឺ បុគ្គលដែលមានបដិសន្ធិចិត្តកើតរួមនឹងសោមនស្សនោះ រមែងជាបុគ្គលដែលមានសេចក្តីត្រេកអរ រីករាយ ពេញចិត្ត សប្បាយជានិច្ច កាលជួបប្រសព្វនឹងអារម្មណ៍ដែលមិនល្អ ក៏មិនកើតទុក្ខក្តៅក្រហាយ កាលបានជួបប្រសព្វអារម្មណ៍ដែលល្អ ដែលពេញចិត្ត ក៏រមែងកើតសោមនស្ស សប្បាយចិត្ត រីករាយ ត្រេកអរ ព្រោះដូច្នោះ កាលបដិសន្ធិមកដោយសោមនស្សយ៉ាងនេះ ទើបជាហេតុឱ្យកើតសោមនស្ស ។

ពាក្យថា **អគម្ភីរបកតិតា** គឺ **អ** + **គម្ភីរ** + **បកតិ** + **តា**

**អ** : មិន ឥត អត់ គ្មាន, **គម្ភីរ** : សុខុម ឬ ជ្រាលជ្រៅ, **បកតិ** : ប្រក្រតី, **តា** : ភាពជា ។

បានសេចក្ដីថា ជាអ្នកមិនមានសេចក្ដីសុខមជាប្រក្រតី គឺ កាលលោភមូលចិត្ត កើតព្រមទឹងសោមនស្ស រមែងឱ្យកើតសេចក្ដីត្រេកអរ រីករាយទៅក្នុងរឿងនោះ ៗ ទើបមិនមានភាពសុខុម ភាពជាអ្នកមិនមានសេចក្ដីសុខុមជាប្រក្រតី ទើបជាហេតុឱ្យកើតសោមនស្ស ។

ពាក្យថា **ឥដ្ឋារម្មណសមាយោគោ** គឺ **ឥដ្ឋ** + **អារម្មណ** + **សមាយោគោ**

បានសេចក្ដីថា ការប្រកបជាមួយអារម្មណ៍ដែលល្អដែលគួររីករាយត្រេកអរ គឺ ជួបប្រសព្វជាមួយនឹងវត្ថុដែលល្អដោយសេចក្ដីពេញចិត្ត ទើបជាហេតុឱ្យកើតសោមនស្ស ។

ពាក្យថា **ព្យសនវិមុត្តិ** គឺ **ព្យសន** + **វិមុត្តិ**

**ព្យសនៈ** : ការវិនាស, ការហិនហោច, ការបាត់បង់,

**វិមុត្តិ** : ផុតចាក ។

បានសេចក្ដីថា ផុតចាកការវិនាស គឺ មិនមានសេចក្ដី

វិនាស កាលមិនមានសេចក្តីវិនាសយ៉ាងណាមួយ ក៏ជាហេតុឱ្យកើតសោមនស្សវេទនា ។

**ព្យសនៈ ការវិនាស ៥ យ៉ាង**

១. ញាតិព្យសន ការវិនាសចាកញាតិ

២. ភោគព្យសន ការវិនាសចាកភោគៈ

៣. រោគព្យសន ការវិនាសព្រោះរោគ

៤. សីលព្យសន ការវិនាសចាកសីល

៥. ទិដ្ឋិព្យសន ការវិនាសចាកសម្មាទិដ្ឋិ

បានសេចក្តីថា បើជួប ឬទឹកដល់ការវិនាសសាបសូន្យ ដែលកើតអំពីព្យសនធម៌ទាំង ៥ នេះ សោមនស្សរមែងកើតបានដោយលំបាក កាលមិនជួប ឬមិនទឹកដល់ការវិនាសសាបសូន្យទាំងនោះទេ សោមនស្សនោះ បានបច្ច័យក៏កើតឡើង ទើបពោលថា ផុតចាកសេចក្តីវិនាសជាហេតុឱ្យ

កើតសោមនស្ស ។

## ហេតុឱ្យកើតឧបេក្ខា មាន ៤ យ៉ាង

**១. ឧបេក្ខាបដិសន្ធិកតា** ភាពជាអ្នកបដិសន្ធិមកដោយឧបេក្ខា

**២. គម្ភីរបកតិតា** ភាពជាអ្នកមានប្រក្រតីសុខុម

**៣. មជ្ឈត្តារម្មណសមាយោគោ** ប្រកបជាមួយនឹងអារម្មណ៍ប្រភេទជាកណ្តាល

**៤. ព្យសនវិមុត្តិ** ផុតចាកការវិនាស

* **មុគធាតុកតា** មានធាតុជាអ្នកមិនសូវនិយាយ ក៏ជាហេតុឱ្យកើតឧបេក្ខាបានដែរ

ពាក្យថា **ឧបេក្ខាបដិសន្ធិកតា គឺ ឧបេក្ខា + បដិសន្ធិក + តា**

បានសេចក្តីថា បដិសន្ធិចិត្តកើតព្រមនឹងឧបេក្ខាវេទនា, ធម្មតាអ្នកបដិសន្ធិមកដោយឧបេក្ខាវេទនានោះ រមែងជាអ្នក

ព្រងើយ ៗ ធ្ងឹង ៗ សូម្បីបានជួបអារម្មណ៍ដែលល្អ ដែលពេញចិត្ត ក៏គេពេញចិត្តជាកណ្ដាល មិនដល់សោមនស្សសប្បាយរីករាយខ្លាំងទេ ។

ពាក្យថា **គម្ភីរបកតិតា** គឺ **គម្ភីរ + បកតិ + តា** បានសេចក្ដីថា មានសេចក្ដីសុខុម ល្អិត ជ្រាលជ្រៅ មានគំនិតពិចារណា មិនត្រេកអរ មិនតូចចិត្តបានងាយ ៗ, ដឹងស្គាល់ការរម្ងាប់បាន អាចធ្វើចិត្តឱ្យជាកណ្ដាល ដោយភាពព្រងើយ ព្រោះជាអ្នកដែលធ្លាប់សន្សំសន្ដានមកយ៉ាងនោះ ពិចារណានូវអារម្មណ៍បានយ៉ាងត្រឹមត្រូវក្នុងហេតុផលដោយភាពសុខុម ជ្រាលជ្រៅ ដូច្នោះ បុគ្គលអ្នកមានចិត្តជាសុខុមមានអារម្មណ៍ជាកណ្ដាល ទើបជាហេតុឱ្យកើតឧបេក្ខា ។

ពាក្យថា **មជ្ឈត្តតារម្មណសមាយោគោ** គឺ **មជ្ឈត្តតា + អារម្មណ + សមាយោគោ**

បានសេចក្ដីថា ប្រកបជាមួយនឹងអារម្មណ៍ ប្រភេទជាកណ្ដាល ៗ ឬប្រសព្វជាមួយអារម្មណ៍ល្មមប្រមាណ ដែលធ្វើចិត្តមិនដល់សោមនស្ស ទើបជាហេតុឱ្យកើតឧបេក្ខា ។

ពាក្យថា **ព្យសនវិមុត្តិ** គឺ **ព្យសន + វិមុត្តិ**

សេចក្ដីថា ផុតចាកការវិនាស ៥ យ៉ាង, បើចិត្តមានព្យសនធម៌ ៥ នេះ ជាអារម្មណ៍ខណៈណា ខណៈនោះឧបេក្ខាវេទនា រមែងកើតមិនបាន ព្រោះការវិនាស រមែងធ្វើចិត្តឱ្យកើតទោមនស្សវេទនា ។

**ហេតុឱ្យកើតទិដ្ឋិគតសម្បយុត្តចិត្ត មាន ៥ យ៉ាង គឺ**

១. **ទិដ្ឋិជ្ឈាសយតា** មានការយល់ខុស ជាអធ្យាស្រ័យ

២. **ទិដ្ឋិវិប្បន្នបុគ្គលសេវនតា** សេពគប់បុគ្គលដែលវិបត្តិព្រោះទិដ្ឋិ

៣. **សទ្ធម្មវិមុខតា** បែរមុខចេញពីព្រះសទ្ធម្ម

៤. **មិច្ឆាវិតក្កពហុលតា** ជាអ្នកច្រើនទៅដោយមិច្ឆាវិតក្កៈ

**៥. អយោនិសោ ឧម្មុជ្ជនំ** មិនពិចារណាដោយឧបាយប្រាជ្ញា

ពាក្យថា **ទិដ្ឋជ្ឈាសយតា** គឺ **ទិដ្ឋិ + អជ្ឈាសយ + តា**

បានសេចក្តីថា លោភមូលចិត្តដែលប្រកបជាមួយនឹងការយល់ខុស ព្រោះមានអធ្យាស្រ័យគិតក្រៅពីហេតុផល និងសន្សំអប់រំក្នុងផ្លូវដែលខុស ទើបជាហេតុឱ្យលោភមូលចិត្តកើតឡើងសម្បយុត្តនឹងការយល់ខុស ។

ពាក្យថា **ទិដ្ឋិវិប្បន្នបុគ្គលសេវនតា** គឺ **ទិដ្ឋិ + វិប្បន្ន + បុគ្គល + សេវនតា**

**វិប្បន្ន** : វិបត្តិ វិបរិត ឃ្លៀងឃ្លាត ខុស,

**បុគ្គល** : បុគ្គល,

**សេវនតា** : ការគប់ ការសមាគម,

បានសេចក្តីថា ការគប់រក ការសមាគមនឹងបុគ្គលដែលមានវិបត្តិ ព្រោះទិដ្ឋិ ក៏ធ្វើឱ្យមានការយល់ខុសទៅផង ព្រោះបុគ្គលបែបនោះ រមែងដឹកនាំឱ្យទៅតាមការយល់ខុសរបស់ខ្លួន ។

ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ពោលថា ៖
ទិដ្ឋិដែលមានទោសច្រើន មាន ៣ យ៉ាង គឺ

**ក. អកិរិយទិដ្ឋិ** យល់ថា ការធ្វើមិនជាអំពើ( គឺមិនជាអំពើល្អ-អាក្រក់ )

**ខ. អហេតុកទិដ្ឋិ** យល់ថា អ្វី ៗគ្រប់យ៉ាងមិនមានហេតុ( បុព្វកម្ម )

**គ. នត្ថិកទិដ្ឋិ** យល់ថា បុណ្យនិងបាបមិនមាន

បណ្តាទិដ្ឋិទាំង ៣ នោះ គឺ

**អកិរិយទិដ្ឋិ** ជាការយល់របស់គ្រូបូរណកស្សបៈ ជាគណាចារ្យមួយក្នុងបណ្តាគ្រូទាំង ៦ នាសម័យពុទ្ធកាល ការយល់ខុសនេះ បដិសេធការធ្វើល្អ ធ្វើអាក្រក់ទាំងអស់ គេពោលថា សូម្បីវិញ្ញាណរបស់អ្នកនោះឯង ក៏ព្រងើយ" មិនដឹងនូវអំពើនោះ ៗ កាលបើបដិសេធការធ្វើហើយ ក៏ដូចជា

ការបដិសេធផលរបស់កម្មនោះ ថា មិនមានផងដែរ ។

**អហេតុកទិដ្ឋិ** ជាការយល់របស់គ្រូមក្ខលិគោសាល ទិដ្ឋិនោះ សម្តែងថា របស់ដែលកើតឡើងក្នុងជីវិតរបស់មនុស្សនោះ មិនថា ជាសេចក្តីសុខ សេចក្តីទុក្ខ សេចក្តីបរិសុទ្ធិ សុទ្ធតែកើតឡើងមកឯង ៗ មិនមានហេតុ មិនមានបច្ច័យនាំឱ្យកើតផលទាំងនេះមកទេ វត្ថុទាំងអស់កើតខ្លួនឯងរលត់ខ្លួនឯង ដោយមិនចាំបាច់អាស្រ័យហេតុ បច្ច័យ ជាទិដ្ឋិជំទាស់នឹងពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលប្រកបដោយហេតុផលថា "វត្ថុគ្រប់យ៉ាង កើតអំពីហេតុ និងរលត់ទៅ ក៏ព្រោះ អស់ហេតុ, សេចក្តីសុខ សេចក្តីទុក្ខ សេចក្តីបរិសុទ្ធិ សុទ្ធតែកើតមកអំពីហេតុដែលផ្សេង ៗគ្នា" ។ ការយល់ឃើញរបស់មក្ខលិគោសាលនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា **"ភិក្ខវេ យានិ កានិចិ តន្តាវុតានំ វត្ថានំ កេសកម្ពលោ តេសំ បដិកិដ្ឋោ អក្ខាយតិ ។**

*កេសកម្ពលោ ភិក្ខវេ សីតេ សីតោ ឧណ្ហេ ឧណ្ហោ ទុព្វណ្ណោ ទុគ្គន្ធោ ទុក្ខសម្ផស្សោ ។ ឯវមេវ ខោ ភិក្ខវេ យានិ កានិចិ បុថុសមណព្រាហ្មណវាទានំ មក្ខលិវាទោ តេសំ បដិកិដ្ឋោ អក្ខាយតិ ។ មក្ខលិ ភិក្ខវេ មោឃបុរិសោ ឯវំវាទី ឯវំទិដ្ឋិ : នត្ថិ កម្មំ នត្ថិ កិរិយំ នត្ថិ វីរិយន្តិ :* ម្នាលភិក្ខុទាំងឡាយ សំពត់ទាំងឡាយណាមួយ ដែលគេត្បាញដោយតម្បាញ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ប្រាកដជាអាក្រក់បំផុតជាងសំពត់ទាំងនោះ ម្នាលភិក្ខុទាំងឡាយ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ត្រជាក់ក្នុងពេលត្រជាក់ ក្តៅក្នុងពេលក្តៅ មានសម្បុរអាក្រក់ មានក្លិនអាក្រក់ មានសម្ផស្សអាក្រក់, យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ វាទៈរបស់សមណៈច្រើននាក់ណាមួយ វាទៈនៃគ្រូឈ្មោះមក្ខលិ ប្រាកដជាអាក្រក់ជាងវាទៈនៃសមណៈទាំងនោះ ក៏យ៉ាងនោះដែរ, ម្នាលភិក្ខុទាំងឡាយ មក្ខលិជា

មោឃបុរស មានសេចក្តីប្រកាន់យ៉ាងនេះថា កម្មមិនមាន អំពើដែលត្រូវធ្វើមិនមាន សេចក្តីព្យាយាមមិនមាន”[១] ដូច្នេះ ។

**នត្ថិកទិដ្ឋិ** ជាការយល់ឃើញរបស់អជិតកេសកម្ពល យល់ឃើញថា “មិនមាន” ជាការបដិសេធទាំងហេតុ ទាំងផល គឺ យល់ឃើញថា បាប បុណ្យ ការធ្វើ ផលរបស់អំពើដែលធ្វើ និងបដិសេធថា “លោកខាងមុខមិនមាន, ទីបំផុតរបស់សត្វទាំងអស់ បញ្ចប់ត្រឹមសេចក្តីស្លាប់” ទិដ្ឋិនេះដូចគ្នានឹងឧច្ឆេទទិដ្ឋិ ។

ការយល់ឃើញខុសទាំង ៣ នេះ ហៅថា និយតមិច្ឆាទិដ្ឋិ ជាការយល់ ឃើញយ៉ាងមាំ មិនអាចនឹងដោះចេញឱ្យផុតបានទេ ជាការយល់ឃើញដែលមាន ទោសខ្លាំងជាកម្មធ្ងន់បំផុតក្នុងផ្នែកអកុសល ។ ព្រោះមានការយល់

---

១. អង្គុ. តិក. យោធាជីវវគ្គ. ៤១. ១៣៩/៤៥៨ ។

ខុសនេះ ទើបជាហេតុឱ្យលោភមូលចិត្ត កើតសម្បយុត្តនឹងការយល់ខុស ។

ពាក្យថា **សទ្ធម្មវិមុខតា** គឺ **សទ្ធម្ម + វិ + មុខតា**

**សទ្ធម្ម** : ព្រះសទ្ធម្ម ( ធម៌របស់សប្បុរស )

**វិមុខតា** : ការបែរមុខចេញ

បានសេចក្តីថា មិនសិក្សាព្រះសទ្ធម្ម គឺ ធម៌របស់សប្បុរស ឬហៅថា ព្រះពុទ្ធសាសនា ព្រះធម៌វិន័យ នវង្គសត្ថុសាសន៍ ក្រោយមកហៅថា ព្រះត្រៃបិដក ។ ព្រះសទ្ធម្មមាន ៣ យ៉ាង គឺ បរិយត្តិសទ្ធម្ម បដិបត្តិសទ្ធម្ម បដិវេធសទ្ធម្ម ។

**<u>ក្នុងអភិធម្មវិភង្គ</u>** ពោលសទ្ធម្មទុក ១០ យ៉ាង គឺ មគ្គ ៤ ផល ៤ និព្វាន ១ និងព្រះបរិយត្តិ ១ ។ កាលមិនសិក្សាព្រះសទ្ធម្ម ក៏មិនអាចនឹងលះការយល់ខុស ព្រោះដូច្នោះ ការបែរមុខចេញពីព្រះសទ្ធម្មនោះ ទើបជាហេតុឱ្យ

លោភមូលចិត្តសម្បយុត្តនឹងការយល់ខុស ។

ពាក្យថា **មិច្ឆាវិតក្កពហុលតា** គឺ **មិច្ឆា + វិតក្ក + ពហុលតា**; **មិច្ឆា** : ខុស, **វិតក្ក** : ត្រិះរិះ នឹកគិត, **ពហុលតា** : ជាអ្នកច្រើន ។

បានសេចក្ដីថា ជាអ្នកច្រើនទៅដោយការត្រិះរិះក្នុងផ្លូវដែលខុស ជាអ្នកដែលនឹកគិត ដោយការមិនឆ្លាសវៃ ហៅថា មិច្ឆាវិតក្កៈ ឬហៅថា អកុសលវិតក្កៈ[១] ។

## អកុសលវិតក្កៈ មាន ៣ គឺ

១. **កាមវិតក្កៈ** ត្រិះរិះនឹកដល់ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ដែលគួរប្រាថ្នា គួរត្រូវការ គួរពេញចិត្ត ។

២. **ព្យាបាទវិតក្កៈ** សេចក្ដីត្រិះរិះដោយអំណាចព្យាបាទ ដូចអ្នកខ្លះ កើតសេចក្ដីក្រោធ ហើយក៏នៅរក្សា

---

១. អង្គ. ឆក្ក. ទេវតាវគ្គ. ៤៦. ៧៤/២៩៧ ។

សេចក្ដីក្រោធនោះទុក ដោយអំណាចការចងពៀរវេរា ។

៣. **វិហឹសាវិតក្កៈ** សេចក្ដីត្រិះរិះដោយការមិនពេញចិត្ត ចង់ឱ្យអ្នកដទៃវិនាស ដោយសេចក្ដីក្ដៅក្រហាយ យ៉ាងណាមួយ ។

កាលបុគ្គលជាអ្នកច្រើនដោយមិច្ឆាវិតក្កៈយ៉ាងនេះ ក៏ជាហេតុឱ្យលោភមូលចិត្ត កើតសម្បយុត្តនឹងការយល់ខុស ។

ពាក្យថា **អយោនិសោឧម្មុជ្ជនំ** គឺ **អ** + **យោនិសោ** + **ឧម្មុជ្ជនំ**

**អ** : មិន អត់ ទេ, **យោនិសោ** : ដោយឧបាយប្រាជ្ញា, **ឧម្មុជ្ជន** : ការផុសឡើង, ការងើបឡើង, លេចឡើង, គឺ ការពិចារណា ។

បានសេចក្ដីថា ជាអ្នកមិនពិចារណាដោយប្រាជ្ញា គឺ កាលជួបប្រសព្វអារម្មណ៍ណា ៗ ក៏មិនពិចារណាអារម្មណ៍នោះ ៗ ឱ្យត្រឹមត្រូវតាមសភាពពិតទេ ការមិនគិតពិចារណា

ឱ្យល្អិតល្អន់ ក៏ជាហេតុឱ្យលោភមូលចិត្ត កើតសម្បយុត្តនឹងការយល់ខុស ។

## ហេតុឱ្យកើតទិដ្ឋិវិប្បយុត្តចិត្ត ៥ យ៉ាង

១. ***អទិដ្ឋិជ្ឈាសយតា*** ជាអ្នកមិនមានការយល់ខុសជាអធ្យាស្រ័យ

២. ***ទិដ្ឋិវិប្បន្នបុគ្គលអសេវនតា*** ជាអ្នកមិនសេពគប់បុគ្គលដែលវិបត្តិ ព្រោះទិដ្ឋិ

៣. ***សទ្ធម្មសម្មុខតា*** ជាអ្នកមានមុខឆ្ពោះទៅរកព្រះសទ្ធម្ម

៤. ***មិច្ឆាវិតក្កាពហុលតា*** ជាអ្នកមិនច្រើនដោយមិច្ឆាវិតក្កៈ

៥. ***យោនិសោឧម្មុជ្ជនំ*** ជាអ្នកមានការពិចារណាដោយឧបាយប្រាជ្ញា

បានសេចក្តីថា ហេតុឱ្យកើតទិដ្ឋិគតវិប្បយុត្ត ៥ នេះជាធម៌ផ្ទុយនឹងហេតុឱ្យកើតទិដ្ឋិគតសម្បយុត្តចិត្ត ដូច្នោះបណ្ឌិតគប្បីប្រៀបធៀប នឹងន័យដែលពោលរួចហើយ

នោះ ៗបុះ ។

**ហេតុឱ្យកើតអសង្ខារិកចិត្ត មាន ៦ យ៉ាង គឺ**

១. ***អសង្ខារិកកម្មជនិតបដិសន្ធិកតា*** ជាអ្នកបដិសន្ធិដោយកម្មដែលជាអសង្ខារិក

២. ***កល្លកាយចិត្តតា*** ជាអ្នកមានកាយនិងចិត្តរឹងប៉ឹងមាំមួន

៣. ***ខន្តិពហុលតា*** ជាអ្នកច្រើនដោយសេចក្តីអត់ធន់

៤. ***កត្តព្វកម្មេសុ ទិដ្ឋានិសំសតា***[1] ជាអ្នកឃើញប្រយោជន៍ក្នុងការងារដែលគប្បីធ្វើ

៥. ***កម្មេសុ ចិណ្ណវសិតា*** ជាអ្នកជំនាញក្នុងការងារទាំងឡាយ

៦. ***ឧតុភោជនាទិសប្បាយលាភោ*** បានសេចក្តីសប្បាយចិត្តក្នុងឧតុនិងភោជនជាដើម

---

១. ទីខ្លះថា បុរិសាការេសុ ទិដ្ឋានិសំសតា ជាអ្នកឃើញប្រយោជន៍ក្នុងការងាររបស់បុរសទាំងឡាយ ។

ពាក្យថា **អសង្ខារិកកម្មជនិតបដិសន្ធិកតា** គឺ **អសង្ខារិក + កម្ម + ជនិត + បដិសន្ធិកតា** ។

**អសង្ខារិក :** មិនមានអ្នកណាបបួលដឹកនាំ, **កម្ម :** កម្ម, អំពើ, ការងារ, **ជនិត :** កើតហើយ, **បដិសន្ធិកតា :** ភាពជាអ្នកបដិសន្ធិ ។

ពាក្យថា **កល្លកាយចិត្តតា** គឺ **កល្ល + កាយ + ចិត្ត + តា ;**

**កល្ល** អាច រឹងប៉ឹង មាំមួន ឈ្លាសវៃ សប្បាយ, **កាយ** កាយ( កម្លាំងកាយ ), **ចិត្ត** ចិត្ត, **តា** ភាព,

បានសេចក្តីថា សភាពកាយនិងចិត្តរបស់បុគ្គលនោះ មានភាពអង់អាចដោយខ្លួនឯង មិនបាច់ត្រូវអាស្រ័យការបបួលពីអ្នកដទៃទេ សភាពចិត្តប្បាទរបស់គេនោះ រមែងកើតក្នុងកាលដ៏សមគួរ គឺ កុសលក្តី អកុសលក្តី ដែលគេបានអប់រំសន្សំមកនោះ រមែងមានកម្លាំងខ្លាំងក្លាឡើងខ្លួនឯង កើត

ឡើងឯង ដោយមិនអាស្រ័យអ្នកដទៃបបួល មិនស្រប ឬ បណ្ដោយតាមអ្នកណាឡើយ ៗ ព្រោះហេតុនេះ ទើបជាហេតុឱ្យអសង្ខារិកកើតឡើង ។

ពាក្យថា **ខន្តិពហុលតា** គឺ **ខន្តិ** + **ពហុល** + **តា**

**ខន្តិ** : សេចក្ដីអត់ធន់, **ពហុល** : មានច្រើន ដោយច្រើន ច្រើនដោយ, **តា** : ភាពជាអ្នក ។

បានសេចក្ដីថា ជាអ្នកដែលមានសេចក្ដីអត់ធន់ព្យាយាមស៊ូទ្រាំចំពោះត្រជាក់ រងា ក្ដៅ ស្អុះ អត់ធន់ចំពោះវត្ថុដែលជាសត្រូវដល់ចិត្តរបស់ខ្លួន ដរាបដល់ជាទម្លាប់ ធម្មតាអ្នកមានភាពរឹងប៉ឹង បេះអត់ធន់ រមែងធ្វើកម្មណា ៗ ដោយចិត្តដែលជាអសង្ខារិក មិនចាំបាច់អាស្រ័យការបបួលរបស់អ្នកដទៃ ព្រោះធ្លាប់អត់ធន់តស៊ូចំពោះភាពលំបាកមកច្រើន និងធ្លាប់ឆ្លងកាត់ឧបសគ្គៈមកក៏ច្រើន សូម្បីនឹងជួបការខុសភ្លាំងភ្លាត់ក៏ព្យាយាមដោះស្រាយមិនរាថយ សភាពចិត្ត

ដូច្នេះ ទើបជាហេតុឱ្យអសង្ខារិកកើតឡើង ។

ពាក្យថា **កត្តព្វកម្មេសុ ទិដ្ឋានិសំសតា** គឺ **កត្តព្វ** + **កម្មេសុ** + **ទិដ្ឋិ** + **អានិសំស** + **តា** ។ **កត្តព្វ** : គប្បីធ្វើត្រូវបំពេញ, **កម្មេសុ** : ក្នុងការងារទាំងឡាយ, **ទិដ្ឋិ** : ការឃើញ, **អានិសំស** : អានិសង្ស ផល ប្រយោជន៍, **តា** : ជាអ្នក, បានសេចក្តីថា ចិត្តរបស់គេ បានឃើញផលនៃការងារ គឺ ឃើញប្រយោជន៍ដែលសម្រេចពីការធ្វើកន្លងមកហើយ កាលឃើញប្រយោជន៍ ក្នុងការងារនោះ ៗ ក៏ក្លៀវក្លាក្នុងការធ្វើដោយខ្លួនឯង ដោយមិនត្រូវអាស្រ័យអ្នកដទៃ បបួលនាំឱ្យធ្វើទេ ព្រោះហេតុនេះ ទើបជាហេតុឱ្យអសង្ខារិកកើតឡើង ។

ពាក្យថា **កម្មេសុ ចិណ្ណវសិតា** គឺ **កម្មេសុ** + **ចិណ្ណ** + **វសិ** + **តា** ។

**កម្មេសុ** : ក្នុងការងារទាំងឡាយ, **ចិណ្ណ** : ដែលខ្លួនប្រព្រឹត្តហើយ សន្សំហើយ, **វសិ** : មានភាពស្ទាត់ជំនាញ

ចងចាំបានច្បាស់, **តា** : ភាពជាអ្នក ។

បានសេចក្តីថា ជាអ្នកធ្លាប់ធ្វើការងារនោះ ៗ មកហើយ ទើបមានភាពជំនាញ មិនចាំបាច់មានអ្នកដទៃដឹកនាំ ឬបបួលទេ ក៏ហ៊ានធ្វើ ព្រោះធ្លាប់បានធ្វើ ឬ បានរៀនមកដោយល្អនឹងមានភាពស្ទាត់ជំនាញ ( ដឹងកិច្ចការនោះ ៗ ) ដូច្នេះ ទើបជាហេតុឱ្យអសង្ខារិកកើតឡើង ។

ពាក្យថា **ឧតុភោជនាទិសប្បាយលាភោ** គឺ **ឧតុ** + **ភោជន** + **អាទិ** + **សប្បាយ** + **លាភោ** ។

**ឧតុ** : ឧតុ រដូវ អាកាស ឧណ្ហភូមិ, **ភោជន** : អាហារ ភោជន, **អាទិ** : ជាដើម, **សប្បាយ** : សេចក្តីសប្បាយ, **លាភោ** : ការបាន ។

បានសេចក្តីថា បានទទួលរដូវ គឺ អាកាសដែលល្អ អាហារដែលសមគួរ មានសេចក្តីស្រណុកសុខសប្បាយ គឺ មានអនាម័យល្អ ប្រាសចាករោគភ័យ កាលរាងកាយមិនមាន

ពោគភ័យ បៀតបៀន ចិត្តក៏ស្រឡះស្រស់ស្រាយសប្បាយ ស្វាហាប់ មិនទទន់ខ្សោយ អាចធ្វើកិច្ចអ្វី ៗ ដោយចិត្តដែលជាអសង្ខារិក ។

## ហេតុឱ្យកើតសសង្ខារិកចិត្ត ៦ គឺ

១, **សសង្ខារិកកម្មជនិតបដិសន្ធិកតា** ជាអ្នកបដិសន្ធិដោយកម្មដែលជាសសង្ខារិក

២, **អកល្លកាយចិត្តតា** ជាអ្នកមានកាយនិងចិត្តមិនរឹងប៉ឹង មិនមាំមួន

៣, **អខន្តិពហុលតា** ជាអ្នកច្រើនដោយសេចក្ដីមិនអត់ធន់

៤, **អកត្តព្វកម្មេសុ ទិដ្ឋានិសំសតា** ជាអ្នកមិនឃើញប្រយោជន៍ ក្នុងការងារដែលគប្បីធ្វើ

៥, **កម្មេសុ អចិណ្ណវសិតា** មិនជំនាញក្នុងការងារទាំងឡាយ

៦, **ឧតុភោជនាទិ អសប្បាយលាភោ** មិនបានសេចក្ដីសប្បាយចិត្ត ក្នុងឧតុ និង ភោជនជាដើម

ហេតុឱ្យកើតសសង្ខារិកទាំង ៦ នេះ មានសេចក្តីផ្ទុយនឹងហេតុឱ្យកើតអសង្ខារិកទាំង ៦ នុ៎ះឯង សេចក្តីថា បដិសន្ធិចិត្តដែលជាផលរបស់កម្ម ជាសសង្ខារិក កាលកម្មជាសសង្ខារិកនោះ ជាជនកកម្ម នាំបដិសន្ធិ ក៏ឱ្យបដិសន្ធិចិត្តជាសសង្ខារិក, អ្នកដែលបដិសន្ធិដោយកម្មជាសសង្ខារិកនោះ រមែងទន់ខ្សោយ មិនរឹងប៉ឹង មិនក្លៀវក្លា ដូច្នោះ កាលធ្វើកិច្ចអ្វី ៗ រមែងមិនហ៊ានធ្វើដោយខ្លួនឯង គឺ ទាល់តែមានអ្នកបបួលនាំ ឬត្រូវមានការជួយជ្រោមជ្រែងអំពីអ្នកដទៃ (នេះជាសេចក្តីអធិប្បាយទី ១) ។

សភាពកាយនិងចិត្តរបស់អ្នកនោះ មិនក្លាហានដោយខ្លួនឯងទេ ព្រោះជាអ្នកមិនអង់អាច ដូច្នោះ កាលចិត្តនេះ កើតឡើង ទើបត្រូវអាស្រ័យអ្នកដទៃបបួល (នេះជាសេចក្តីអធិប្បាយទី ២) ។

សភាពរបស់ចិត្តដែលមិនអត់ធន់ចំពោះការលំបាក

និងឧបសគ្គៈផ្សេង ៗ ជាចិត្តដែលរួញរាថយ ចុះចាញ់ឧបសគ្គៈនោះ ដូច្នោះ ចិត្តរបស់គេ ទើបត្រូវអាស្រ័យអ្នកដទៃបបួល ( នេះជាសេចក្តីអធិប្បាយទី ៣ ) ។

សភាពចិត្តរបស់បុគ្គលដែលមិនឃើញផលរបស់ការងារ មិនឃើញប្រយោជន៍ក្នុងការធ្វើ ឬមិនឃើញប្រយោជន៍របស់សេចក្តីព្យាយាម សភាពចិត្តរបស់គេ ទើបមិនមានការក្លៀវក្លាដោយខ្លួនឯងទេ ត្រូវអាស្រ័យអ្នកដទៃបបួល ( នេះជាសេចក្តីអធិប្បាយទី ៤ ) ។

សភាពចិត្តមិនជំនាញ ក្នុងការងារទាំងឡាយ ក៏ត្រូវអាស្រ័យអ្នកដទៃបបួល ( នេះជាការអធិប្បាយទី ៥ ) ។

សភាពចិត្តរបស់បុគ្គលដែលមិនបានឧតុ គឺអាកាសដែលល្អ និងអាហារដែលសមគួរ ជាអ្នកមិនមានអនាម័យ រាងកាយមិនរឹងមាំ ក៏ត្រូវអាស្រ័យអ្នកដទៃបបួលដឹកនាំ ( នេះជាសេចក្តីអធិប្បាយទី ៦ ) ។

## ចែកលោភមូលចិត្ត ៨ ដោយន័យផ្សេងៗ

១. ដោយជាតិ ជាអកុសលជាតិ

២. ដោយភូមិ ជាកាមាវចរភូមិ (កើត ៣០ ភូមិ)

៣. ដោយវេទនា ជាសោមនស្ស ៤ ឧបេក្ខា ៤

៤. ដោយហេតុ ជានហេតុ និងជាទ្វិហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាទិដ្ឋិគតសម្បយុត្ត ៤ ជាទិដ្ឋិគតវិប្បយុត្ត ៤

៦. ដោយសង្ខារ ជាអសង្ខារិក ៤ ជាសសង្ខារិក ៤

៧. ដោយសោភណៈ ជាអសោភណចិត្ត

៨. ដោយឈាន ជាអកុសលឈាន[១]

៩. ដោយលោក ជាលោកិយចិត្ត

១០. ដោយកិច្ច ជាចិត្តធ្វើជវនកិច្ច

១១. ដោយអារម្មណ៍ ជាចិត្តមានអារម្មណ៍ ៦

១២. ដោយទ្វារ ជាចិត្តកើតបានតាមទ្វារ ៦

១៣. **ដោយវត្ថុ** កើតត្រង់ហទយវត្ថុ ( ភូមិដែលមានខន្ធ៥ )
១៤. **ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ

## វិបាកចិត្តដែលកើតពីលោភមូលចិត្ត

លោភមូលចិត្ត ជាហេតុឱ្យកើតវិបាកចិត្ត ( ផលរបស់លោភមូលចិត្ត ) ដរាបណា កាលនៅមានហេតុបច្ច័យ គឺ លោភមូលចិត្តហើយ វិបាក គឺផលរបស់លោភមូលចិត្តក៏ត្រូវតែមាន, វិបាករបស់លោភមូលចិត្តនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "សម័យណា ពួកមនុស្សមានសន្ដានច្រើនដោយលោភៈ សម័យនោះ រមែងកើតទុព្ភិក្ខន្តរាយ គឺអន្តរាយដែលកើតអំពីការក្រ អត់បាយ ( អង្ករមានតម្លៃថ្លៃ ) ជាហេតុឱ្យកើតសេចក្ដីស្រេកឃ្លានចូលមកគ្របសង្កត់ រហូតដល់ដួលដេកស្លាប់ជាច្រើន ទុក្ខផ្សេង ៗនឹងប្រាកដដល់មហាជនច្រើនហួសប្រមាណ" នេះ ជាផលក្នុងបច្ចុប្បន្នដែលកើត

ដោយអំណាចលោភមូលចិត្ត ។

ចំណែកផលរបស់លោភមូលចិត្ត ដែលប្រាកដក្នុងអនាគតកាលនោះ ក្នុងមូលរាសិវណ្ណនា និងចត្តាឡីសកម្មដ្ឋានវណ្ណនាពោលទុកថា ៖

"**យេភុយ្យេន ហិ សត្តា តណ្ហាយ បេត្តិវិសយំ ឧបបជ្ជន្តិ** : សត្វទាំងឡាយ ដោយច្រើន រមែងចូលដល់បេត្តិវិស័យ (កំណើតប្រេត) ព្រោះតណ្ហា (លោភមូលចិត្ត) ជាហេតុ ។[១]

**លោភមូលចិត្ត ៨ ចប់**

---

១. មជ្ឈិ. ឧប. គោបកមោគ្គល្លានសូត្រ. ២៦. ១១៥/១៨៤ អកុសលឈាន សំដៅដល់ នីវរណៈ ។

# ទោសមូលចិត្ត ២

ទោសមូលចិត្ត ជាចិត្តកើតឡើង ព្រោះមានទោសជាហេតុ សេចក្ដីមិនពេញចិត្តក្នុងអារម្មណ៍ផ្សេង ៗ នោះ រមែងកើតឡើង ព្រោះទោសៈ ឬមានទោសៈជាដើមហេតុ, ទោសៈជាអកុសលចេតសិកតាក់តែងចិត្ត ឱ្យកើតការខឹងក្រោធ ការស្អប់ ការខ្ទាប ការតូចចិត្ត និងការតក់ស្លុត ការចង្អៀតចង្អល់ចិត្តជាដើម ព្រោះទោសៈជាសភាពគ្រោតគ្រាត ។

## ទោសមូលចិត្ត ២ គឺ

**១. ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ ទោសមូលចិត្តំ** : ទោសមូលចិត្តកើតឡើង ព្រមដោយទោមនស្សវេទនា ប្រកបដោយបដិឃៈ មិនមានការបបួលដឹកនាំ

**២. ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ**

**ទោសមូលចិត្តំ** : ទោសមូលចិត្តកើតឡើង ព្រមដោយទោមនស្សវេទនា ប្រកបដោយបដិឃៈ មានការបបួលដឹកនាំ

**ឥមានិ ទ្វេបិ បដិឃសម្បយុត្តចិត្តានិ នាម** ចិត្តទាំង ២ នេះ ឈ្មោះថា បដិឃសម្បយុត្តចិត្ត (ចិត្តនេះហៅថា បដិឃចិត្តខ្លះ ទោសមូលចិត្តខ្លះ) ។

## អធិប្បាយ

<u>ក្នុងអភិធម្មត្ថវិភាវិនី</u> អធិប្បាយទោមនស្ស និងបដិឃៈថា ៖

**ទុដ្ឋមនោ តំ វា ឯតស្សាតិ = ទុមនោ** : ចិត្តដែលអាក្រក់ ឈ្មោះថា ទុមនៈ ឬបុគ្គលឈ្មោះថា ទុមនៈ (ចិត្តអាក្រក់) ព្រោះអត្ថថា មានចិត្តអាក្រក់ ។

**តស្ស ភាវោ = ទោមនស្សំ** : ភាវៈនៃចិត្តអាក្រក់នោះ ឈ្មោះថា ទោមនស្ស ។

ពាក្យថា ទោមនស្ស ជាឈ្មោះនៃទុក្ខវេទនាដែលមានក្នុងចិត្ត ។ ចិត្តកើតព្រមនឹងទោមនស្សនោះ ឈ្មោះថា ទោមនស្សសហគតចិត្ត ។

**អារម្មណេ បដិហញ្ញតីតិ = បដិឃោ ទោសោ :** ទោសៈ ឈ្មោះថា បដិឃៈ ព្រោះអត្ថថា ថ្នាំងថ្នាក់នឹងអារម្មណ៍ ។

ពិតមែន ទោសៈនេះ រមែងជាហេតុឱ្យថ្នាំងថ្នាក់នឹងអារម្មណ៍ ព្រោះមានសភាពអាក្រក់ គ្រោតគ្រាត ។ សូម្បីចិត្តដែលកើតព្រមដោយទោមនស្ស ក៏មិនផ្សេងគ្នាដោយវេទនា ដើម្បីកំណត់ចិត្ត ២ នេះ ដោយអំណាចនៃធម៌ដែលមិនទូទៅ, ទើបលោកអាចារ្យពោលដល់ទោមនស្សស័ព្ទ តែគប្បីជ្រាបថា ការដែលចិត្តប្រកបដោយបដិឃៈ លោកពោលទុកដើម្បីសម្តែងសេចក្តីតាមពិត ដែលចិត្តទាំង ២ នេះប្រព្រឹត្តនៅដូចគ្នា ។

ចំណែកសេចក្ដីប្លែកគ្នានៃទោមនស្ស និងបដិឃៈនេះ គឺ

ទោមនស្ស បានដល់ ធម៌ដែលរាប់បញ្ចូលក្នុងវេទនាខន្ធ មានការសោយអនិដ្ឋារម្មណ៍ ជាលក្ខណៈ,

ចំណែកបដិឃៈ បានដល់ ធម៌ គឺ ទោសចេតសិកដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ មានការកាច ជាលក្ខណៈ

គប្បីជ្រាបថា អនិដ្ឋារម្មណ៍ យ៉ាងណាមួយ និងអាឃាតវត្ថុ ៩ យ៉ាង ជាហេតុនៃទោមនស្ស និងបដិឃៈ ។

មួយទៀត បណ្ឌិតគប្បីជ្រាបការកើតឡើងនៃចិត្ត ២ នេះ ក្នុងវេលាដែលប្រព្រឹត្តទៅខ្លាំងក្លា (អសង្ខារិក) និងទន់ខ្សោយ (សសង្ខារិក) ក្នុងអកុសលកម្មបថ មានបាណាតិបាតជាដើម (ក្នុងវិភាវិនី លោកអធិប្បាយទុកត្រឹមប៉ុណ្ណោះ) ។

## អធិប្បាយលក្ខណៈនៃទោសចេតសិក

*ទោសមូលចិត្តនេះ មានលក្ខណៈផ្ទុយពីលោភមូលចិត្ត ព្រោះទោសមូលចិត្ត ជាចិត្តកើតឡើងដោយមានទោសៈជាហេតុ ជាទ្វិហេតុកចិត្ត គឺ ជាចិត្តដែលមានទោសៈ និងមោហៈជាហេតុ សភាពរបស់ទោសចេតសិកនោះ គ្រោតគ្រាត មិនត្រូវចិត្ត មិនពេញចិត្ត មានលក្ខណៈកាច, សព្ទដែលជាឈ្មោះរបស់ទោសៈ មានច្រើនយ៉ាង ។*

## លក្ខណាទិចតុក្កៈរបស់ទោសចេតសិក

**១-ចណ្ឌិកលក្ខណោ** *មានការកាច ជាលក្ខណៈ ដូចអាសិរពិសដែលត្រូវគេវាយ*

**២-វិសប្បនរសោ** *មានការសោប់សេល់ ជាកិច្ច ដូចថ្នាំពិសជ្រាបចូល*

*វា* **អត្តនោ និស្សយទហនរសោ** *ឬដុតសម្បយុត្តធម៌បំផ្លាញទីនៅរបស់ខ្លួន ជាកិច្ច ដូចភ្លើងឆេះព្រៃ*

**៣-ទុស្សនបច្ចុប្បដ្ឋានោ** មានការប្រទូសរ៉ាយ ជាផល ដូចសត្រូវបានឱកាស

**៤-អាឃាតវត្ថុបទដ្ឋានោ** មានអាឃាតវត្ថុ ជាហេតុជិត ។

## អាឃាតវត្ថុ ១០

១. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ

២. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ

៣. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ

៤. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ

៥. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិន

ជាប្រយោជន៍ដល់ បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្ត របស់អាត្មាអញ

៦. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជា ប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្ត របស់អាត្មាអញ

៧. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជា ប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញ ចិត្តរបស់អាត្មាអញ

៨. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើជា ប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញ ចិត្តរបស់អាត្មាអញ

៩. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើជា ប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញ ចិត្តរបស់អាត្មាអញ

១០. សេចក្ដីក្រោធកើតឡើងក្នុងទីមិនគួរ ដូចពេលដែលដើរជំពប់ ឬ ជាន់បន្លាជាដើម ។

( ក្នុងអដ្ឋកថាឥតិវុត្តក ទោសសូត្រទី២ មានអាឃាតវត្ថុ១៩ )

## ប្រភេទរបស់ទោសៈ

**ចិត្តស្ស អាឃាតោ** : ការគុំកួននៃចិត្ត **បដិឃាតោ** : ការគុំកួនតប **បដិឃំ** : សេចក្ដីថ្នាំងថ្នាក់ **បដិវិរោធោ** : ការខឹងតប, **កោបោ** : ការខឹងញាប់ញ័រ **បកោបោ** : ការក្រោធខ្លាំង **សម្បកោបោ** : ការក្រោធញាប់ញ័រ **ទោសោ** : ការប្រទូស្ត **បទោសោ** : ការប្រទូស្តតប **សម្បទោសោ** : ការប្រទូស្តគ្រប់យ៉ាង **ចិត្តស្ស ព្យាបត្តិ** : ការខូចចិត្ត **មនោបទោសោ** : ការប្រទូសនៃចិត្ត **កោធោ** : ការក្រោធ **កុជ្ឈនា** : ការខឹង **កុជ្ឈិតត្តំ** : ភាពនៃចិត្តខឹង, **ទោសោ** : សេចក្ដីប្រទូស្ត **ទុស្សនា** : អាការប្រទូស្ត **ទុស្សិតត្តំ** : ភាពនៃចិត្តប្រទូស្ត **ព្យាបត្តិ** : សេចក្ដីវិនាស **ព្យាបជ្ជនា** :

អាការវិនាស **ព្យាបជ្ជិតត្តំ** : ភាពនៃចិត្តវិនាស **វិរោធោ** : ការខឹង **បដិវិរោធោ** : ការខឹងតប **ចណ្ឌិក្កំ** : ភាពនៃចិត្តកាច **អសុរោបោ** : ការពោលពាក្យអសុរោះ **អនត្តមនតា** **ចិត្តស្ស** : ការតូចចិត្ត នេះហៅថា ទោសៈ ។[១]

## ហេតុឱ្យកើតទោសមូលចិត្ត មាន ៤ យ៉ាង

១. **ទោសជ្ឈាសយតា** មានអធ្យាស្រ័យជាអ្នកក្រោធច្រើន
២. **អគម្ភីរបកតិតា** មានសេចក្តីមិនសុខុមជាប្រក្រតី
៣. **អប្បសុតតា** មានការស្តាប់ព្រះសទ្ធម្មតិច
៤. **អនិដ្ឋារម្មណសមាយោគោ** ប្រកបជាមួយនឹងអារម្មណ៍ដែលមិនល្អ

ពាក្យថា **ទោសជ្ឈាសយតា** គឺ **ទោស** + **អជ្ឈាសយ** + **តា**; **ទោស** : ការខឹងក្រោធ, **អជ្ឈាសយ** : អធ្យាស្រ័យ, **តា** : ភាពជា; បានសេចក្តីថា ជាអ្នកមាន

---

១. អភិ. សង្គ. ហេតុគោច្ឆក. ៧៩. ១៩១/១៤៣ ។

និស្ស័យឆាប់ក្រោធ ក្រោធឆាយទាំងនេះ ព្រោះខ្លួនសន្សំទោសៈទុកមកច្រើន ដរាបទៅជាចរិត អធ្យាស្រ័យនិស្ស័យ សន្តាន លំបាកលះបង់បាន កាលទោសៈ កើតឡើងខណៈណា ទោមនស្សវេទនា ក៏កើតឡើងផង ព្រោះដូច្នោះ ទើបលោកពោលថា ទោសៈ ជាភ័យដ៏សាហាវ មានទោសច្រើន តែលះបង់បានរហ័សជាងលោភៈ នឹងឃើញបានថា កាលទោសៈកើតឡើងធ្វើចិត្តឱ្យកម្រើក ព្យាបាទ មិនពេញចិត្ត កន្ទ្វល់ តក់ស្លុត ខ្លាច មិនត្រូវការឱ្យអ្នកដទៃមានសេចក្តីសុខ សេចក្តីចម្រើនទេ ។

ពាក្យថា **អគម្ភីរបកតិតា** គឺ **អ** + **គម្ភីរ** + **បកតិ** + **តា**; បានសេចក្តីថា កាលទោសចិត្តកើតឡើង ចិត្តនេះមិនមានសេចក្តីសុខុម ជាអ្នកក្រវល់ក្រវាយ រមែងញុំាងវត្ថុដែលមិនជាប្រយោជន៍ឱ្យកើតឡើង ជានីវរណៈរាំងចិត្តមិនឱ្យដឹងអត្ថ មិនឱ្យដឹងធម៌ តាមសេចក្តីពិត សមដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ដូច្នេះថា ៖

អនត្ថជននោ ទោសោ ទោសោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ ។
កុទ្ធោ អត្ថំ ន ជានាតិ កុទ្ធោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ កោធោ សហតេ នរំ ។

*ទោសៈជាកិលេស ញុំាងសេចក្តីវិនាសឱ្យកើត ទោសៈជាកិលេសញុំាងចិត្តឱ្យកម្រើក ទោសៈជាភ័យកើតហើយក្នុងខាងក្នុង ជនពាលរមែងមិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកក្រោធ រមែងមិនដឹងអត្ថ បុគ្គលអ្នកក្រោធ រមែងមិនឃើញធម៌. សេចក្តីក្រោធ គ្របសង្កត់ជនណា សេចក្តីងងឹតសូន្យឈឹង (នៃជននោះ) ក៏មាន ក្នុងកាលនោះ ។*[១]

ពាក្យថា **អប្បសុតតា** គឺ **អប្ប + សុត + តា .**

១. ខុទ្ទ. មហា. កាមសុត្តនិទ្ទេស. ៦៤. ២២/២៨ ។

***អប្ប*** : តិច, ***សុត*** : អ្នកស្ដាប់, ***តា*** : ភាពជា,

*បានសេចក្ដីថា អ្នកដែលសិក្សារៀនសូត្រ ព្រះសទ្ធម្មតិច រមែងមិនដឹងថា "វត្ថុនេះជាគុណ វត្ថុនេះជាទោស វត្ថុណាមានប្រយោជន៍ វត្ថុណាគួរលះ វត្ថុណាគួរចម្រើន កាលមិនដឹង ក៏ជាហេតុឱ្យទោសៈកើតឡើង ។*

*ពាក្យថា **អនិដ្ឋារម្មណសមាយោគោ** គឺ **អនិដ្ឋ** + **អារម្មណ** + **សមាយោគោ**; **អនិដ្ឋ** មិនគួរប្រាថ្នា មិនគួរពេញចិត្ត, **អារម្មណ** អារម្មណ៍, **សមាយោគោ** ការប្រកប ការប្រសព្វ ។*

*សេចក្ដីថា ការប្រកបឬប្រសព្វជាមួយនឹងរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ដែលមិនជាទីប្រាថ្នា ក៏កើតទោមនស្សទោសមូលចិត្ត រមែងកើត ព្រោះហេតុដែលប្រសព្វនឹងអារម្មណ៍ដែលមិនគួរប្រាថ្នា មិនគួរពេញចិត្តនេះ ។*

## ចែកទោសមូលចិត្ត ២ ដោយន័យផ្សេង ៗ

១. ដោយជាតិ ជាអកុសលជាតិ

២. ដោយភូមិ ជាកាមាវចរភូមិ (កាមភូមិ១១)

៣. ដោយវេទនា ជាទោមនស្សវេទនា

៤. ដោយហេតុ ជានហេតុ និងជាទ្វិហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាបដិឃសម្បយុត្ត

៦. ដោយសង្ខារ ជាអសង្ខារិក ១ ជាសសង្ខារិក ១

៧. ដោយសោភណៈ ជាអសោភណចិត្ត

៨. ដោយឈាន ជាអកុសលឈាន

៩. ដោយលោកិយ ជាលោកិយចិត្ត

១០. ដោយកិច្ច ជាចិត្តធ្វើជវនកិច្ច

១១. ដោយអារម្មណ៍ ជាចិត្តមានអារម្មណ៍ ៦

១២. ដោយទ្វារ ជាចិត្តកើតបានទ្វារ ៦

១៣. ដោយវត្ថុ កើតត្រង់ហទយវត្ថុ

១៤. ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ

## ផលដែលកើតពីទោសមូលចិត្ត

*ទោសមូលចិត្តនេះ ជាចិត្តដែលកើតឡើង ព្រោះមានទោសៈជាហេតុ ជាចិត្តដែលមិនត្រេកអរ មិនសប្បាយក្នុងអារម្មណ៍ដែលកំពុងប្រាកដ កាលទោសកើតដល់បុគ្គលណា បុគ្គលនោះ រមែងសៅហ្មង ក្ដៅក្រហាយ អន្ទះអន្ទែង រសាប់រសល់ ក្រវល់ក្រវាយ មុខក្រញូវ មុខជូរ មុខខ្ចូត តានតឹង (ចិត្ត) មិនគួរមើល អ្នកណាបានជួប បានប្រទះឃើញហើយក៏ឆ្លងនូវការក្ដៅក្រហាយចិត្តតាមផងដែរ ។*

*សម័យណា មនុស្សមានសន្ដានកាចឃោរឃៅច្រើនទៅដោយទោសៈ សម័យនោះ រមែងកើតសត្ថន្តរាយ (អន្តរាយដែលកើតអំពីការបៀតបៀនគ្នាដោយសស្ត្រាវុធ) ផ្សេង ៗ ជាហេតុឱ្យច្បាំងកាប់សម្លាប់គ្នា អន្តរាយទាំងនោះនឹងកើតដល់មហាជនទូទៅ ។ ចំណែកវិបាករបស់ទោសមូលចិត្ត ក្នុងអនាគតកាលនោះ រមែងធ្លាក់នរក ដូចក្នុងមូលរាសិវណ្ណនា និងចត្តាឡីសកម្មដ្ឋានវណ្ណនាថា ៖*

*ទោសេន ហិ ចណ្ឌជាតតាយ ទោសសទិសំ និរយំ ឧបបជ្ជន្តិ : ពិតមែន ព្រោះទោសជាហេតុ ទើបសត្វទាំងឡាយចូលដល់នរក ដូចគ្នានឹងទោសៈ ព្រោះសភាពរបស់ទោសមូលចិត្តនោះ ជាជាតិកាចសាហាវ ។*

**ធម៌ដែលជាហេតុលះទោសៈ[១] មាន ៦ យ៉ាង គឺ**

*១. មេត្តានិមិត្តស្ស ឧគ្គហោ ការរៀនមេត្តានិមិត្ត*

*២. មេត្តាភាវនានុយោគោ ការបំពេញព្យាយាមចម្រើនមេត្តា*

*៣. កម្មស្សកតាបច្ចវេក្ខណា ការពិចារណាថា សត្វមានកម្មជារបស់ខ្លួន*

*៤. បដិសង្ខានពហុលីកតា ជាអ្នកច្រើនដោយការពិចារណា*

*៥. កល្យាណមិត្តតា ជាអ្នកមានកល្យាណមិត្ត*

*៦. សប្បាយកថា សន្ទនារឿងជាទីសប្បាយ*

**ទោសមូលចិត្ត ២ ចប់**

---

*១. បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ មូលបណ្ណាសក ។*

# មោហមូលចិត្ត ២

មោហមូលចិត្ត ជាចិត្តដែលមានមោហៈជាហេតុ ជាចិត្តដែលមិនដឹង វង្វេង ល្ងង់ខ្លៅ មិនដឹងតាមសេចក្ដីពិត ព្រោះហេតុនោះ ទើបលោកហៅថា មោហមូលចិត្ត ។

## មោហមូលចិត្ត ២ គឺ

១. **ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ អសង្ខារិកំ មោហមូលចិត្តំ** : មោហមូលចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយវិចិកិច្ឆា មិនមានការបបួលដឹកនាំ

២. **ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ អសង្ខារិកំ មោហមូលចិត្តំ** : មោហមូលចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយឧទ្ធច្ចៈ មិនមានការបបួលដឹកនាំ

**ឥមានិ ទ្វេបិ មោហមូលចិត្តានិ នាម** ចិត្ត ២ នេះឈ្មោះថា មោមូហចិត្ត ឬហៅថា មោហមូលចិត្ត ។

# អធិប្បាយ

<u>ក្នុងវិភាវិនីដីកា</u>

**វិចិកិច្ឆា** មានវចនត្ថៈថា **សភាវំ វិចិនន្តោ តាយ កិច្ឆតិ កិលមតីតិ = វិចិកិច្ឆា :** ធម្មជាតិដែលឈ្មោះថា វិចិកិច្ឆា ព្រោះអត្ថថា ជាហេតុឱ្យវិនិច្ឆ័យសភាវៈបានដោយកម្រ គឺលំបាកកាត់សេចក្តីឱ្យដាច់ ។

ន័យមួយទៀត មានវចនត្ថៈថា **ចិកិច្ឆិតុំ ទុក្ករតាយ វិគតា ចិកិច្ឆា ញាណបដិករោ ឥមិស្សាតិ = វិចិកិច្ឆា** ដែលឈ្មោះថា វិចិកិច្ឆា ព្រោះអត្ថថា ធម្មជាតិនោះ អស់ការព្យាបាលរក្សា ព្រោះលំបាកនឹងចាត់ចែងជាធម៌រាំងញាណ ។

ចិត្តដែលប្រកបដោយវិចិកិច្ឆានោះ ឈ្មោះថា វិចិកិច្ឆាសម្បយុត្តចិត្ត ។

**ឧទ្ធច្ច** មានវចនត្ថៈថា **ឧទ្ធតស្ស ភាវោ = ឧទ្ធច្ចំ :** ភាវៈនៃចិត្តដែលរាយមាយ ឈ្មោះថា ឧទ្ធច្ចៈ ។

*ចិត្តដែលប្រកបព្រមដោយឧទ្ធច្ចៈនោះ ឈ្មោះថា ឧទ្ធច្ចសម្បយុត្តចិត្ត ។*

*ឧទ្ធច្ចៈ ជាអកុសលចេតសិក កើតទូទៅក្នុងអកុសលចិត្ត ជាប្រធាននៃសម្បយុត្តធម៌ក្នុងមោហមូលចិត្ត ព្រោះហេតុដូច្នោះ អកុសលចិត្តនេះ ទើបលោកពោលឱ្យប្លែកចេញទៅដោយឧទ្ធច្ចៈនោះ ៗ ក្នុងធម្មទ្ទេសបាលី ត្រាស់ឧទ្ធច្ចៈទុកក្នុងអកុសល ដោយយេវាបនកធម៌ ចំណែកអកុសលចិត្តចុងក្រោយ ( ទី ១២ )នេះ ត្រាស់ឧទ្ធច្ចៈដោយសរុបថា រមែងកើតឡើង ។*

## គាថាសម្ដែងសរុបឧទ្ធច្ចៈ

សព្វាកុសលយុត្តម្បិ ឧទ្ធច្ចំ អន្តមានសេ
ពលវំ ឥតិ តំយេវ វុត្តមុទ្ធច្ចយោគតោ ។

*សូម្បីឧទ្ធច្ចៈប្រកបក្នុងអកុសលចិត្តទាំងអស់ តែឧទ្ធច្ចៈ*

**មានកម្លាំងក្នុងចិត្តចុងក្រោយនេះ ព្រោះហេតុនោះ ចិត្តនោះឯង ព្រះអនុរុទ្ធាចារ្យទើបពោលថា សម្បយុត្តដោយឧទ្ធច្ចៈ ប្រកបដោយឧទ្ធច្ចៈ ។**

ព្រោះហេតុនោះឯង ព្រះចមមុនី ( កំពូលអ្នកប្រាជ្ញ ) ទើបត្រាស់ឧទ្ធច្ចៈ ដោយ**យោវាបនកន័យ** ហើយទ្រង់សម្តែងដោយសរុបទុកក្នុងអកុសលចិត្ត ចុងក្រោយនេះប៉ុណ្ណោះ ។

មួយទៀត អកុសលទាំង ២ នេះ វៀរចាកសេចក្តីត្រេកអរ និងសេចក្តីថ្នាំងថ្នាក់ ក្នុងអារម្មណ៍ទាំងពួង ព្រោះមិនមានលោភមូល ទោសមូល ជាចិត្តវង្វេងក្រៃលែង ព្រោះវៀរចាកមូលដទៃ និងជាចិត្តញាប់ញ័រ ព្រោះប្រព្រឹត្តទៅប្រកបដោយវិចិកិច្ឆាសេចក្តីងឿងឆ្ងល់ និងឧទ្ធច្ចៈការរវើរវាយ រមែងកើតព្រមនឹងឧបេក្ខាវេទនាប៉ុណ្ណោះ ព្រោះហេតុនោះឯង ការផ្សេងគ្នានៃសង្ខារ ក៏មិនមានដល់ចិត្តទាំងពីរនោះ ។

## គាថាសម្តែងសេចក្តីសង្ខេប

មូឡ្ហត្តា ចេវ សំសប្ប    វិក្ខេបា ចេកហេតុកំ
សោបេក្ខំ សព្វទា នោ ច ភិន្នំ សព្វារភេទតោ ។

***ចិត្តទាំង២ ជាឯកហេតុកៈ កើតព្រមនឹងឧបេក្ខា ព្រោះជាចិត្តវង្វេង និងសង្ស័យរាយមាយ ទាំងមិនផ្សេងគ្នាដោយសង្ខារសព្វ ៗកាល ។***

ពិតមែន មោហមូលចិត្តទាំងពីរនេះ ជាភាវៈនៃចិត្ត ដែលកើតឡើងមានការសង្ស័យ និងការរវើរវាយដោយខ្លួនឯង គឺ មិនមានការបបួល(ពីអ្នកដទៃ) ដែលជាអសង្ខារិកដូចគ្នា គ្រប់កាល ។

***មោហមូលចិត្ត*** មានវចនត្ថៈថា ៖

***មោហេន មុយ្ហន្តិ អតិសយេន សម្មុយ្ហន្តិ មូលន្តរវិរហតោតិ = មោមូហានិ*** ចិត្តដែលឈ្មោះថា មោមូហៈ ព្រោះអត្ថថា វង្វេងវង្វាន់ដោយមោហៈ គឺ ល្ងង់ខ្លៅយ៉ាង

ក្រៃលែង ព្រោះវៀរចាកហេតុដទៃ ( លោភ-ទោសហេតុ ) ។

មោហមូលចិត្ត ២ គឺ វិចិកិច្ឆាសម្បយុត្តចិត្ត ១ ឧទ្ធច្ចសម្បយុត្តចិត្ត ១ ចិត្តទាំង ២ នេះ មានមោហចេតសិកជាមូល ហៅថា ឯកហេតុកចិត្ត ( ចិត្តដែលមានហេតុ ១ គឺ មោហៈ ) ។

## ហេតុឱ្យកើតមោហមូលចិត្ត មាន ២ យ៉ាង

១. ***អយោនិសោមនសិការោ*** ការមិនធ្វើទុកក្នុងចិត្តដោយឧបាយត្រឹមត្រូវ

២. ***អាសវសមុប្បាទោ*** មានអាសវៈជាហេតុកើតឡើង

ការធ្វើទុកក្នុងចិត្តដោយមិនត្រឹមត្រូវនោះ បានដល់ការមិនពិចារណាអារម្មណ៍ ដែលមកប៉ះខ្ទប់តាមទ្វារនោះ ៗ ឱ្យដឹងតាមសេចក្តីពិត មិនពិចារណាហេតុផល មិនពិចារណាវត្ថុខាងដើម-ខាងចុង របស់ធម៌នោះ ៗ ទើបជាហេតុឱ្យកើតមោហមូលចិត្ត ២ ។

ម្យ៉ាងទៀត ហេតុឱ្យកើតមោហមូលចិត្ត ២ នេះ មានអាសវៈជាហេតុឱ្យកើតឡើង ក៏អាសវៈនោះ ជាអ្វី ? គឺ កិលេសគ្រឿងដេកត្រាំនៅក្នុងសន្តាន មាន ៤ ប្រភេទ[១] គឺ

១. ***កាមាសវៈ*** អាសវៈ គឺ កាម បានដល់ សេចក្ដីប្រាថ្នាពេញចិត្ត ក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ។

២. ***ភវាសវៈ*** អាសវៈ គឺ ភព បានដល់ សេចក្ដីត្រេកអរជាប់ចិត្តក្នុងភព

៣. ***ទិដ្ឋាសវៈ*** អាសវៈ គឺ មិច្ឆាទិដ្ឋិទាំងអស់

៤. ***អវិជ្ជាសវៈ*** អាសវៈ គឺ អវិជ្ជា បានដល់ សេចក្ដីល្ងង់ខ្លៅ មិនដឹងពិតក្នុងវត្ថុទាំងពួង ។

---

១. អភិ. សង្គ. ចូឡន្តរទុកនិក្ខេប. ៧៩. ២០៨/១៥៤ ។

ក្នុងធម្មសង្គណី[១] ពោលពាក្យមោហចេតសិកនេះ ថា ៖ **អញ្ញាណំ** ការមិនដឹងច្បាស់ **ពាល្យំ** ភាពនៃចិត្តល្ងង់ **អទស្សនំ** ការមិនឃើញ **អសម្បជញ្ញំ** ការមិនដឹងខ្លួន **អនភិសមយោ** ការមិនត្រាស់ដឹង **មោហោ** ការវង្វេង **អននុពោធោ** ការមិនយល់ **បមោហោ** ការវង្វេងជ្រប់ **អសម្ពោធោ** ការមិនត្រាស់ដឹងព្រម **សម្មោហោ** ការភ្លេចភ្លាំង **អប្បដិវេធោ** ការមិនចាក់ធ្លុះ **អវិជ្ជា** សេចក្តីល្ងង់ **អសង្គាហនា** ការមិនបានផ្ទៀងផ្ទាត់ **អវិជ្ជោឃោ** អន្លង់គឺអវិជ្ជា **អបរិយោគាហនា** ការមិនចុះចិត្តស៊ប់ **អវិជ្ជាយោគោ** ការប្រកបគឺ អវិជ្ជា **អសមបេក្ខនា** ការមិនរំពឹងមើល **អវិជ្ជានុសយោ** អនុស័យគឺ អវិជ្ជា **អប្បច្ចវេក្ខណា** ការមិនពិចារណា **អវិជ្ជាលង្គី** គន្លឹះគឺ អវិជ្ជា **អប្បច្ចក្ខកម្មំ** អំពើមិនជាក់ច្បាស់ **អវិជ្ជាបរិយុដ្ឋាន** ការស្ទាក់ដំណើរគឺ

---

១. អភិ. សង្គ. ៧៩. ១៩១/១៨៤ ។

អវិជ្ជា ទុម្មេជ្ឈំ ការយល់ស្មាក់ស្មើរ ។

## មោហៈ មិនដឹងក្នុងធម៌ ៨ យ៉ាង គឺ

១. ទុក្ខេ អញ្ញាណំ សេចក្តីមិនដឹងក្នុងទុក្ខសច្ចៈ
២. ទុក្ខសមុទយេ អញ្ញាណំ សេចក្តីមិនដឹងក្នុងសមុទយសច្ចៈ
៣. ទុក្ខនិរោធេ អញ្ញាណំ សេចក្តីមិនដឹងក្នុងទុក្ខនិរោធសច្ចៈ
៤. ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ សេចក្តីមិនដឹងក្នុងមគ្គសច្ចៈ ដែលជាផ្លូវនាំឱ្យដល់ទីរំលត់ទុក្ខ ១២ កង
៥. បុព្វន្តេ អញ្ញាណំ សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត
៦. អបរន្តេ អញ្ញាណំ សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអនាគត
៧. បុព្វន្តាបរន្តេ អញ្ញាណំ សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត និងអនាគត
៨. ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ

សេចក្តីមិនដឹងក្នុងបដិច្ចសមុប្បាទ គឺ មិនដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នាកើតឡើងថា "ធម៌នេះជាបច្ច័យ" ។

## លក្ខណាទិចតុក្កៈរបស់មោហៈ

១. *អញ្ញាណលក្ខណោ* មានការមិនដឹង(ធម៌) តាមសេចក្តីពិត ជាលក្ខណៈ

២. *អារម្មណសភាវច្ឆាទនរសោ* មានការបិទបាំងសភាវៈនៃអារម្មណ៍ ជាកិច្ច

៣. *អន្ធការបច្ចុប្បដ្ឋានោ* មាននូវភាពងងឹត ជាអាការប្រាកដ

៤. *អយោនិសោមនសិការបទដ្ឋានោ* មានអយោនិសោមនសិការៈ ជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់វិចិកិច្ឆា

១. *សំសយនលក្ខណា* មានការសង្ស័យ ជាលក្ខណៈ

២. *កម្បនរសា* មានការញាប់ញ័រក្នុងអារម្មណ៍ ជាកិច្ច

៣. **អវិនិច្ឆយបច្ចុប្បដ្ឋានា** មិនមានការវិនិច្ឆ័យក្តីនៃអារម្មណ៍ដាច់បាន ជាអាការប្រាកដ

៤. **អយោនិសោមនសិការបទដ្ឋានា** មានអយោនិសោមនសិការៈជាហេតុជិត ។

## សេចក្តីសង្ស័យ ៨ យ៉ាង គឺ

១. **ពុទ្ធេ កង្ខតិ** សង្ស័យក្នុងព្រះពុទ្ធ

២. **ធម្មេ កង្ខតិ** សង្ស័យក្នុងព្រះធម៌

៣. **សង្ឃេ កង្ខតិ** សង្ស័យក្នុងព្រះសង្ឃ

៤. **សិក្ខាយ កង្ខតិ** សង្ស័យក្នុងសិក្ខា

៥. **បុព្វន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត

៦. **អបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអនាគត

៧. **បុព្វន្តាបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ អាយតនៈ ធាតុ

ដែលជាអតីតនិងអនាគត

**៨. បដិច្ចសមុប្បាទេ កង្ខតិ** សង្ស័យក្នុងបដិច្ចសមុប្បាទធម៌ ។

## អធិប្បាយវិចិកិច្ឆា៨

**១- ពុទ្ធេ កង្ខតិ** សង្ស័យក្នុងព្រះពុទ្ធ គឺ សង្ស័យក្នុងសរីរៈរបស់ព្រះពុទ្ធថា មានពិត ឬមិនមានទេហ្ន៎ បើមិនមានតួខ្លួនទេ ប្រហែលជាសន្មតឡើង ដើម្បីជាឧបាយឱ្យពួកជនស្រឡាញ់គ្នា ស្មោះស្ម័គ្រ សាមគ្គីគ្នា ឬសង្ស័យក្នុងព្រះគុណទាំង ១០ បទ មានពាក្យថា **អរហំ** ជាដើម គឺ ៖

១. ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសិកសត្រូវ គឺ កិលេសព្រមទាំងវាសនា គឺ កាយបយោគ និងវចីបយោគ ។

ទ្រង់ព្រះនាមថា អរហន្ត ព្រោះព្រះអង្គឆ្ងាយចាកកិលេស ១ ព្រះអង្គកំចាត់សត្រូវ គឺ កិលេស ១ ទ្រង់កាច់បំបាក់នូវកាំនៃសង្សារចក្រ ១ ព្រះអង្គជាអ្នកគួរដល់

បច្ច័យទាំងឡាយ ១ ទ្រង់មិនធ្វើបាបក្នុងទីស្ងាត់កំបាំង ១

២. ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងញ្ញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

៣. ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូណ៌ ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥

៤. ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គមានដំណើរ យាងទៅកាន់សុន្ទរស្ថាន គឺ អមតមហានិព្វាន

៥. ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក

៦. ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន

៧. ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គ ជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យ គួរទូន្មានបាន

៨. ទ្រង់ព្រះនាមថា **សត្ថាទេវមនុស្សានំ** ព្រោះព្រះអង្គ ជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ

៩. ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គ ត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង

១០. ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គ មានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថា ព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

សេចក្តីសង្ស័យកើតឡើងថា "ព្រះនាមទាំង ១០ នេះ មានពិត ឬមិនមានទេហ្ន៎ ? "

**២- ធម្មេ កង្ខតិ** សង្ស័យក្នុងព្រះធម៌ គឺ មគ្គ ៤ ផល ៤ និព្វាន ១ ឬមានសេចក្តីសង្ស័យក្នុងព្រះធម្មគុណ ៦ បទ គឺ ៖

១. **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺ ព្រះត្រៃបិដក ជាធម៌ គឺ ព្រះមានព្រះភាគទ្រង់ត្រាស់

សម្តែងហើយដោយល្អ

២. **សន្ទិដ្ឋិកោ** ជាធម៌ គឺ ព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថា នឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះទេ គឺ ឃើញ ច្បាស់ដោយខ្លួនឯង

៣. **អកាលិកោ** ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថា កាលបើ ព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុង លំដាប់គ្នា មិនបានយឺតយូរឡើយ

៤. **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថា បើព្រះ អរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹង ហៅបុគ្គលឱ្យចូលមកមើលបាន

៥. **ឱបនយិកោ** ជាធម៌ គឺ ព្រះអរិយបុគ្គល គប្បីបង្អោន ចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា

៦. **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺ អ្នកប្រាជ្ញទាំងឡាយ

មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ៗ

មានសេចក្តីសង្ស័យថា "ព្រះធម៌ទាំងនេះ ជាធម៌នាំឱ្យផុតទុក្ខ ឬមិនអាចនាំឱ្យរួចចាកទុក្ខទេហ្ន៎ ?"

៣- **សង្ឃេ កង្ខតិ** រមែងសង្ស័យក្នុងព្រះអរិយសង្ឃទាំងនេះថា មានពិតឬទេហ្ន៎ ? ឬស្ទាក់ស្ទើរសង្ស័យក្នុងគុណព្រះសង្ឃ ៩ បទ នេះ គឺ ៖

១. **សុបដិបន្នោ** ជាអ្នកប្រតិបត្តិហើយដោយប្រពៃ

២. **ឧជុបដិបន្នោ** ជាអ្នកប្រតិបត្តិហើយដោយត្រង់

៣. **ញាយបដិបន្នោ** ជាអ្នកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន

៤. **សាមីចិបដិបន្នោ** ជាអ្នកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺ សីល សមាធិ បញ្ញា

៥. **អាហុនេយ្យោ** ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែល

គេបង្អោនចូលមកបូជាដល់អ្នកមានសីល

៦. **បាហុនេយ្យោ** ជាអ្នកគួរទទួលនូវអាគន្តុកទាន ដែលគេតាក់តែងដើម្បីញាតិនិងមិត្ត ហើយបង្អោនចូលមកបូជា

៧. **ទក្ខិណេយ្យោ** ជាអ្នកគួរទទួលនូវទានដែលគេជឿនូវកម្មនិងផលនៃកម្ម ហើយបូជា

៨. **អញ្ជលិករណីយោ** ជាអ្នកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ

៩. **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** ជាបុញ្ញក្ខេត្ត គឺ ជាទីដុះឡើងនូវពូជ គឺ បុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន

សេចក្តីសង្ស័យកើតឡើងថា "គុណព្រះអរិយសង្ឃទាំងនេះ មានពិត ឬមិនមានទេហ្ន៎ ? "

៤- **សិក្ខាយ កង្ខតិ** រមែងសង្ស័យក្នុងសិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិបញ្ញាសិក្ខា ១ ។

១. **អធិសីលសិក្ខា** គឺ មានសីលដល់ព្រមដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោស សូម្បីមានប្រមាណតិចជាដើម ហៅថា អធិសីលសិក្ខា ។

២. **អធិចិត្តសិក្ខា** គឺ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ សម្រេចបឋមជ្ឈានជាដើម ហៅថា អធិចិត្តសិក្ខា ។

៣. **អធិបញ្ញាសិក្ខា** គឺ ជាអ្នកមានបញ្ញាឃើញការកើតការរលត់ ជ្រែកចូលទៅទម្លុះទម្លាយអនុស័យកិលេស ឱ្យអស់ដោយប្រពៃ គឺ រមែងដឹងច្បាស់តាមសេចក្ដីពិតថា នេះទុក្ខ នេះទុក្ខសមុទ័យ នេះទុក្ខនិរោធ នេះទុក្ខនិរោធគាមិនីបដិបទាជាដើម ហៅថា អធិបញ្ញាសិក្ខា ។

សេចក្ដីសង្ស័យកើតឡើងថា "សិក្ខាទាំងនេះ មានពិតឬមិនមានទេហ្ន៎ ?" និងសង្ស័យក្នុងផលានិសង្សនៃការបដិបត្តិនូវសិក្ខាទាំង ៣ នោះថា "នឹងជួយមិនឱ្យធ្លាក់ទៅកាន់អបាយពិតមែនឬហ្ន៎ ? "

៥- **បុព្វន្តេ កង្ខតិ** រមែងសង្ស័យក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត គឺ សង្ស័យថា សភាវៈធម៌ទាំងនេះ ដែលសម្មតិថា ជាតួខ្លួន មនុស្ស សត្វ ធ្លាប់កើតមកហើយក្នុងអតីត មានពិតឬមិនមានទេហ្ន៎ ? ឬមានសេចក្ដីសង្ស័យថា ជាតិមុន មានពិត ឬមិនមានទេហ្ន៎ ?

៦- **អបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអនាគត គឺ សភាវធម៌ដែលសម្មតិថា ជាតួខ្លួន មនុស្ស សត្វ ដែលនឹងប្រាកដក្នុងអនាគត មានពិត ឬមិនមានទេហ្ន៎ ? ឬមានសេចក្ដីសង្ស័យ ក្នុងជាតិមុខថា "សត្វស្លាប់ហើយ នឹងកើតក្នុងជាតិមុខ ភពខាងមុខ មានពិត ឬមិនមានទេហ្ន៎ ?

៧- **បុព្វន្តាបរន្តេ កង្ខតិ** រមែងសង្ស័យក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត និងអនាគត ថា មានពិត ឬមិនមានទេហ្ន៎ ?

៨- បដិច្ចសមុប្បាទេ កង្ខតិ វេមែងសង្ស័យក្នុងបដិច្ចសមុប្បាទធម៌ ក្នុងជាតិនេះថា ធម៌មានអវិជ្ជាជាដើម ជាបច្ច័យឱ្យកើតបុណ្យបាបជាដើម ដែលនឹងនាំឱ្យកើតផលបុណ្យផលបាបបន្តទៅក្នុងភពថ្មីជាដើម មានពិត ឬមិនមានទេហ្ន៎ ?

## សេចក្តីសង្ស័យក្នុងព្រះសូត្រ[១] ១៦ យ៉ាង

*សង្ស័យក្នុងអតីត ៥ អនាគត ៥ និងបច្ចុប្បន្ន ៦*

### សង្ស័យក្នុងអតីត ៥ គឺ

១. **អហោសឹ នុ ខោ អហំ អតីតមទ្ធានំ** *អំពីអតីតកាលអាត្មាអញបានកើតដែរឬ*

២. **ន នុ ខោ អហោសឹ អតីតមទ្ធានំ** *ឬអំពីអតីតកាលអាត្មាអញមិនបានកើតទេ*

៣. **កឹ នុ ខោ អហោសឹ អតីតមទ្ធានំ** *អំពីអតីតកាល*

---

១. មជ្ឈិ. មូល. មូលបរិយាយសូត្រ. ២០. ១២/២៥ ។

អាត្មាអញមានជាតិជាអ្វី

៤. **កថំ នុ ខោ អហោសឹ អតីតមទ្ធានំ** អំពីអតីតកាល អាត្មាអញមានសណ្ឋានទ្រង់ទ្រាយ ដូចម្ដេច

៥. **កឹ ហុត្វា កឹ អហោសឹ នុ ខោ អហំ អតីតមទ្ធានំ** អំពីអតីតកាល អាត្មាអញកើតជាជាតិអ្វី ឬ មួយអាត្មាអញមានសណ្ឋានទ្រង់ទ្រាយ ដូចម្ដេច

## សង្ស័យក្នុងអនាគត ៥ គឺ

១. **ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ** ក្នុងអនាគតកាល អាត្មាអញនឹងកើតទៀតដែរឬ

២. **ន នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** ឬក្នុងអនាគតកាល អាត្មាអញនឹងមិនកើតទៀតទេ

៣. **កឹ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** ក្នុងអនាគតកាល អាត្មាអញនឹងកើតជាជាតិអ្វី

៤. **កថំ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ** ក្នុងអនាគត

កាល អាត្មាអញមានសណ្ឋានទ្រង់ទ្រាយ ដូចម្តេច

៥. **កឹ ហុត្វា កឹ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ** ក្នុងអនាគតកាល អាត្មាអញនឹងមានជាតិជាអ្វី ឬ មានសណ្ឋានទ្រង់ទ្រាយ ដូចម្តេច

## សង្ស័យក្នុងបច្ចុប្បន្ន ៦ គឺ

១. **អហំ នុ ខោស្មិ** ឥឡូវនេះ អាត្មាអញមានឬ

២. **នោ នុ ខោស្មិ** ឬមិនមានទេ

៣. **កឹ នុ ខោស្មិ** ឥឡូវនេះ អាត្មាអញមានជាតិជាអ្វី

៤. **កថំ នុ ខោស្មិ** មានសណ្ឋានទ្រង់ទ្រាយ ដូចម្តេច

៥. **អយំ នុ ខោ សត្តោ កុតោ អាគតោ** តើសត្វនេះ មកអំពីណាហ្ន៎

៦. **សោ កុហឹ គាមី ភវិស្សតិ** សត្វនោះ នឹងទៅកាន់ទីណាវិញហ្ន៎

មួយទៀត សេចក្តីសង្ស័យដែលមិនមែនជាវិចិកិច្ឆា

ដូចក្នុងរឿងព្រះវង្គីសត្ថេរ[១] សង្ស័យចំពោះព្រះឧបជ្ឈាយ៍របស់លោក ឈ្មោះនិគ្រោធកប្បៈដែលបរិនិព្វានថា "ព្រះឧបជ្ឈាយ៍របស់អញ បរិនិព្វានហើយ ឬមិនទាន់បរិនិព្វានទេ" ទើបទូលសួរ ព្រះមានព្រះភាគ ។

## លក្ខណាទិចតុក្កៈរបស់ឧទ្ធច្ចៈ

១. **អវូបសមលក្ខណំ** មានការមិនស្ងប់ ជាលក្ខណៈ

២. **អនវត្ថានរសំ** មានការមិនតាំងនៅ(ក្នុងអារម្មណ៍មួយ) ជាកិច្ច ដូចទង់ត្រូវខ្យល់បក់

៣. **ភន្តត្តបច្ចុប្បដ្ឋានំ** មានការញាប់ញ័រ ជាអាការប្រាកដ

៤. **អយោនិសោមនសិការបទដ្ឋានំ** មានអយោនិសោមនសិការៈជាហេតុជិត ។

១. ខុទ្ទ. សុត្ត. វង្គីសសូត្រ. ៥៤. ៣៦/១១០ ។

## ធម៌ដែលជាហេតុលះវិចិកិច្ឆា ៦

១. ពហុស្សុតតា ភាពជាអ្នកស្តាប់រៀនច្រើន
២. បរិបុច្ឆកតា ភាពជាអ្នកចេះសាកសួរ
៣. វិនយេបកតញ្ញុតា ការដឹងក្នុងព្រះវិន័យដោយជុំវិញ
៤. អធិមោក្ខពហុលតា ភាពជាអ្នកច្រើនដោយអធិមោក្ខ
៥. កល្យាណមិត្តតា ភាពជាអ្នកមានកល្យាណមិត្ត
៦. សប្បាយកថា មានការសន្ទនារឿងជាទីសប្បាយ ។[១]

## ធម៌ដែលជាហេតុលះឧទ្ធច្ចៈ ៦

១. ពហុស្សុតតា ភាពជាអ្នកស្តាប់រៀនច្រើន
២. បរិបុច្ឆកតា ភាពជាអ្នកចេះសាកសួរ
៣. វិនយេបកតញ្ញុតា ការដឹងជុំវិញក្នុងព្រះវិន័យ
៤. ពុទ្ធសេវិតា ជាអ្នកពេញចិត្តក្នុងធម៌របស់ព្រះពុទ្ធ
៥. កល្យាណមិត្តតា ជាអ្នកមានកល្យាណមិត្ត

---

១.២. បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ។

៦. សប្បាយកថា មានការសន្ទនារឿងជាទីសប្បាយ ៗ[២]

## ចែកមោហមូលចិត្ត ២ ដោយន័យផ្សេង ៗ

១. ដោយជាតិ ជាអកុសលជាតិ

២. ដោយភូមិ ជាកាមាវចរភូមិ (កើតក្នុងភូមិ ៣០)

៣. ដោយវេទនា ជាឧបេក្ខាវេទនា

៤. ដោយហេតុ ជានហេតុ និងជាឯកហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាវិចិកិច្ឆាសម្បយុត្ត១ ឧទ្ធច្ចសម្បយុត្ត១

៦. ដោយសង្ខារ ជាអសង្ខារិក

៧. ដោយសោភណៈ ជាអសោភណចិត្ត

៨. ដោយឈាន ជាអកុសលឈាន

៩. ដោយលោកិយ ជាលោកិយចិត្ត

១០. ដោយកិច្ច ជាចិត្តធ្វើជវនកិច្ច

១១. ដោយអារម្មណ៍ ជាចិត្តមានអារម្មណ៍ ៦

១២. ដោយទ្វារ ជាចិត្តកើតតាមទ្វារ ៦

**១៣. ដោយវត្ថុ** *ជាចិត្តកើតត្រង់ហទយវត្ថុ (បញ្ចវោការភូមិ)*
**១៤. ដោយវិញ្ញាណធាតុ** *ជាមនោវិញ្ញាណធាតុ*

## ផលវិបាកដែលកើតអំពីមោហមូលចិត្ត

*មោហមូលចិត្តជាចិត្ត ល្ងង់ ខ្លៅ, អ្នកណា ត្រូវមោហចេតសិក គ្របសង្កត់ អ្នកនោះ រមែងវង្វេង ល្ងិតល្ងង់មិនដឹងអារម្មណ៍តាមសេចក្តីពិត ក្នុងសម័យណា មនុស្សមានសន្តានច្រើនទៅដោយមោហៈ សម័យនោះ រមែងកើតរោគន្តរាយ (អន្តរាយកើតអំពីរោគភ័យបៀតបៀន) ជាហេតុឱ្យកើតរោគ ដួលស្លាប់ជាច្រើន ។*

អនត្ថជននោ មោហោ មោហោ ចិត្តប្បកោបនោ
ភយមន្តរតោ ជាតំ តំ ជនោ នាវពុជ្ឈតិ ។
មូឡ្ហោ អត្ថំ ន ជានាតិ មូឡ្ហោ ធម្មំ ន បស្សតិ
អន្ធតមំ តទា ហោតិ យំ មោហោ សហតេ នរំ ។

*មោហៈជាកិលេស ញុំាងសេចក្តីវិនាសឱ្យកើត*

មោហៈជាកិលេសញុំាងចិត្តឱ្យកម្រើក ភ័យកើតហើយខាងក្នុង ជនរមែងមិនយល់ច្បាស់នូវភ័យនោះទេ បុគ្គលអ្នកវង្វេង រមែងមិនដឹងអត្ថ បុគ្គលអ្នកវង្វេងរមែងមិនឃើញធម៌. មោហៈគ្របសង្កត់ជនណា សេចក្ដីងងឹតសូន្យឈឹង (នៃជននោះ) ក៏មានក្នុងកាលនោះ ដូច្នេះ ។[១]

ចំណែកក្នុងអនាគត មោហមូលចិត្តនេះ រមែងឱ្យសត្វកើតជាសត្វតិរច្ឆាន ដូចក្នុងគុហដ្ឋកសុត្តនិទ្ទេសវណ្ណនាថា ៖

**មោហេន ហិ និច្ចសម្មូឡ្ហំ តិរច្ឆានយោនិយំ ឧប្បជ្ជន្តិ** : ពិតមែន ព្រោះមោហៈជាហេតុ សត្វទាំងឡាយ រមែងចូលដល់កំណើតសត្វតិរច្ឆាន ដែលមានសេចក្ដីវង្វេងជានិច្ច ។

## មោហមូលចិត្ត ២ ចប់

---

១. ខុទ្ទ. មហា. កាមសុត្តនិទ្ទេស. ៦៤. ២២/២៨ ។

## សម្តែងសម្បយុត្ត ក្នុងអកុសលចិត្ត១២

ក្នុងអកុសលចិត្ត១២ គឺ លោភមូលចិត្ត៨ ទោសមូលចិត្ត២ មោហមូលចិត្ត២ មានពាក្យសម្បយុត្ត៤ យ៉ាង គឺ

១. **ទិដ្ឋិគតសម្បយុត្ត** ប្រកបដោយទិដ្ឋិក្នុងលោភមូលចិត្ត ៤

២. **បដិឃសម្បយុត្ត** ប្រកបដោយសេចក្តីថ្នាំងថ្នាក់ ក្នុងទោសមូលចិត្ត ២

៣. **វិចិកិច្ឆាសម្បយុត្ត** ប្រកបដោយសេចក្តីឆ្ងល់សង្ស័យ ក្នុងមោហមូលចិត្តទី ១

៤. **ឧទ្ធច្ចសម្បយុត្ត** ប្រកបដោយសេចក្តីរវើរវាយ ក្នុងមោហមូលចិត្តទី ២

## ហេតុឱ្យកើតអកុសលចិត្ត ១២ មាន ៤ យ៉ាង គឺ

១. បុព្វេ អកតបុញ្ញតា មិនបានធ្វើបុណ្យទុកពីកាលមុន

២. អប្បដិរូបទេសវាស នៅក្នុងប្រទេសដែលមិនសមគួរ

៣. អសប្បុរិសូបនិស្សយ មិនសេពគប់សប្បុរស

៤. អត្តមិច្ឆាបណិធិ តម្កល់ខ្លួនទុកខុស

# អកុសលកម្មបថ

អកុសលចិត្ត ១២ នឹងមានទោសច្រើន ឬមានទោសតិច ក៏ស្រេចហើយតែចេតនាកម្មដែលជាកម្មបថ បើអកុសលចិត្តនោះ ជាកម្មបថមានទោសច្រើន រមែងនាំឱ្យកើតក្នុងអបាយភូមិ បើមិនទាន់ដល់កម្មបថ មានទោសតិចឱ្យផលក្នុងបវត្តិកាល ។ ដើម្បីពន្យល់សេចក្ដីឱ្យបរិបូណ៌ពិស្ដារ ទើបត្រូវសង្គ្រោះអកុសលចិត្ត ១២ ចូលក្នុងកម្មបថផង ។

## អកុសលកម្មបថ ១០ ចែកជា ៣ ទ្វារ

១. កើតតាមកាយទ្វារ មាន ៣ គឺ

**បាណាតិបាតា** ការសម្លាប់សត្វ,

**អទិន្នាទានា** ការលួចទ្រព្យអ្នកដទៃ,

**កាមេសុមិច្ឆាចារា** ការប្រព្រឹត្តិខុសក្នុងកាម,

២. កើតតាមវាចា មាន ៤ គឺ

| | |
|---|---|
| មុសាវាទោ | ការនិយាយពាក្យកុហក, |
| បិសុណាវាទោ | ការនិយាយពាក្យញុះញង់ |
| ផរុសវាទោ | ការនិយាយពាក្យគ្រោតគ្រាត, |
| សម្ផប្បលាបោ | ការនិយាយពាក្យឥតប្រយោជន៍ |

៣. កើតតាមមនោទ្វារ មាន ៣ គឺ

| | |
|---|---|
| អភិជ្ឈា | ការសំឡឹងរំពៃ ចង់បានទ្រព្យគេ |
| ព្យាបាទោ | ការចងគំនុំព្យាបាទ, |
| មិច្ឆាទិដ្ឋិ | ការយល់ខុស ( គឺ និយតមិច្ឆាទិដ្ឋិ ) |

## អកុសលកម្មបថ ១០ មានអាការ ៥

១. ដោយមូល មានលោភៈ ទោសៈ និងមោហៈ ជាមូល

២. ដោយកម្ម ជាកាយកម្ម វចីកម្ម និងមនោកម្ម

៣. ដោយទ្វារ ជាកាយទ្វារ វចីទ្វារ និងមនោទ្វារ

៤. ដោយទោស ជាអប្បសាវជ្ជៈ មានទោសតិច មហាសា

វជ្ជៈ មានទោសច្រើន

**៥. ដោយអង្គ** គឺ អង្គរបស់ការប្រព្រឹត្តិកន្លងកម្មបថ

## អធិប្បាយ

### ១- បាណាតិបាត

ពាក្យថា **បាណាតិបាត (បាណ+អតិ+បាត)** : ញ៉ាំងជីវិតសត្វឱ្យធ្លាក់ចុះទៅ( សម្លាប់សត្វ ) ។

ក៏កាលបុគ្គលគិតថា នឹងទៅបាញ់សត្វ ទើបចាត់ចែងធ្នូ លំពែង ច្បូក ខ្សែ បរិភោគអាហារ ពាក់អាវសំពត់ដោយហេតុត្រឹមប៉ុណ្ណោះ កម្មក៏ដល់នូវការកម្រើកញ័រតាមកាយទ្វារ គេត្រាច់ទៅក្នុងព្រៃអស់ ១ ថ្ងៃ មិនបានអ្វីឡើយ ដោយទីបំផុតសូម្បីទន្សាយ ១ ក៏មិនបាន ។

សួរថា អកុសលចិត្តនេះ ជាកាយកម្ម ឬទេ ?

ឆ្លើយថា មិនមែន

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះមិនដល់កម្មបថទេ តែគប្បីជ្រាបថា អកុសលចិត្តនេះ ឈ្មោះថា កាយទុច្ចរិតតែម្យ៉ាង សូម្បីការទៅរកត្រីជាដើម ក៏ន័យនេះដូចគ្នា ។ តែបើសត្វនោះ ត្រូវស្លាប់ដោយការធ្វើនោះ គប្បីជ្រាបដោយអាការនៃការសម្លាប់ ។

## អាការនៃការសម្លាប់ ៥ យ៉ាង

១. **ដោយមូល** កើតព្រោះទោសៈ មោហៈ ជាមូល

២. **ដោយកម្ម** ជាកាយកម្ម ព្រោះសម្រេចដោយកាយធ្វើតាមផ្លូវកាយ

៣. **ដោយទ្វារ** កើតតាមទ្វារ ២ គឺ កាយទ្វារ និងវចីទ្វារ

៤. **ដោយវជ្ជៈ** បានដល់ មហាសាវជ្ជៈ និងអប្បសាវជ្ជៈ គឺ

សម្លាប់សត្វដែលមានគុណច្រើន មានមនុស្សរក្សាសីលជាដើម មានទោសច្រើន

សម្លាប់សត្វដែលមានគុណតិច មានទោសតិច

សម្លាប់សត្វដែលមានសីលធម៌ មានទោសច្រើន

សម្លាប់សត្វដែលឥតសីលធម៌ មានទោសតិច

សម្លាប់សត្វដែលមានកាយធំ មានទោសច្រើន

សម្លាប់សត្វដែលមានកាយតូច មានទោសតិច

បើកិលេសនិងព្យាយាមខ្លាំង មានទោសច្រើន

បើកិលេសនិងព្យាយាមខ្សោយ មានទោសតិច

៥. **ដោយអង្គ** បាណាតិបាត មានអង្គ ៥ គឺ

១. **បាណោ** សត្វមានជីវិត

២. **បាណសញ្ញិតា** សេចក្តីដឹងថា សត្វមានជីវិត

៣. **វធកចិត្តំ** ចិត្តគិតនឹងសម្លាប់

៤. **ឧបក្កមោ** ព្យាយាមនឹងសម្លាប់

៥. **តេន មរណំ** សត្វស្លាប់ដោយការព្យាយាមនោះ ។

កាលគ្រប់អង្គ ៥ សីលរមែងដាច់ ដល់ភាពជាកម្មបថអាចជាជនកកម្ម នាំឱ្យកើតក្នុងអបាយភូមិ បើមិន

គ្រប់អង្គ ៥ សីលមិនដាច់ ជាទុច្ចរិតកម្ម មិនឱ្យផល បដិសន្ធិក្នុងអបាយភូមិទេ ឱ្យផលតែក្នុងបវត្តិកាល គឺ បន្ទាប់អំពីបដិសន្ធិចិត្តរហូតដល់មុនចុតិចិត្ត ។

## ២_ អទិន្នាទាន

ពាក្យថា អទិន្នាទាន បានដល់ ការកាន់យកវត្ថុរបស់ដែលគេមិនឱ្យ បែកចេញជា **អទិន្ន** របស់ដែលគេមិនឱ្យ, **អាទាន** ការកាន់យក, សេចក្ដីថា មានថេយ្យចេតនា គឺ ចេតនាលួចយករបស់អ្នកដទៃដែលគេនៅហួងហែងរក្សា ។

## អាការនៃការលួច ៥ យ៉ាង

១. **ដោយមូល** កើតព្រោះលោភៈ ទោសៈ មោហៈ ជាមូល គឺ

- បើថេយ្យចេតនា កើតព្រោះលោភៈ មោហៈជាមូល

ជាហេតុឱ្យលួច ដើម្បីឱ្យបានមកនូវវត្ថុដែលត្រូវការ ។

- បើថេយ្យចេតនា កើតព្រោះទោសៈ មោហៈ ជាមូល ក៏លួចដោយបំណងឱ្យគេវិនាស តែមិនយកទ្រព្យនោះទេ ។

**២. ដោយកម្ម** ជាកាយកម្ម ព្រោះសម្រេចដោយកាយកម្ម ធ្វើតាមផ្លូវកាយ

**៣. ដោយទ្វារ** កើតតាមទ្វារ ២ គឺ កាយទ្វារ និងវចីទ្វារ

**៤. ដោយវជ្ជៈ** បានដល់ មហាសាវជ្ជៈ និងអប្បសាវជ្ជៈ គឺ

| | |
|---|---|
| វត្ថុនោះ ប្រណីតមានតម្លៃច្រើន | មានទោសច្រើន |
| វត្ថុនោះ អាក្រក់ មានតម្លៃតិច | មានទោសតិច |
| វត្ថុនោះ ជារបស់អ្នកមានគុណ | មានទោសច្រើន |
| វត្ថុនោះ ជារបស់អ្នកមិនមានគុណ | មានទោសតិច |
| វត្ថុនោះ ជារបស់ធំ | មានទោសច្រើន |
| វត្ថុនោះ ជារបស់តូច | មានទោសតិច |

បើកិលេស និងព្យាយាមខ្លាំង មានទោសច្រើន

បើកិលេស និងព្យាយាមខ្សោយ មានទោសតិច

**៥. ដោយអង្គ** អទិន្នាទាន មានអង្គ ៥ គឺ

**១. បរបរិគ្គហិតំ** ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា

**២. បរបរិគ្គហិតសញ្ញិតា** សេចក្ដីដឹងថា ទ្រព្យនោះមានម្ចាស់ គេហួងហែងរក្សា

**៣. ថេយ្យចិត្តំ** មានចិត្តគិតនឹងលួច

**៤. ឧបក្កមោ** ព្យាយាមនឹងលួច

**៥. តេន ហរណំ** លួចបានមកដោយសេចក្ដីព្យាយាមនោះ

កាលគ្រប់អង្គ ៥ សីលរមែងដាច់ ដល់ភាពជាកម្មបថអាចជាជនកកម្ម នាំឱ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ៥ សីលមិនដាច់ ជាទុច្ចរិតកម្ម មិនឱ្យផល ក្នុងបដិសន្ធិកាលទេ ឱ្យផលតែក្នុងបវត្តិកាល ។

## ៣- កាមេសុមិច្ឆាចារៈ

ពាក្យថា **កាមេសុមិច្ឆាចារ** គឺ **កាមេសុ** + **មិច្ឆា** + **អាចារ**

**កាមេសុ** : ក្នុងកាមទាំងឡាយ, **មិច្ឆា** : ខុស, **អាចារ** : ប្រព្រឹត្ត ។

កាមទាំងឡាយដែលគួរប្រាថ្នា គួរពេញចិត្ត រមែងធ្វើឱ្យលិចចុះក្នុងវដ្តៈ ការជ្រប់ងប់ស្រវឹងនៅក្នុងកាមដោយអំណាចនៃសេចក្តីវង្វេង ត្រេកអរ ទើបធ្វើឱ្យកើតទុច្ចរិតកម្ម នាំសេចក្តីទុក្ខ ក្តៅក្រហាយផ្សេង ៗ មកប្រគល់ឱ្យ ។

**កាមេសុមិច្ឆាចារ** បានដល់ អគមនីយដ្ឋានវីតិក្កមចេតនា គឺ ចេតនាដែលប្រព្រឹត្តកន្លងឋាន ដែលបុគ្គលមិនគប្បីដល់ដោយប្រាថ្នាអសទ្ធម្ម បានដល់ ការប្រព្រឹត្តិខុសក្នុងកាម ក្នុងស្ត្រី ២០ ជំពូក ដែលមានមាតាបិតារក្សាឃុំគ្រងជាដើម ។

## អាការនៃការប្រព្រឹត្តិខុសក្នុងកាម ៥ យ៉ាង

**១. ដោយមូល** កើតឡើងព្រោះលោភៈ និងមោហៈ ជាមូល

**២. ដោយកម្ម** ជាកាយកម្ម ព្រោះរមែងសម្រេចដោយការធ្វើតាមផ្លូវកាយ

**៣. ដោយទ្វារ** ជាកាយទ្វារ ព្រោះប្រព្រឹត្តតាមផ្លូវកាយ

**៤. ដោយសាវជ្ជៈ** គឺ ទោស

បុគ្គលដែលខ្លួនប្រព្រឹត្តកន្លងនោះ មានគុណ មានសីលជាដើមច្រើន មានទោសច្រើន

បុគ្គលដែលខ្លួន ប្រព្រឹត្តកន្លងនោះ មានគុណ មានសីលជាដើមតិច មានទោសតិច

បើមិនមានឆន្ទៈរួមគ្នាទេ មានទោសច្រើន

បើមានឆន្ទៈរួមគ្នា មានទោសតិច

បើកិលេសនិងព្យាយាមខ្លាំង មានទោសច្រើន

បើកិលេសនិងព្យាយាមខ្សោយ មានទោសតិច

**៥. ដោយអង្គ** កាមេសុមិច្ឆាចារៈ មានអង្គ ៤ គឺ

**១. អគមនីយវត្ថុ** ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា

**២. តស្មឹ សេវនចិត្តំ** ចិត្តគិតសេពនូវមេថុនធម្មនឹងស្ត្រីនោះ

**៣. ឧបក្កមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

**៤. មគ្គេន មគ្គប្បដិបាទនំ** ញ៉ាំងមគ្គ និងមគ្គឱ្យដល់គ្នា

កាលគ្រប់អង្គ ៤ សីលរមែងដាច់ ដល់ភាពជាកម្មបថ អាចជាជនកកម្ម នាំឱ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ៤ សីលមិនដាច់ទេ ជាទុច្ចរិតកម្ម មិនឱ្យផលក្នុងបដិសន្ធិកាលទេ ឱ្យផលតែក្នុងបវត្តិកាល ។

## ៤_ មុសាវាទ

ពាក្យថា **មុសាវាទ** គឺ **មុសា + វាទ** ;

**មុសា** : កុហក, **វាទ** : និយាយ, ពោល, ថ្លែង ។

បានសេចក្តីព្យាយាមដោយវាចា (វចីបយោគ) ឬ សេចក្តីព្យាយាមដោយកាយ ដែលទម្លាយប្រយោជន៍អ្នកដទៃ ដោយប្រាថ្នាឱ្យជំទាស់គ្នា ឈ្មោះថា មុសា,ក៏ចេតនាដែលឱ្យតាំងឡើងដោយសេចក្តីព្យាយាមផ្លូវកាយ ឬផ្លូវវាចា ដែលប្រាថ្នានឹងពោលឱ្យឃ្លៀងឃ្លាតចាកសេចក្តីពិត ឈ្មោះថា មុសាវាទ ។ មួយទៀត រឿងដែលមិនពិត ឈ្មោះថា មុសា ការដែលឱ្យអ្នកដទៃ ដឹងរឿងដែលមិនពិតនោះ ហៅថា មុសាវាទ ។ ក្នុងអដ្ឋកថាមជ្ឈិមនិកាយសល្លេខសូត្រថា "ជនពួកណានិយាយកុហក ព្រោះហេតុនោះ ជនទាំងនោះ ឈ្មោះថា មុសាវាទី អធិប្បាយថា អ្នកនិយាយវាចាទទេ គឺ ឡេះឡោះដែលបំផ្លាញប្រយោជន៍របស់អ្នកដទៃ" ។ ក្នុង

សមន្តប្បាសាទិកាថា "ពោលពាក្យដទៃ មិនមែនពោលញាប់មាត់ មិនមែន ពោលដោយភ្លាត់មាត់, ភិក្ខុនោះ រមែងត្រូវអាបត្តិពិត" ។

## អាការនៃការពោលកុហក ៥ យ៉ាង

១. **ដោយមូល** មុសាវាទ កើតព្រោះលោភៈ ទោសៈ និងមោហៈ ជាមូល ដូចជាថា កាលប្រាថ្នាត្រូវការវត្ថុដែលជារបស់អ្នកដទៃ ដរាបដល់ឃាត់ចិត្តមិនបាន ទើបត្រូវនិយាយកុហក សូម្បីពាក្យនិយាយនោះ ធ្វើឱ្យអ្នកដទៃខូចប្រយោជន៍ ក៏និយាយមុសា ដោយអំណាចលោភៈនិងមោហៈ, ចំណែកមុសាវាទដែលកើតព្រោះទោសៈនិងមោហៈជាមូលនោះ ដូចជាថា កាលក្រោធ ក៏និយាយខុសចាកសេចក្ដីពិត ដើម្បីឱ្យអ្នកដទៃវិនាសដោយមិនប្រាថ្នាទ្រព្យនោះទេ ក្រៅអំពីការកាត់ប្រយោជន៍អ្នកដទៃ ដោយសេចក្ដីក្រោធ ប៉ុណ្ណោះ ។

២. **ដោយកម្ម** ជាវចីកម្ម ព្រោះសម្រេចដោយការនិយាយ ឬជាការធ្វើ ដែលឱ្យដឹងសេចក្តី, ក្នុងបំណងឱ្យឃ្លៀងឃ្លាតចាកសេចក្តីពិត ។

៣. **ដោយទ្វារ** កើតតាមទ្វារ ២ គឺ វចីទ្វារ និងកាយទ្វារ មុសាវាទ កុហកតាមវចីទ្វារ បានដល់ ការនិយាយកុហកមុសាវាទ កុហកតាមកាយទ្វារ បានដល់ ការធ្វើសេចក្តីសម្គាល់ ចំណាំឱ្យដឹងរឿងដោយកាយ ដូចជាញាក់មុខ ងក់ក្បាល សរសេរអក្សរ ឬសម្ដែងកិរិយាផ្សេង ៗ ឱ្យដឹងសេចក្តីដែលមិនពិតនោះ ដោយមិនពោលវាចា ។

៤. **ដោយសាវជ្ជៈ** គឺ ទោស

ប្រយោជន៍អ្នកដទៃវិនាសខូចច្រើន មានទោសច្រើន
ប្រយោជន៍អ្នកដទៃវិនាសខូចតិច មានទោសតិច
ម្ចាស់ទ្រព្យមានគុណច្រើន មានទោសច្រើន

ម្ចាស់ទ្រព្យមានគុណតិច មានទោសតិច
បើកិលេសនិងព្យាយាមខ្លាំង មានទោសច្រើន
បើកិលេសនិងព្យាយាមខ្សោយ មានទោសតិច

**៥. ដោយអង្គ** មុសាវាទ មានអង្គ ៤ គឺ

**១. អតថំ វត្ថុ** វត្ថុមិនពិត

**២. វិសំវាទនចិត្តំ** គិតនឹងពោលឱ្យខុស

**៣. តជ្ជោ វាយាមោ** ព្យាយាមនឹងពោលឱ្យខុស

**៤. បរស្ស តទត្ថវិជាននំ** ញុំាងអ្នកដទៃឱ្យដឹងសេចក្ដីនោះ

កាលគ្រប់អង្គ ៤ នេះ សីលរមែងដាច់ ដល់ភាពជាកម្មបថ អាចជាជនកកម្ម នាំឱ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ៤ សីលមិនដាច់ត្រឹមតែជាទុច្ចរិតកម្ម ឱ្យផលតែក្នុងបវត្តិកាល ។

## ៥- បិសុណាវាទ

ពាក្យថា បិសុណាវាទ គឺ **បិសុណា + វាទ**;

**បិសុណា** ស៊កសៀត ញុះញង់, **វាទ** ពោល និយាយ ។

បិសុណាវាទ ឬបិសុណាវាចា បានដល់សន្និដ្ឋចេតនា ជាចេតនារបស់អ្នកមានចិត្តសៅហ្មង ព្រោះលោភៈ ទោសៈបៀតបៀនឱ្យប្រាថ្នានិយាយស៊កសៀត ញុះញង់ ទម្លាយអ្នកដទៃ ដើម្បីឱ្យខ្លួនជាទីស្រលាញ់ដោយលោភៈ និងដើម្បីឱ្យអ្នកដទៃជាទីស្អប់ដោយទោសៈ ដូចនិយាយរឿងមិនល្អរបស់អ្នកដទៃឱ្យអ្នកណាស្តាប់ ព្រោះប្រាថ្នាឱ្យអ្នកនោះជាទីស្អប់ដោយទោសមូលចិត្ត ដែលក្រោធ ព្រោះមិនពេញចិត្តអ្នកនោះ ឬការផ្គាប់ផ្គុនសរសើរ ដើម្បីឱ្យខ្លួនជាទីស្រឡាញ់ ដោយដឹងថា អ្នកនោះពេញចិត្តស្តាប់រឿងមិនល្អរបស់អ្នកដទៃ ក៏និយាយរឿងមិនល្អរបស់អ្នកដទៃឱ្យស្តាប់

ដែលជាការទម្លាយបុគ្គលនោះ ដើម្បីឱ្យខ្លួនជាទីស្រឡាញ់ ។

## អាការនៃការពោលញុះញង់ ៥ យ៉ាង

**១. ដោយមូល** កើតព្រោះលោភៈ ទោសៈ និងមោហៈ ជាមូល

**២. ដោយកម្ម** ជាវចីកម្ម

**៣. ដោយទ្វារ** កើតតាមទ្វារ ២ គឺ វចីទ្វារ និងកាយទ្វារ

**៤. ដោយសាវជ្ជៈ** គឺ ទោស

និយាយស៊កសៀតចំពោះអ្នកមានគុណ មានសីលជាដើមច្រើន មានទោសច្រើន

និយាយស៊កសៀតចំពោះអ្នកមានគុណ មានសីលជាដើមតិច មានទោសតិច

បើគេទាំង ២ ផ្ទែកបែកគ្នា មានទោសច្រើន

បើគេទាំង ២ ផ្ទែកមិនបែកគ្នា មានទោសតិច

បើកិលេសនិងព្យាយាមខ្លាំង មានទោសច្រើន

បើកិលេសនិងព្យាយាមខ្សោយ មានទោសតិច

**៥. ដោយអង្គ** បិសុណាវាទ មានអង្គ ៤ គឺ

**១. ភិន្ទិតព្វោ បរោ** អ្នកដទៃដែលមានរូប គឺ ខ្លួនគប្បីញុះញង់បំបែក

**២. ភេទបុរេក្ខារតា** គិតនឹងញុះញង់បំបែកអ្នកដទៃ

**៣. តជ្ជោ វាយាមោ** ព្យាយាមញុះញង់បំបែកអ្នកដទៃនោះ

**៤. តស្ស តទត្ថវិជាននំ** ញុាំងអ្នកដទៃឱ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់នោះ ។

កាលគ្រប់អង្គ ៤ សីលរមែងដាច់ ដល់ភាពជាកម្មបថ អាចឱ្យផលជាជនកកម្ម នាំឱ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ៤ សីលមិនដាច់ ជាទុច្ចរិតកម្ម ឱ្យផលតែក្នុងបវត្តិកាល ។

## ៦_ ផរុសវាទ

ពាក្យថា **ផរុសវាទ** គឺ **ផរុស + វាទ**

**ផរុស** អាក្រក់, គ្រោតគ្រាត, ទ្រគោះ, បោះបោក,

**វាទ** និយាយ, ពោល, ថ្លែង,

ពាក្យថា **ផរុសវាទ** ឬ**ផរុសវាចា** បានដល់ទុដ្ឋុល្លចេតនា (ចេតនាអាក្រក់) របស់អ្នកនិយាយពាក្យមិនជាទីស្រឡាញ់មិនធ្វើឱ្យសប្បាយចិត្ត ព្រោះត្រូវទោសៈប្រទូសរ៉ាយ និងប្រាថ្នាបំផ្លាញអ្នកដទៃឱ្យវិនាស ។

ចំណែកពាក្យនិយាយគ្រោតគ្រាត ដោយប្រាថ្នាឱ្យអ្នកដទៃ ប្រព្រឹត្តល្អ មិនចាត់ជាផរុសវាទ ។

ក្នុងអដ្ឋកថា អដ្ឋសាលិនី ពោលទុកថា ៖

បានឮថា ក្មេងម្នាក់មិនស្ដាប់ពាក្យមាតា ហើយចូលទៅព្រៃ មាតាមិនអាចហាមឃាត់បាន ទើបបានផ្ដាសាថា "សូមឱ្យមេក្របីកាច ដេញតាមវាចុះ" ដូច្នេះ ពេលនោះ មេក្របី

ក្នុងព្រៃក៏បានប្រាកដដល់គេ ដូចពាក្យដែលមាតាពោលនោះឯង ក្មេងនោះ បានធ្វើសច្ចកិរិយាថា “មាតារបស់ខ្ញុំពោលពាក្យណា ដោយមាត់មិនគិតប្រទូសរ៉ាយ សូមពាក្យនោះ កុំមានឡើយ បើមាតាគិតពាក្យណាដោយចិត្ត សូមពាក្យនោះ មានចុះ” ដូច្នេះ ហើយទៅ មេក្របីនោះ ឈរនៅទ្រឹង ដូចបុគ្គលចងទុកក្នុងទីនោះ ។ សូម្បីឧបជ្ឈាយ៍ និងអាចារ្យដែលពោលទូន្មានសិស្ស ក៏មានន័យដូចគ្នានេះឯង ។

## អាការនៃការពោលពាក្យអាក្រក់ ៥ យ៉ាង

១. **ដោយមូល** ផរុសវាទ កើតព្រោះទោសៈនិងមោហៈ ជាមូល

២. **ដោយកម្ម** ជាវចីកម្ម

៣. **ដោយទ្វារ** កើតតាមទ្វារ ២ គឺ វចីទ្វារ និងកាយទ្វារ

៤. **ដោយសាវជ្ជៈ** គឺ ទោស

ពោលពាក្យអាក្រក់ចំពោះអ្នកមានគុណ គឺ សីលជាដើមច្រើន មានទោសច្រើន

ពោលពាក្យអាក្រក់ចំពោះអ្នកមានគុណ គឺ សីលជា ដើមតិច មានទោសតិច

ផរុសវាចដែលដល់កម្មបថ (គ្រប់អង្គ) មានទោសច្រើន

ផរុសវាចដែលមិនដល់កម្មបថមានទោសតិច

បើកិលេសនិងព្យាយាមខ្លាំង មានទោសច្រើន

បើកិលេសនិងព្យាយាមខ្សោយ មានទោសតិច

**៥. ដោយអង្គ** ផរុសវាច មានអង្គ ៣ គឺ

**១. អក្កោសិតព្វោ បរោ** អ្នកដទៃដែលមានរូប គឺ ខ្លួនគប្បីជេរប្រទេច

**២. កុបិតចិត្តំ** មានចិត្តខឹងក្រោធ

**៣. អក្កោសនា** បានជេរគេ

កាលគ្រប់អង្គ ៣ សីលរមែងដាច់ ដល់ភាពជាកម្មបថអាចជាជនកកម្ម នាំឱ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ៣ សីលមិនដាច់ ជាទុច្ចរិតកម្ម ឱ្យផលតែក្នុងបវត្តិកាល ។

## ៧_ សម្ផប្បលាបៈ

ពាក្យថា **សម្ផប្បលាប** គឺ **សម្ផ** + **បលាប**

**សម្ផ** : ផ្ដេសផ្ដាស, ឥតប្រយោជន៍,

**បលាប** : ពោល និយាយ ។

**សម្ផប្បលាប** បានដល់ អនត្ថវិញ្ញាបិកាចេតនា គឺ ចេតនាដែលប្រាប្ថាឱ្យអ្នកដទៃ ដឹងវត្ថុដែលមិនជាប្រយោជន៍

អធិប្បាយថា ពាក្យថា **អនត្ថ** ប្រែថា មិនមែនប្រយោជន៍ **វិញ្ញាបិកា** ប្រែថា ឱ្យគេដឹងដោយលោភមូលចិត្ត គឺ ដោយសេចក្ដីត្រូវការត្រេកអរឱ្យគេដឹងវត្ថុ ដែលមិនមែនប្រយោជន៍ និងដោយទោសមូលចិត្ត គឺ ដោយសេចក្ដីមិនពេញចិត្ត ទើបឱ្យដឹងវត្ថុដែលមិនមែនជាប្រយោជន៍នោះ ដើម្បីឱ្យគេក្ដៅក្រហាយ ជាទុក្ខ ចេតនាដែលប្រាប្ថាឱ្យអ្នកដទៃដឹងវត្ថុដែលមិនមែនជាប្រយោជន៍នោះ រមែងជាការបៀតបៀន ដោយលោភៈ និងទោសៈ ។

ខណៈណាដែលអ្នកនិយាយ និយាយដោយចិត្តមាន លោភៈ ទោសៈ មោហៈ មិនមានចេតនាប្រាថ្នាឱ្យអ្នកដទៃដឹង វត្ថុដែលមិនមែនជាប្រយោជន៍ ក៏ត្រឹមតែជាវចីទ្វាររបស់ អកុសលចិត្ត មិនមែនវចីទ្វារដែលជារបស់អកុសលកម្មទេ, តែខណៈណា មានចិត្តប្រាថ្នាឱ្យអ្នកដទៃដឹងវត្ថុដែលមិនមែន ជាប្រយោជន៍ ខណៈនោះ ក៏ជាវចីទ្វាររបស់អកុសល ។

## អាការនៃការពោលពាក្យឥតប្រយោជន៍ ៥ យ៉ាង

**១. ដោយមូល** កើតព្រោះលោភៈ ទោសៈ និងមោហៈ ជា មូល

**២. ដោយកម្ម** ជាវចីកម្ម

**៣. ដោយទ្វារ** កើតតាមទ្វារ ២ គឺ វចីទ្វារ និងកាយទ្វារ

**៤. ដោយវជ្ជៈ** គឺ ទោស

ការសេព ( និយាយ ) ច្រើន មានទោសច្រើន

ការសេព ( និយាយ ) តិច មានទោសតិច

អ្នកដទៃកាន់យករឿងឥតប្រយោជន៍នោះ មានទោសច្រើន
អ្នកដទៃមិនកាន់យករឿងនោះទេ មានទោសតិច

**៥. ដោយអង្គ** សម្ផប្បលាប មានអង្គ ២ គឺ

១. **ភារតយុទ្ធសិតាហរណាទិនិរត្ថកថា** ពាក្យឥតប្រយោជន៍ មានរឿងចម្បាំងនៃមហាភារតៈ និងរឿងរាពណ៍ លួចនាំយកនាងសិតាទៅជាដើម ។

២. **តថារូបីកថាកថនំ** បានពោលពាក្យឥតប្រយោជន៍មានសភាពដូច្នោះ

កាលគ្រប់អង្គ ២ សីលរមែងដាច់ ដល់ភាពជាកម្មបថ អាចជាជនកកម្ម នាំឱ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ២ សីលមិនដាច់ ជាទុច្ចរិតកម្ម ឱ្យផលតែក្នុងបវត្តិកាល ។

## ៨. អភិជ្ឈា

អភិជ្ឈាដែលជាមនោកម្ម បានដល់ ចេតនាដែលប្រព្រឹត្តទៅជាមួយសេចក្តីលោភដ៏ខ្លាំងក្លា រហូតដល់គិតប្រាថ្នាយកទ្រព្យរបស់របរអ្នកដទៃ មកជារបស់ខ្លួន បើពេញចិត្តក្នុងរបស់គេនោះថា ល្អស្អាត ដោយមិនចង់បានមកជារបស់ខ្លួនទេ មិនជាមនោកម្មបថ ត្រឹមតែជាលោភមូលចិត្ត តែកាលលោភមានកម្លាំងខ្លាំងក្លា រហូតដល់គិតប្រាថ្នា ចង់បានទ្រព្យរបស់របរអ្នកដទៃ មកជារបស់ខ្លួន ដោយបៀតបៀនអ្នកនោះ ក្នុងផ្លូវទុច្ចរិត ចេតនាក្នុងលោភមូលចិត្តនោះ ក៏ជាមនោកម្មបថ ។

### អាការនៃការសម្លឹងរំពៃទ្រព្យអ្នកដទៃ ៥ យ៉ាង

១. **ដោយមូល** អភិជ្ឈាកើតព្រោះលោភៈ និងមោហៈ ជាមូល

២. **ដោយកម្ម** ជាមនោកម្ម ព្រោះចេតនានោះប្រព្រឹត្តទៅជាមួយនឹងលោភៈដ៏ខ្លាំងក្លា ដរាបដល់គិតចង់បានទ្រព្យអ្នកដទៃ

៣. **ដោយទ្វារ** កើតតាមទ្វារ៣ គឺមនោទ្វារ វចីទ្វារ និងកាយទ្វារ

**តាមមនោទ្វារ** គឺ ខណៈដែលគិតប្រាថ្នាយកទ្រព្យអ្នកដទៃដោយឧបាយ ឬដោយទុច្ចរិតកម្មផ្សេង ៗ,

**តាមវចីទ្វារ** គឺ កាលចិត្តគិតប្រាថ្នាយកទ្រព្យអ្នកដទៃមកជារបស់ខ្លួន ក៏និយាយចេញមកដោយសេចក្តីគិតនោះ ដើម្បីបានរបស់នោះមក,

**តាមកាយទ្វារ** គឺ កាលចិត្តគិតប្រាថ្នាយកទ្រព្យអ្នកដទៃមកជារបស់ខ្លួន ក៏ធ្វើទុច្ចរិតដោយកាយ ដើម្បីបានរបស់នោះមក ។

ចេតនានិយាយ ដើម្បីឱ្យបានរបស់នោះមកជារបស់ខ្លួន ឬការធ្វើដែលនាំឱ្យបានទ្រព្យអ្នកដទៃមកជារបស់ខ្លួនដែលកើតអំពីការគិតប្រាថ្នាដោយសេចក្តីលោភនោះ ជាមនោកម្ម តាមកាយទ្វារ និងវចីទ្វារ, មិនមែនកាយកម្មវចីកម្មទេ ព្រោះមនោកម្មកើតអំពីសេចក្តីគិតប្រាថ្នាឱ្យទ្រព្យអ្នកដទៃមកជារបស់ខ្លួន ៗ ដោយសេចក្តីលោភៈ ដូច្នោះ

លោភៈ ឬអភិជ្ឈា ទើបជាប្រធានរបស់ការធ្វើនោះ ៗ កាលលោភអភិជ្ឈាជាប្រធាន ចេតនាដែលកើតរួមនោះ ក៏ជាមនោកម្ម, បើចេតនាដែលធ្វើតាមផ្លូវកាយជាប្រធាន ចេតនានោះ ក៏ជាកាយកម្ម, ដូចជាកាលឃើញប្រាក់ជ្រុះ ក៏រើសយកដោយមិនឱ្យដល់ម្ចាស់គេវិញ ជាកាយកម្ម មិនមែនមនោកម្មទេ ។

**៤. ដោយសាវជ្ជៈ** គឺ ទោស ដូចគ្នានឹងអទិន្នាទាន

**៥. ដោយអង្គ** អភិជ្ឈា មានអង្គ ២ គឺ

**១. បរភណ្ឌំ** ទ្រព្យជារបស់អ្នកដទៃ

**២. អត្តនោ បរិណាមនំ** គិតបង្វែរទ្រព្យរបស់អ្នកដទៃនោះ ឱ្យមកជាទ្រព្យរបស់ខ្លួនដោយកលឧបាយផ្សេង ៗ ។

កាលគ្រប់អង្គ ២ ទើបជាកម្មបថ អាចឱ្យផលកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គមិនជាកម្មបថ ជាទុច្ចរិតកម្មឱ្យផលតែក្នុងបវត្តិកាល ។

## ៩_ ព្យាបាទ

ព្យាបាទដែលជាមនោកម្ម បានដល់ ចេតនាដែលប្រព្រឹត្តទៅ ជាមួយសេចក្ដីក្រោធដ៏ខ្លាំងក្លា រហូតគិតចង់ឱ្យអ្នកដទៃវិនាស ជាមនោកម្មបថ គឺ បើចិត្តក្រោធ មិនពេញចិត្តខ្លាំងក្លា ដរាបគិតឱ្យអ្នកដទៃវិនាស ក្នុងខណៈណា ចេតនាក្នុងទោសមូលចិត្តនោះ ក៏ជាមនោកម្មបថ បើចិត្តក្រោធ មិនពេញចិត្តកើតឡើង ត្រឹមតែជាទោសមូលចិត្ត ជាអកុសលចិត្តមិនមែនមនោកម្មបថទេ ។

### អាការនៃការចង់ឱ្យវិនាស ៥ យ៉ាង

១. **ដោយមូល** កើតព្រោះទោសៈ និងមោហៈ ជាមូល

២. **ដោយកម្ម** ជាមនោកម្ម ព្រោះចេតនានោះប្រព្រឹត្តជាមួយសេចក្ដីក្រោធ ដ៏ខ្លាំងក្លា ដរាបដល់គិតចង់ឱ្យអ្នកដទៃវិនាស

៣. **ដោយទ្វារ** កើតតាមទ្វារ ៣ គឺមនោទ្វារ វចីទ្វារ និងកាយទ្វារ

**មនោទ្វារ** ដូចក្នុងខណៈដែលសេចក្ដីក្រោធដ៏ខ្លាំងក្លា ដរាប

គិតឱ្យអ្នកដទៃវិនាស ដោយទុច្ចរិតកម្មផ្សេង ៗ ។

**តាមវចីទ្វារ** ដូចកាលចិត្តគិតឱ្យអ្នកដទៃវិនាស ដោយសេចក្ដីព្យាបាទ ក៏ប្រើ ឬបញ្ជាអ្នកដទៃឱ្យធ្វើនូវសេចក្ដីវិនាសដល់អ្នកដែលខ្វួន ក្រោធនោះ

**តាមកាយទ្វារ** ដូចកាលចិត្តគិតប្រាថ្នាឱ្យអ្នកដទៃវិនាស ដោយការព្យាបាទ ក៏ធ្វើទុច្ចរិតផ្សេង ៗ ដោយកាយរបស់ខ្លួន ដើម្បីឱ្យអ្នកដទៃវិនាស ។

ចេតនានិយាយ ឬធ្វើឱ្យអ្នកដទៃវិនាស ដែលកើតដោយចិត្តព្យាបាទ ជាមនោកម្ម មិនមែនកាយកម្ម និងវចីកម្មទេ ព្រោះកើតជាមួយចិត្តដែលព្យាបាទ ការនិយាយ ឬការធ្វើនោះ កើតអំពីចិត្តដែលព្យាបាទ ព្យាបាទនោះ ក៏ជាប្រធានរបស់ការធ្វើនោះ កាលសេចក្ដីព្យាបាទជាប្រធាន ចេតនាដែលកើតរួមនឹងទោសមូលចិត្ត ព្យាបាទនោះ ក៏ជាមនោកម្មបថ ។

បើកាយកម្ម គឺ ធ្វើដោយកាយ ឬវចីកម្ម ធ្វើដោយ

វាចាចេតនាដែលធ្វើដោយកាយកម្ម និងវចីកម្មនោះ ក៏ជាប្រធាន មិនមែនព្យាបាទជាប្រធាន ដូចការសម្លាប់មូស ការសម្លាប់ស្រមោច ជាកាយកម្ម ព្រោះចេតនាដែលធ្វើដោយកាយជាប្រធាន ការប្រយុទ្ធ ការពារខ្លួននោះ ធ្វើឱ្យអ្នកដទៃឈឺចាប់ ឬស្លាប់នោះ ជាកាយកម្ម មិនមែនមនោកម្ម ព្រោះចេតនាដែលធ្វើដោយកាយជាប្រធាននោះ មិនមែនព្យាបាទជាប្រធាន ។

**៤. ដោយវជ្ជៈ** គឺ ទោស ដូចគ្នានឹងផរុសវាចា

**៥. ដោយអង្គ** ព្យាបាទ មានអង្គ ២ គឺ

**១. បរសត្តោ** អ្នកដទៃក្រៅពីខ្លួន

**២. តស្ស តំ តំ វិនាសចិន្តា** គិតគុំកួនប្រុងនឹងឱ្យអ្នកនោះ ដល់នូវសេចក្តីវិនាសដោយហេតុនោះ ៗ

កាលគ្រប់អង្គ២ សីលរមែងដាច់ ដល់ភាពជាកម្មបថ អាចជាជនកកម្ម នាំឱ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ២ មិនជាកម្មបថ ជាទុច្ចរិតកម្ម ឱ្យផលតែក្នុងបវត្តិកាល ។

## ១០- មិច្ឆាទិដ្ឋិ

មិច្ឆាទិដ្ឋិដែលជាមនោកម្ម បានដល់ ចេតនាដែលកើតរួមនឹងសេចក្ដីយល់ខុសដ៏ខ្លាំងក្លា ហៅថា និយតមិច្ឆាទិដ្ឋិ ជាចេតនាដែលផ្ដោតចិត្តមាំ ក្នុងការយល់ខុសនោះ ។

### អាការនៃការយល់ខុស ៥ យ៉ាង

១. **ដោយមូល** មិច្ឆាទិដ្ឋិ កើតព្រោះមោហៈនិងលោភៈ ជាមូល

២. **ដោយកម្ម** ជាមនោកម្ម ព្រោះចេតនាដែលកើតឡើងរួមនឹងការយល់ខុស ជាផ្លូវចិត្ត

៣. **ដោយទ្វារ** កើតតាមទ្វារ ៣ គឺ មនោទ្វារ វចីទ្វារ កាយទ្វារ

**តាមមនោទ្វារ** បានដល់ ចេតនាដែលកើតរួមនឹងសេចក្ដីយល់ខុសដ៏មុតមាំនោះ,

**តាមវចីទ្វារ** បានដល់ កាលយល់ខុសយ៉ាងនោះហើយក៏មានចេតនា និយាយរឿងដែលខុសនោះ ៗ,

**តាមកាយទ្វារ** បានដល់ កាលយល់ខុសយ៉ាងមុតមាំនោះហើយ ក៏មានចេតនាធ្វើទុច្ចរិតកម្មផ្សេង ៗ ដោយចិត្តដែលយល់ខុសនោះ ។

៤. **ដោយសាវជ្ជៈ** គឺ ទោស

មានអាសេវនៈ (គឺសេព)មកច្រើន មានទោសច្រើន

មានអាសេវនៈ (គឺសេព)មកតិច មានទោសតិច

បើសេចក្តីយល់ខុសមិនស៊ប់មាំ មានទោសតិច

បើសេចក្តីយល់ខុសស៊ប់មាំ មានទោសច្រើន

៥. **ដោយអង្គ** មិច្ឆាទិដ្ឋិ មានអង្គ ២ គឺ

១. **វត្ថុនោ ច គហិតាការវិបរិតតា** ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម

២. **យថា ច តំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ** គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះថា ជាត្រូវវិញ ។

កាលគ្រប់អង្គ ២ សីលរមែងដាច់ ដល់ភាពជាកម្មបថ អាចជាជនកកម្ម នាំឱ្យកើតក្នុងអបាយភូមិ បើមិនគ្រប់អង្គ ២ សីលមិនដាច់ ជាទុច្ចរិតកម្ម ឱ្យផលតែក្នុងបវត្តិកាល ។

**ក្នុងអដ្ឋសាលិនី** លោកពោលថា ៖

ក្នុងកម្មបថទី ១០ គឺ មិច្ឆាទិដ្ឋិ រមែងដល់ភាពជាកម្មបថ ដោយអកិរិយទិដ្ឋិ អហេតុកទិដ្ឋិ និងនត្ថិកទិដ្ឋិប៉ុណ្ណោះ មិច្ឆាទិដ្ឋិដទៃមិនដល់ភាពជាកម្មបថទេ ។

បណ្ដាទិដ្ឋិទាំង ៣ នោះ គឺ ៖

**អកិរិយៈ** បដិសេធការធ្វើ ជាការយល់របស់គ្រូបូរណកស្សបៈ ការយល់ខុសនេះ បដិសេធការធ្វើល្អ ធ្វើអាក្រក់ទាំងអស់ គេថា ការធ្វើល្អមិនមាន ការធ្វើអាក្រក់មិនមានសូម្បីវិញ្ញាណនោះឯង ក៏ស្ងៀមព្រងើយ ៗ មិនទទួលដឹងនូវការធ្វើនោះ ៗ ។

**អហេតុកទិដ្ឋិ** បដិសេធហេតុ ជាការយល់របស់គ្រូមក្ខ

លិគោសាល ដែលយល់ឃើញថា សត្វទាំងឡាយដែលសៅហ្មងអាក្រក់ ឬល្អបរិសុទ្ធខ្លួនឯង មិនមានហេតុ មិនមានបច្ច័យ ។

**នត្ថិកទិដ្ឋិ** បដិសេធទាំងហេតុ ទាំងផល ជាការយល់ឃើញរបស់គ្រូអជិតកេសកម្ពល ដែលយល់ថា ការធ្វើល្អ ធ្វើអាក្រក់មិនមាន, ផលរបស់ការធ្វើល្អ ធ្វើអាក្រក់ក៏មិនមាន ។

ការយល់ឃើញទាំង ៣ នេះ ជានិយតមិច្ឆាទិដ្ឋិ មានទោសច្រើនជាងកម្មណា ៗ ក្រៃលែងជាងអនន្តរិយកម្ម ព្រោះទោសរបស់និយតមិច្ឆាទិដ្ឋិ ដែលមិនអាចកំណត់កាលនៃការរួចផុតចាកទុក្ខបានឡើយ ។

## អកុសលមូល ៣ ជាហេតុកើតអកុសលកម្មបថ ១០

**១. លោភមូល** ជាហេតុឱ្យកើតទុច្ចរិត ៧ បានទ្វារ ៣ គឺ

ក. កាយកម្ម ២ បានដល់ អទិន្នាទាន កាមេសុមិច្ឆាចារ

ខ. វចីកម្ម ៣ បានដល់ មុសាវាទ បិសុណាវាទ

សម្ផប្បលាប

គ. មនោកម្ម ២ បានដល់ អភិជ្ឈា មិច្ឆាទិដ្ឋិ

**២. ទោសមូល** ជាហេតុឱ្យកើតទុច្ចរិត ៧ បានទ្វារ ៣ គឺ

ក. កាយកម្ម ២ បានដល់ បាណាតិបាត អទិន្នាទាន

ខ. វចីកម្ម ៤ បានដល់ មុសាវាទ បិសុណាវាទ ផរុសវាទ សម្ផប្បលាប

គ. មនោកម្ម ១ បានដល់ ព្យាបាទ

**៣. ដោយទ្វារ** មោហមូល ជាហេតុឱ្យកើតទុច្ចរិត ១០ បានទ្វារ ៣ គឺ

ក. កាយកម្ម ៣ បានដល់ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារៈ

ខ. វចីកម្ម ៤ បានដល់ មុសាវាទ បិសុណាវាទ ផរុសវាទ សម្ផប្បលាបៈ

គ. មនោកម្ម ៣ បានដល់ អភិជ្ឈា ព្យាបាទៈ មិច្ឆាទិដ្ឋិ

សម្រាប់អកុសលកម្មបថនោះ នឹងឃើញបានថា ត្រូវមានចេតនាប្រាថ្នាឱ្យអ្នកដទៃខូចប្រយោជន៍ ដូច្នោះ ចេតនានោះ ទើបជាកម្មបថ មិនមែនលោភៈ ទោសៈ និង មោហៈ ដែលត្រឹមតែជាអកុសលចិត្ត ។

បើការធ្វើនោះ សម្រេចដោយការបៀតបៀនអ្នកដទៃ ឱ្យក្តៅក្រហាយ ឱ្យវិនាស ឱ្យមានទុក្ខ និងគ្រប់អង្គដែល កំណត់ទុក ក៏ជាកម្មបថ អាចឱ្យផលបដិសន្ធិក្នុងអបាយភូមិ បើមានចេតនាបៀតបៀនប្រទូសរ៉ាយ មិនគ្រប់អង្គ ក៏ជា ទុច្ចរិតកម្មឱ្យផលក្នុងបវត្តិកាល ។

បើមានចេតនាបៀតបៀនអ្នកដទៃ ឱ្យមានទុក្ខក្តៅ ក្រហាយ តែធ្វើដោយលោភៈ ទោសៈ និងមោហៈ ក៏ជា កាយទ្វារ និងវចីទ្វាររបស់អកុសលចិត្ត មិនមែនអកុសល កម្ម ។ ដូចការនិយាយទំនាក់ទំនងគ្នា ការដើរទៅមក ធ្វើកិច្ច ការផ្សេង ៗ បើខណៈនោះ ចិត្តមិនមែនកុសល ការ

កម្រើកចរចានោះ ៗ ក៏ត្រឹមតែជាកាយទ្វារ វចីទ្វាររបស់អកុសលចិត្ត មិនមែនអកុសលកម្ម ព្រោះមិនប្រាថ្នាឱ្យអ្នកដទៃមានទុក្ខក្តៅក្រហាយ ។

ការដែលនឹងដឹងថា កម្មណាជាកាយកម្ម វចីកម្ម មនោកម្ម ក៏ត្រូវពិចារណាថា អកុសលកម្មដែលកើតឡើងនោះ ព្រោះអភិជ្ឈា ព្យាបាទៈ មិច្ឆាទិដ្ឋិ មែនឬទេ, បើមែនជាមនោកម្ម, បើមិនមែន ក៏ជាកាយកម្ម ឬវចីកម្ម មិនមែនជាមនោកម្ម, ចំណែកចេតនាក្នុងមនោកម្មនោះ សូម្បីធ្វើដោយកាយទ្វារ វចីទ្វារ ក៏មិនឈ្មោះថា កាយកម្ម ឬវចីកម្មទេ ព្រោះចេតនាក្នុងមនោកម្មនោះ មានអភិជ្ឈា ព្យាបាទៈ មិច្ឆាទិដ្ឋិជាប្រធាន ។

ចំណែកចេតនាក្នុងកាយកម្មនិងវចីកម្ម មិនមែនមនោកម្ម ព្រោះចេតនាដែលឱ្យសម្រេចជាកាយកម្ម និងវចីកម្មនោះ មានចេតនាប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវវាចា

ជាប្រធាន មិនមែនមនោកម្មក្នុងអភិជ្ឈា ព្យាបាទៈ មិច្ឆាទិដ្ឋិ ជាប្រធាន ។

មនោកម្ម ៣ កើតបានទ្វារ ៣ គឺ កាយទ្វារ វចីទ្វារ មនោទ្វារ

វចីកម្ម ៤ កើតបានទ្វារ ២ កាយទ្វារ និងវចីទ្វារ

កាយកម្ម ២ គឺ បាណាតិបាត និងអទិន្នាទាន កើតបានទ្វារ ២ កាយទ្វារ និងវចីទ្វារ

កាយកម្ម ១ គឺ កាមេសុមិច្ឆាចារ កើតបានទ្វារ ១ គឺ កាយទ្វារ

សេចក្ដីជ្រាលជ្រៅរបស់កម្ម មានច្រើនប្រការ ព្រោះកម្មដែលធ្វើនោះៗ ផ្សេងគ្នាដោយកម្ម ដោយទ្វារ ដោយចេតនា ដោយវត្ថុ ដោយកិលេស ដោយសេចក្ដីព្យាយាម និងដោយទោសដែលធ្ងន់ខ្លះ ស្រាលខ្លះ តាមកម្លាំងរបស់កម្ម

ដូចមានសម្ដែងទុកក្នុងអង្គុត្តរនិកាយ[១]ដូច្នេះ ៖

១. វិបាកធ្ងន់របស់បាណាតិបាត ធ្វើឱ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតជាមនុស្ស ធ្វើឱ្យមានអាយុខ្លី ។

២. វិបាកធ្ងន់របស់អទិន្នាទាន ធ្វើឱ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតជាមនុស្ស ធ្វើឱ្យវិនាសភោគ ។

៣. វិបាកធ្ងន់របស់កាមេសុមិច្ឆាចារ ធ្វើឱ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតជាមនុស្សធ្វើឱ្យមានសត្រូវនិងពៀរ ។

៤. វិបាកធ្ងន់របស់មុសាវាទ ធ្វើឱ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតជាមនុស្ស ត្រូវគេពោលកុហក មួលបង្កាច់ បង្ខូចឈ្មោះ ដោយ

---

១. អង្គុ. អដ្ឋ. ទានវគ្គ. ៤៨. ៤០/១៨០ ។

ពាក្យមិនពិត ។

៥. វិបាកធ្ងន់របស់បិសុណាវាចា ធ្វើឱ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតជាមនុស្ស រមែងធ្វើឱ្យបែកមិត្រ ។

៦. វិបាកធ្ងន់របស់ផរុសវាទ ធ្វើឱ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតជាមនុស្ស ធ្វើឱ្យបាននូវសំឡេង មិនជាទីគាប់ចិត្ត ។

៧. វិបាកធ្ងន់របស់សម្ផប្បលាបវាចា ធ្វើឱ្យកើតក្នុងអបាយភូមិ វិបាកស្រាលបំផុត កាលកើតជាមនុស្សធ្វើឱ្យមានពាក្យមិនគួរកាន់យក ។

៨. វិបាកធ្ងន់និងស្រាលរបស់អភិជ្ឈា ដូចអទិន្នាទាន ។

**អភិជ្ឈានេះ** រមែងតាមជុត( រាគគ្គិ )

<u>អដ្ឋកថា សង្គីតិសូត្រ</u> ពោលក្នុងករណីនេះថា ៖

នាងភិក្ខុនីមួយរូប ទៅកាន់រោងឧបោសថនៃវិហារឈ្មោះ

**ចិត្តលតាបពិត** ឈរមើលរូបរាងរបស់បុរសដែលរក្សាទ្វារ ហើយរាគៈក៏កើតឡើងខាងក្នុងចិត្តរបស់នាង, នាងត្រូវរាគៈនោះឯង ដុតដរាបដល់ស្លាប់ នៅក្នុងពេលដែលឈរនោះឯង ពួកភិក្ខុនី កាលត្រឡប់មកទើបពោលថា "ភិក្ខុនីនេះឈរនៅទីនោះឯង ទៅហៅនាងមក", ភិក្ខុនីមួយរូបបានទៅចាប់ដៃ ដោយនិយាយថា "ឈរនៅទីនេះធ្វើអ្វី" ល្មមចាប់ត្រូវដៃប៉ុណ្ណោះ រាងកាយនាងភិក្ខុនី( ស្លាប់ )នោះ ក៏ដួលចុះទៅ ។

៩. វិបាកធ្ងន់-ស្រាល របស់ព្យាបាទ ដូចគ្នានឹងផរុសវាចា ។

<u>**ក្នុងអដ្ឋកថាសង្គីតិសូត្រ**</u> ពោលថា ៖

ពួកទេវតាមនោបទោសិកា គឺ អ្នកប្រទូស្តដោយចិត្តក្រោធរបស់ខ្លួនឯង ទេវតាប្រភេទនេះ កាលក្រោធកើតឡើងហើយក៏ចុតិ ដោយអំណាចសេចក្តីក្រោធនោះ( ទោសគ្គិ ) ។

១០. វិបាកធ្ងន់-ស្រាលរបស់មិច្ឆាទិដ្ឋិ បើសេពមកច្រើន ដរាបដល់ខ្លាំងក្លា ក៏កើតក្នុងលោកន្តរនរក បើសេពតិច ក៏ធ្វើឱ្យកើតក្នុងអបាយភូមិ ។

សេចក្តីល្អិតល្អន់ និងការឱ្យផលរបស់កម្មនោះ អ្នកណា ៗ រមែងមិនអាចជ្រាបបានច្បាស់ ដូចព្រះមានព្រះភាគជាសព្វញ្ញូ ព្រោះដូច្នោះ ទើបមនុស្សខ្លះយល់ខុស គិតថាការធ្វើកម្មអាក្រក់បានទទួលផលល្អ ឬការធ្វើល្អបានទទួលផលអាក្រក់ ។ សេចក្តីពិត ការធ្វើល្អ ឬធ្វើអាក្រក់នោះ កាលបានឱកាស និងបច្ច័យរមែងឱ្យផល មិនមានអ្នកណាគេចផុតពីផលរបស់កម្មល្អ និងអាក្រក់បានឡើយ ។

**អកុសលកម្មបថ ចប់**

## ពាក្យនិគម

**ឥច្ចេវំ សព្វថាបិ ទ្វាទស អកុសលចិត្តានិ សមត្តានិ**

: អកុសលចិត្ត ១២ ចប់បរិបូណ៌ ដោយប្រការទាំងពួង ត្រឹមប៉ុណ្ណេះ ។

ពាក្យនិគម គឺ ពាក្យចុងក្រោយ បញ្ចប់អកុសលចិត្ត ១២ ថា ចប់ហើយដោយប្រការដូច្នេះ ។

ពាក្យថា **ដោយប្រការទាំងពួង** ក្នុងពាក្យនិគមនេះ មានសេចក្តីថា អកុសលចិត្ត ១២ នេះ កាលចែកដោយន័យផ្សេង ៗ បានដូច្នេះ គឺ ៖

-**ដោយវេទនាន័យ** បានវេទនា ៣ គឺ សោមនស្សវេទនា១ ទោមនស្សវេទនា១ ឧបេក្ខាវេទនា១

-**ដោយយោគាយោគន័យ** (ប្រកបនិងមិនប្រកប)មាន ៥ គឺ ទិដ្ឋិសម្បយុត្ត១ ទិដ្ឋិវិប្បយុត្ត១ បដិឃសម្បយុត្ត១ វិចិកិច្ឆាសម្បយុត្ត១ ឧទ្ធច្ចសម្បយុត្ត១

**-ដោយមូលន័យ** មាន ៣ គឺ លោភមូល ១ ទោសមូល ១ មោហមូល ១

**-ដោយជាតិន័យ** ជាអកុសលជាតិទាំង ១២

**-ដោយលក្ខណៈ** អកុសលចិត្ត ១២ មានលក្ខណៈតែមួយ គឺ មានការដឹងអារម្មណ៍ ជាលក្ខណៈ **"អារម្មណវិជាននលក្ខណំ"**

កាលប្រមូល គឺរួបរួមអកុសលចិត្តដែលមានទាំងអស់ ដោយន័យផ្សេង ៗហើយ ក៏មានត្រឹមតែ ១២ ប៉ុណ្ណោះ ។

## សរុបអកុសលចិត្ត ១២

- អកុសលចិត្ត ១២
  - លោភមូលចិត្ត ៨
    - សោមនស្ស
      - ទិដ្ឋិគតសម្បយុត្ត
        - អសង្ខារិក១
        - សសង្ខារិក១
      - ទិដ្ឋិគតវិប្បយុត្ត
        - អសង្ខារិក១
        - សសង្ខារិក១
    - ឧបេក្ខា
      - ទិដ្ឋិគតសម្បយុត្ត
        - អសង្ខារិក១
        - សសង្ខារិក១
      - ទិដ្ឋិគតវិប្បយុត្ត
        - អសង្ខារិក១
        - សសង្ខារិក១
  - ទោសមូលចិត្ត ២
    - ទោមនស្ស បដិឃសម្បយុត្ត
      - អសង្ខារិក១
      - សសង្ខារិក១
  - មោហមូលចិត្ត ២
    - ឧបេក្ខា
      - វិចិកិច្ឆាសម្បយុត្ត អសង្ខារិក ១
      - ឧទ្ធច្ចសម្បយុត្ត អសង្ខារិក ១

## ចប់ អកុសលចិត្ត ១២

# សំនួរ-ចម្លើយ ក្នុងគាថាបករណ៍

១- បណាមគាថា ក្នុងអភិធម្មត្ថសង្គហបាលី និងប្រែ ពោលទុកយ៉ាងណា ?

\+ បណាមគាថា (គាថានមស្សការ)ថា ៖

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

នមោ តស្សារហន្តស្ស ភគវន្តស្ស សត្ថុនោ
សម្មាសម្ពុទ្ធស្ស មាយត្ថោ លោកជេដ្ឋស្ស តាទិនោ

ខ្ញុំព្រះអង្គសូមនមស្សការ ចំពោះព្រះដ៏មានព្រះ
ភាគអរហន្តសម្មាសម្ពុទ្ធ ជាបរមសាស្តាដ៏ប្រសើរ
បំផុតក្នុងលោក អង្គនោះ ។

២- ចូរសម្តែងបឋមគាថា ព្រមដោយពាក្យប្រែ

\+ បឋមគាថា(គាថាទី១) ព្រមដោយពាក្យប្រែ

សម្មាសម្ពុទ្ធមតុលំ សសទ្ធម្មគណុត្តមំ
អភិវាទិយ ភាសិស្សំ អភិធម្មត្ថសង្គហំ ។

ខ្ញុំសូមអភិវាទព្រះសម្មាសម្ពុទ្ធ ទ្រង់រកបុគ្គល
ប្រៀបមិនបាន ព្រមទាំងព្រះសទ្ធម្ម និងពួក

នៃអរិយសង្ឃដ៏ឧត្តម, ហើយទើងពោល

បករណ៍ ឈ្មោះថា អភិធម្មត្ថសង្គហៈ ។

៣- ព្រះអនុរុទ្ធពោលថា "អតុលំ" ប្រសើរមិនមានអ្នកណាប្រៀបស្មើ តើព្រះដ៏មានព្រះភាគ ទ្រង់មានគុណដ៏ប្រសើរយ៉ាងណា ? សូមពន្យល់

\+ ព្រះដ៏មានព្រះភាគ ទ្រង់មានគុណដ៏ប្រសើរមិនមានអ្នកណា ប្រៀបផ្ទឹម ព្រោះទ្រង់ដល់ព្រមដោយសម្បទា ៣ គឺ

ហេតុសម្បទា១ ផលសម្បទា១ សត្តូបការសម្បទា១

បណ្តាសម្បទាទាំង ៣ នេះ ការដែលព្រះអង្គទ្រង់ប្រកបដោយព្រះមហាករុណា និងដែលទ្រង់បានអប់រំព្រះពោធិសម្ភារៈបរិបូណ៌ ឈ្មោះថា ហេតុសម្បទា ។

ផលសម្បទា បែកជា ៤ ប្រភេទ គឺ

១. ញាណសម្បទា បានដល់ មគ្គញ្ញាណ ដែលជាទីប្រតិស្ឋាននៃព្រះសព្វញ្ញុតញ្ញាណ និងទសពលញ្ញាណជាដើម

២. បហានសម្បទា បានដល់ ការប្រហារកិលេសទាំងអស់

ព្រមទាំងវាសនាបានដោយអស់រលីង

៣. អានុភាវសម្បទា បានដល់ ការប្រកបព្រមដោយភាពធំក្រៃលែង ក្នុងការឱ្យសម្រេចកិច្ចបានតាមដែលទ្រង់ប្រាថ្នា

៤- រូបកាយសម្បទា បានដល់ ការដល់ព្រមដោយរូបសម្បត្តិ ដែលប្រកបដោយមហាបុរិសៈ ៣២ ប្រការ និងអនុព្យញ្ជន ៨០ ដែលគួររីករាយសប្បាយចិត្ត តាមផ្លូវភ្នែករបស់សត្វលោកទាំងពួង ។

សត្តូបការសម្បទា មាន ២ គឺ

-**អាសយសម្បទា** ទ្រង់ដល់ព្រមដោយព្រះអធ្យាស្រ័យ

-**បយោគសម្បទា** ទ្រង់ដល់ព្រមដោយព្រះឧស្សាហៈ

ពិតមែន ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះអធ្យាស្រ័យអនុគ្រោះដល់សព្វសត្វជានិច្ច ដោយមិនរើសមុខ សូម្បីក្នុងពួកសត្វដែលប្រព្រឹត្តខុស ប្រទូសរ៉ាយចំពោះព្រះអង្គ ដូចភិក្ខុទេវទត្តជាដើម និងការរង់ចាំវេលាចាស់ក្លានៃបញ្ញារបស់សត្វដែលនៅមិនទាន់ចាស់ក្លា ដើម្បីទ្រង់អនុគ្រោះ គឺទ្រង់ជួយ

នេះឈ្មោះថា **អាសយសម្បទា** ។

**បយោគសម្បទា** គឺ ការដល់ព្រមដោយព្រះឧស្សាហៈ ដើម្បីនាំសត្វទាំងឡាយ ឱ្យចេញចាកវដ្តសង្សារ មិនមានព្រះទ័យរារែកទេ សូម្បីវេនេយ្យសត្វនោះ នៅឆ្ងាយសែនឆ្ងាយ ក៏យាងទៅប្រោស ទ្រង់មិនបានប្រាថ្នាលាភ សក្ការៈឡើយ ។

ព្រះដ៏មានព្រះភាគទ្រទ្រង់ព្រះគុណដ៏ប្រសើរ ដោយសម្បទាដូចពោលមកនេះ ទើបបណ្ឌិតឱ្យឈ្មោះថា **សម្មាសម្ពុទ្ធមតុលំ** គឺព្រះសម្មាសម្ពុទ្ធទ្រង់មិនមានអ្នកណា ប្រៀបបានឡើយ ។

៤- ការនមស្សការព្រះរតនត្រ័យ មុននឹងធ្វើកិច្ចការដែលសំខាន់ មានប្រយោជន៍យ៉ាងណា ? ក្នុងគាថាទី ១ នេះ ព្រះអនុរុទ្ធ ពោលពាក្យប្តេជ្ញា និងពាក្យនមស្សការ ព្រះរតនត្រ័យថា យ៉ាងណា ?

+ ធម្មតាអ្នកមានបញ្ញា នឹងធ្វើកិច្ចការដែលសំខាន់ រមែងនមស្សការចំពោះវត្ថុ ដែលខ្ពង់ខ្ពស់ ដើម្បីឱ្យ(បានបុណ្យ បុណ្យក៏ធ្វើ) ការឃុំគ្រងរក្សា ដូចព្រះអនុរុទ្ធាចារ្យរចនា

គម្ពីរព្រះអភិធម្មត្ថសង្គហៈនេះ លោកពោលពាក្យនមស្ការព្រះរតនត្រ័យ ដើម្បីឱ្យកើតសិរីមង្គល ក្នុងការធ្វើកិច្ចដែលតាំងចិត្តទុកនោះ ឱ្យសម្រេច ប្រាសចាកអន្តរាយ ក្នុងគាថាទី ១ នេះ លោកពោលពាក្យប្ដេជ្ញា ដោយពាក្យថា "**ភាសិស្សំ អភិធម្មត្ថសង្គហំ**" ពោលនមស្ការព្រះរតនត្រ័យ ដោយពាក្យថា "**សម្មាសម្ពុទ្ធមតុលំ សសទ្ធម្មគណុត្តមំ អភិវាទិយ**" ដូច្នេះ

៥- ព្រះសទ្ធម្ម គឺ ធម៌អ្វី មានអ្វីខ្លះ ?

\+ ព្រះសទ្ធម្ម គឺ ធម៌របស់សប្បុរស មាន ៣ យ៉ាង

១. **បរិយត្តិសទ្ធម្ម** បានដល់ ព្រះពុទ្ធវចនៈ ដែលគួររៀនសូត្រ

២. **បដិបត្តិសទ្ធម្ម** បានដល់ ការរក្សាសីល កាន់ធុតង្គ ចម្រើនកម្មដ្ឋាន

៣. **បដិវេធសទ្ធម្ម** បានដល់ ការសម្រេចមគ្គ ផល និព្វាន ឈាន អភិញ្ញា

៦- បរមត្ថធម៌ សំដៅដល់ ធម៌អ្វី ?

\+ បរមត្ថធម៌ សំដៅដល់ សភាវៈរបស់នាមនិងរូប

ដែលមិនវិបរិត មាន៤ គឺ ចិត្ត ចេតសិក រូប និព្វាន

៧- ចិត្ត និងបរមត្ថធម៌ ៤ ផ្សេងគ្នា ឬដូចគ្នា ?

\+ ចិត្តជាបរមត្ថធម៌មួយប្រភេទ ក្នុងបណ្តាបរមត្ថធម៌ ៤ ហៅថា ចិត្តបរមត្ថ, ចំណែកពាក្យថា បរមត្ថ ៤ នោះ សំដៅយកបរមត្ថទាំងអស់ គឺ ចិត្ត ចេតសិក រូប និព្វាន ។

៨- បរមត្ថ៤ មានលក្ខណៈ យ៉ាងណា ? ចូរអធិប្បាយ

\+ បរមត្ថ ៤ មានលក្ខណៈដូច្នេះ

លក្ខណៈរបស់**ចិត្ត** គឺ **អារម្មណវិជានេនលក្ខណំ** មានការដឹងអារម្មណ៍ ជាលក្ខណៈ សេចក្តីថា ចិត្តនេះតែងទទួលអារម្មណ៍ជានិច្ច វៀរចាកអារម្មណ៍ ចិត្តក៏មិនកើតឡើង ។

មានវចនត្ថៈថា **អារម្មណំ ចិន្តេតីតិ = ចិត្តំ** ឈ្មោះថាចិត្ត ព្រោះអត្ថថា រមែងគិត គឺ ទទួលដឹងអារម្មណ៍ ។

លក្ខណៈរបស់**ចេតសិក** គឺ **ចិត្តនិស្សិតលក្ខណំ** មានការអាស្រ័យចិត្តកើត ជាលក្ខណៈ គឺ ចេតសិកទាំងអស់ ត្រូវអាស្រ័យចិត្ត ទើបកើតឡើង បើមិនមានចិត្ត ក៏កើតមិនបាន ។

មានវចនត្ថៈថា **ចេតសិ ភវំ = ចេតសិកំ** ធម្មជាតិដែលកើតក្នុងចិត្ត ឈ្មោះថា ចេតសិក **ចេតសិ និយុត្តំ = ចេតសិកំ** ធម៌ដែលប្រកបជាមួយចិត្តជានិច្ច ឈ្មោះថា ចេតសិក ។

លក្ខណៈរបស់**រូប** គឺ **រុប្បនលក្ខណំ** មានការប្រែប្រួលទៅ ជាលក្ខណៈ

មានវចនត្ថៈថា **សីតុណ្ហាទិវិរោធិបច្ចយេហិ រុប្បតីតិ = រូបំ** ធម្មជាតិណា រមែងប្រែប្រួល បែកធ្លាយ រលាយទៅព្រោះបច្ច័យដែលជាសត្រូវ មានត្រជាក់ និងក្តៅជាដើម ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា រូប ។

លក្ខណៈរបស់**និព្វាន** គឺ **សន្តិលក្ខណំ** មានសេចក្តីស្ងប់ជាលក្ខណៈ

ព្រះនិព្វានជាធម៌មានដោយពិត តែជាខន្ធវិមុត្ត គឺ ផុតបាកសភាពជាខន្ធ ។

៩- ព្រោះហេតុអ្វី ទើបសម្តែងចិត្តទុក ៤ ប្រភេទ ?

\+ ព្រោះភូមិរបស់ចិត្តផ្សេងគ្នា ៤ ប្រភេទ គឺ

១.កាមាវចរចិត្ត ចិត្តត្រាច់ក្នុងកាម ជាចិត្តជាន់ទាប ហៅថា **ហីនចិត្ត**, ២.រូបាវចរចិត្ត ចិត្តត្រាច់ទៅក្នុងរូបឈាន ជាចិត្តប្រសើរ ហៅថា **ឧក្កដ្ឋចិត្ត**, ៣.អរូបាវចរចិត្ត ចិត្តប្រសើរជាងរូបាវចរចិត្ត ហៅថា **ឧក្កដ្ឋតរចិត្ត**, ៤.លោកុត្តរចិត្ត ចិត្តប្រសើរបំផុត ហៅថា **ឧក្កដ្ឋតមចិត្ត** ។

១០- ចិត្ត ៤ប្រភេទ មានព្រះបាលីពោលទុកយ៉ាងណា ?

+ មានបាលីថា **តត្ថ ចិត្តំ តាវ ចតុព្វិធំ ហោតិ កាមាវចរំ រូបាវចរំ អរូបាវចរំ លោកុត្តរញ្ចេតិ** បណ្ដាអត្ថនៃព្រះអភិធម្ម ៤ នេះ ចិត្តជាលំដាប់ដំបូង មាន៤ គឺ

១. កាមាវចរំ ចិត្តដែលត្រាច់ទៅក្នុងកាម

២. រូបាវចរំ ចិត្តដែលត្រាច់ទៅក្នុងរូបឈាន

៣. អរូបាវចរំ ចិត្តដែលត្រាច់ទៅក្នុងអរូបឈាន

៤. លោកុត្តរំ លោកុត្តរចិត្ត គឺ មគ្គ៤ ផល៤

១១- សព្ទមានប្រភេទដូចគ្នានឹងចិត្ត ដែលហៅថាវេវចនៈ គឺ ពាក្យមានរូបសព្ទផ្សេងគ្នា តែអត្ថដូចគ្នា មានប៉ុន្មាន អ្វីខ្លះ ?

+ សព្ទ មានប្រភេទដូចគ្នានឹងចិត្ត ដែលហៅថា វេវចនៈរបស់ចិត្ត មាន ១០ ឈ្មោះ ក្នុងបាលីមហាវគ្គពោលទុកថា ៖

"យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ ចិត្តំ"

ចិត្ត មនោ មានសៈ ហទយៈ បណ្ឌរៈ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ សព្ទទាំងនេះ ជាឈ្មោះរបស់ចិត្ត ។

១២- ដែលឈ្មោះថា ចិត្ត ព្រោះអត្ថថា វិចិត្រ សំដៅសេចក្តីយ៉ាងណា ?

+ ដែលឈ្មោះថា ចិត្ត ព្រោះអត្ថថា វិចិត្រ មានសេចក្តីថា ចិត្តនោះ អាចធ្វើវត្ថុផ្សេង ៗឱ្យល្អស្អាតបាន ដោយប្រការផ្សេង ៗ ដូចវិចិត្រករ អាចគូររូបភាពល្អស្អាតបានជាដើម និង

ចិត្តនោះឯង អាចធ្វើកិរិយា អាការគួរមើល គួរសរសើរ ជាដើម ក៏បាន ព្រោះពាក្យថា វិចិត្រ សំដៅដល់អាការផ្សេង ៗ ( ពាក្យថា វិចិត្រ មកពីស័ព្ទថា **វិ** + **ចិត** ធាតុ ចុះ **ត្រ** បច្ច័យ លុបទីបំផុត គឺ **ត** ( នៃចិត ) សម្រេចរូបជា **វិចិត្រ** ។

ដូចមានវចនត្ថៈថា **វិចិន្តិ តព្វន្តិ** = **វិចិត្រំ នានាការំ** ដែលឈ្មោះថា វិចិត្រ ព្រោះចេតនា មានប្រការផ្សេង ៗ គឺ មានអាការច្រើនយ៉ាង ។

## សំនួរ-ចម្លើយក្នុងអកុសលចិត្ត១២

១៣- អកុសលចិត្ត សំដៅសេចក្តីយ៉ាងណា ?

\+ អកុសលចិត្ត សំដៅដល់ ចិត្តដែលមានទោស និងឱ្យផល ផ្ទុយគ្នាពីកុសលចិត្ត មាន ៣ គឺ ១. លោភមូលចិត្ត៨ ២. ទោសមូលចិត្ត ២ ៣. មោហមូលចិត្ត ២ ។

១៤- លោភៈ និងលោភមូលចិត្ត ផ្សេងគ្នាយ៉ាងណា ?

+ លោភៈ ជាចេតសិក ចំណែកលោភមូលចិត្ត ជាចិត្តដែលមានលោភជាមូល ។

១៥- លោភមូលចិត្ត ប្រកបដោយហេតុអ្វីខ្លះ ?

+ លោភមូលចិត្ត ប្រកបដោយហេតុ ២ គឺ លោភហេតុ និងមោហហេតុ ។

១៦- ទោសមូលចិត្ត ផ្សេងពីលោភមូលចិត្តយ៉ាងណា ?

+ ទោសមូលចិត្ត ជាចិត្តដែលមិនពេញចិត្តក្នុងអារម្មណ៍ ចំណែកលោភមូលចិត្ត ជាចិត្តដែលពេញចិត្តក្នុងអារម្មណ៍ ។

១៧- លោភៈ ទោសៈ មោហៈ ជាចេតសិកប្រភេទណា ?

+ លោភៈ ទោសៈ មោហៈ ជាប្រភេទអកុសលចេតសិក

១៨- អកុសលកម្ម ដែលធ្វើដោយលោភមូលចិត្ត ស្លាប់ហើយ ទៅកើតទីណា ?

+ អកុសលកម្ម ដែលធ្វើដោយលោភមូលចិត្តនោះ ស្លាប់ហើយ ទៅកើតក្នុងអបាយភូមិ ( គឺកំណើតប្រេត ) ។

<u>ក្នុងអដ្ឋសាលិនី</u> ពោលថា ៖

យេភុយ្យេន ហិ សត្តា លោភេន បេត្តិវិសយំ ឧបជ្ជន្តិ ពិតមែន ដោយច្រើន សត្វទាំងឡាយ រមែងចូលដល់បេត្តិវិស័យ (គឺកំណើតប្រេត) ព្រោះលោភៈ ជាហេតុ ។

១៩-បើទោសមូលចិត្តកើតមុនស្លាប់ នឹងទៅកើតក្នុងទីណា ?

\+ បើក្រោធហើយស្លាប់ ទោសមូលចិត្តនោះ ជាបច្ច័យឱ្យអកុសលវិបាក កើតក្នុងនិរយភូមិ ដូចព្រះបាលីថា ៖

ទោសេន ហិ ចណ្ឌជាតតាយ ទោសសទិសំ និរយំ ឧបបជ្ជន្តិ ពិតមែន ព្រោះទោសជាហេតុ សត្វទាំងឡាយ ទើបចូលដល់នរក ដែលមានជាតិកាចសាហាវ ដូចគ្នានឹងទោសៈ ។

២០- បើមោហមូលចិត្តកើតមុនស្លាប់ នឹងទៅកើតក្នុងទីណា ?

\+ មោហមូលចិត្ត មាន ២ គឺ មោហមូលចិត្ត ដែល

ប្រកបដោយវិចិកិច្ឆា មោហមូលចិត្ត ដែលប្រកបដោយឧទ្ធច្ចៈ មោហមូលចិត្ត ដែលប្រកបដោយឧទ្ធច្ចៈ មិនជាបច្ច័យ ឱ្យបដិសន្ធិកើត ចំណែកចិត្ត ដែលប្រកបដោយសេចក្ដីសង្ស័យ ៨ មានសេចក្ដីសង្ស័យ ក្នុងព្រះពុទ្ធជាដើម ជានីវរណៈ ស្លាប់ហើយ រមែងកើតជាសត្វតិរច្ឆាន ព្រោះព្រះបាលីថា ៖

មោហេន ហិ និច្ចំ សម្មុឡ្ហំ តិរច្ឆានយោនិយំ ឧប្បជ្ជន្តិ ពិតមែន ព្រោះមោហៈជាហេតុ សត្វទាំងឡាយទើបចូលដល់កំណើតសត្វតិរច្ឆាន ដែលមានសេចក្ដីវង្វេងជានិច្ច ។

២១- ពាក្យថា "ទិដ្ឋិ" (គឺទិដ្ឋិគតសម្បយុត្តំ) ក្នុងលោភមូលចិត្ត៤ និងពាក្យថា "មិច្ឆាទិដ្ឋិ" ក្នុងអកុសលកម្មបថ ដូចគ្នា ឬផ្សេងគ្នាយ៉ាងណា ?

+ ទិដ្ឋិ តាមដែលពោលមកផ្សេងគ្នា គឺ ទិដ្ឋិដែលនៅក្នុងលោភមូលចិត្តនោះ សំដៅយកសេចក្ដីយល់ខុសទាំងអស់ គឺ

សក្កាយទិដ្ឋិ សីលព្វតទិដ្ឋិ និយតមិច្ឆាទិដ្ឋិ, ចំណែកមិច្ឆាទិដ្ឋិក្នុងអកុសលកម្មបថនោះ ប្រាថ្នាយកនិយតមិច្ឆាទិដ្ឋិ៣ គឺ អកិរិយទិដ្ឋិ អហេតុកទិដ្ឋិ និងនត្ថិកទិដ្ឋិ ។

និយតមិច្ឆាទិដ្ឋិ ៣ មានអង្គ ២ គឺ

១. **វត្ថុនោ ច គហិតាការវិបរីតតា** ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម

២. **យថា ច តំ គណ្ហាតិ តថាភាវេន តស្សុបដ្ឋានំ** គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្ដីខុសនោះថា ជាត្រូវវិញ

គ្រប់អង្គ ២ នេះ ជាកម្មបថ បើមិនគ្រប់អង្គ ២ មិនជាច់កម្មបថ ។

**ក្នុងអដ្ឋសាលិនី** លោកពោលថា ៖

"**តត្ថ នត្ថិកាហេតុកអកិរិយទិដ្ឋីហិយេវ កម្មបថភេទោ ន ហោតិ នអញ្ញទិដ្ឋីហិ** បណ្ដាមិច្ឆាទិដ្ឋិទាំងនោះ កម្មបថ រមែងបែកធ្លាយព្រោះនត្ថិកទិដ្ឋិ អហេតុកទិដ្ឋិ អកិរិយទិដ្ឋិប៉ុណ្ណោះ មិច្ឆាទិដ្ឋិ ដទៃរមែងមិនដល់ភាពជាកម្មបថ ។

២២-ការសម្លាប់ខ្លួនឯង តើឱ្យវិបាកកើតក្នុងអបាយភូមិឬទេ ?

+កម្មបថរបស់បុគ្គលសម្លាប់ខ្លួនឯងនោះ មិនគ្រប់អង្គ៥ ទេ មិនជាកម្មបថ មានអង្គ៥ គឺ

១ **បាណោ** សត្វមានជីវិត

២ **បាណសញ្ញិតា** ដឹងថា សត្វមានជីវិត

៣ **វធកចិត្តំ** មានចិត្តគិតនឹងសម្លាប់

៤ **ឧបក្កមោ** មានការព្យាយាមសម្លាប់

៥ **តេន មរណំ** សត្វស្លាប់ដោយសេចក្ដីព្យាយាមនោះ

ការសម្លាប់ខ្លួនឯង ទើបមិនគ្រប់អង្គកម្មបថ មិននាំឱ្យ

កើតក្នុងអបាយភូមិ ។

២៣- ទោសមូលចិត្ត មានក្នុងបុគ្គលទូទៅ ឬមិនទូទៅ ?

+ ទោសមូលចិត្ត (មិនកើតទូទៅទេ) កើតបានទូទៅតែបុថុជ្ជនដែលជាកាមបុគ្គល (និងអរិយបុគ្គល២ខាងក្រោមគឺសោតាបន្ន និងសកទាគាមី) វៀរព្រះអនាគាមី ព្រះអរហន្តព្រោះលះបានដោយសមុច្ឆេទ និងមិនកើតក្នុងសន្តានរបស់រូបបុគ្គល និងអរូបបុគ្គល លះទោសៈបានដោយវិក្ខម្ភនៈ ។

២៤- មោហមូលចិត្ត២នេះ ចិត្តណាមានទោសច្រើនជាង ?

+ មោហមូលចិត្ត ២ គឺ វិចិកិច្ឆាសម្បយុត្តចិត្ត និងឧទ្ធច្ចសម្បយុត្តចិត្តនេះ វិចិកិច្ឆាសម្បយុត្តចិត្ត មានទោសច្រើនជាង ព្រោះជាបច្ច័យឱ្យបដិសន្ធិបាន ចិត្តនេះ ក្រៅពីភាពល្ងង់ហើយ នៅមានការឆ្ងល់ សង្ស័យក្នុងវត្ថុប្រសើរ ដែលគួរបូជា ដែលខ្លួនមិនអាចដឹងដល់ ទំនងល្ងង់ខ្លៅក្រៃលែង ចំណែកឧទ្ធច្ចសម្បយុត្តចិត្ត មិនជាបច្ច័យឱ្យកើតអកុសលវិបាកបដិសន្ធិ

ត្រឹមតែជាសេចក្តីរវើរវាយ ចាប់អារម្មណ៍មិនមាំ ដូចអណ្តាតភ្លើងប្រទីប អុជនៅក្នុងទីមានខ្យល់បក់ ក៏មានអាការរង្គាករវេទាំងមិនបានប្រព្រឹត្តកន្លងចំពោះវត្ថុដទៃណា

២៥- វិចិកិច្ឆាសម្បយុត្តចិត្ត គឺ ចិត្តដែលប្រកបដោយវិចិកិច្ឆា ដែលជានីវរណៈ មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

+ វិចិកិច្ឆាសម្បយុត្តចិត្ត ដែលជានីវរណៈ មាន៨យ៉ាង គឺ

១. **ពុទ្ធេ កង្ខតិ** សង្ស័យក្នុងព្រះពុទ្ធ

២. **ធម្មេ កង្ខតិ** សង្ស័យក្នុងព្រះធម៌

៣. **សង្ឃេ កង្ខតិ** សង្ស័យក្នុងព្រះសង្ឃ

៤. **សិក្ខាយ កង្ខតិ** សង្ស័យក្នុងសិក្ខា

៥. **បុព្វន្តេ កង្ខតិ** សង្ស័យក្នុងខន្ធជាដើម ដែលជាអតីតសេចក្តីថា មិនធ្លាប់ដឹងមកឡើយថា ខ្លួនធ្លាប់កើតមកហើយ

៦. **អបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធជាដើមដែលជាអនាគតគឺមិនដឹងថា ខ្លួនត្រូវកើតក្នុងអនាគត ។

៧. **បុព្វន្តាបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ អាយតនៈ ធាតុដែល

ជាអតីត និងអនាគត សេចក្តីថា មិនដឹងថា ខ្លួនធ្លាប់កើតមកហើយ ក្នុងអតីត និងត្រូវកើតក្នុងអនាគតទៀត

៨. **បដិច្ចសមុប្បាទេ កង្ខតិ** សង្ស័យក្នុងបដិច្ចសមុប្បាទ គឺធម៌ដែលអាស្រ័យគ្នាកើតឡើង ។

ទាំង៨ នេះ មានពិតឬ ? ឬមិនមានទេដឹង ? ។

២៦_ សង្ស័យក្នុងព្រះពុទ្ធនោះ តើសង្ស័យយ៉ាងណា ?

\+ សង្ស័យក្នុងព្រះពុទ្ធនោះ គឺ សង្ស័យក្នុងសរីរៈនិងគុណរបស់ព្រះពុទ្ធ ។ សង្ស័យក្នុងសរីរៈ បានដល់ សង្ស័យថា (អត្តភាពជា)ព្រះពុទ្ធ មានពិតឬមិនមានទេហ្ន៎ ? ឬក៏ប្រហែលជាសម្មតិឡើងប៉ុណ្ណោះទេ និងសង្ស័យ ក្នុងព្រះគុណទាំង១០បទ មានពាក្យថា អរហំ ជាដើមនោះ ក៏ប្រហែលជាមិនមានដូចគ្នា ឬក៏មានហ្ន៎ ?

២៧_ សេចក្តីសង្ស័យក្រៅអំពី ៨ យ៉ាង ជានីវរណៈនេះក៏មានដែរ ហេតុអ្វីបានជាមិនមែនវិចិកិច្ឆា តើនឹងជាអ្វីទៅវិញ ?

\+ ការសង្ស័យ៨ យ៉ាងជានីវរណៈ ឯសេចក្តីសង្ស័យក្រៅពី

នេះ មិនមែនវិចិកិច្ឆានីវរណៈ លោកហៅថា បដិរូបកវិចិកិច្ឆា ។

២៨- បដិរូបកវិចិកិច្ឆានោះ មិនមែនវិចិកិច្ឆានីវរណៈទេ តើជាចិត្តអ្វី ?

\+ បដិរូបកវិចិកិច្ឆានោះ មិនប្រាកដថា ជាចិត្តណាទេ គឺថា បើសេចក្តីសង្ស័យ ជាប់ទាក់ទងដោយលោភៈ ឬទោសៈ ចិត្តនោះ ក៏ជាលោភមូលចិត្ត ឬទោសមូលចិត្ត ។

២៩- ការចែកអកុសលចិត្ត ១២ ដោយន័យផ្សេង ៗ មានជាតិន័យជាដើម តើយ៉ាងណា ?

\+ ចែកអកុសលចិត្ត ១២ ដោយន័យផ្សេង ៗ គឺ

១. ដោយជាតិ ជាអកុសលជាតិ

២. ដោយភូមិ ជាកាមាវចរភូមិ

៣. ដោយវេទនា ជាសោមនស្សវេទនា ៤
ជាទោមនស្សវេទនា ២
ជាឧបេក្ខាវេទនា ៦

៤. ដោយហេតុ ជានហេតុ និងជាសហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាសម្បយុត្ត ៨ ជាវិប្បយុត្ត ៤

៦. ដោយសង្ខារ ជាអសង្ខារិក ៧ ជាសសង្ខារិក៥

៧. ដោយសោភណៈ ជាអសោភណចិត្ត

៨. ដោយឈាន ជាអកុសលឈាន

៩. ដោយលោកៈ ជាលោកិយចិត្ត

១០. ដោយកិច្ច ជាជវនកិច្ច

១១. ដោយអារម្មណ៍ មានអារម្មណ៍ ៦

១២. ដោយទ្វារ ជាចិត្តកើតបានទ្វារ៦

១៣. ដោយវត្ថុ កើតត្រង់ហទយវត្ថុ

១៤. ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ

៣០- សួរថា អកុសលចិត្ត ជាចិត្តអាក្រក់ មានទោស ឱ្យផលជាទុក្ខ ជាបច្ច័យឱ្យកើតក្នុងអបាយភូមិបាន ហេតុអ្វី បានជាយកមករៀន បើរៀនត្រឹមតែចិត្តដែលល្អ មានសោមនស្ស ឱ្យផលជាសុខតែម្យ៉ាង មិនបានឬ ? ឬមានការយល់យ៉ាងណា ?

+ ពិតមែន អកុសលចិត្ត ជាចិត្តអាក្រក់ មានទោស ឱ្យផលជាទុក្ខ ជាបច្ច័យឱ្យកើតក្នុងអបាយភូមិ កាលជាដូច្នេះ ទើបសមគួរត្រូវយកមករៀន ដើម្បីរកផ្លូវកំចាត់ជុសខាត់ ឬ

ធ្វើឱ្យស្រោលចុះ បើមិនសិក្សាឱ្យយល់ដឹងទេ ក៏មិនមានផ្លូវអាចទំលាយកិលេស ដែលធ្វើចិត្តឱ្យសៅហ្មង អ្នកឃើញទុក្ខមិនចង់ឱ្យមានទុក្ខ ក៏ត្រូវនាំគ្នាព្យាយាម សិក្សារៀនសូត្រឱ្យយល់ចូលចិត្ត; មួយទៀត អកុសលចិត្ត ៣ ប្រភេទនេះ លោភមូលចិត្ត៨ ជាចិត្តត្រេកអរ ពេញចិត្ត ធ្វើចិត្តឱ្យជាប់នៅក្នុងអារម្មណ៍, ចំណែកទោសទាំង២ នោះសោត ក៏ជាចិត្តដែលជាទុក្ខ មិនពេញចិត្ត, ឯមោហមូលចិត្ត២ ជាចិត្តកើតអំពីមោហៈ គឺ អវិជ្ជា ក៏អវិជ្ជានេះ ទ្រង់ត្រាស់ថា "ជាសីសៈរបស់កិលេស" ជាប្រធានរបស់កិលេស ជាបច្ច័យនៃសង្សារវដ្តៈ ដកចេញបានដោយលំបាក បើមិនបានសិក្សារៀនសូត្រទេ មិនអាចដឹងថា ខ្លួនមានកិលេស មិនដឹងថាកិលេសកើតដោយសារអ្វី មិនដឹងថា ត្រូវបដិបត្តិយ៉ាងណាទើបលះកិលេស, ដូច្នេះ ទើបជាកិច្ចចាំបាច់ក្រៃលែង ដែលអ្នកមានបញ្ញាទាំងឡាយ ត្រូវសិក្សារៀនសូត្រ ។

ចប់ សំនួរ-ចម្លើយ

# អហេតុកចិត្ត ១៨

## សង្គហគាថា

៤. សត្តាកុសលបាកានិ បុញ្ញបាកានិ អដ្ឋធា
កិរិយាចិត្តានិ តីណីតិ អដ្ឋារស អហេតុកា ។

*អកុសលវិបាកចិត្ត ៧ កុសលវិបាកចិត្ត ៨ កិរិយាចិត្ត ៣ រួមជាអហេតុកចិត្ត ១៨ ។*

## អធិប្បាយ

*ព្រះអនុរុទ្ធាចារ្យ កាលចែកអកុសលចិត្ត ៣ ប្រភេទ ដោយសេចក្តីផ្សេងគ្នានៃហេតុ ៣ មានលោភហេតុជាដើម ដែលហៅថា សហេតុកចិត្ត ( ចិត្តដែលមានហេតុប្រកប ) រួម ជា ១២ យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងអត្ថនៃអហេតុកចិត្ត ដែលជាចិត្តមិនប្រកបដោយហេតុ ៦ គឺ លោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈ មាន ១៨ ដោយចែកចេញជា ៣ ប្រភេទ ។*

## អហេតុកចិត្ត ៣ ប្រភេទគឺ

១.អកុសលវិបាកចិត្ត ៧, ២.កុសលវិបាកចិត្ត ៨, ៣.កិរិយាចិត្ត ៣, រួមជាអហេតុកចិត្ត ១៨ ។

## ១.អកុសលវិបាកចិត្ត ៧

**១, ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ** : អកុសលវិបាកចក្ខុវិញ្ញាណ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យចក្ខុប្រសាទ ឃើញនូវរូបដែលមិនល្អ មិនមានការបបួលដឹកនាំ

**២, ឧបេក្ខាសហគតំ សោតវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ** : អកុសលវិបាកសោតវិញ្ញាណ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យសោតប្រសាទ ឮសំឡេងដែលមិនល្អ មិនមានការបបួលដឹកនាំ

**៣, ឧបេក្ខាសហគតំ ឃានវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ** : អកុសលវិបាកឃានវិញ្ញាណ កើតឡើងព្រមដោយ

ឧបេក្ខាវេទនា អាស្រ័យឃានប្រសាទ ធុំក្លិនដែលមិនល្អ មិនមានការបបួលដឹកនាំ

**៤, ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ** : អកុសលវិបាកជិវ្ហាវិញ្ញាណ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យជិវ្ហាប្រសាទ ស្រូបរសដែលមិនល្អ មិនមានការបបួលដឹកនាំ

**៥, ទុក្ខសហគតំ កាយវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ** : អកុសលវិបាកកាយវិញ្ញាណ កើតឡើងព្រមដោយទុក្ខវេទនា អាស្រ័យកាយប្រសាទ ប៉ះខ្ទប់សម្ផស្សដែលមិនល្អ មិនមានការបបួលដឹកនាំ

**៦, ឧបេក្ខាសហគតំ មនោធាតុ អសង្ខារិកំ អកុសលវិបាកំ** : អកុសលវិបាកមនោធាតុ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យហទយវត្ថុ ទទួលនូវបញ្ចារម្មណ៍ដែលមិនល្អ មិនមានការបបួលដឹកនាំ

**៧, ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អសង្ខារិកំ អកុសលវិបាកំ** : អកុសលវិបាកមនោវិញ្ញាណធាតុ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យហទយវត្ថុ ពិចារណានូវបញ្ចារម្មណ៍ដែលមិនល្អ មិនមានការបបួលដឹកនាំ ។

## អធិប្បាយ អកុសលវិបាកចិត្ត ៧

អកុសលវិបាកចិត្ត ជាអហេតុកចិត្ត ជាចិត្តលំដាប់ដំបូងមាន ៧ ដោយធម៌ដែលជាហេតុអាស្រ័យឱ្យវិបាកចិត្តកើតឡើង មានចក្ខុប្រសាទជាដើម និងដោយកិច្ច មានសម្បដិច្ឆន្នកិច្ចជាដើម ទើបពោលពាក្យមានជាដើមថា **ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ** ដូច្នេះ, ចិត្តទាំង ៧ នេះ ជាផលរបស់អកុសលកម្មដែលធ្វើទុកហើយ ។

ពិតមែន អកុសលចិត្តដែលមិនមានកម្លាំង គឺ មិនបានប្រព្រឹត្តកន្លងកម្មបថ តាមផ្លូវកាយ វាចា និងចិត្ត ក៏មាន, អកុសលចិត្ត មានកម្លាំងខ្លាំង អាចប្រព្រឹត្តកន្លងកម្មបថ តាម

ផ្លូវកាយ វាចា និងចិត្ត ក៏មាន. អកុសលទាំងអស់នេះ រលត់ទៅហើយ រមែងជាបច្ច័យឱ្យអកុសលវិបាកចិត្ត កើតឡើង អកុសលចិត្តជាបច្ច័យ ឱ្យកើតអកុសលវិបាកចិត្តនោះ ទឹងជាអកុសលចិត្តដែលធ្វើកម្មក្នុងជាតិនេះក៏ដោយ ឬក្នុងអនន្តជាតិក៏ដោយ រមែងជាបច្ច័យឱ្យកើតអកុសលវិបាកចិត្តទាំងនោះ ។

**១. ចក្ខុវិញ្ញាណ ជាអហេតុកចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា**

កើតឡើងទទួលនូវផលរបស់កម្មដែលធ្វើទុកហើយ ចក្ខុវិញ្ញាណនេះ កើតគ្រាដំបូង ឬប៉ុន្មានគ្រាក៏ដោយ រមែងឃើញរូបារម្មណ៍ ជាអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ មិនដឹងយ៉ាងដទៃ (ថាជាសត្វ បុគ្គលឡើយ) ។

<u>**ក្នុងអដ្ឋកថាសម្មោហវិនោទនី**</u> ពោលថា ៖

ចក្ខុ មកពី **ចក្ខតិ** ស័ព្ទ មានអត្ថថា សម្តែង, ទើបពោលថា **ចក្ខតិ រូបំ វិភាវេតីតិ = ចក្ខុ** ធម្មជាតិដែលឈ្មោះ

ថា ចក្ខុ ព្រោះអត្ថថា ប្រាប់ គឺ សម្ដែងនូវរូបឱ្យប្រាកដច្បាស់ ។

<u>ក្នុងវិភាវិនី</u> ពោលថា **ចក្ខុស្មឹ វិញ្ញាណំ តន្និស្សិតត្តាតិ = ចក្ខុវិញ្ញាណំ** វិញ្ញាណក្នុងចក្ខុ ព្រោះអាស្រ័យចក្ខុនោះ ហេតុនោះ ទើបឈ្មោះថា ចក្ខុវិញ្ញាណ ។

ចក្ខុប្រសាទ ជាឧបាទាយរូបដែលអាស្រ័យមហាភូតរូប. នឹងកើតឡើង ព្រោះកម្មដែលជាកាមាវចរជាបច្ច័យ ។

ពាក្យថា ចក្ខុនោះ ដោយព្យញ្ជនៈ សំដៅដល់ ភ្នែក ឬកែវភ្នែក ដោយបរមត្ថសំដៅដល់ ចក្ខុប្រសាទរូប. ពាក្យថា ប្រសាទ សំដៅដល់ ភាពថ្លារបស់មហាភូតរូប តែមិនមែនមហាភូតរូបទេ ។

បើអកុសលកម្មឱ្យផល ក៏ធ្វើឱ្យចក្ខុវិញ្ញាណ ឃើញនូវរូបារម្មណ៍ដែលមិនល្អ, បើកុសលកម្មឱ្យផល ក៏ធ្វើឱ្យចក្ខុវិញ្ញាណឃើញរូបារម្មណ៍ដែលល្អ; ការឃើញរូបដែលល្អនិងមិនល្អនោះ មិននៅក្នុងអំណាច និងមិនប្រព្រឹត្តទៅតាម

សេចក្ដីត្រូវការរបស់អ្នកណា ស្រេចហើយតែកម្មណា មានឱកាសឱ្យផល, ព្រោះចក្ខុវិញ្ញាណនោះ ជាវិបាកចិត្តដែលកើតឡើង ទទួលផលតាមផ្លូវភ្នែក ដោយអាស្រ័យចក្ខុប្រសាទឃើញពណ៌ដែលជាឥដ្ឋារម្មណ៍ខ្លះ អនិដ្ឋារម្មណ៍ខ្លះ.

ចក្ខុវិញ្ញាណឃើញរូបារម្មណ៍ដែលមិនល្អ មិនគួរប្រាថ្នា ជាផលរបស់អកុសលកម្ម និងឃើញរូបារម្មណ៍ដែលល្អ គួរប្រាថ្នា ជាផលរបស់កុសលកម្ម ។

ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ការដែលទឹងដឹងថា ឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍នោះ មិនមែនជាកិច្ចនាទីរបស់ចក្ខុវិញ្ញាណ ព្រោះចក្ខុវិញ្ញាណធ្វើទស្សនកិច្ចតែម្យ៉ាង និងចក្ខុវិញ្ញាណដែលឃើញពណ៌ ( រូបារម្មណ៍ ) ធ្វើនាទីត្រឹមតែឃើញប៉ុណ្ណោះ មិនដឹងថា អារម្មណ៍នោះ ជាអារម្មណ៍អ្វី គឺ មិនដឹងថា អារម្មណ៍នោះល្អ ឬអាក្រក់ និងមិនដឹងថា ឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍ ។

ចក្ខុវិញ្ញាណកើតរួមនឹងឧបេក្ខា ចក្ខុវិញ្ញាណឃើញពណ៌

នោះ កើតឡើងព្រោះអាស្រ័យឧបាទាយរូបប៉ះខ្ទប់ នឹងចក្ខុប្រសាទ, ការប៉ះខ្ទប់គ្នារបស់ចក្ខុប្រសាទនិងពណ៌នោះ ជាឧបាទាយរូបប៉ះខ្ទប់នឹងឧបាទាយរូប មិនមែនមហាភូតរូប ប៉ះខ្ទប់នឹងឧបាទាយរូប ព្រោះដូច្នោះ វេទនាចេតសិកដែលកើតរួមនឹងចក្ខុវិញ្ញាណនោះ ទើបត្រឹមតែជាឧបេក្ខាវេទនា ។

<u>អភិធម្មវិភាវិនី បាលី</u> ពោលថា ៖

តេសញ្ហិ ចតុន្នម្បិ វត្ថុភូតានិ ចក្ខាទីនិ ឧបាទារូបានេវ ។ តថា អារម្មណភូតានិបិ រូបាទីនិ ។ ឧបាទារូបកេន ច ឧបាទារូបស្ស សង្ឃដ្ដនំ អតិទុព្វលំ បិចុបិណ្ឌកេន បិចុបិណ្ឌកស្ស ផុសនំ វិយ តស្មា តានិ សព្វថាបិ ឧបេក្ខាសហគតានេវ ។

ពិតមែន ចក្ខុវិញ្ញាណដែលជាវត្ថុនៃវិញ្ញាណ សូម្បីទាំង ៤ នោះ ជាឧបាទាយរូបប៉ុណ្ណោះ រូបដែលជាអារម្មណ៍ ក៏ជាឧបាទាយរូបដូចគ្នា ការដែលឧបាទាយរូបនិងឧបាទាយរូបប៉ះ

ខ្ទប់គ្នា មានកម្លាំងខ្សោយក្រៃលែង ដូចជាដុំសំឡី និង ដុំសំឡីប៉ះខ្ទប់គ្នា ព្រោះដូច្នោះ ចក្ខុវិញ្ញាណជាដើមទាំងនេះ ទើបកើតឡើងព្រមនឹងឧបេក្ខាវេទនា ។

**២. សោតវិញ្ញាណ ជាអហេតុកចិត្ត កើតព្រមនឹង ឧបេក្ខាវេទនា**

ដូចបានពោលក្នុងចក្ខុវិញ្ញាណនោះឯង សោតវិញ្ញាណនេះ កើតឡើង ដើម្បីទទួលផលរបស់អកុសលកម្មដែលរលត់ទៅហើយ ។

ពាក្យថា **សោត** នោះ ដោយព្យញ្ជនៈ សំដៅដល់ត្រចៀក, ដោយបរមត្ថ សំដៅដល់ សោតប្រសាទរូប ជារូបដែលទទួលការប៉ះខ្ទប់នឹងសំឡេង សោតប្រសាទរូបនោះ នៅត្រង់កណ្ដាលខាងក្នុងត្រចៀក ជាបច្ច័យឱ្យចិត្តបានឮសំឡេង ចិត្តនេះជាវិបាក ហៅថា សោតវិញ្ញាណ ។

សោតប្រសាទរូបកើតឡើង ព្រោះកម្មដែលជា

កាមាវចរជាបច្ច័យ ដូចគ្នានឹងចក្ខុប្រសាទរូបនោះឯង ។

**៣. ឃានវិញ្ញាណ ជាអហេតុកចិត្ត កើតព្រមនឹងឧបេក្ខាវេទនា**

ចិត្តនេះកើតឡើង ដើម្បីទទួលផលរបស់អកុសលកម្ម ដែលធ្វើទុកហើយ ធ្វើឱ្យបានធុំក្លិនដែលជាអនិដ្ឋារម្មណ៍ ។

ពាក្យថា **ឃានៈ** ដោយព្យញ្ជនៈសំដៅដល់ ច្រមុះ, តែដោយបរមត្ថ សំដៅដល់ ឃានប្រសាទរូប សម្រាប់ប៉ះខ្ទប់នឹងក្លិន ។

**៤. ជិវ្ហាវិញ្ញាណ ជាអហេតុកចិត្ត កើតព្រមនឹងឧបេក្ខាវេទនា**

ចិត្តនេះ កើតឡើងដើម្បីទទួលផលរបស់អកុសលកម្ម ដែលធ្វើទុកហើយ ធ្វើឱ្យបានស្រូបរសដែលជាអនិដ្ឋារម្មណ៍ ។

ពាក្យថា **ជិវ្ហា** ដោយព្យញ្ជនៈសំដៅដល់ អណ្តាត, តែដោយបរមត្ថសំដៅដល់ ជិវ្ហាប្រសាទរូប សម្រាប់ប៉ះខ្ទប់នឹងរស ។

### ៥. កាយវិញ្ញាណ ជាអហេតុកចិត្ត កើតព្រមនឹងទុក្ខវេទនា ឬសុខវេទនា

បើជាកុសលវិបាក ក៏កើតព្រមនឹងសុខវេទនា. តែក្នុងទីនេះ ជាអកុសលវិបាកកាយវិញ្ញាណកើតព្រមជាមួយទុក្ខវេទនា ដែលប្រព្រឹត្តទៅតាមផ្លូវកាយ ទើបជាទុក្ខវេទនា ។

ពាក្យថា **កាយ** ដោយព្យញ្ជនៈ សំដៅដល់ រាងកាយ, ដោយបរមត្ថសំដៅដល់កាយប្រសាទរូប ជារូបសម្រាប់ប៉ះខ្ទប់នឹងធាតុទាំង ៣ គឺ ត្រជាក់ក្តៅ ទន់រឹង តឹងញ័រ (វៀរអាបោធាតុ) ។

កាយវិញ្ញាណដែលកើតព្រមនឹងទុក្ខវេទនានោះ រមែងប្រព្រឹត្តទៅតាមសភាវៈ ព្រោះសភាពធម៌ប៉ះខ្ទប់នឹងកាយនោះបានដល់ មហាភូតរូប ៣ គឺ ធាតុដី មានលក្ខណៈរឹង, ធាតុភ្លើង មានលក្ខណៈក្តៅ, ធាតុខ្យល់ មានលក្ខណៈញ័រ ។ ធាតុទាំង ៣ នេះ ជាមហាភូតរូបដែលជាទីអាស្រ័យនៃឧបាទាយរូបនោះ ធាតុណា ដែលប៉ះខ្ទប់នឹងកាយប្រសាទរូបដែលជា

ឧបាទាយរូបហើយ ក៏ប្រាកដនូវសម្ផស្សដ៏ខ្លាំង ដូចការយក ញញួរដំនូវសំឡី ដែលដាក់ទុកលើកំណាល់នោះឯង ព្រោះ ហេតុនេះ ទើបជាហេតុឱ្យទុក្ខវេទនាកើតឡើង មិនមែនឧបេក្ខា វេទនា ។

៦. ធាតុ គឺ មនោនោះឯង ឈ្មោះថា **មនោធាតុ** ធាតុដឹង (នូវបញ្ចារម្មណ៍)ដែលឈ្មោះថា ធាតុ ព្រោះអត្ថថា សូន្យ គឺ សូន្យចាកសត្វ បុគ្គលជាដើម និងចិត្តនេះ ជា វិបាកចិត្ត ធ្វើ**សម្បដិច្ឆន្នកិច្ច** (កិច្ចទទួល) គឺ ទទួល អារម្មណ៍តពីបញ្ចវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ជា អហេតុកចិត្ត កើតព្រមនឹងឧបេក្ខាវេទនា មិនកើតព្រមនឹង វេទនាដទៃ ។

ពាក្យថា **សម្បដិច្ឆន្នំ** មកពីពាក្យថា **សំ** + **បដិ** + **ឥច្ឆន្នំ** រួមគ្នាជា **សម្បដិច្ឆន្នំ** ប្រែថា ទទួល,

បើចែកដោយព្យញ្ជនៈ **សំ** ព្រម, **បដិ** ចំពោះ, **ឥច្ឆន្នំ** ប្រាថ្នា, គឺ កាលចក្ខុវិញ្ញាណជាដើមរលត់ហើយ មនោធាតុ

នេះ ក៏ទទួលអារម្មណ៍តពីចក្ខុវិញ្ញាណនោះ ជាផលរបស់អកុសល ឬកុសលក៏ដោយ កាលរលត់ហើយ មនោធាតុនេះក៏ធ្វើនាទីទទួលអារម្មណ៍ មនោធាតុនេះ អាស្រ័យហទយវត្ថុកើតឡើង ។

**៧. មនោវិញ្ញាណធាតុ** គឺ ធាតុដឹងវិញ្ញាណផង បានដល់ ដឹងបញ្ចារម្មណ៍ផង ដឹងវិញ្ញាណផង, អហេតុកវិបាកមនោវិញ្ញាណធាតុនេះ ជាចិត្តធ្វើ**សន្តីរណកិច្ច** ពាក្យថា **សន្តីរណៈ** គឺ ការពិចារណា ឬការពិនិត្យពិច័យអារម្មណ៍, ចិត្តដែលពិចារណាអារម្មណ៍នេះ ជាអហេតុកវិបាកចិត្ត ធ្វើកិច្ចពិចារណាអារម្មណ៍ដែលកើតឡើងតាមទ្វារ ៦ គឺ

១. ចក្ខុទ្វារ មានពណ៌ជាអារម្មណ៍
២. សោតទ្វារ មានសំឡេងជាអារម្មណ៍
៣. ឃានទ្វារ មានក្លិនជាអារម្មណ៍
៤. ជិវ្ហាទ្វារ មានរសជាអារម្មណ៍
៥. កាយទ្វារ មានសម្ផស្សជាអារម្មណ៍

៦. មនោទ្វារ មានធម៌ជាអារម្មណ៍

បើមនោធាតុទទួលអនិដ្ឋារម្មណ៍ មនោវិញ្ញាណធាតុដែលជាអកុសលវិបាក ក៏កើតឡើងពិចារណាអារម្មណ៍នោះ បើមនោធាតុទទួលឥដ្ឋារម្មណ៍ មនោវិញ្ញាណធាតុដែលជាអហេតុកកុសលវិបាក ក៏ពិចារណាអារម្មណ៍ដែលជាឥដ្ឋារម្មណ៍នោះ តែក្នុងទីនេះ ចិត្តនេះ ជាផលរបស់អកុសលទើបធ្វើកិច្ចពិចារណាអារម្មណ៍ដែលជាអនិដ្ឋារម្មណ៍ ។

**អកុសលវិបាកមនោវិញ្ញាណធាតុធ្វើកិច្ច ៥ គឺ**

១. បដិសន្ធិកិច្ច ធ្វើកិច្ចកើតក្នុងភពថ្មី
២. ភវង្គកិច្ច ធ្វើកិច្ចរក្សាភព
៣. ចុតិកិច្ច ធ្វើកិច្ចឃ្លាតចាកភព
៤. សន្តីរណកិច្ច ធ្វើកិច្ចពិចារណាអារម្មណ៍
៥. តទាលម្ពណកិច្ច ធ្វើកិច្ចទទួលអារម្មណ៍ តពីជវន

**ចប់ អកុសលវិបាកចិត្ត**

## ២.អហេតុកកុសលវិបាកចិត្ត ៨ គឺ

**១, ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ អសង្ខារិកំ អហេតុក កុសលវិបាកំ** : អហេតុកកុសលវិបាកចក្ខុវិញ្ញាណ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យចក្ខុប្រសាទឃើញនូវរូបដែលល្អ មិនមានការបបួលដឹកនាំ

**២, ឧបេក្ខាសហគតំ សោតវិញ្ញាណំ អសង្ខារិកំ អហេតុក កុសលវិបាកំ** : អហេតុកកុសលវិបាកសោតវិញ្ញាណ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យសោតប្រសាទឮសំឡេងដែលល្អ មិនមានការបបួលដឹកនាំ

**៣, ឧបេក្ខាសហគតំ ឃានវិញ្ញាណំ អសង្ខារិកំ អហេតុក កុសលវិបាកំ** : អហេតុកកុសលវិបាកឃានវិញ្ញាណ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យឃានប្រសាទធុំក្លិនដែលល្អ មិនមានការបបួលដឹកនាំ

**៤, ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ អសង្ខារិកំ អហេតុក**

**កុសលវិបាកំ :** អហេតុកកុសលវិបាកជិវ្ហាវិញ្ញាណ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យជិវ្ហាប្រសាទស្រូបរសដែលល្អ មិនមានការបបួលដឹកនាំ

**៥, សុខសហគតំ កាយវិញ្ញាណំ អសង្ខារិកំ អហេតុកកុសលវិបាកំ :** អហេតុកកុសលវិបាកកាយវិញ្ញាណ កើតឡើងព្រមដោយសុខវេទនា អាស្រ័យកាយប្រសាទប៉ះខ្ទប់សម្ផស្សដែលល្អ មិនមានការបបួលដឹកនាំ

**៦, ឧបេក្ខាសហគតំ មនោធាតុ អសង្ខារិកំ អហេតុកកុសលវិបាកំ :** អហេតុកកុសលវិបាកមនោធាតុ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យហទយវត្ថុទទួលនូវបញ្ចារម្មណ៍ដែលល្អ មិនមានការបបួលដឹកនាំ

**៧, សោមនស្សសហគតំ មនោវិញ្ញាណធាតុ អសង្ខារិកំ អហេតុកកុសលវិបាកំ :** អហេតុកកុសលវិបាកមនោវិញ្ញាណធាតុ កើតឡើងព្រមដោយសោមនស្សវេទនា អាស្រ័យហទយ

វត្ថុពិចារណានូវបញ្ចារម្មណ៍ដែលល្អក្រៃលែង មិនមានការបបួលដឹកនាំ

**៨, ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អសង្ខារិកំ អហេតុកកុសលវិបាកំ** : អហេតុកកុសលវិបាកមនោវិញ្ញាណធាតុ កើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យហទយវត្ថុ ពិចារណានូវបញ្ចារម្មណ៍ដែលល្អ មិនមានការបបួលដឹកនាំ ។

## អធិប្បាយ អហេតុកកុសលវិបាកចិត្ត ៨

កាមាវចរកុសលវិបាក មាន ១៦ គឺ អហេតុកកុសលវិបាកចិត្ត៨ និងសហេតុកកុសលវិបាកចិត្ត ៨ ក្នុងទីនេះ ជាវារៈនៃការពន្យល់សេចក្ដីរបស់អហេតុកកុសលវិបាកចិត្ត ៨ បន្តពីអកុសលវិបាកចិត្ត ៧ តាមដែលពោលហើយនោះ ។

សម្រាប់អហេតុកកុសលវិបាកចិត្ត ៨ នេះ កើតអំពីចេតនាក្នុងមហាកុសលចិត្ត ដែលខ្លួនធ្វើទុកហើយក្នុងអតីតជាតិ ឬបច្ចុប្បន្នជាតិ ដោយចេតនាកុសលនោះ មានកម្លាំង

ខ្សោយ ទើបឱ្យផលក្នុងបវត្តិកាល ។

អហេតុកកុសលវិបាកចិត្ត ៨ នេះ កើតឡើងទទួលអារម្មណ៍តាមបញ្ចទ្វារ មានទំនងដូចអកុសលវិបាកចិត្ត ៧ នុ៎ះឯង ផ្សេងគ្នាតែបានទទួលអារម្មណ៍ដែលល្អប៉ុណ្ណោះ ព្រោះជាផលរបស់កុសល ទើបធ្វើឱ្យឃើញរូប បានឮសំឡេង ធុំក្លិនស្រួបរស ប៉ះខ្ទប់សម្ផស្សដែលល្អ ដែលប្រព្រឹត្តទៅដោយន័យផ្ទុយគ្នានឹងអកុសលវិបាកចិត្តទាំង ៧ នោះ ។

ន័យមួយទៀត អហេតុកកុសលវិបាកចិត្ត៨ នេះ ច្រើនជាងអកុសលវិបាកចិត្ត១ គឺ សោមនស្ស មនោវិញ្ញាណធាតុ ព្រោះសោមនស្សមនោវិញ្ញាណធាតុ ធ្វើនាទីពិចារណាអារម្មណ៍ក្នុងផ្នែកកុសលវិបាក មាន ២ ប្រភេទ គឺ

១. ឥដ្ឋមជ្ឈត្តារម្មណ៍ បានដល់ អារម្មណ៍ដែលល្អធម្មតា

២. អតិឥដ្ឋារម្មណ៍ បានដល់ អារម្មណ៍ដែលល្អ

ក្រៃលែង

ចំណែកអកុសលវិបាកចិត្ត ៧ នោះ មានអារម្មណ៍ដែលជាអនិដ្ឋារម្មណ៍តែម្យ៉ាង មិនមានអារម្មណ៍ដែលជាអតិអនិដ្ឋារម្មណ៍ ដូចក្នុងអហេតុកកុសលវិបាកចិត្តទាំង ៨ នេះទេ ។

## អហេតុកកុសលវិបាកចិត្ត ៨ គឺ

១.ចក្ខុវិញ្ញាណ ២.សោតវិញ្ញាណ ៣.ឃានវិញ្ញាណ
៤.ជិវ្ហាវិញ្ញាណ ៥.កាយវិញ្ញាណ ៦.មនោធាតុ
៧.ឧបេក្ខាអហេតុកកុសលវិបាកមនោវិញ្ញាណធាតុ
៨.សោមនស្សអហេតុកកុសលវិបាកមនោវិញ្ញាណធាតុ

សម្រាប់អហេតុកកុសលវិបាកមនោវិញ្ញាណធាតុ ដែលកើតព្រមនឹងឧបេក្ខាវេទនា ទទួលអារម្មណ៍ដែលល្អ តអំពីមនោធាតុហើយ ក៏ធ្វើការពិចារណា ឬត្រិះរិះពិនិត្យអារម្មណ៍នោះហើយក៏រលត់ទៅ, ចំណែកអហេតុកកុសលវិបាកមនោ

វិញ្ញាណធាតុ ដែលកើតព្រមទឹងសោមនស្សវេទនានោះ ជាវិបាកដែលកើតឡើង ពិចារណាអារម្មណ៍ដែលល្អក្រៃលែង ព្រោះជាផលរបស់កុសលកម្មដែលល្អក្រៃលែង ធ្វើការពិចារណាអារម្មណ៍ដែលល្អក្រៃលែងនោះហើយ ក៏រលត់ទៅដូចគ្នា ។

សួរថា អារម្មណ៍ដែលល្អក្រៃលែង[១] បានដល់អារម្មណ៍អ្វី ?

ឆ្លើយថា អារម្មណ៍ដែលល្អក្រៃលែង ដូចការបានឃើញសរីរៈរបស់ព្រះពុទ្ធក្តី ការឃើញភិក្ខុសង្ឃរបស់អ្នកមានសទ្ធាមុតមាំក្តី ហៅថា ការឃើញដែលជាអតិឥដ្ឋារម្មណ៍ កាលការឃើញ គឺ ចក្ខុវិញ្ញាណរលត់ហើយ កុសលវិបាកមនោធាតុកើតឡើងធ្វើកិច្ចហើយក៏រលត់ទៅ តពីនោះ សោមនស្ស

១. អង្គុ. ឆក្ក. អាហុនេយ្យវគ្គ. ៤៦. ៨/១០, ក្នុងមនោរថបូរណី អធិប្បាយ អនុត្តរិយ ៦ ទាំងលោកិយ និងលោកុត្តរ ។

អហេតុកវិបាកមនោវិញ្ញាណធាតុ ទើបកើតឡើងធ្វើកិច្ច ។

ក្នុងការស្តាប់សំឡេងដែលល្អក្រៃលែង ដូចបានស្តាប់ព្រះសូរសៀងរបស់ព្រះពុទ្ធក្តី ស្តាប់ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដកក្តី សូម្បីបានស្តាប់ពាក្យថា **ពុទ្ធោ លោកេ ឧប្បន្នោ** ( ព្រះពុទ្ធទ្រង់ឧប្បត្តិក្នុងលោកហើយ )ក្តី របស់អ្នកមានសទ្ធាមុតមាំ ក៏ហៅថា អតិឥដ្ឋារម្មណ៍បាន ព្រោះសោមនស្សអហេតុកវិបាកមនោវិញ្ញាណធាតុនោះ មានឱកាសទើបកើតឡើង ការបានហិតក្លិនក្តី ភ្លក់រសអាហារក្តី ប៉ះខ្ទប់សម្ផស្សក្តី រមែងជាហេតុឱ្យសោមនស្សអហេតុកវិបាកមនោវិញ្ញាណធាតុកើតបាន ពោលតាមសភាវៈហើយ អតិឥដ្ឋារម្មណ៍ក្នុងឋានមនុស្សមានតិចជាងក្នុងឋានសួគ៌ ព្រោះនៅក្នុងឋានសួគ៌ ជាភូមិដែលមានរូប សំឡេង... ដ៏ប្រណីត ៗ ។

**ចប់ អហេតុកកុសលវិបាកចិត្ត ៨**

## ៣.អហេតុកកិរិយាចិត្ត ៣

ឥឡូវនេះ ដើម្បីសម្តែងអហេតុកកិរិយាចិត្ត ៣ ដែលមានកិច្ចផ្សេងគ្នា ទើបលោកពោលពាក្យថា “**ឧបេក្ខាសហគតំ**”ជាដើម ។

ចិត្តដែលឈ្មោះថា កិរិយាហេតុកមនោធាតុ គឺជាចិត្តធ្វើអាវជ្ជនៈតាមទ្វារ៥, អាវជ្ជនៈ ព្រោះអត្ថថា រំពឹង គឺ នឹកដល់អារម្មណ៍ដែលប៉ះនឹងទ្វារ ៥ មានចក្ខុទ្វារជាដើម មិនឱ្យចិត្តប្រព្រឹត្តទៅដោយភវង្គ ហើយបង្អោនទៅ ដើម្បីភាពជាវិថី ។

ភវង្គចិត្ត ជាអនន្តរប្បច្ច័យ ដល់អាវជ្ជនចិត្ត ។ ដែលឈ្មោះថា មនោទ្វារ ព្រោះជាប្រកផ្លូវនៃការកើតឡើងរបស់វិថីទាំងឡាយ ។ ដែលឈ្មោះថា មនោទ្វារាវជ្ជនៈ ព្រោះអត្ថថា រំពឹងដល់អារម្មណ៍ដែលមកកាន់គន្លងមនោទ្វារ ដោយអំណាចនៃអារម្មណ៍ដែលបានឃើញ បានឮ និងបានដឹងជាដើម ឬបង្អោនទៅ ដោយន័យដែលពោលហើយនុ៎ះឯង កើតព្រមនឹងឧបេក្ខា ដែលជាកិរិយាហេតុកមនោវិញ្ញាណធាតុ, ចិត្តនេះឯង

ហៅថា វោដ្ឋព្វន ព្រោះអត្ថថា រមែងកំណត់អារម្មណ៍ តាមដែលសញ្ជឹងគិតហើយ ក្នុងទ្វារទាំង ៥ ។

*<u>ក្នុងវិភាវនីដីកា</u>* ពោលអធិប្បាយទុកថា ៖

ដែលឈ្មោះថា ហសិតុប្បាទៈ ព្រោះអត្ថថា ឱ្យកើតការញញឹម បានដល់ ចិត្តដែលកើតឡើង ព្រមទីងសោមនស្សដែលជាកិរិយាអហេតុកមនោវិញ្ញាណធាតុ ដែលមានហេតុត្រឹមតែការរីករាយ ក្នុងអារម្មណ៍ដែលមិនគ្រោតគ្រាតរបស់ព្រះខីណាស្រពទាំងឡាយ ។

## អហេតុកកិរិយាចិត្ត ៣ គឺ

**១, *ឧបេក្ខាសហគតំ មនោធាតុ អសង្ខារិកំ អហេតុកកិរិយា*** : អហេតុកកិរិយាមនោធាតុ កើតឡើងព្រមដោយឧបេក្ខាវេទនា រាវរកអារម្មណ៍តាមបញ្ចទ្វារ មិនមានការបបួលដឹកនាំ

**២, *ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អសង្ខារិកំ អហេតុកកិរិយា*** : អហេតុកកិរិយាមនោវិញ្ញាណធាតុ កើត

ឡើងព្រមដោយឧបេក្ខាវេទនា រាវរកអារម្មណ៍តាមមនោទ្វារ មិនមានការបបួលដឹកនាំ ។

**៣, សោមនស្សសហគតំ មនោវិញ្ញាណធាតុ អសង្ខារិកំ អហេតុកកិរិយា** : អហេតុកកិរិយាមនោវិញ្ញាណធាតុ កើតឡើងព្រមដោយសោមនស្សវេទនា ធ្វើការញញឹមរបស់ព្រះអរហន្ត មិនមានការបបួលដឹកនាំ ។

## អធិប្បាយអហេតុកកិរិយាចិត្ត

ពាក្យថា **បញ្ចទ្វារាវជ្ជន** ចែកជា ៣ បទ គឺ **បញ្ច** + **ទ្វារ** + **អាវជ្ជន** រាវរកអារម្មណ៍តាមទ្វារ ៥ ។

១. មនោធាតុ នេះកើតព្រមនឹងឧបេក្ខា ជាអហេតុកកិរិយាចិត្ត កាលកិរិយាមនោធាតុ មិនកើតឡើងមុនទេ វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម នឹងមិនកើត ព្រោះកាលអារម្មណ៍ ៥ មានរូបជាដើម ប៉ះខ្ទប់នឹងប្រសាទរូប ៥ មានចក្ខុប្រសាទជាដើម កិរិយាមនោធាតុនោះ ទើបកើតឡើងរាវរកអារម្មណ៍តាមផ្លូវភ្នែក ឬត្រចៀកជាដើម ហើយក៏រលត់

ទៅ បើជាអារម្មណ៍តាមផ្លូវភ្នែក វិបាកចិត្តមានចក្ខុវិញ្ញាណជាដើម ក៏កើតឡើងរលត់ទៅ តពីនោះ វិបាកមនោធាតុ ក៏កើតឡើងរលត់ហើយ បន្ទាប់មកបើអារម្មណ៍ជាអនិដ្ឋារម្មណ៍ អកុសលវិបាកមនោវិញ្ញាណធាតុ ក៏កើតឡើង, បើអារម្មណ៍នោះ ជាឥដ្ឋារម្មណ៍ ឧបេក្ខាហេតុកកុសលវិបាកមនោវិញ្ញាណធាតុ ក៏កើតឡើង, បើអារម្មណ៍នោះ ជាអតិឥដ្ឋារម្មណ៍ សោមនស្សអហេតុកកុសលវិបាកមនោវិញ្ញាណធាតុ ក៏កើតឡើង, ធ្វើកិច្ចពិចារណាហើយរលត់ទៅ. តពីនោះ ចិត្តដទៃ ៗ ក៏កើតឡើងជាប់តគ្នា ទៅដរាបដល់អស់អាយុរបស់អារម្មណ៍ការដែលកិរិយាមនោធាតុរាវរកអារម្មណ៍ កើតរលត់ហើយ ចិត្តដទៃ ៗ ក៏កើតរលត់ជាប់តគ្នា ដរាបដល់អស់អាយុរបស់អារម្មណ៍ដែលកើតឡើងមួយដង នេះហៅថា ចិត្តនិយាម[1]

---

១. ក្នុងអដ្ឋសាលិនីថា និយាម ៥ គឺ ពីជនិយាម ឧតុនិយាម កម្មនិយាម ធម្មនិយាម ចិត្តនិយាម ។ ២. ហៅតាមអដ្ឋកថា និងដីកា ។

( ភាពពិតប្រាកដរបស់ចិត្ត ) ។

កិរិយាមនោធាតុនេះ ហៅតាមកិច្ចថា អាវជ្ជនចិត្ត[២] កើតឡើង ព្រោះអារម្មណ៍ដែលជារូបមកប៉ះខ្ទប់នឹងប្រសាទរូបជាបច្ច័យ បើអាវជ្ជនចិត្ត រាវរកអារម្មណ៍តាមផ្លូវភ្នែក ក៏ហៅថា ចក្ខុទ្វារាវជ្ជនចិត្ត, បើទទួលអារម្មណ៍តាមផ្លូវត្រចៀក ក៏ហៅថា សោតទ្វារាវជ្ជនចិត្ត, បើទទួលអារម្មណ៍តាមផ្លូវច្រមុះ ក៏ហៅថា ឃានទ្វារាវជ្ជនចិត្ត, បើទទួលអារម្មណ៍តាមផ្លូវអណ្តាត ក៏ហៅថា ជិវ្ហាទ្វារាវជ្ជនចិត្ត, បើទទួលអារម្មណ៍តាមផ្លូវកាយ ក៏ហៅថា កាយទ្វារាវជ្ជនចិត្ត, រួម ៥ ទ្វារនេះ ហៅថា បញ្ចទ្វារាវជ្ជនចិត្ត ។

បញ្ចទ្វារាវជ្ជនចិត្ត ដឹងអារម្មណ៍ដែលមកប៉ះខ្ទប់នឹងប្រសាទរូប ៥ ត្រង់អារម្មណ៍នីមួយ ៗ បានទាំង ៥ អារម្មណ៍ ។

អដ្ឋកថាចារ្យ បានឧបមាបញ្ចទ្វារាវជ្ជនចិត្ត ទុកក្នុងរឿងសត្វពីងពាង និងក្នុងរឿងនាយរក្សាទ្វារជាដើម ដោយ

បាលីថា សុត្តំ ទោវារិកោ ច គាមិកោ អម្ពោ កោលិយកេន ច ជច្ចន្ធោ បីឋសប្បិ ច វិសយគាហោ ច ឧបនិស្សយមត្តសោ : រឿងពីងពាង ១ រឿងអ្នករក្សាទ្វារ ១ រឿងក្មេងអ្នកស្រុក ១ រឿងស្វាយនិងម្ចាស់ឃ្នាបអំពៅ ១ រឿងបុរសខ្វាក់និងខ្វិន ១ រឿងការទទួលអារម្មណ៍ដោយឧបនិស្សយប្បច្ច័យ ១ ។

មានពាក្យអធិប្បាយថា ពីងពាងនៅប្រកផ្លូវមួយ បានបន្ទាយខ្សែទៅ ៥ ទិស ធ្វើសំណាញ់ហើយដេកត្រង់កណ្ដាល កាលខ្សែដែលបន្ទាយទៅក្នុងទិសដំបូង ត្រូវប៉ះខ្ទប់ដោយសត្វតូច ៗ វាក៏ចេញពីទីដេកទៅតាមខ្សែ ចោះក្បាល បឺតឈាមរបស់សត្វនោះ ហើយត្រឡប់មកដេក នៅត្រង់កណ្ដាលខ្សែនោះឯងទៀត, ក្នុងកាលខ្សែក្នុងទិសទី ២ ត្រូវប៉ះខ្ទប់ហើយក៏ធ្វើដូច្នោះទៀតនោះឯង ។

ក្នុងសេចក្ដីនេះ ប្រសាទទាំង ៥ ដូចខ្សែពីងពាងដែលបន្ទាយទៅតាមទិសទាំង ៥ ។ ចិត្ត ដូចពីងពាងដេកនៅត្រង់

កណ្តាល ។ វេលាដែលអារម្មណ៍មកប៉ះខ្ទប់ប្រសាទ ដូចសត្វតូច ៗ មកប៉ះនឹងខ្សែពីងពាង ។ វេលាកិរិយាមនោធាតុទទួលអារម្មណ៍ដែលប៉ះខ្ទប់ប្រសាទហើយ ធ្វើភវង្គឱ្យផ្លាស់ប្តូរទៅ ដូចការញ័ររបស់ខ្សែទៅប៉ះពីងពាងដែលដេកនៅត្រង់កណ្តាល ។ សភាពជារបស់វិថីចិត្ត ដូចវេលាដែលពីងពាងទៅតាមខ្សែ ។ វេលាដែលជវនចិត្តសេពសោយអារម្មណ៍ ដូចការបោះក្បាល បឺតឈាម ។ ភវង្គចិត្តដែលអាស្រ័យហទយវត្ថុប្រព្រឹត្តទៅ ដូចពីងពាងដែលត្រឡប់មកដេកនៅត្រង់ទីកណ្តាលខ្សែនោះទៀត ។

ការដែលលោកធ្វើឧបមារឿងពីងពាងនេះមក ក៏ដើម្បីឱ្យជ្រាបថា កាលអារម្មណ៍ប៉ះខ្ទប់ប្រសាទហើយ ចិត្តដែលអាស្រ័យហទយវត្ថុកើត រមែងកើតឡើងមុនចិត្តដែលអាស្រ័យប្រសាទរូបកើត និងរមែងអធិប្បាយឱ្យជ្រាបថា អារម្មណ៍នីមួយ ៗ រមែងមកកាន់គន្លងក្នុងទ្វារទាំងពីរ ។ ចំណែកពាក្យឧបមាដទៃ សូមមេត្តាមើលសេចក្តីពិស្តារ ក្នុង

អដ្ឋសាលិនីអដ្ឋកថាធម្មសង្គណី ។

២. មនោវិញ្ញាណធាតុកើតឡើង ព្រមដោយឧបេក្ខាវេទនា ជាអហេតុកកិរិយាចិត្ត ធ្វើកិច្ចពិចារណាអារម្មណ៍តាមមនោទ្វារ ហៅថា **មនោទ្វារាវជ្ជន** ។

**មនោទ្វារាវជ្ជន** បែកជា ៣ បទ គឺ

**មនោ** : ចិត្ត, **ទ្វារ** : ទ្វារ ឬផ្លូវ, **អាវជ្ជនំ** : ការពិចារណា, កាលអារម្មណ៍តាមបញ្ចទ្វារ មានចក្ខុទ្វារជាដើម រលត់ហើយ មនោទ្វារាវជ្ជនចិត្ត[1] ក៏ដឹងអារម្មណ៍នោះ

---

១. <u>**ចំណាំ**</u> អហេតុកកិរិយាចិត្តទាំង៣ សរសេរតាមកិច្ច(ក្នុងអដ្ឋកថា ដីកាក៏មាន) ដើម្បីសម្រួលពាក្យឱ្យខ្លី និងងាយចាំងាយយល់ផង, បើសរសេរតាមឈ្មោះចិត្ត វែងនិងពិបាក ម្យ៉ាងទៀត មនោវិញ្ញាណធាតុ មានចំនួនច្រើន និងមានឈ្មោះថា អកុសល មហាកុសលជាដើមដែរ មិនមែនទៅតែមនោវិញ្ញាណធាតុ ៗនោះទេ; តែក៏សូមឱ្យចាំបានថា បញ្ចទ្វារាវជ្ជនចិត្ត គឺកិរិយាមនោធាតុ, មនោទ្វារាវជ្ជនចិត្ត គឺ ឧបេក្ខាហេតុកកិរិយាមនោវិញ្ញាណធាតុ, ហសិតុប្បាទចិត្ត គឺសោមនស្សអហេតុកកិរិយាមនោវិញ្ញាណធាតុ ។

បន្ត, មនោទ្វារាវជ្ជនចិត្ត អាចដឹងបញ្ញត្តិផ្សេង ៗ បានយ៉ាង ច្រើន ដឹងអារម្មណ៍ បានទាំងដែលជាឥដ្ឋារម្មណ៍ អនិដ្ឋារម្មណ៍ និងរូបដទៃ ៗ ទាំងចិត្ត ចេតសិក និងនិព្វាន ។

កាលមនោទ្វារាវជ្ជនចិត្តនេះ ធ្វើកិច្ចសម្រេចហើយ ចិត្ត ដែលកើតតពីនោះ ជាកុសលចិត្តក៏មាន ជាអកុសលចិត្តក៏មាន មហាកិរិយាចិត្តក៏មាន កិច្ចរបស់មនោទ្វារាវជ្ជនចិត្ត គឺ

រាវរកអារម្មណ៍ទាំង ៦ និងធ្វើកិច្ចកំណត់អារម្មណ៍ តាមបញ្ចទ្វារ ហៅថា វោដ្ឋព្វនចិត្ត ។

៣. មនោវិញ្ញាណធាតុកើតឡើង ព្រមដោយ សោមនស្សវេទនា ជាអហេតុកកិរិយាចិត្ត ធ្វើកិច្ចញញឹមហៅ តាមកិច្ចថា **ហសិតុប្បាទចិត្ត** ចែកជា ៣ បទ គឺ

**ហសិត** : ការញញឹម, **ឧប្បាទ** : ការកើតឡើង, **ចិត្តំ** : ចិត្ត, ហសិតុប្បាទចិត្តនេះ ជាចិត្តរបស់ព្រះអរហន្ត កើតព្រមនឹងសោមនស្សវេទនា ជាចិត្តដែលធ្វើរូបឱ្យញញឹម ដូចរឿងព្រះមហាមោគ្គល្លាន ឃើញប្រេតដែលកំពុងទទួលទុក្ខ

វេទនា ការឃើញនោះ គឺ ឃើញដោយកិរិយាអភិញ្ញាចិត្ត ដែលប្រព្រឹត្តទៅ ព្រមដោយការពិចារណាថា "សភាពដូច្នេះ នឹងមិនកើតដល់យើងទៀតឡើយ" ហើយហសិតុប្បាទចិត្ត ក៏កើតឡើង ។

<u>ក្នុងសុពោធាលង្ការ</u> បានពោលការញញឹមសើច៦ យ៉ាង គឺ

**១. សិតៈ** ញញឹមមិនឃើញអញ្ចាញធ្មេញ ជាការញញឹមរបស់ព្រះពុទ្ធ

**២. ហសិតៈ** ញញឹមល្មមឃើញអញ្ចាញធ្មេញ ជាការញញឹមរបស់ព្រះអរហន្ត ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន និងបុថុជ្ជន ការញញឹម នេះ បើក្រៅពីព្រះអរហន្តហើយ រមែងប្រាកដដោយហេតុបុណ្យ ឬហេតុបាប ។

**៣. វិហសិតៈ** សើចមានសំឡេងស្រាល ៗ កើតនឹងចិត្តរបស់ព្រះអរិយៈ ៣ គឺ ព្រះអនាគាមី ព្រះសកទាគាមី

ព្រះសោតាបន្ន និងបុថុជ្ជន

៤. **អតិហសិតៈ** សើចមានសំឡេងខ្លាំង កើតដល់ព្រះសកទាគាមី ព្រះសោតាបន្ន និងបុថុជ្ជន ។

៥. **ឧបហសិតៈ** សើចដរាបញ័រកាយ ជាការសើចរបស់បុថុជ្ជន

៦. **អវហសិតៈ** សើចដរាបហូរទឹកភ្នែក ជាការសើចរបស់បុថុជ្ជន ។

**សិតៈ** និង **ហសិតៈ** ជាការញញឹមរបស់ព្រះអរហន្តជាចិត្តញញឹម ដោយមិនប្រកាន់មាំក្នុងអារម្មណ៍ ដូចការសើចរបស់បុគ្គលដទៃទេ ចិត្តនេះទើបមានកម្លាំងទន់ខ្សោយ ជាចិត្តវិសេស ហៅថា **ហសិតុប្បាទចិត្ត** ការដែលចិត្តមានកម្លាំងតិចនេះឯង ទើបជាអហេតុកចិត្ត ចំណែកចិត្តសើចដទៃ ៗ ជាសហេតុកចិត្ត ។

**ចប់ អហេតុកកិរិយា ៣**

## សង្ខារភេទនៃអហេតុកៈ

អហេតុកចិត្ត ១៨ នេះ លោកមិនបានពោលថា ជាអសង្ខារិកចិត្ត ឬសសង្ខារិកចិត្ត ដែលមានសេចក្តីប្រាកដក្នុងទីផ្សេង ៗ លុះមប្រមូលមក បាន ៣ ន័យ គឺ

១ **ក្នុងមូលដីកា** និង**អភិធម្មត្ថវិភាវិនី** ពោលថា ៖

"អហេតុកចិត្ត ១៨ នេះ ជាសង្ខារវិមុត្ត គឺ ផុតចាកពីអសង្ខារិកចិត្ត ឬសសង្ខារិកចិត្ត ព្រោះមិនមានបាលីពោលទុក"

២ **ក្នុងបរមត្ថទីបនីដីកា** ពោលថា ៖

"អហេតុកចិត្ត ១៨ នេះ ជាអសង្ខារិកចិត្តផង ជាសសង្ខារិកចិត្តផង ព្រោះក្នុងមរណាសន្នជវនកាល គឺ កាលជិតស្លាប់វិថីចិត្តផ្សេង ៗ នឹងប្រាកដឡើងខ្លួនឯង ឬមានអ្នកបបួលឱ្យមើលរូបព្រះពុទ្ធ ឬឱ្យស្តាប់ព្រះសង្ឃសូត្រមន្តជាដើម

ទើបចាត់ថា ជាអសង្ខារិកចិត្តផង ជាសសង្ខារិកចិត្តផង" ។

៣ <u>ព្រះបុរាណាចារ្យ</u> ពោលថា ៖

"អហេតុកចិត្ត ១៨ ជាអសង្ខារិកចិត្ត ព្រោះការឃើញ ការឮ ការធុំក្លិន ការស្រូបរស ការប៉ះពាល់ត្រូវទាំងនេះ រមែងប្រព្រឹត្តទៅខ្លួនឯង គឺ រមែងបានឃើញឯង បានឮឯង បានធុំក្លិនឯង បានស្រូបរសឯង បានប៉ះពាល់ត្រូវឯង ដោយអាស្រ័យឧប្បត្តិហេតុ ឱ្យចិត្តទាំងនេះកើតឡើង ព្រោះដូច្នោះ ទើបពោលថា ជាអសង្ខារិកទាំង ១៨ ។

ការឃើញទាំង ៣ នេះ ការឃើញថា អហេតុកចិត្ត ១៨ នេះ សង្គ្រោះចូលក្នុងអសង្ខារិក ព្រោះកើតឡើងឯង ដោយអាស្រ័យឧប្បត្តិហេតុ គឺ ហេតុដែលប្រជុំគ្នាកើតឡើង សូម្បីមានអ្នកមកបបួល តែបើហេតុមិនគ្រប់អង្គ ចិត្តមានចក្ខុវិញ្ញាណជាដើម ក៏មិនកើត (ន័យទី ៣ នេះត្រឹមត្រូវ) ។

# ឧប្បត្តិហេតុនៃអហេតុកចិត្ត ១៨

ក្នុងអដ្ឋកថាអដ្ឋសាលិនី ពោលទុកថា ឧប្បត្តិហេតុ គឺ ហេតុកើតឡើងនៃអហេតុកចិត្ត ១៨

១- ហេតុឱ្យកើតចក្ខុវិញ្ញាណ ២ មាន ៤ គឺ

-អសម្ភិន្នត្តា ចក្ខុស្ស ព្រោះចក្ខុប្រសាទមិនទាន់បែកធ្លាយ

-អាបាថគតត្តា រូបានំ ព្រោះរូបមកកាន់គន្លងនៃចក្ខុប្រសាទ

-អាលោកសន្និស្សិតំ អាស្រ័យពន្លឺ

-មនសិការហេតុកំ មានមនសិការៈជាហេតុជិត ។

បណ្ដាបច្ច័យទាំង ៤ នោះ ចក្ខុរបស់អ្នកស្លាប់ក្ដី ចក្ខុរបស់អ្នកនៅរស់រលត់( គឺ ខ្វាក់ )ក្ដី ឬ ត្រូវទឹកប្រមាត់ ឬ

ត្រូវទឹកស្អែស ឬលោហិត រុំបាំង(ធ្វើឱ្យងងឹត)ក្តី មិនអាចជាបច្ច័យដល់ចក្ខុវិញ្ញាណ ឈ្មោះថា បែកធ្លាយ កាលចក្ខុប្រសាទអាចជាបច្ច័យបាន ឈ្មោះថា មិនទាន់បែកធ្លាយ ។

សូម្បីកាលចក្ខុប្រសាទមិនទាន់បែកធ្លាយ តែរូបារម្មណ៍មិនមកកាន់គន្លងនៃចក្ខុប្រសាទ ចក្ខុវិញ្ញាណ កើតមិនបាន, កាលរូបារម្មណ៍នោះ មកកាន់គន្លងហើយ តែបច្ច័យ គឺពន្លឺមិនមាន ចក្ខុវិញ្ញាណក៏កើតមិនបាន, កាលកិរិយាមនោធាតុធ្វើភវង្គកិច្ចឱ្យផ្លាស់ប្តូរទៅហើយ ចក្ខុវិញ្ញាណ ទើបកើតឡើងធ្វើទស្សនកិច្ច (ឃើញរូបារម្មណ៍) ចក្ខុវិញ្ញាណ កាលកើតរមែងកើតព្រមនឹងសម្បយុត្តធម៌ទាំងឡាយ ដោយពិត ព្រោះដូច្នោះ ទើបពោលថា ចក្ខុវិញ្ញាណកើតព្រោះអាស្រ័យ បច្ច័យ ៤ ប៉ុណ្ណោះ ។

**២- ហេតុឱ្យកើតសោតវិញ្ញាណ ២ មាន ៤ គឺ**

**-អសម្ភិន្នត្តា សោតស្ស** ព្រោះសោតប្រសាទមិន

ទាន់បែកធ្លាយ

**-អាបាថគតត្តា សទ្ទានំ** ព្រោះសំឡេងមកកាន់គន្លងនៃសោតប្រសាទ

**-អាកាសសន្និស្សិតំ** អាស្រ័យអាកាស

**-មនសិការហេតុកំ** មានមនសិការៈជាហេតុជិត ។

បណ្ដាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យអាកាស គឺ សោតវិញ្ញាណនោះ ទាល់តែបានអាស្រ័យអាកាស ទើបកើតឡើង វៀរចាកអាកាសមិនកើតឡើងទេ ព្រោះកាលបុគ្គលបិទត្រចៀក សោតវិញ្ញាណនោះ ក៏កើតឡើងមិនបាន ។ ពាក្យដែលនៅសល់ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងចក្ខុវិញ្ញាណចុះ ។

**៣- ហេតុឱ្យកើតឃានវិញ្ញាណ ២** មាន ៤ គឺ

**-អសម្ភិន្នត្តា ឃានស្ស** ព្រោះឃានប្រសាទមិនទាន់បែកធ្លាយ

**-អាបាថគតត្តា គន្ធានំ** ព្រោះក្លិនមកកាន់គន្លងនៃឃានប្រសាទ

**-វាយោសន្និស្សិតំ** អាស្រ័យវាយោ ( ខ្យល់ )

**-មនសិការហេតុកំ** មានមនសិការៈជាហេតុជិត ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យវាយោ គឺ កាលខ្យល់បក់នាំក្លិនទាំងឡាយ ចូលទៅកាន់គន្លងប្រមុះនោះឯង ឃានវិញ្ញាណ ទើបកើតឡើង, កាលវាយោ គឺខ្យល់មិនមានឃានវិញ្ញាណ ក៏កើតឡើងមិនបាន ។

**៤- ហេតុឱ្យកើតជិវ្ហាវិញ្ញាណ ២ មាន ៤ គឺ**

**-អសម្ភិន្នត្តា ជិវ្ហាយ** ព្រោះជិវ្ហាប្រសាទមិនទាន់បែកធ្លាយ

**-អាបាថគតត្តា រសានំ** ព្រោះរសមកកាន់គន្លងនៃជិវ្ហាប្រសាទ

**-អាបោសន្និស្សិតំ** អាស្រ័យអាបោ គឺ ទឹក

**-មនសិការហេតុកំ** មានមនសិការៈជាហេតុផិត ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យអាបោ គឺ ទឹកធ្វើឱ្យអណ្តាតសើម ជិវ្ហាវិញ្ញាណទើបកើតឡើង, វៀរអាបោចេញ ជិវ្ហាវិញ្ញាណក៏មិនកើតឡើង ព្រោះបុគ្គលដែលមានអណ្តាតស្ងួត សូម្បីដាក់វត្ថុដែលគួរបរិភោគទុកត្រង់អណ្តាតនោះ ជិវ្ហាវិញ្ញាណ ក៏កើតឡើងមិនបាន ។

**៥- ហេតុឱ្យកើតកាយវិញ្ញាណ ២** មាន ៤ គឺ

**-អសម្ភិន្នត្តា កាយស្ស** ព្រោះកាយប្រសាទមិនទាន់បែកធ្លាយ

**-អាបាថគតត្តា ផោដ្ឋព្វានំ** ព្រោះផោដ្ឋព្វៈ មកកាន់គន្លងនៃកាយប្រសាទ

**-បឋវីសន្និស្សិតំ** អាស្រ័យបឋវី

**-មនសិការហេតុកំ** មានមនសិការៈជាហេតុផិត ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យបឋវី

បានដល់ បឋវីដែលគួបផ្សំគ្នា គឺ កាយប្រសាទនោះឯង ជាបច្ច័យ កាយវិញ្ញាណទើបកើតឡើង វៀរកាយប្រសាទហើយ កាយវិញ្ញាណក៏កើតមិនបាន ព្រោះមហាភូតរូបជាអារម្មណ៍ខាងក្រៅប៉ះខ្ទប់កាយប្រសាទខាងក្នុងទ្វារកាយ រមែងប៉ះខ្ទប់មហាភូតរូបទាំងឡាយ ដែលមានកាយប្រសាទជាបច្ច័យ ។

**៦- ហេតុឱ្យកើតមនោធាតុ ៣** មាន ៤ គឺ

**-អសម្ភិន្នត្តា បសាទស្ស** ព្រោះប្រសាទរូប មិនទាន់បែកធ្លាយ

**-អាបាថគតត្តា បញ្ចារម្មណានំ** មានអារម្មណ៍ ៥ មកកាន់គន្លង

**-ហទយសន្និស្សិតំ** អាស្រ័យហទយវត្ថុ

**-មនសិការហេតុកំ** មានមនសិការៈជាហេតុជិត ។

មនោធាតុ ៣ គឺ កិរិយាមនោធាតុ១ វិបាកមនោធាតុ ២ ។ ចិត្ត៣ នេះ ហៅថា មនោធាតុ "ធាតុដឹងបញ្ចារម្មណ៍"

៧- ហេតុឱ្យកើតមនោវិញ្ញាណធាតុ គឺ

**-អសម្ភិន្នត្តា មនស្ស** ព្រោះមនោមិនទាន់បែកធ្លាយ

**-អាបាថគតត្តា ធម្មារម្មណានំ** ព្រោះមានធម្មារម្មណ៍មកកាន់គន្លង

**-ហទយសន្និស្សិតំ** អាស្រ័យហទយវត្ថុ

**-មនសិការហេតុកំ** មានមនសិការៈជាហេតុជិត

បណ្តាបច្ច័យទាំង ៤ នេះ ពាក្យថា **មនោ** បានដល់ភវង្គចិត្តនោះរលត់ហើយក្តី មានកម្លាំងខ្សោយក្តី មិនអាចជាបច្ច័យដល់អាវជ្ជនចិត្ត ឈ្មោះថា បែកធ្លាយ, ដែលអាចជាបច្ច័យដល់អាវជ្ជនចិត្តបាន ឈ្មោះថា នៅមិនទាន់បែកធ្លាយទេ, ពាក្យថា **ព្រោះមានធម្មារម្មណ៍ មកកាន់គន្លង** គឺធម្មារម្មណ៍ មកកាន់គន្លង, ពាក្យថា **អាស្រ័យហទយវត្ថុ** គឺអាស្រ័យហទយវត្ថុ ទើបកើតឡើង វៀរហទយវត្ថុហើយក៏មិនកើត ក្នុងសេចក្តីនេះ លោកសំដៅដល់ភពដែលមានខន្ធ ៥,

ពាក្យថា **មានមនសិការជាហេតុជិត** អធិប្បាយថា កិរិយាមនោវិញ្ញាណធាតុ ញុំាងភវង្គឱ្យផ្លាស់ប្តូរទៅជាមុនសិន ទើបមនោវិញ្ញាណកើតបាន ។

មនោវិញ្ញាណធាតុ ជាចិត្តដែលអាចមានសេចក្តីដឹងអារម្មណ៍ បានច្រើនជាងបញ្ចវិញ្ញាណ និងមនោធាតុ, ក្នុងអហេតុកចិត្តនេះ មនោវិញ្ញាណធាតុ មាន ៥ គឺ មនោទ្វារាវជ្ជនចិត្ត១ អហេតុកវិបាកមនោវិញ្ញាណធាតុ៣ ហសិតុប្បាទចិត្ត ១. ដែលពិតចិត្តទាំងអស់ ៨៩ ឬ ១២១ នោះ វៀរតែទ្វិបញ្ចវិញ្ញាណ ១០ និងមនោធាតុ ៣ ហើយ ចិត្តដែលនៅសល់ ៧៦ ឬ១០៨ ទាំងអស់នោះ ជាមនោវិញ្ញាណធាតុ ។

## កិច្ច ១៤ របស់អហេតុកចិត្ត ១៨

១. ចក្ខុវិញ្ញាណ ២ ធ្វើទស្សនកិច្ច ( ឃើញរូប )
២. សោតវិញ្ញាណ ២ ធ្វើសវនកិច្ច ( ឮសំឡេង )
៣. ឃានវិញ្ញាណ ២ ធ្វើឃាយនកិច្ច ( ធុំក្លិន )

៤. ជិវ្ហាវិញ្ញាណ ២ ធ្វើសាយនកិច្ច ( ស្របរស )

៥. កាយវិញ្ញាណ ២ ធ្វើផុស្សនកិច្ច ( ប៉ះខ្ទប់សម្ផស្ស )

៦. វិបាកមនោធាតុ ២ ធ្វើសម្បដិច្ឆន្នកិច្ច ( ទទួលបញ្ចារម្មណ៍ )

៧. ឧបេក្ខាអហេតុកវិបាកមនោវិញ្ញាណធាតុ ២ ធ្វើកិច្ច ៥ គឺ

-បដិសន្ធិកិច្ច ធ្វើការបន្តក្នុងភពថ្មី

-ភវង្គកិច្ច ធ្វើការរក្សាភព

-ចុតិកិច្ច ធ្វើការឃ្លាតចាកភព

-សន្តីរណកិច្ច ធ្វើការពិចារណាអារម្មណ៍

-តទាលម្ពណកិច្ច ធ្វើការទទួលអារម្មណ៍តពីជវន

៨. សោមនស្សអហេតុកវិបាកមនោវិញ្ញាណធាតុ ១ ធ្វើកិច្ច ២ គឺ

-សន្តីរណកិច្ច ធ្វើការពិចារណាអារម្មណ៍

-តទាលម្ពណកិច្ច ធ្វើការទទួលអារម្មណ៍តពីជវន

៩. បញ្ចទ្វារាវជ្ជនចិត្ត១ ធ្វើអាវជ្ជនកិច្ច គឺការទទួលបញ្ចារម្មណ៍

១០. មនោទ្វារាវជ្ជនចិត្ត ១ ធ្វើកិច្ច ២ គឺ

-អាវជ្ជនកិច្ច គឺ ការទទួលអារម្មណ៍តាមមនោទ្វារ

-វោដ្ឋពនកិច្ច គឺ ការកំណត់អារម្មណ៍តាមបញ្ចទ្វារ

១១. ហសិតុប្បាទចិត្ត ១ ធ្វើជវនកិច្ច ការសេពសោយអារម្មណ៍ ធ្វើឱ្យកើតការញញឹមរបស់ព្រះអរហន្ត ។

## ទ្វាររបស់អហេតុកចិត្ត ១៨ គឺ

១. ចក្ខុវិញ្ញាណ ២ កើតតាមចក្ខុទ្វារ

២. សោតវិញ្ញាណ ២ កើតតាមសោតទ្វារ

៣. ឃានវិញ្ញាណ ២ កើតតាមឃានទ្វារ

៤. ជិវ្ហាវិញ្ញាណ ២ កើតតាមជិវ្ហាទ្វារ

៥. កាយវិញ្ញាណ ២ កើតតាមកាយទ្វារ

៦. បញ្ចទ្វារាវជ្ជនចិត្ត ១ កើតតាមបញ្ចទ្វារ

៧. វិបាកមនោធាតុ ២ កើតតាមបញ្ចទ្វារ

៨. មនោទ្វារាវជ្ជនចិត្ត ១

៩. អហេតុកវិបាកមនោវិញ្ញាណធាតុ ៣ } កើតតាមទ្វារទាំង ៦

១០. ហសិតុប្បាទចិត្ត ១

## វត្ថុរបស់អហេតុកចិត្ត ១៨ គឺ

១. ចក្ខុវិញ្ញាណ ២ កើតត្រង់ចក្ខុវត្ថុ
២. សោតវិញ្ញាណ ២ កើតត្រង់សោតវត្ថុ
៣. ឃានវិញ្ញាណ ២ កើតត្រង់ឃានវត្ថុ
៤. ជិវ្ហាវិញ្ញាណ ២ កើតត្រង់ជិវ្ហាវត្ថុ
៥. កាយវិញ្ញាណ ២ កើតត្រង់កាយវត្ថុ
៦. វិបាកមនោធាតុ ២
៧. អហេតុកវិបាកមនោវិញ្ញាណធាតុ៣
៨. បញ្ចទ្វារាវជ្ជនចិត្ត ១
៩. មនោទ្វារាវជ្ជនចិត្ត ១
១០. ហសិតុប្បាទចិត្ត ១

(៦–១០) កើតត្រង់ហទយវត្ថុ

## អហេតុកចិត្ត ១៨ ជាវិញ្ញាណធាតុ ៧ គឺ

-ទ្វិបញ្ចវិញ្ញាណ ១០ ជាវិញ្ញាណធាតុ ៥
-វិបាកមនោធាតុ ២
-បញ្ចទ្វារាវជ្ជនចិត្ត ១

(វិបាកមនោធាតុ ២ និង បញ្ចទ្វារាវជ្ជនចិត្ត ១) ជាមនោធាតុ ១

-អហេតុកវិបាកមនោវិញ្ញាណធាតុ ៣
-មនោទ្វារាវជ្ជនចិត្ត ១
-ហសិតុប្បាទចិត្ត ១
} ជាមនោវិញ្ញាណធាតុ១

## ចែកអហេតុកចិត្ត ១៨ ដោយន័យផ្សេង ៗ

**១. ដោយជាតិ** ជាវិបាកជាតិ ១៥ ជាកិរិយាជាតិ ៣

**២. ដោយភូមិ** ជាកាមាវចរភូមិទាំង ១៨ (ក្នុងភូមិ ៣០តាមសមគួរ)[១]

**៣. ដោយវេទនា** ជាសុខវេទនា ១ ជាទុក្ខវេទនា ១
ជាសោមនស្សវេទនា ២ ឧបេក្ខាវេទនា ១៤

**៤. ដោយហេតុ** ជានហេតុ និងជាអហេតុកចិត្តទាំង ១៨

---

១. គឺឃាន-ជិវ្ហា-កាយវិញ្ញាណ ៦ កើតក្នុងកាមភូមិ១១ ។ ចក្ខុវិញ្ញាណ២ សោតវិញ្ញាណ២ បញ្ចទ្វារាវជ្ជនៈ១ សម្បដិច្ឆន្នៈ២ សន្តីរណៈ៣ កើតក្នុងកាមភូមិ១១ រូបភូមិ១៥ ។ មនោទ្វារាវជ្ជនៈ ១ កើតក្នុងភូមិ ៣០ ។ ហសិតុប្បាទចិត្ត កើតក្នុងភូមិ ២២ គឺ កាមសុគតិ៧ រូបភូមិ១៥ ។

៥. ដោយសម្បយុត្ត ជាវិប្បយុត្តចិត្តទាំង ១៨

៦. ដោយសង្ខារ ជាអសង្ខារិកទាំង ១៨

៧. ដោយសោភណៈ ជាអសោភណចិត្ត

៨. ដោយឈាន ជាអកុសលឈាន

៩. ដោយលោក ជាលោកិយចិត្ត

១០. ដោយកិច្ច ធ្វើកិច្ចទាំង ១៤

១១. ដោយអារម្មណ៍ ទទួលអារម្មណ៍ បាន ៦

១២. ដោយទ្វារ កើតបានទ្វារ ៦

១៣. ដោយវត្ថុ កើតបានទាំង ៦ វត្ថុ

១៤. ដោយវិញ្ញាណធាតុ ជាវិញ្ញាណធាតុ ៧

## បាលីពាក្យនិគម

ឥច្ចេវំ សព្វថាបិ អដ្ឋារស អហេតុកចិត្តានិ សមត្តានិ

អហេតុកចិត្ត ១៨ ចប់បរិបូណ៌ហើយ ដោយប្រការទាំងពួង

## សរុបអហេតុកចិត្ត ១៨

- អហេតុកចិត្ត១៨
  - អកុសលវិបាក៧
    - ឧបេក្ខាសហគត៤
      - ចក្ខុវិញ្ញាណ១
      - សោតវិញ្ញាណ១
      - ឃានវិញ្ញាណ១
      - ជិវ្ហាវិញ្ញាណ១
    - ទុក្ខសហគត ១ កាយវិញ្ញាណ១
    - ឧបេក្ខាសហគត ២
      - មនោធាតុ១
      - មនោវិញ្ញាណធាតុ១
  - អហេតុកកុសលវិបាក៨
    - ឧបេក្ខាសហគត ៤
      - ចក្ខុវិញ្ញាណ១
      - សោតវិញ្ញាណ១
      - ឃានវិញ្ញាណ១
      - ជិវ្ហាវិញ្ញាណ១
    - សុខសហគត ១ ← កាយវិញ្ញាណ១
    - ឧបេក្ខាសហគត ២
      - មនោធាតុ១
      - មនោវិញ្ញាណធាតុ១
    - សោមនស្សសហគត១←មនោវិញ្ញាណធាតុ១
  - អហេតុកកិរិយា៣
    - ឧបេក្ខាសហគត ២
      - បញ្ចទ្វារាវជ្ជនចិត្ត១
      - មនោទ្វារាវជ្ជនចិត្ត១
    - សោមនស្សសហគត១ ← ហសិតុប្បាទចិត្ត១

**អហេតុកចិត្ត ១៨ ចប់**

# សំនួរ-ចម្លើយក្នុងអហេតុកចិត្ត ១៨

១. អហេតុកចិត្ត ១៨ ជាចិត្តដែលមិនមានហេតុ បើដូច្នេះ មិនជំទាស់វាទៈរបស់ព្រះពុទ្ធសាសនា ដែលពោលថា យេ ធម្មា ហេតុប្បភវា ធម៌ទាំងឡាយ ទាំងពួងណា មានហេតុ ជាដែនកើត ។ល ។ ដូច្នេះ មិនមែនឬ ?

\+ មិនជំទាស់ទេ ព្រោះពាក្យថា អហេតុកចិត្តនោះ សំដៅដល់ចិត្ត ដែលមិនមានហេតុ គឺ មិនមានលោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈ កើតរួម, មិនបាន សំដៅដល់ឧប្បត្តិហេតុ គឺ ហេតុដែលឱ្យកើតឡើងនោះទេ ។

២. អហេតុកចិត្ត (ចិត្តដែលមិនមានហេតុ) ផ្សេងពី សហេតុកចិត្ត (ចិត្តដែលមានហេតុ)យ៉ាងណា ?

\+ ផ្សេងគ្នាត្រង់អហេតុកចិត្ត មានកម្លាំងខ្សោយ សហេតុកចិត្ត មានកម្លាំងខ្លាំង ដូចដើមឈើដែលមិនមានឫសកែវ និងដើមឈើដែលមានឫសកែវ សេចក្តីមាំទាំ ក៏រមែងផ្សេងគ្នា ដូច្នេះ ។

៣. ក្នុងអហេតុកចិត្ត មានពាក្យថា ចិត្ត និងវិញ្ញាណ

ផ្សេងគ្នាយ៉ាងណា ?

+ ពាក្យថា ចិត្ត និងវិញ្ញាណ ទាំង២នេះ បើពោលដោយលក្ខណៈ ក៏ដូចគ្នា គឺ ជាធម្មជាតិដឹងអារម្មណ៍ ។ ដែលហៅថា វិញ្ញាណនោះ លោកហៅចិត្តដែលកើតតាមទ្វារ ដូចចិត្តដែលកើតត្រង់ចក្ខុទ្វារ ក៏ហៅថា ចក្ខុវិញ្ញាណ ជាដើម ចំណែកពាក្យថា ចិត្តនោះ លោកប្រើទូទៅក្នុងការដឹងអារម្មណ៍ ដូចបាលីថា វិជាននលក្ខណំ ចិត្តំ ចិត្តមានការដឹងអារម្មណ៍ ជាលក្ខណៈ

៤. ព្រោះហេតុអ្វី អហេតុកចិត្ត ១៨ ទើបមាន៣ ជាតិ ?

+ ព្រោះអហេតុកចិត្ត១៨ មាន៣ ពួក គឺ អកុសលវិបាកចិត្ត ៧ ដែលកើតឡើង ជាផលរបស់អកុសលកម្ម មួយពួក អហេតុកកុសលវិបាកចិត្ត ៨ កើតពីកុសលកម្មមួយពួក និងអហេតុកកិរិយាចិត្ត ៣ មិនមែនចិត្ត ដែលជាអកុសល កុសល និងវិបាក ជាចិត្តត្រឹមតែការធ្វើប៉ុណ្ណោះ មួយពួក ។

៥. អហេតុកចិត្ត ១៨ កាលចែកដោយវិញ្ញាណ ៧ គឺ វិញ្ញាណធាតុ ៥ មនោធាតុ១ មនោវិញ្ញាណធាតុ ១ ចិត្តទាំងនោះ មានទីអាស្រ័យកើតផ្សេងគ្នាយ៉ាងណា ?

+ វិញ្ញាណធាតុទាំងនោះ មានទីអាស្រ័យកើតផ្សេងគ្នា និងដឹងអារម្មណ៍ច្រើនតិចក៏ផ្សេងគ្នា គឺ វិញ្ញាណធាតុ ៥ អាស្រ័យបសាទ៥ គឺ ចក្ខុបសាទរូប សោតបសាទរូប ឃានបសាទរូប ជិវ្ហាបសាទរូប និងកាយបសាទរូប, មនោធាតុ ៣ គឺ បញ្ចទ្វារាវជ្ជនចិត្ត១ វិបាកមនោធាតុ២ អាស្រ័យហទយវត្ថុកើត និងមនោវិញ្ញាណធាតុ ក៏អាស្រ័យ ហទយវត្ថុកើត. ចំណែកការដឹងអារម្មណ៍ផ្សេងគ្នា គឺ វិញ្ញាណធាតុ ដឹងអារម្មណ៍បានតិច (គឺដឹងតែមួយ ៗ មានរូបារម្មណ៍ជាដើមរបស់ខ្លួន) មនោធាតុដឹងអារម្មណ៍បាន ច្រើនជាងវិញ្ញាណធាតុ (គឺដឹងបានអារម្មណ៍ទាំង៥) មនោវិញ្ញាណធាតុ ដឹងអារម្មណ៍បានច្រើនជាទីបំផុត ។

៦. ព្រោះហេតុអ្វី បានជាអកុសលវិបាកចិត្ត មិនហៅថា

អហេតុកអកុសលវិបាកចិត្ត ដូចពាក្យថា អហេតុកកុសលវិបាកចិត្ត ?

+ ព្រោះផលរបស់អកុសលនោះ ជាអហេតុកចិត្តតែម៉្យាង ចំណែកផលរបស់កុសល មានទាំងអហេតុកចិត្ត ទាំងសហេតុកចិត្ត ដើម្បីបែកផលរបស់កុសលនោះ លោកទើបប្រើពាក្យថា អហេតុកកុសលវិបាកចិត្ត ។

៧. អហេតុកចិត្តទាំង ១៨ មានវេទនាអ្វីខ្លះ ?

+ មានឧបេក្ខាវេទនា១៤ ទុក្ខវេទនា ១ សុខវេទនា ១ សោមនស្សវេទនា ២

៨. អហេតុកចិត្តទាំង ១៨ មានឧបេក្ខាវេទនា ១៤ កើតរួមនឹងអ្វីខ្លះ ?

+ អហេតុកចិត្តទាំង ១៨ មានឧបេក្ខាវេទនា ១៤ គឺ

- ទ្វិបញ្ចវិញ្ញាណ ៨ ( វៀរកាយវិញ្ញាណ២ )
- វិបាកមនោធាតុ ២
- ឧបេក្ខាហេតុកវិបាកមនោវិញ្ញាណធាតុ ២
- បញ្ចទ្វារាវជ្ជនចិត្ត ១

-មនោទ្វារាវជ្ជនចិត្ត ១ ។

៩. ព្រោះហេតុអ្វី អហេតុកវិបាកមនោវិញ្ញាណធាតុផ្នែកកុសលវិបាក ទើបមានចិត្តប្រកបដោយវេទនា ២ គឺ ឧបេក្ខា និងសោមនស្ស ចំណែកអហេតុកវិបាកមនោវិញ្ញាណធាតុផ្នែកអកុសលវិបាក មានចិត្តប្រកបដោយឧបេក្ខាប៉ុណ្ណោះ ?

+ ព្រោះវិបាកចិត្តដែលធ្វើសន្តីរណផ្សេងគ្នា គឺ អហេតុកវិបាកមនោវិញ្ញាណធាតុផ្នែកកុសលវិបាក ធ្វើកិច្ចពិចារណាអារម្មណ៍ ដែលល្អក្រៃលែង (អតិឥដ្ឋារម្មណ៍) និងអារម្មណ៍ដែលកណ្តាល, ចំណែកអហេតុកវិបាកមនោវិញ្ញាណធាតុផ្នែកអកុសលវិបាក មានការពិចារណាអារម្មណ៍ដែលមិនល្អតែម្យ៉ាង មិនមានអារម្មណ៍ ដែលមិនល្អក្រៃលែងទេ ។

១០. ព្រោះហេតុអ្វី អហេតុកកុសលវិបាកចិត្ត ទើបមាន ៨ ចំណែកអកុសលវិបាកចិត្ត មានតែ ៧ ?

+ ព្រោះអហេតុកកុសលវិបាកចិត្ត មានអតិឥដ្ឋារម្មណ៍ គឺ អារម្មណ៍ដែលល្អក្រៃលែង ទើបមានសោមនស្សអហេតុកវិបាកមនោវិញ្ញាណធាតុ ពិចារណាអារម្មណ៍ដែលល្អក្រៃលែង បន្ថែម

១ មកទៀត ចំណែកអកុសលវិបាកចិត្ត មិនមាន ។

១១. កាយវិញ្ញាណកុសលវិបាកនោះ មិនកើតព្រមនឹងសោមនស្សវេទនា ព្រោះហេតុអ្វី ?

\+ ព្រោះកាយវិញ្ញាណនោះ កើតព្រមនឹងសុខវេទនាផ្លូវកាយ មិនកើតរួមនឹងសោមនស្សវេទនា ដែលជាផ្លូវចិត្តទេ ។

១២. វិបាកដែលកើតអំពីលោភៈ ទោសៈ និងមោហៈជាមូល ធ្ងន់ខ្លះស្រាលខ្លះ ឱ្យកើតក្នុងអបាយភូមិ គឺ នរក ប្រេត អសុរកាយ និងសត្វតិរច្ឆាន មូលក៏ផ្សេងគ្នា ភូមិក៏ផ្សេងគ្នា ប្រភេទខ្លះជាអនន្តរិយកម្ម ហេតុអ្វីទើបថា ចិត្តដែលធ្វើកិច្ចបដិសន្ធិ ជាឧបេក្ខាអកុសលវិបាកមនោវិញ្ញាណធាតុ ដែលជាអហេតុកចិត្ត តែម្យ៉ាង ?

\+ ព្រោះឧបេក្ខាអកុសលវិបាកមនោវិញ្ញាណធាតុនេះ មាននាទី ធ្វើកិច្ចបដិសន្ធិក្នុងអបាយភូមិទាំងអស់ មិនថា កម្មនោះជាកម្ម ធ្ងន់ ឬស្រាល ប្រៀបដូចវត្ថុមានទម្ងន់ច្រើន ឬតិចកាលធ្លាក់ចុះ ក៏រមែងធ្លាក់ដល់ផែនដី (ឬផ្ទៃផ្សេង ៗ មិនទើលើអាកាស) ដូច្នោះ កាលសត្វនឹងទៅកើតក្នុងនរក ប្រេត

អសុរកាយ និងសត្វតិរច្ឆាន ឧបេក្ខាអកុសលវិបាក មនោវិញ្ញាណធាតុប៉ុណ្ណោះ ធ្វើកិច្ចបដិសន្ធិតែម្យ៉ាង ។

១៣. សត្វក្នុងនរក រមែងឃើញរូប ស្តាប់សំឡេង ធុំក្លិន ស្រូបរស ពាល់ត្រូវសម្ផស្ស ដែលមិនល្អទាំងនោះឬ ?

\+ សត្វនរកទាំងនោះ រមែងបានទទួលផលរបស់កម្មអាក្រក់ប៉ុណ្ណោះ តែមានពេលខ្លះ ចក្ខុវិញ្ញាណកុសលវិបាកជាដើមរបស់ពួកសត្វនរកទាំងនោះ រមែងកើតបាន ដូចកាលដែលព្រះមោគ្គល្លានជាដើម ចុះទៅប្រោសសត្វនរក បាននិមិត្តផ្កាឈូកក្នុងនរក គង់នៅលើផ្កាឈូក សម្តែងធម្មកថាដល់សត្វនរក, កាលនោះ ចក្ខុវិញ្ញាណ ដែលជាកុសលវិបាកជាដើម ក៏កើតឡើង ព្រោះឃើញព្រះថេរៈ ស្តាប់សំឡេងសម្តែងព្រះធម៌ ធុំក្លិនចីវររបស់ព្រះថេរៈ (មានក្លិនចន្ទន៍ព្រោះព្រះថេរៈ សំរាកនៅក្នុងព្រៃខ្លឹមចន្ទន៍) កាលព្រះថេរៈបណ្តាលឱ្យមាន ភ្លៀង សត្វទាំងនោះ ក៏បានផឹកទឹក កាលបណ្តាលឱ្យមាន ខ្យល់បក់មករំភើយ ៗ ក៏បានសុខផ្សវកាយ ដែលជាអារម្មណ៍ល្អ ៗ កុសលវិបាក ក៏កើតឡើងតាមទ្វារទាំង ៦ ។

១៤. ពួកនាគក្តី ពួកគ្រុឌ ពួកវេមានិកប្រេតក្តី ពួកសេះមង្គល ដំរីមង្គលរបស់ស្តេចចក្រពត្តិក្តី សុទ្ធតែនៅទីល្អ ស៊ីល្អ និងមានឫទ្ធិ អំណាចច្រើន វិបាកអ្វីធ្វើបដិសន្ធិកិច្ចឱ្យកើតមក ?

+ អកុសលវិបាកចិត្ត ធ្វើកិច្ចបដិសន្ធិកិច្ចឱ្យកើតមក តែពួកខ្លះ មានការនៅទីល្អ ស៊ីល្អ ព្រោះផលរបស់កុសលកម្ម ឱ្យផលក្នុងបវត្តិកាល ។

១៥. បញ្ចទ្វារាវជ្ជនចិត្ត និងមនោទ្វារាវជ្ជនចិត្ត ទាំង២ នេះ ជាអហេតុកកិរិយាចិត្ត និងធ្វើអាវជ្ជកិច្ច ដូចគ្នា ព្រោះហេតុអ្វី បានជាបញ្ចទ្វារាវជ្ជនចិត្ត ជាមនោធាតុ ដឹងអារម្មណ៍តិច ចំណែកមនោទ្វារាវជ្ជនចិត្ត ជាមនោវិញ្ញាណធាតុ ដឹងអារម្មណ៍បានច្រើនជាង ?

+ ដែលផ្សេងគ្នា ព្រោះបញ្ចទ្វារាវជ្ជនចិត្ត ធ្វើអាវជ្ជកិច្ច គឺ រាវរកអារម្មណ៍ ដែលមកប៉ះខ្ទប់តាមបញ្ចទ្វារប៉ុណ្ណោះ មិនមាននាទីដទៃ ចំណែកមនោទ្វារាវជ្ជនចិត្ត ធ្វើកិច្ច គឺ រាវរកអារម្មណ៍តាមមនោទ្វារ និងធ្វើនាទីវោដ្ឋព្វនកិច្ច គឺ កាត់ក្តីអារម្មណ៍តាមបញ្ចទ្វារផង ទើបដឹងអារម្មណ៍ច្រើនជាង ។

១៦. កិរិយាមនោធាតុនិងវិបាកមនោធាតុ ជាមនោធាតុនិងធ្វើកិច្ចតាមបញ្ចទ្វារដូចគ្នា ព្រោះហេតុអ្វី បានជាមនោធាតុនេះ ជាកិរិយាចិត្តផង ជាវិបាកចិត្តផង ?

\+ ព្រោះកិរិយាមនោធាតុធ្វើអាវជ្ជកិច្ចនឹករាវរកអារម្មណ៍ដែលមកប៉ះខ្ទប់, កើតឡើង ព្រោះអារម្មណ៍ និងវត្ថុប៉ះខ្ទប់គ្នា មិនមែនជាផលរបស់កុសល ឬអកុសលកម្មទេ; ចំណែកវិបាកមនោធាតុ២ ជាវិបាករបស់កុសល ឬអកុសលកម្ម កើតឡើងទទួលផលរបស់កម្ម ។

១៧. មនោទ្វារាវជ្ជនចិត្ត មានឈ្មោះមួយយ៉ាងទៀតថា វោដ្ឋព្វនចិត្ត មានឈ្មោះក៏ផ្សេងគ្នា កិច្ចនាទីក៏ផ្សេងគ្នាដូចគ្នា តែជាបច្ច័យឱ្យដល់ជវនប៉ុណ្ណោះ ហេតុអ្វី ទើបពោលថា ជាចិត្តតែមួយ ?

\+ ការដែលចិត្ត ២ នេះ ផ្សេងគ្នា ព្រោះមានកិច្ចនាទីផ្សេងគ្នា គឺ មនោទ្វារាវជ្ជនចិត្ត ធ្វើអាវជ្ជនកិច្ចតាមមនោទ្វារ

វោដ្ឋពូនចិត្ត ធ្វើវោដ្ឋពូនកិច្ចតាមបញ្ចទ្វារ, ចំណែកដែលថា ចិត្ត ២ នេះ ជាចិត្តតែមួយ ព្រោះមានចេតសិកប្រកបប៉ុនគ្នា និងជាកិរិយាចិត្តដូចគ្នា ។

១៨. អហេតុកចិត្ត ដែលជាវិបាក និងកិរិយាចិត្ត មិនមានហេតុប្រកប មានកម្លាំងខ្សោយ មិនដូចសហេតុកចិត្ត ជាចិត្តដែលមានកម្លាំងច្រើនជាង តែមនោទ្វារាវជ្ជនចិត្ត ដែលជាអហេតុកកិរិយាចិត្តនោះ មិនកើតក្នុងអសញ្ញសត្តព្រហ្ម និងក្នុងមគ្គបុគ្គល, ក្រៅពីនោះ មនោទ្វារាវជ្ជនចិត្ត រមែងកើត បានគ្រប់ភូមិ គ្រប់បុគ្គល គ្រប់ទ្វារ ទទួលបានគ្រប់អារម្មណ៍ និងគ្រប់កាល នឹងថា ចិត្តនេះ មានកម្លាំងខ្សោយយ៉ាងណា ?

+ ចិត្តនេះ ជាចិត្តទូលំទូលាយ កើតបានច្រើនជាងចិត្តដទៃដូចពោលមក លោកហៅមនោទ្វារាវជ្ជនចិត្តនេះ ថា មហាគជៈ ក្នុងអដ្ឋសាលិនីនេះ បានពោលទុកថា “វត្ថុដែលមិនជាអារម្មណ៍របស់ចិត្តនេះ មិនមានទេ” និងពោលទុកទៀត ថា “ចិត្ត

ដែលមិនមែនជាសព្វញ្ញុតញ្ញាណ តែមានគតិដូច សព្វញ្ញុតញ្ញាណ គឺ មនោវិញ្ញាណធាតុ ដែលជាកិរិយាចិត្ត សហគតដោយឧបេក្ខា” ក៏គឺ មនោទ្វារាវជ្ជនចិត្ត នោះឯង លោកពោលថា “ចិត្តនេះ មានកម្លាំងខ្សោយ និងចិត្តនេះ ធ្វើកិច្ចជាអាវជ្ជនៈឱ្យដល់ជវនហើយ ក៏រលត់ទៅ” ។

១៩. ហសិតុប្បាទចិត្ត (ចិត្តញញឹម) របស់ព្រះពុទ្ធ ឬ ព្រះអរហន្ត ព្រោះហេតុអ្វីទើបពោលថា ហសិតុប្បាទចិត្ត ជាអសោភណចិត្តទៅវិញ ?

+ ហសិតុប្បាទចិត្ត ជាអសោភណចិត្តនោះ សំដៅយកចិត្តមិនមានសោភណចេតសិកប្រកប ។

២០. ហសនចិត្ត គឺចិត្តដែលញញឹមឬសើច មានប៉ុន្មាន អ្វីខ្លះ ?

+ ហសនចិត្ត មាន ១៣ គឺ

១. បុថុជ្ជន ញញឹមឬសើច ដោយចិត្ត ៨ គឺ

សោមនស្សមហាកុសលចិត្ត៤ សោមនស្សលោភមូលចិត្ត៤

២. ព្រះសេក្ខបុគ្គល ញញឹម ឬសើច ដោយចិត្ត ៦ គឺ

សោមនស្សលោភមូលចិត្ត ដែលមិនប្រកបដោយទិដ្ឋិ២

សោមនស្សមហាកុសលចិត្ត ៤

៣. ព្រះអសេក្ខបុគ្គល ញញឹមដោយចិត្ត ៥ គឺ

សោមនស្សមហាកិរិយាចិត្ត ៤

សោមនស្សហសិតុប្បាទចិត្ត ១

២១. ក្នុងសុពោធាលង្ការ ពោលហសនចិត្តទុកយ៉ាងណា ?

+ ហសនចិត្ត ដែលពោលទុកក្នុងសុពោធាលង្ការ មាន៦ គឺ

១. សិតៈ ញញឹម មិនឃើញធ្មេញ របស់ព្រះពុទ្ធ (គឺញញឹមព្រះឱស្ឋ)

២. ហសិតៈ ការញញឹមល្មមឃើញអញ្ចាញធ្មេញ របស់ព្រះអរហន្ត ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន និង

បុថុជ្ជន

៣. វិហសិតៈ សើចមានសំឡេងស្រាល ៗ កើតនឹងចិត្ត របស់ព្រះអរិយៈ ៣ គឺ ព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន និងបុថុជ្ជន

៤. អតិហសិតៈ សើចមានសំឡេងខ្លាំង កើតដល់ព្រះសកទាគាមី ព្រះសោតាបន្ន និងបុថុជ្ជន

៥. ឧបហសិតៈ សើចដរាបញ័រកាយ ជាការសើចរបស់បុថុជ្ជន

៦. អវហសិតៈ សើចដរាបហូរទឹកភ្នែក ជាការសើចរបស់បុថុជ្ជន

២២. ព្រះអរហន្តញញឹមដោយមហាកិរិយាចិត្ត ៤ ដែលជាសោមនស្ស ក៏បានដែរ មិនមែនឬ ? ហេតុអ្វី បានជាត្រូវញញឹម ដោយហសិតុប្បាទចិត្តទៀត ?

+ មហាកិរិយាចិត្ត ដែលជាសោមនស្សនោះ តាមប្រក្រតី

មានអារម្មណ៍ជាឱឡារិការម្មណ៍ (វៀរលែងតែខណៈធ្វើនាទីបច្ចវេក្ខណៈ ទើបជាអនោឡារិការម្មណ៍ អារម្មណ៍ល្អិត) ចំណែកហសិតុប្បាទចិត្ត មានអារម្មណ៍ ជាអនោឡារិការម្មណ៍ ដឹងបានដោយអភិញ្ញាចិត្ត ឬដោយបច្ចវេក្ខណញ្ញាណ ។

<u>**ក្នុងបរមត្ថទីបនីដីកា**</u> ពោលទុកថា ៖

ខីណាសវា អនោឡារិកេសុ យេន ចិត្តេន សតំ ធាតុករោន្តិ តស្សេតំ ឆាមំ ន ហិ ខីណាសវា លោកិយមហាជនា វិយ រជ្ជនិយាតិ ភាវេន ឱឡារិកេសុ ហាសនីយវត្ថុសុ ហសន្តីតិ

ព្រះខីណាស្រពទាំងឡាយ រមែងធ្វើការញញឹមឱ្យប្រាកដក្នុងអារម្មណ៍ ដែលជាអនោឡារិក ដោយចិត្តណា នេះជាឈ្មោះរបស់ចិត្តនោះ លោកិយមហាជនទាំងឡាយ រមែងសើច ឬញញឹមដោយកាមគុណារម្មណ៍ តែព្រះអរហន្តទាំងឡាយ មិនជាដូច្នោះទេ ។

២៣. ឱឡារិការម្មណ៍ ផ្សេងគ្នាពីអនោឡារិការម្មណ៍ យ៉ាងណា ?

+ ឱឡារិការម្មណ៍ បានដល់ អារម្មណ៍ដែលធំ ឬអារម្មណ៍ដែលដឹងដោយចិត្តធម្មតា ដូចចក្ខុវិញ្ញាណឃើញពណ៌រូប សោតវិញ្ញាណ ឮសំឡេងជាដើម ចំណែកអនោឡារិការម្មណ៍ ជាអារម្មណ៍ដែលល្អិត មិនអាចដឹងបានដោយចិត្តធម្មតា រមែងដឹងបានដោយអភិញ្ញាចិត្ត ឬបច្ចវេក្ខណញ្ញាណប៉ុណ្ណោះ ។

២៤- ព្រះអរហន្តឃើញប្រេត ដែលកំពុងត្រូវភ្លើងឆេះ ដែលជាអនិដ្ឋារម្មណ៍ គឺ អារម្មណ៍ដែលមិនគួរប្រាថ្នា ការឃើញ ដូច្នោះ ជាវិបាករបស់អកុសលកម្ម ឬកុសលកម្ម ?

+ ការឃើញអនិដ្ឋារម្មណ៍ ជាអកុសលវិបាក ការឃើញនោះ ទឹងថា ជាព្រះអរហន្តក៏ដោយ និងឃើញដោយអភិញ្ញាក៏ដោយ មិនមានអ្នកណាអាចកែត្រឡប់វិបាកនោះ ឱ្យទៅជាយ៉ាងដទៃបានទេ ។

២៥. ហសិតុប្បាទចិត្ត របស់ព្រះអរហន្ត មានគ្រប់ ៗភូមិ ឬយ៉ាងណា ?

+ ហសិតុប្បាទចិត្ត របស់ព្រះអរហន្ត មានក្នុងកាមភូមិ រូបភូមិ មិនមានក្នុងអរូបភូមិ ព្រោះក្នុងអរូបភូមិ មិនមានរូប

**ចប់ បញ្ហាក្នុងអហេតុកចិត្ត**

**ចប់ អហេតុកចិត្ត ១៨**

# សោភណចិត្ត

## សង្គហគាថា

៥. បាបាហេតុកមុត្តានិសោភណានីតិ វុច្ចរេ
ឯកូនសដ្ឋី ចិត្តានិ អថេកនវុតីបិ វា ។

*ចិត្តទាំងឡាយដែលផុតចាកអកុសលចិត្ត ១២ និង អហេតុកចិត្ត ១៨ នោះ ឈ្មោះថា សោភណចិត្ត មានចំនួន ៥៩ ឬ ៩១ ។*

*គាថានេះ ព្រះដីកាចារ្យ បានពោលពង្រីកសេចក្តីថា "ព្រះអនុរុទ្ធាចារ្យកាលសម្តែងចិត្ត ៣០ គត់ ដោយអំណាចនៃអកុសលចិត្ត ១២ និងអហេតុកចិត្ត ១៨ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីតាំងវោហារ (ឈ្មោះ) ចិត្តដែលក្រៅពីអកុសលចិត្ត និងអហេតុកចិត្តទាំងនោះថា សោភណៈ ទើបពោលពាក្យថា ចិត្តទាំងឡាយដែលក្រៅអំពីបាបចិត្ត និងអហេតុកចិត្ត ដូច្នេះជាដើម ។*

## សោភណចិត្ត ៤ ប្រភេទ គឺ

១. កាមាវចរសោភណចិត្ត ២៤
២. រូបាវចរសោភណចិត្ត ១៥
៣. អរូបាវចរសោភណចិត្ត ១២
៤. លោកុត្តរសោភណចិត្ត ៨ ឬ ៤០
រួមសោភណចិត្តមានចំនួន ៥៩ ឬ ៩១ ។

# កាមាវចរសោភណ

## សង្គហគាថា

៦. វេទនាញាណសង្ខារ ភេទេន ចតុវីសតិ
សហេតុកាមាវចរ បុញ្ញបាកក្រិយា មតា ។

សោភណចិត្ត២៤ គឺ កុសលចិត្ត៨ វិបាកចិត្ត៨ កិរិយាចិត្ត៨ ដែលព្រះសម្មាសម្ពុទ្ធសម្ដែងហើយ ផ្សេងគ្នា ដោយវេទនា ញាណ និងសង្ខារ ។

## អធិប្បាយ សង្គហគាថា

ក្នុងសង្គហគាថាទី ៦ ពាក្យថា កុសលចិត្ត វិបាកចិត្ត និងកិរិយាចិត្ត ដែលជាកាមាវចរសហេតុកចិត្ត លោកពោលទុក ២៤ ដោយសេចក្ដីផ្សេងគ្នានៃវេទនា ញាណ និងសង្ខារ ក្នុងចិត្ត មួយ ៗ គឺ ៖

-ដោយសេចក្ដីផ្សេងគ្នានៃវេទនា ក៏ជាចិត្ត ២

-ដោយសេចក្ដីផ្សេងគ្នានៃញាណ ក៏ជាចិត្ត ៤

-ដោយសេចក្ដីផ្សេងគ្នានៃសង្ខារ ក៏ជាចិត្ត ៨

## កាមាវចរសោភណចិត្ត ២៤ គឺ

## មហាកុសលចិត្ត៨ មហាវិបាកចិត្ត៨ មហាកិរិយាចិត្ត៨

ឥឡូវនេះ ព្រះអនុរុទ្ធាចារ្យ ប្រាប្ធានឹងសម្ដែងកាមាវចរកុសលចិត្តមុន បន្ទាប់ពីនេះ នឹងសម្ដែងវិបាករបស់កាមាវចរកុសលចិត្ត ក្នុងលំដាប់នៃវិបាកនោះ នឹងសម្ដែងកាមាវចរកិរិយាចិត្ត ដែលរាប់ជាប់ក្នុងភូមិតែមួយជាមួយនឹងវិបាកនោះ

ដែលក្នុងប្រភេទនីមួយ ៗ មានចិត្ត ៨ ដោយសេចក្ដីផ្សេងគ្នានៃវេទនា(ការសោយអារម្មណ៍) ញាណ(បញ្ញា) និងសង្ខារ(ការបបួល) ព្រោះក្នុងបណ្ដាសោភណចិត្តទាំងនោះ លោកលើកកាមាវចរចិត្តប៉ុណ្ណោះឡើងសម្ដែងមុន សូម្បីក្នុងបណ្ដាកាមាវចរចិត្តទាំងនោះ ក៏មានកុសលជាខាងដើម ទើបព្រះដីកាចារ្យពោលពាក្យជាដើមថា "**សោមនស្ស សហគតំ** : ចិត្តសហគតដោយសោមនស្ស" ដូច្នេះ ។ សោភណចិត្ត ជាចិត្តអ្វី ?

សោភណចិត្តនោះ ជាចិត្តដែលមានសោភណចេតសិកប្រកប ជាចិត្តល្អស្អាត ផុតពីមន្ទិល គឺ កិលេសជាដើម ។

**សោភណ** មានវចនត្ថៈថា **សោភណេហិ យុត្តានីតិ** = **សោភណានិ** ចិត្តដែលប្រកបដោយធម៌ដ៏ល្អស្អាត ឈ្មោះថាសោភណចិត្ត ។

ធម៌ដែលល្អ លោកហៅថា សោភណៈ ក៏សោភណ

ធម៌នេះ សំដៅដល់ចេតសិកធម៌ មានសទ្ធា សតិ ហិរិ និង ឱត្តប្បៈជាដើម កាលធម៌ គឺ ចេតសិកទាំងនេះ ប្រកបក្នុង ចិត្តណា ចិត្តនោះ ក៏ហៅថា សោភណចិត្ត ។

**មហាកុសលចិត្ត ៨ គឺ**

១, **សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** : មហាកុសលចិត្តកើតឡើង ព្រមដោយ សោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ

២, **សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** : មហាកុសលចិត្តកើតឡើង ព្រមដោយ សោមនស្សវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ

៣, **សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** : មហាកុសលចិត្តកើតឡើង ព្រមដោយ សោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ

៤, **សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ**

**មហាកុសលចិត្តំ** : មហាកុសលចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ

**៥, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** : មហាកុសលចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ

**៦, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** : មហាកុសលចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ

**៧, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** : មហាកុសលចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ

**៨, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** : មហាកុសលចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ ។

## អធិប្បាយ មហាកុសលចិត្ត ៨

ក្នុងបណ្ដាកុសលចិត្ត ៨ នោះ (ទី ១) ក្នុងកាលណា បុគ្គលដែលបរិបូរណ៍ដោយទេយ្យធម៌ (វត្ថុដែលគប្បីឱ្យ) និងបដិគ្គាហក(អ្នកទទួល)ជាដើម ឬហេតុនៃសោមនស្សយ៉ាងដទៃ មានសេចក្ដីត្រេកអរីករាយ ធ្វើសម្មាទិដ្ឋិឱ្យប្រព្រឹត្តទៅ ដោយន័យថា "ទានដែលឱ្យហើយមានផល" ដូច្នេះជាដើម ទុកខាងមុខ (គឺ ធ្វើសេចក្ដីគោរព) មិនរាថយ មិនចាំបាច់ឱ្យអ្នកដទៃណាមកបបួលទេ ប្រឹងប្រែងធ្វើបុណ្យ មានការឱ្យទានជាដើម ក្នុងកាលនោះ ចិត្តរបស់បុគ្គលនោះ ជាចិត្តដែលសហគតដោយសោមនស្សសម្បយុត្តដោយញាណ ជាអសង្ខារិក ។

កុសលចិត្តទី ២ ក៏កាលណា បុគ្គលមានសេចក្ដីត្រេកអរីករាយ ដោយន័យដូចដែលពោលហើយ (ក្នុងកុសលចិត្តទី ១)នុ៎ះឯង មានសម្មាទិដ្ឋិទុកនៅខាងមុខ តែចិត្តរារែកដោយភាពជាអ្នកកំណាញ់ (គឺ មិនចង់ឱ្យ) ឬត្រូវ

អ្នកដទៃមកបបួល ទើបធ្វើបុណ្យក្នុងកាលនោះ ចិត្តរបស់បុគ្គលនោះឯង (រមែងជាចិត្តដែលសហាគតដោយសោមនស្ស សម្បយុត្តដោយញាណ) ជាសសង្ខារិក ។

កុសលចិត្តទី ៣ មួយទៀត ក្នុងកាលណា ក្មេងឥតដឹងក្តី ដែលធ្លាប់បានឃើញការបដិបត្តិរបស់ជនជាញាតិ ឃើញភិក្ខុទាំងឡាយ ហើយកើតសោមនស្ស រមែងឱ្យវត្ថុដែលមាននៅក្នុងដៃយ៉ាងណាមួយ ឬរមែងសំពះដោយរួសរាន់ ក្នុងកាលនោះ ចិត្តទី ៣ (ព្រមដោយសោមនស្ស មិនប្រកបដោយញាណ ជាអសង្ខារិក) រមែងកើតឡើងដល់ពួកក្មេងដែលឥតដឹងក្តីនោះ ។

កុសលចិត្តទី ៤ មួយទៀត ក្នុងកាលណា ក្មេងឥតដឹងក្តីទាំងនោះ ត្រូវពួកញាតិឱ្យឧស្សាហ៍ (បបួល)ថា អ្នកចូរឱ្យចូរសំពះ ដូច្នេះ ក៏បដិបត្តិតាម ក្នុងកាលនោះ ចិត្តទី ៤ (ព្រមដោយសោមនស្ស មិនប្រកបដោយញាណ ជាសសង្ខារិក) របស់ក្មេងនោះ រមែងកើតឡើង ។

## កុសលចិត្តកើតព្រមដោយឧបេក្ខា ៤

កុសលចិត្ត ៤ ក្រោយនេះ ជាចិត្តសហគតដោយឧបេក្ខាវេទនា លោកពោលទុកថា ម្យ៉ាងទៀត ក្នុងកាលណាបុគ្គលមិនបរិបូរណ៍ ដោយទេយ្យធម៌ និងបដិគ្គាហកៈជាដើម ឬ មិនមានហេតុឱ្យសោមនស្សយ៉ាងដទៃកើតឡើង ទើបជាអ្នកវៀរចាកសោមនស្សវេទនា ក្នុងវិកប្បទាំង ៤ (គឺ ក្នុងការដែលកំណត់ទុកទាំង ៤) ក្នុងកាលនោះ កុសលចិត្តក៏សហគតដោយឧបេក្ខា ៤ ដែលនៅសល់ (គឺ ចិត្តសហគតដោយឧបេក្ខា ប្រកបដោយញាណ ជាអសង្ខារិក ១ ចិត្តសហគតដោយឧបេក្ខា ប្រកបដោយញាណ ជាសសង្ខារិក ១ ចិត្តសហគតដោយឧបេក្ខា ប្រាសចាកញាណ ជាអសង្ខារិក ១ ចិត្តសហគតដោយឧបេក្ខា ប្រាសចាកញាណ ជាសសង្ខារិក ១) រមែងកើតឡើងឯង ៗ

## វិធីរាប់កុសលចិត្ត ដោយពិស្តារ

<u>ក្នុងអភិធម្មត្ថសង្គហបាលីដីកា</u> អធិប្បាយទុកថា ៖

**បិ** ស័ព្ទ ក្នុងបទថា **អដ្ឋបិ** នេះ រមែងប្រមូលមកនូវចិត្តច្រើនយ៉ាង ដោយអំណាចនៃបុញ្ញកិរិយាវត្ថុ ១០ ជាដើម ពិតណាស់ ដូចព្រះអាចារ្យទាំងឡាយ បានចងគាថាទុកថា ៖

កាមេន បុញ្ញវត្ថូហិ  គោចរាធិបតីហិ
កម្មហីនាធិតោ ចេវ  គណេយ្យ នយកោវិទោតិ

***អ្នកឆ្លាតក្នុងន័យ គប្បីរាប់នូវចិត្តទាំងឡាយ ដោយបុញ្ញកិរិយាវត្ថុ ១០ ដោយគោចរ គឺ អារម្មណ៍ ៦ ដោយអធិបតី ៤ ដោយកម្ម ៣ ដោយចិត្តទន់ទាបជាដើម ៣ តាមលំដាប់ ។***

គប្បីជ្រាបវិធីរាប់ កុសលចិត្តនោះ យ៉ាងនេះគឺ ៖

១. មហាកុសលចិត្ត៨ គុណនឹងបុញ្ញកិរិយាវត្ថុ១០ ជា ៨០
២. មហាកុសលចិត្ត៨០ គុណនឹងអារម្មណ៍៦ ជា ៤៨០
៣. ចិត្ត៤៨០ បែកជា ២ពួក គឺ ញាណវិប្បយុត្ត ២៤០

ញាណសម្បយុត្ត ២៤០ ដូច្នេះ ។

+ ចិត្តវិប្បយុត្តចាកញាណ ២៤០ គុណនឹងអធិបតី ៣ បាន ៧២០,

+ ចិត្តដែលសម្បយុត្តដោយញាណ ២៤០ គុណនឹងអធិបតី៤ បាន ៩៦០, រួមចិត្ត ១៦៨០ ។[១]

៤. ចិត្ត ១៦៨០ នោះ គុណដោយកម្ម៣ មានកាយកម្មជាដើម = ៥.០៤០

៥. ចិត្ត ៥.០៤០ នោះ គុណដោយចិត្ត ៣ គឺ ដែលទន់ទាប កណ្តាល និងប្រណីត ជាចិត្ត ១៥.១២០ ។

កាមាវចរកុសលចិត្តដែលរាប់ចំនួនបានដល់ ១៥.១២០ នោះ បើសម្តែងសេចក្តីឱ្យល្អិតទៀត ដូចដោយកាល និង

---

១. ព្រះពុទ្ធត្ថេរាប់ទុកក្នុងអភិធម្មាវតារត្រង់ទីនេះ មិនចែកជាពីរទេ គឺគុណនឹងបួនទាំងអស់ បាន ១.៩២០ លទ្ធផលចុងក្រោយ បាន ១៧.២៨០ ។

ទោសៈទាំងអស់ ក៏នឹងរាប់បានច្រើនណាស់ ។

## អធិប្បាយ ពាក្យថា កុសល

កុសល គឺ អ្វី ?

ក្នុងអភិធម្មត្ថវិភាវិនី លោកធ្វើវិគ្រោះ កុសល សព្ទ ទុក ៣ ន័យដូច្នេះ គឺ ៖

**១. កុច្ឆិតេ បាបធម្មេ សលយន្តិ កម្បេន្តិ ហឹសេន្តិ អបគមេន្តីតិ វា = កុសលានិ** ឈ្មោះថា កុសល ព្រោះអត្ថថា ទម្លាយបាបធម៌ដែលគួរខ្ពើម គឺ រមែងញ៉ាំងបាបធម៌នោះឱ្យញាប់ញ័រ ឬថា រមែងបៀតបៀន ឬរមែងឱ្យប្រាសចាកទៅ (កាមកុសល មហគ្គតកុសល លោកុត្តរកុសល ដោយលំដាប់) ។

**២. កុច្ឆិតាការេន សន្តានេ សយនតោ បវត្តនតោ កុសសង្ខាតេ បាបធម្មេ លុនន្តិ ឆិន្ទន្តីតិ = កុសលានិ :** ឈ្មោះថា កុសល ព្រោះអត្ថថា កាត់ គឺ បៀតបៀនបាបធម៌

ទាំងឡាយ ដែលឈ្មោះថា កុសៈ ព្រោះដេកជាប់រឿយ ៗ គឺប្រព្រឹត្តទៅក្នុងសន្តាន ដោយអាការដែលគួរខ្ពើម ។

**៣. កុច្ឆិតេ បាបធម្មេ សានតោ តនុករណតោ ឱសានករណតោ វា កុសសង្ខាតេន ញាណេន សទ្ធាទិធម្មជាតេន វា លាតព្វានិ សហជាតឧបនិស្សយភាវេន យថារហំ បវត្តេតព្វានីតិ = កុសលានិ :** ឈ្មោះថា កុសល ព្រោះអត្ថថា ដែលបុគ្គលគប្បីកាត់ គឺ គប្បីឱ្យប្រព្រឹត្តទៅដោយភាពជាសហជាតៈ និងឧបនិស្ស័យតាមសមគួរដោយញាណ ឈ្មោះថា កុសៈ ឬថា ដោយសេចក្តីកើតឡើងនៃធម៌ មានសទ្ធាជាដើម ព្រោះញ៉ាំងបាបធម៌ដែលគួរខ្ពើមឱ្យស្រោល ឬឱ្យស្រោលខ្លះ ឱ្យអស់ជាសមុច្ឆេទ ។

## កុសល មានអត្ថ ៥ យ៉ាងគឺ

១. *អារោគ្យត្ថ* មានអត្ថថា មិនមានរោគ គឺ មិនមានកិលេស មានរាគៈ ទោសៈ និងមោហៈជាដើម ដែលឈ្មោះថា រោគ ព្រោះចាក់ដោត គឺ ប្រទូសរ៉ាយចិត្តឱ្យទុព្វល ។

***រោគ*** មានវិគ្រោះស័ព្ទថា ៖

***រុជ្ជតីតិ = រោគោ*** ធម្មជាតិណា រមែងចាក់ដោតហេតុនោះ ធម្មជាតិនោះ ឈ្មោះថា រោគ ។

២. ***សុន្ទរត្ថោ*** មានអត្ថថា ជាធម្មជាតិល្អស្អាត គឺ ជាប្រយោជន៍ ដល់សត្វទាំងឡាយ

៣. ***ឆេកត្ថោ*** មានអត្ថថា ឆ្លាតវាងវៃ

៤. ***អនវជ្ជត្ថោ*** មានអត្ថថា មិនមានទោសដែលគួរតិះដៀល

៥. ***សុខវិបាកត្ថោ*** មានអត្ថថា មានសេចក្តីសុខជាវិបាក

## អធិប្បាយពាក្យថា បុញ្ញ “បុណ្យ”

ពាក្យថា បុញ្ញ ប្រែថា បុណ្យ ប្រើជំនួសពាក្យថា កុសល

បុញ្ញ មានវិគ្រោះស័ព្ទថា ៖

**អត្តនោ សន្តានំ បុនាតិ សោធេតីតិ = បុញ្ញំ** ធម្មជាតិណា រមែងជម្រះ គឺ រមែងញ៉ាំងសន្តានរបស់ខ្លួនឱ្យបរិសុទ្ធ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា បុណ្យ ។

## លក្ខណាទិចតុក្កៈរបស់កុសល

១. *អនវជ្ជសុខវិបាកត្តលក្ខណំ* មានវិបាកជាសុខដែលមិនមានទោស ជាលក្ខណៈ

២. *អកុសលវិទ្ធំសនរសំ* មានការកំចាត់អកុសល ជាកិច្ច

៣. *វោទានបច្ចុប្បដ្ឋានំ* មានភាពផូរផង់ ជាអាការប្រាកដ

៤. *យោនិសោមនសិការបទដ្ឋានំ* មានយោនិសោមនសិការៈ ជាហេតុជិត ។

ពាក្យថា **កុសលធម៌មានវិបាកជាសុខ មិនមានទោសជាលក្ខណៈ** គឺ កុសលធម៌ដែលឱ្យផលជាសុខតាមផ្លូវកាយ ហៅថា កាយិកសុខ, ឱ្យផលជាសុខតាមផ្លូវចិត្ត ហៅថា ចេតសិកសុខ ។

ពាក្យថា **មានការកំចាត់អកុសលជាកិច្ច** គឺ ខណៈដែលកុសលចិត្តកើតឡើងនោះ រមែងលះអកុសលធម៌ គឺ លោភៈ ទោសៈ មោហៈជាដើម ដោយការប្រហារ ៣ យ៉ាង

**១. តទង្គប្បហាន** លះជាខណៈ ៗ

**២. វិក្ខម្ភនប្បហាន** លះដោយការគ្របសង្កត់របស់ឈាន

**៣. សមុច្ឆេទប្បហាន** លះដោយកាត់ផ្តាច់របស់អរិយមគ្គ ។

ពាក្យថា **មានភាពផូរផង់ ជាអាការប្រាកដ** គឺ ក្នុងខណៈដែលកុសលចិត្តកើតឡើងនោះ ចិត្តរមែងផូរផង់ ប្រាសចាកកិលេស មានលោភៈ ទោសៈ មោហៈជាដើម ។

ពាក្យថា **មានយោនិសោមនសិការៈ ជាហេតុជិត** គឺ

មានការពិចារណា ដោយប្រពៃ ក្នុងរូប ( ពណ៌ )ដែលប្រាកដ ក្នុងសំឡេងដែលប្រាកដ ក្នុងក្លិនដែលប្រាកដ ក្នុងរសដែលប្រាកដ ក្នុងផោដ្ឋព្វៈដែលប្រាកដ ក្នុងធម៌ដែលប្រាកដ ព្រោះយោនិសោមនសិការៈនេះ ជាខាងដើមរបស់កុសលធម៌

**លក្ខណាទិចតុក្កៈរបស់កុសលចិត្ត** ( ន័យមួយទៀត )

១. ***អនវជ្ជលក្ខណមេវ*** កុសលមានសភាព មិនមានទោស ជាលក្ខណៈ

២. ***វោទានភាវរសំ*** មានភាពផូរផង់ ជាកិច្ច

៣. ***ឥដ្ឋវិបាកបច្ចុប្បដ្ឋានំ*** មានវិបាកដែលគួរត្រេកអរ ជាអាការប្រាកដ

៤. ***យថាវុត្តបទដ្ឋានមេវ*** មានហេតុជិតតាមដែលពោលហើយនោះឯង ។

ពាក្យថា ***កុសលមានសភាពមិនមានទោស ជាលក្ខណៈ*** បានដល់ លក្ខណៈដែលទូទៅរបស់កុសលនោះ មិនមាន

ទោស មិនដូចលក្ខណៈរបស់កិលេស មានលោភៈជាដើម ។

ពាក្យថា **មានភាពផូរផង់ជាកិច្ច** បានដល់ ជាសម្បត្តិរស គឺ កិច្ចដែលបរិបូរណ៍ហើយ ទើបធ្វើឱ្យផូរផង់ក្នុងខណៈនោះ

ពាក្យថា **មានវិបាកដែលគួរត្រេកអរ** ជាអាការប្រាកដ បានដល់ ឱ្យវិបាកដែលគួរប្រាថ្នា ។

ពាក្យថា **មានហេតុជិត តាមដែលពោលហើយនុ៎ះឯង** បានដល់ មានយោនិសោមនសិការៈនោះឯង ជាហេតុជិត ព្រោះកុសលទាំងឡាយ មានយោនិសោមនសិការៈនោះឯង ជាហេតុជិត ឱ្យកើតឡើង ។

## សេចក្ដីផ្សេងគ្នារបស់ន័យទាំង ២

*ក្នុងលក្ខណាទិចតុក្កៈទាំង ២ ន័យនោះ ន័យទី ១ លោកប្រាថ្នាសម្ដែងផល ដែលល្អរបស់កុសលកម្មដែលកើតឡើងក្នុងអនាគត ជាលក្ខណៈ គឺ កាលកុសលចិត្តកើតឡើងហើយ សេចក្ដីសុខដែលប្រាសចាកទោសក៏កើតឡើង មិនសម្ដែងសេចក្ដីសុខដែលមានទោស ដូចសុខដែលកើតអំពីលោភមូលចិត្ត និងសម្ដែងការកំចាត់អកុសលថា ជាកិច្ចរស គឺ កាលកុសលកើតឡើង ក៏ធ្វើនាទីកំចាត់អកុសលភ្លាម និងសម្ដែងភាពផូរផង់របស់ចិត្តដែលជាផល ។*

*ចំណែកន័យទី ២ លោកប្រាថ្នាសម្ដែងកុសលចិត្តដែលកើតឡើងក្នុងបច្ចុប្បន្ន ជាលក្ខណៈ, ជាលក្ខណៈទូទៅរបស់កុសលចិត្តដែលប្រកបដោយអត្ថ ៣ គឺ ៖*

*ឈ្មោះថា កុសល ព្រោះមិនមានរោគ គឺ មិនមានសេចក្ដីរសាប់រសល់ ដោយកិលេស ១ ព្រោះមិនមាន*

ទោស គឺ កិលេសដែលធ្វើឱ្យក្រវល់ក្រវាយ ១ ព្រោះកើតអំពីបញ្ញាដែលឈ្មោះថា កោសល្ល:(ភាពជាអ្នកឆ្លាត) ១ បើជាកុសលញាណវិប្បយុត្ត ក៏មិនប្រកបដោយកោសល្ល: ចំណែកភាវ:ដែលធ្វើឱ្យផូរផង់នោះ សម្តែងដល់សម្បត្តិរស គឺ នាទីដែលបរិបូរណ៍ហើយ ទើបធ្វើឱ្យផូរផង់ និងសម្តែងដល់វិបាករបស់កុសលនោះថា ជាផលដែលគួរប្រាថ្នា គួរពេញចិត្ត ចំណែកហេតុជិតឱ្យកើតឡើងនោះ ប្រព្រឹត្តទៅក្នុងយោនិសោមនសិការ: ដូចគ្នា ។

កុសលចិត្តដែលកើតឡើងបាន ព្រោះយោនិសោមនសិការ: និងយោនិសោមនសិការ: កាលនឹងកើតឡើង ក៏ត្រូវអាស្រ័យហេតុដែលជាអតីត និងបច្ចុប្បន្នជាបច្ច័យ ។

# ចក្កៈ ៤

ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត[១] ហៅហេតុដែលធ្វើឱ្យកុសលកើតឡើងនេះថា ចក្កៈ ៤ (ចក្ក គឺ សម្បត្តិ)

**១-បដិរូបទេសវាសោ** ការនៅក្នុងប្រទេសដ៏សមគួរ

**២-សប្បុរិសូបស្សយោ** ការចូលទៅសេពគប់នឹងពួកសប្បុរស

**៣-អត្តសម្មាបណិធិ** ការតម្កល់ខ្លួនទុកដោយល្អ

**៤-បុព្វេ ច កតបុញ្ញតា** បុណ្យដែលបានធ្វើទុកហើយក្នុងកាលមុន

ពាក្យថា ចក្កៈ គឺ ដល់ព្រមដោយបច្ច័យ ៤ នេះ ជាបច្ច័យឱ្យកើតយោនិសោមនសិការៈ ព្រោះការរស់នៅក្នុងទីឋាន ឬប្រទេសដែលសមគួរ មានវត្ថុច្រើនដែលល្អ ដូចនៅក្នុងស្ថានទីដែលមានសប្បុរស រមែងនឹងមានការឃើញការព្វជាដើម ក្នុងផ្នែកដែលល្អ ។

---

១. អង្គុ. ចក្កុ. ចក្កវគ្គ. ៤២. ៣២/៧៩ ។

<u>**ក្នុងអដ្ឋកថា**</u> ពោលថា ៖
នៅក្នុងស្ថានទីដែលមានពុទ្ធបរិស័ទប្រាកដ ហៅថា **បដិរូបទេសវាសោ.** អាស្រ័យការសេពគប់សប្បុរស មានព្រះពុទ្ធជាដើម ហៅថា **សប្បុរិសូបស្សយោ.** ការតាំងខ្លួនទុកនៅក្នុងគុណធម៌មានសទ្ធាជាដើម ហៅថា **អត្តសម្មាបណិធិ.** ភាពជាអ្នកមានកុសលដែលសន្សំទុកហើយ ក្នុងកាលមុន ឈ្មោះថា **បុព្វេ ច កតបុញ្ញតា** ។

ក្នុងចក្កៈទី ៤ នេះ ជាហេតុបច្ច័យ និងជាប្រយោជន៍ច្រើន ព្រោះកម្មប៉ុណ្ណោះ ដែលបុគ្គលធ្វើដោយចិត្តណាសម្បយុត្តដោយញាណណា កុសលចិត្តនោះឯង រមែងនាំអ្នកនោះឱ្យនៅក្នុងទីដ៏សមគួរ ឱ្យសេពគប់សប្បុរស បុគ្គលនោះឈ្មោះថា តាំងខ្លួនទុកដោយប្រពៃ ដោយអាការយ៉ាងនេះ ។

ពិតមែន បុគ្គលប្រកបដោយចក្កធម៌ទាំង ៤ នេះ រមែងជាហេតុឱ្យយោនិសោមនសិការៈកើតឡើង និងជាហេតុញ៉ាំងបុគ្គលនោះឱ្យបានទទួលវត្ថុដែលគួរប្រាថ្នាច្រើនយ៉ាង ។

ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត ពោលគាថាទុកថា ៖

បដិរូបេ វសេ ទេសេ អរិយមិត្តករោ សិយា
សម្មាបណិធិសម្បន្នោ បុព្វេ បុញ្ញកតោ នរោ
ធញ្ញំ ធនំ យសោ កិត្តិ សុខញ្ចេតំ ធិវត្តតិ ។

*ជនណា នៅក្នុងប្រទេសដ៏សមគួរ សេពគប់នូវមិត្តដ៏ប្រសើរ ប្រកបដោយការទុកនូវខ្លួនដោយល្អ បានធ្វើបុណ្យទុកក្នុងកាលមុន ធញ្ញជាត ទ្រព្យ យស សេចក្តីសរសើរ សុខ តែងឃុំគ្រងនូវជននុ៎ះ ។*[១]

មហាកុសល ឬកាមាវចរកុសលចិត្តនេះ ចែកជា ៨ គឺ ព្រោះវេទនា (ជាសោមនស្ស-ឧបេក្ខា) ខ្លះ ញាណខ្លះ សង្ខារខ្លះ ដើម្បីឱ្យជាក់ច្បាស់ គួរជ្រាបធម៌ដែលជាហេតុបច្ច័យឱ្យកើតកុសលសោមនស្សជាដើម ដោយលំដាប់ដូចតទៅនេះ ៖

## ហេតុឱ្យកើតកុសលសោមនស្ស ៦ យ៉ាង

១, សោមនស្សបដិសន្ធិកតា បដិសន្ធិដោយសោមនស្ស

២, សទ្ធាពហុលតា ជាអ្នកមានសទ្ធាច្រើន

៣, វិសុទ្ធទិដ្ឋិតា មានការឃើញប្រាសចាកមន្ទិល

៤, អានិសំសទស្សាវិតា ឃើញអានិសង្សរបស់កុសល

៥, ឥដ្ឋារម្មណសមាយោគោ ប្រសព្វជាមួយនឹងឥដ្ឋារម្មណ៍

៦, កស្សចិបិឡាភាវោ មិនមានឧបសគ្គរាំង

បុគ្គលដែលបដិសន្ធិ(កើត)មក ក្នុងលោកនេះ ដោយកុសលវិបាក ដែលប្រកបដោយសោមនស្ស រមែងជាអ្នកមានចិត្តរីករាយ ស្រស់ស្រាយ មិនត្រិះរិះឱ្យមានទុក្ខក្តៅក្រហាយច្រើន, វេលាធ្វើកុសល ឬអកុសល រមែងជាអ្នកមានចិត្តរីករាយស្រស់ស្រាយ ជាអ្នកច្រើនដោយសោមនស្ស ។

បុគ្គលជាអ្នកច្រើនដោយសទ្ធា ជឿក្នុងបញ្ញាត្រាស់ដឹង

---

១. អង្គុ. ចតុ. ចក្កវគ្គ. ៤២. ៣២/៧៩ ។

របស់ព្រះពុទ្ធ កុសលចិត្តរបស់គេ ក៏ជាសោមនស្ស, ចំណែកអ្នកដែលមិនមានសទ្ធា ឬមានសទ្ធាតិច កុសលចិត្តរបស់គេ រមែងជាឧបេក្ខា ។ បុគ្គលមានសម្មាទិដ្ឋិ យល់ឃើញបានត្រឹមត្រូវ រមែងដឹងថា កុសលឱ្យផលជាសុខ អកុសលឱ្យផលជាទុក្ខ ដូច្នោះ ការធ្វើកុសលរបស់គេ ទើបជាសោមនស្ស ។

បុគ្គលឃើញអានិសង្សរបស់កុសល រមែងធ្វើកុសលដោយចិត្តសោមនស្ស ចំណែកអ្នកមិនឃើញអានិសង្សទេ ទាល់តែមានគេបបួលឱ្យធ្វើ ក៏ធ្វើដោយចិត្តដែលជាឧបេក្ខា ។

បុគ្គលដែលជួបប្រសព្វ នឹងឥដ្ឋារម្មណ៍ តាមផ្លូវភ្នែកត្រចៀកជាដើម រមែងត្រេកអរពេញចិត្ត កាលធ្វើកុសលទើបជាសោមនស្ស បើមនសិការៈមិនល្អ ជាសោមនស្សរបស់លោភៈ ក៏បាន ។ ការធ្វើកុសលគ្រប់យ៉ាង មិនមានឧបសគ្គៈអន្តរាយណា ៗ មកជំទាស់រាំង នេះក៏ជាហេតុឱ្យកុសលដែលកើតព្រមនឹងសោមនស្សដែរ ។

## ហេតុឱ្យកើតកុសលឧបេក្ខា ៦ យ៉ាង

១. ឧបេក្ខាបដិសន្ធិកតា បដិសន្ធិដោយឧបេក្ខា

២. អប្បសទ្ធតា ជាអ្នកមានសទ្ធាតិច

៣. អវិសុទ្ធទិដ្ឋិតា មានការយល់ឃើញមិនបរិសុទ្ធ

៤. អានិសំសអទស្សាវិតា មិនឃើញអានិសង្សរបស់កុសល

៥. មជ្ឈត្តារម្មណសមា យោគោ ប្រកបជាមួយនឹងអារម្មណ៍ប្រភេទកណ្ដាល

៦. កស្សចិបិឡិតតា មានឧបសគ្គរាំង

## ហេតុឱ្យកើតកុសលញាណសម្បយុត្ត ៤ ( ន័យទី១ )

១, បញ្ញាសំវត្តនិកកម្មុបនិស្សយតា ភាពជាអ្នកមានឧបនិស្ស័យក្នុងការធ្វើកុសលដែលប្រកបដោយបញ្ញា

២, អព្យាបជ្ឈលោកូបបត្តិតា ភាពជាអ្នកកើតឡើងក្នុងលោកដែលមិនមានការបៀតបៀន

៣, ឥន្ទ្រិយបរិបាកតា ភាពជាអ្នកមានឥន្ទ្រិយចាស់ក្លា

**៤, កិលេសទូរតា** ភាពជាអ្នកឆ្ងាយចាកកិលេស

ពាក្យថា **បញ្ញាសំវត្តនិកកម្មុបនិស្សយតា** ភាពជាអ្នកមានឧបនិស្ស័យ ក្នុងការធ្វើកុសលដែលប្រកបដោយបញ្ញា ដូចការសម្តែងធម៌ ការបង្រៀនសិល្បៈវិទ្យាដែលមិនមានទោស ការអារាធនាឱ្យសម្តែងធម៌ ការបូជា និងការថ្វាយទានតាំងសេចក្តីប្រាថ្នា ដូចអតីតកម្មរបស់អគ្គសាវកទាំងពីរជាដើម [១] ភាពជាអ្នកមានឧបនិស្ស័យ ក្នុងការធ្វើកុសលប្រកបដោយបញ្ញាយ៉ាងនេះ រមែងជាបច្ច័យឱ្យកើតកុសលញាណសម្បយុត្ត ។

ពាក្យថា **អព្យាបជ្ឈលោកូបបត្តិតា** ភាពជាអ្នកកើតឡើងក្នុងលោកដែលមិនមានការបៀតបៀន រមែងជាបច្ច័យឱ្យកើតកុសលញាណសម្បយុត្ត ។

ពាក្យថា **ឥន្ទ្រិយបរិបាកតា** ភាពជាអ្នកមានឥន្ទ្រិយ

---

១. មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ ឯកនិបាត ។

ចាស់ក្លា គឺ ឥន្ទ្រិយទាំង ៥ មានបញ្ញិន្ទ្រិយជាប្រធាន រមែងជាហេតុឱ្យកើតកុសលញាណសម្បយុត្ត ។

ពាក្យថា **កិលេសទូរតា** ភាពជាអ្នកឆ្ងាយចាកកិលេស ដោយតាំងខ្លួនទុកប្រពៃ ដូចចម្រើនវិបស្សនា ឬចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ ដែលជាសភាវៈឆ្ងាយពីកិលេស ។

## ហេតុឱ្យកើតកុសលញាណសម្បយុត្ត ៧ ( ន័យទី២ )

១. **បរិបុច្ឆកតា** ជាអ្នកចេះសាកសួរបញ្ហាផ្សេង ៗ
២. **វត្ថុវិសទក្រិយតា** ការស្អាតទាំងកាយ ចិត្ត និងវត្ថុ
៣. **ឥន្ទ្រិយសមត្តបដិបាទនតា** មានឥន្ទ្រិយទាំង ៥ ស្មើគ្នា
៤. **ទុប្បញ្ញាបុគ្គលបរិវជ្ជនា** គេចចេញពីអ្នកមានបញ្ញាខ្សោយ
៥. **បញ្ញវន្តបុគ្គលសេវនា** សមាគមនឹងអ្នកមានបញ្ញា
៦. **គម្ភីរញាណចរិយបច្ចវេក្ខណា** ពិចារណាញាណចរិយាដ៏ជ្រាលជ្រៅ
៧. **តទធិមុត្តតា** ភាពជាអ្នកបង្អោនចិត្តទៅក្នុងញាណនោះ

## ហេតុឱ្យកើតកុសលញាណវិប្បយុត្ត ៤ ( ន័យទី១ )

១. *បញ្ញាអសំវត្តនិកកម្មុបនិស្សយតា* ជាអ្នកមានឧបនិស្ស័យក្នុងការធ្វើកុសលមិនប្រកបដោយបញ្ញា

២. *សព្យាបជ្ឈលោកូប្បត្តិតា* ជាអ្នកកើតឡើងក្នុងលោកដែលមានការបៀតបៀន

៣. *ឥន្ទ្រិយអបរិបាកតា* ជាអ្នកមានឥន្ទ្រិយទន់ខ្សោយ

៤. *កិលេសាទូរតា* ជាអ្នកមិនឆ្ងាយចាកកិលេស

## ហេតុឱ្យកើតកុសលញាណវិប្បយុត្ត ៧ ( ន័យទី២ )

១. *អបរិបុច្ឆកតា* ជាអ្នកមិនចេះសាកសួរ

២. *វត្ថុអវិសទតា* មិនស្អាតទាំងកាយចិត្តនិងវត្ថុ

៣. *ឥន្ទ្រិយអសមត្តបដិបាទនតា* មិនបរិបូណ៌ដោយឥន្ទ្រិយ

៤. *ទុប្បញ្ញាបុគ្គលសេវនា* សមាគមនឹងអ្នកមិនមានបញ្ញា

៥. *បញ្ញាវន្តបុគ្គលបរិវជ្ជនា* គេចចេញពីអ្នកមានបញ្ញា

៦. *គម្ភីរញាណចរិយអបច្ចវេក្ខណា* មិនពិចារណានូវញាណ

ចរិយាដ៏ជ្រាលជ្រៅ[១]

**៧. អតទធិមុត្តតា** ជាអ្នកមិនបង្អោនចិត្តទៅក្នុងញាណនោះ

## ហេតុឱ្យកើតអសង្ខារិកចិត្ត ៦ គឺ

**១. អសង្ខារិកកម្មជនិតបដិសន្ធិកតា** ជាអ្នកបដិសន្ធិដោយកម្មដែលជាអសង្ខារិក

**២. កល្លកាយចិត្តតា** ជាអ្នកមានកាយនិងចិត្តរឹងប៉ឹង មាំមួន

**៣. សីតុណ្ហាទីនំ ខមនពហុលតា** អត់ធន់ចំពោះត្រជាក់ និងក្តៅជាដើម

**៤. កត្តព្វកម្មេសុ ទិដ្ឋានិសំសតា** ជាអ្នកឃើញប្រយោជន៍

---

១. សទ្ធម្មប្បកាសិនីនៃបដិសម្ភិទា ក្នុងខគ្គវិសាណសូត្រ ពោលចរិយា ៨ គឺ ឥរិយាបថចរិយា១ អាយតនចរិយា១ សតិចរិយា១ សមាធិចរិយា ១ ញាណចរិយា១ មគ្គចរិយា១ បដិបត្តិចរិយា១ លោកត្ថចរិយា១ ។ "ញាណចរិយាដ៏ជ្រាលជ្រៅ"នេះ សំដៅដល់ ការប្រព្រឹត្តិរបស់អ្នកដែលប្រកបដោយបញ្ញាជាគ្រឿងត្រាស់ដឹង ។

ក្នុងការងារដែលគប្បីធ្វើ

៥. **កម្មេសុ ចិណ្ណវសិតា** ជាអ្នកជំនាញក្នុងការងារទាំងឡាយ

៦. **ឧតុភោជនាទិសប្បាយលាភោ** បានសេចក្តីសប្បាយចិត្ត ក្នុងឧតុ និងភោជនជាដើម ។

<u>**ក្នុងវិសុទ្ធិមគ្គ**</u> សម្តែងសប្បាយ ៧ យ៉ាង គឺ អាវាស គោចរ ភស្ស: (ការនិយាយកថាវត្ថុ ១០) បុគ្គល ភោជន ឧតុ ឥរិយាបថ ។

<u>**ក្នុងវិភាវិនីដីកា**</u> ពោលដោយសង្ខេបថា ៖

**១. អាវាសសប្បាយាទិវសេន កាយចិត្តានំ កល្លភាវតោ** ប្រែថា ព្រោះកាយនិងចិត្ត ជាធម្មជាតិអាច ដោយអំណាចនៃសប្បាយទាំងឡាយ មានអាវាសសប្បាយជាដើម ។

**២. បុព្វេ ទានាទីសុ កតបរិចយតាទីហិ** ប្រែថា ព្រោះបុព្វចរិយាជាដើម ដែលធ្លាប់បានធ្វើបុណ្យ មានទានជាដើម ក្នុងកាលមុន ។

ចំណែកហេតុដែលឱ្យកើតសសង្ខារិកនោះ មានន័យ

ផ្ទុយគ្នានឹងអសង្ខារិក ដែលមានទំនងដូចដែលបានពោលទុកក្នុងសង្ខារុបត្តិហេតុនៃលោភមូលចិត្ត ( ទំព័រ ៥៩ )ខាងដើមនោះហើយ ។

## មហាកុសលចិត្ត ២ ប្រភេទ គឺ

**១, មហាកុសលញាណសម្បយុត្ត ៤ ២, មហាកុសលញាណវិប្បយុត្ត ៤**

មហាកុសលញាណវិប្បយុត្ត ៤ នោះ ជាចិត្តប្រកបដោយហេតុ ២ គឺ អលោភហេតុ និងអទោសហេតុ ហៅថា ទ្វិហេតុកចិត្ត, ចំណែកមហាកុសលញាណសម្បយុត្តប្រកបដោយហេតុ ៣ គឺ អលោភហេតុ អទោសហេតុ និងអមោហហេតុ ហៅថា តិហេតុកចិត្ត ។

ការដែលមហាកុសលញាណវិប្បយុត្ត មានអលោភហេតុ និងអទោសហេតុកើតរួមផង គឺ ព្រោះការធ្វើកុសលណា ៗ ក៏ដោយ មានការឱ្យទាន រក្សាសីលជាដើម ការ

ដែលកុសលនោះ នឹងកើតឡើងបាន ព្រោះខណៈនោះ មិនមានលោភៈ មិនមានទោសៈ បើនៅមានលោភៈ ក៏លំបាកនឹងលះបង់ទ្រព្យរបស់ខ្លួនឱ្យជាទានបាន ឬកាលកំពុងក្រោធ ក៏លំបាកនឹងលះបង់ឱ្យដូចគ្នា ដូច្នោះ កុសលនោះ ទើបមានតែអលោភហេតុ និងអទោសហេតុប៉ុណ្ណោះកើតរួមផង ចំណែកមហាកុសល ញាណសម្បយុត្តនោះ ទើបត្រូវមានចេតសិក ៣ ប្រភេទ កើតរួមជាមួយនឹងចិត្ត គឺ អលោភហេតុ អទោសហេតុ និងអមោហហេតុ, កើតព្រមនឹងអមោហហេតុ គឺ បញ្ញា ការនឹងធ្វើកុសលណា ៗ បើប្រកបដោយបញ្ញា រមែងជាកុសលប្រសើរបំផុត ។

## ហេតុឱ្យកើតបញ្ញា ៣ យ៉ាង

១. **សុតាមយបញ្ញា** បញ្ញាកើតអំពីការស្តាប់

២. **ចិន្តាមយបញ្ញា** បញ្ញាកើតអំពីការគិត

៣. **ភាវនាមយបញ្ញា** បញ្ញាកើតអំពីភាវនា

បញ្ញាទាំងឡាយដែលកើតឡើងបាន ទាល់តែអាស្រ័យបច្ច័យឱ្យកើតការស្តាប់ ក៏គឺ ការរៀន ។

<u>**ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត**</u> ព្រះមានព្រះភាគត្រាស់ប្រយោជន៍របស់ការស្តាប់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃការស្តាប់ព្រះសទ្ធម្មនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ អ្នកស្តាប់តែងបាន ស្តាប់រឿងមិនទាន់បានស្តាប់ ១ រឿងណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្តច្បាស់ នឹងចូលចិត្តច្បាស់ឡើងបាន ១ កំចាត់បង់សេចក្តីសង្ស័យចេញបាន ១ ធ្វើសេចក្តីយើញឱ្យត្រង់ ១ ចិត្តអ្នកស្តាប់ រមែងជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃការស្តាប់ធម៌ មាន ៥ យ៉ាងនេះឯង ។[១]

---

១. អង្គុ. បញ្ច. កិមិលវគ្គ. ៤៥. ១០២/២៣៨ ។

សុតាមយបញ្ញានេះ ត្រូវអាស្រ័យអ្នកដទៃប្រាប់ ឬរៀនយកអំពីគ្រូ ទើបបានបញ្ញានេះ ជាបញ្ញាជាន់ទាប, ចំណែកចិន្តាមយបញ្ញារបស់មនុស្សធម្មតា រមែងកើតព្រោះអាស្រ័យការស្តាប់ជាខាងដើម ទើបកើតបាន តែសម្រាប់អ្នកមានបារមីដែលបានសន្សំមកយ៉ាងល្អ មិនបាច់ស្តាប់អ្នកដទៃក៏អាចកើតឡើងបាន ។

<u>ក្នុងអដ្ឋកថាសម្មោហវិនោទនី</u> បានលើកយកព្រះពោធិសត្វទាំងពីរជាឧបមា ព្រះពោធិសត្វទាំងពីរនោះ គឺសព្វញ្ញុពោធិសត្វ និងបច្ចេកពោធិសត្វ ក្នុងជាតិចុង ក្រោយអាចប្រើចិន្តាមយបញ្ញា ក៏សម្រេចមគ្គផលបាន, ចំណែកភាវនាមយបញ្ញា ជាបញ្ញាកើតអំពីភាវនានោះ បានដល់ ការចម្រើនវិបស្សនា ។

## កម្មស្សកតាបញ្ញា ១០ យ៉ាង

កម្មស្សកតាបញ្ញា បានដល់ បញ្ញាដឹងថា សត្វមានកម្មជារបស់ខ្លួន លោកហៅថា "ទសវត្ថុសម្មាទិដ្ឋិ" មាន១០ គឺ ៖

១. **អត្ថិ ទិន្នំ** យល់ថា ទានដែលគេឱ្យហើយ មានផល

២. **អត្ថិ យិដ្ឋំ** យល់ថា ការបូជាធំ មានផល

៣. **អត្ថិ ហុតំ** យល់ថា ការបូជាតូច មានផល

៤. **អត្ថិ សុកតទុក្កតានំ កម្មានំ វិបាកោ** យល់ថា ផលវិបាករបស់កម្មដែលគេធ្វើល្អ និងធ្វើអាក្រក់ មាន

៥. **អត្ថិ អយំ លោកោ** យល់ថា (សត្វដែលមកកើតក្នុង)លោកនេះ មាន

៦. **អត្ថិ បរោ លោកោ** យល់ថា (សត្វដែលកើតក្នុង) លោកខាងមុខ មាន

៧. **អត្ថិ មាតា** យល់ថា គុណមាតា មាន

៨. **អត្ថិ បិតា** យល់ថា គុណបិតា មាន

៩. **អត្ថិ សត្តា ឱបបាតិកា** យល់ថា ពួកសត្វជាឱបបាតិកៈ

កំណើត មាន

១០. អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យល់ថា ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ដែលធ្វើ ឱ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្តែងបាន មាន ។[១]

**ចេតនាក្នុងមហាកុសលចិត្ត មាន ២ ន័យ គឺ**

ក-ដោយកម្មទ្វារ ៣ ខ-ដោយបុញ្ញកិរិយាវត្ថុ ១០

ក, សម្តែងមហាកុសលចិត្ត ដោយកម្មទ្វារ ៣

| ១. កាយកម្ម ៣ គឺ | ២. វចីកម្ម ៤ គឺ |
|---|---|
| -ចេតនាវៀរចាកបាណាតិបាត | -ចេតនាវៀរចាកមុសាវាទ |
| -ចេតនាវៀរចាកអទិន្នាទាន | -ចេតនាវៀរចាកបិសុណាវាទ |
| -ចេតនាវៀរចាកកាមេសុមិច្ឆាចារ | -ចេតនាវៀរចាកផរុសវាទ |
| | -ចេតនាវៀរចាកសម្ផប្បលាប |

១. អភិ. សង្គ. សុត្តន្តិកទុកនិក្ខេប. ៧៩. ៣៧១/២៣៩ ។

៣. មនោកម្ម ៣ គឺ -មិនសម្លឹងរំពៃចង់បានទ្រព្យគេ

-អព្យាបាទៈ មិនព្យាបាទ

-សម្មាទិដ្ឋិ ការយល់ត្រូវ

## **អង្គធម៌របស់កុសលកម្មបថ ១០ គឺ**

កាយកម្ម៣ គឺ សម្មាកម្មន្តចេតសិក និងសម្មាអាជីវចេតសិក

វចីកម្ម ៤ គឺ សម្មាវាចាចេតសិក និងសម្មាអាជីវចេតសិក

មនោកម្ម ៣ គឺ អនភិជ្ឈា បានដល់ អលោភចេតសិក

អព្យាបាទ បានដល់ អទោសចេតសិក

សម្មាទិដ្ឋិ បានដល់ បញ្ញាចេតសិក

### ***១, សម្តែងមហាកុសលចិត្ត ដោយបុញ្ញកិរិយាវត្ថុ ១០***

***១, ទានមយៈ*** បុណ្យសម្រេចពីការធ្វើទាន គឺ ការលះបង់ទ្រព្យ ឱ្យជាប្រយោជន៍ដល់អ្នកដទៃ ។

***២, សីលមយៈ*** បុណ្យសម្រេចពីការរក្សាសីល គឺ វៀរទុច្ចរិតកម្ម

៣, **ភាវនាមយៈ** បុណ្យសម្រេចពីការចម្រើនសមថ និង វិបស្សនា

៤, **អបចាយនមយៈ** បុណ្យសម្រេចពីការគោរព ឱន លំទោនដល់អ្នកដែលគួរគោរព ឱនលំទោន

៥, **វេយ្យាវច្ចមយៈ** បុណ្យសម្រេចពីការជួយធ្វើកិច្ចការ នៃបុណ្យ

៦, **បត្តិទានមយៈ** បុណ្យសម្រេចពីការឧទ្ទិសចំណែកបុណ្យ ឱ្យអ្នកដទៃ

៧, **បត្តានុមោទនាមយៈ** បុណ្យសម្រេចពីការអនុមោទនា

៨, **ទេសនាមយៈ** បុណ្យសម្រេចពីការសម្តែងធម៌

៩, **ធម្មសវនមយៈ** បុណ្យសម្រេចពីការស្តាប់ធម៌

១០, **ទិដ្ឋុជុកម្ម** ដោយការធ្វើទិដ្ឋិឱ្យត្រឹមត្រូវល្អ ។

ក្នុងបុញ្ញកិរិយាវត្ថុទាំង ១០ នេះ កាលពោលដោយសង្ខេប ក៏មានត្រឹមតែ ៣ ប៉ុណ្ណោះ គឺ

ទី១ ទានមយៈ, ទី៦ បត្តិទានមយៈ, ទី៧ បត្តានុមោទនាមយៈ, រួមទាំង ៣ នេះ សង្គ្រោះចូលក្នុងទាន ។

ទី២ សីលមយៈ, ទី៤. អបចាយនមយៈ, ទី៥. វេយ្យាវច្ចមយៈ, រួមទាំង ៣ នេះ សង្គ្រោះចូលក្នុងសីល ។

ទី៣ ភាវនាមយៈ, ទី៨ទេសនាមយៈ, ទី៩ ធម្មសវនមយៈ, ទី១០ ទិដ្ឋុជុកម្ម, រួមទាំង ៤ នេះ សង្គ្រោះចូលក្នុងភាវនា ។

<u>ក្នុងសុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ សង្គីតិសូត្រ</u> ពោលថា ៖

ទិដ្ឋុជុកម្ម សង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុ ៣ គឺ ទានមយៈ សីលមយៈ ភាវនាមយៈ ពិតមែន ការឱ្យទានក្តី ការរក្សាសីលក្តី ការចម្រើនភាវនាក្តី បើគ្មានទិដ្ឋុជុកម្មទេ កុសលនោះ ៗ មិនបរិបូណ៌ ។

**ចែកមហាកុសល ៨ ប្រកបដោយចេតនា ៣**

**១, បុព្វចេតនា** ចេតនាមុនធ្វើ

**២, មុញ្ចនចេតនា** ចេតនាកំពុងធ្វើ

**៣, អបរចេតនា** ចេតនាកាលធ្វើរួចហើយ

ចេតនាមហាកុសល៨ ដែលជាតិហេតុកៈ និងទុហេតុកៈ មាន ២ ប្រភេទ គឺ

**ឧក្កដ្ឋកុសលំ** កុសលថ្នាក់ប្រសើរ( ឧក្រិដ្ឋ )

**ឱមកកុសលំ** កុសលថ្នាក់ទាប

បណ្ដាកុសលទាំង ២ ប្រភេទនេះ បុគ្គលកាលឱ្យទាន និងរក្សាសីលជាដើម មុននឹងធ្វើ( បុព្វចេតនា )ក្ដី កំពុងធ្វើ( មុញ្ចនចេតនា )ក្ដី ធ្វើរួចហើយ( អបរចេតនា )ក្ដី មានចិត្តមិនប្រកបដោយអកុសល គឺ មានចេតនាបរិសុទ្ធទាំង ៣ កាល ផលរបស់ទានក្ដី ផលរបស់សីលជាដើមក្ដី របស់អ្នកនោះ ទោះជាតិហេតុកៈ ឬទុហេតុកៈក៏ដោយ ក៏ចាត់ជា

ឧក្កដ្ឋកុសល បើចេតនាមុននឹងធ្វើក្តី កំពុងធ្វើក្តី ធ្វើរួចហើយ មានអកុសលលាយ គឺ មានចេតនាមិនបរិសុទ្ធទាំង ៣ កាល កុសលនោះ ទោះជាតិហេតុកៈ ឬទ្វិហេតុកៈក៏ដោយ ក៏បាត់ជាឱមកកុសល ។

## ចែកកុសលដោយឧក្កដ្ឋៈ និងឱមកៈ ជា ៤

១. តិហេតុកៈ ប្រភេទឧក្កដ្ឋៈ ( ឧក្រិដ្ឋ )
២. តិហេតុកៈ ប្រភេទឱមកៈ ( ថ្នាក់បន្ទាប់ )
៣. ទ្វិហេតុកៈ ប្រភេទឧក្កដ្ឋៈ ( ឧក្រិដ្ឋ )
៤. ទ្វិហេតុកៈ ប្រភេទឱមកៈ ( ថ្នាក់បន្ទាប់ )

## ចែកកុសលដោយឧក្កដ្ឋ និងឱមក ៨

១. តិហេតុកកុសល ឧក្កដ្ឋៈ( ថ្នាក់ទី១ ) = តិហេតុកឧក្កដ្ឋុក្កដ្ឋៈ
២. តិហេតុកកុសល ឧក្កដ្ឋៈ( ថ្នាក់រង ) = តិហេតុកឧក្កដ្ឋោមកៈ
៣. តិហេតុកកុសល ឱមកៈ( ថ្នាក់ទី១ ) = តិហេតុកឱមកុក្កដ្ឋៈ
៤. តិហេតុកកុសល ឱមកៈ( ថ្នាក់រង ) = តិហេតុកឱមកោមកៈ

៥. ទ្វិហេតុកកុសល ឧក្កដ្ឋ (ថ្នាក់ទី១) = ទ្វិហេតុកឧក្កដ្ឋុក្កដ្ឋ
៦. ទ្វិហេតុកកុសល ឧក្កដ្ឋ(ថ្នាក់រង) = ទ្វិហេតុកឧក្កដ្ឋោមកៈ
៧. ទ្វិហេតុកកុសល ឱមកៈ (ថ្នាក់ទី១) = ទ្វិហេតុកឱមកុក្កដ្ឋ
៨. ទ្វិហេតុកកុសល ឱមកៈ(ថ្នាក់រង) = ទ្វិហេតុកឱមកោមកៈ

រួមជាកុសល ៨ ប្រការ តាមដែលបានពោលមកនេះ អាស្រ័យមុញ្ចនចេតនាជាប្រធាន គឺ ខណៈដែលមុញ្ចនចេតនាកើតឡើង ប្រកបដោយហេតុ ៣ ក៏ជាតិហេតុកកុសល, បើមុញ្ចនចេតនា ប្រកបដោយហេតុ ២ កុសលនោះ ក៏ឈ្មោះថា ទ្វិហេតុកកុសល ។

ចែកអបរចេតនា ទុកដូច្នេះ គឺ ៖

១. អបរចេតនាល្អ អបរាបរចេតនាល្អ ជាឧក្កដ្ឋុក្កដ្ឋៈ
២. អបរចេតនាល្អ អបរាបរចេតនាមិនល្អ ជាឧក្កដ្ឋោមកៈ
៣. អបរចេតនាមិនល្អ អបរាបរចេតនាល្អ ជាឱមកុក្កដ្ឋៈ
៤. អបរចេតនាមិនល្អ អបរាបរចេតនាមិនល្អ ជាឱមកោមកៈ

## មហាកុសល ៨ ដោយន័យផ្សេង ៗ ដូច្នេះ គឺ

១. ដោយជាតិ ជាកុសលជាតិ

២. ដោយភូមិ ជាកាមាវចរភូមិ( កើតបាន ៣០ ភូមិ )

៣. ដោយវេទនា ជាសោមនស្ស ៤ ជាឧបេក្ខា ៤

៤. ដោយហេតុ ជានហេតុ និងជាសហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាញាណសម្បយុត្ត៤ ជាញាណវិប្បយុត្ត៤

៦. ដោយសង្ខារ ជាអសង្ខារិក ៤ ជាសសង្ខារិក ៤

៧. ដោយសោភណ ជាកាមសោភណចិត្ត

៨. ដោយឈាន ជាអឈានចិត្ត

៩. ដោយលោក ជាលោកិយចិត្ត

១០. ដោយកិច្ច ធ្វើជវនកិច្ច

១១. ដោយអារម្មណ៍ ជាចិត្តមានអារម្មណ៍ ៦

១២. ដោយទ្វារ ជាចិត្តកើតតាមទ្វារ ៦

១៣. ដោយវត្ថុ        កើតត្រង់ហទយវត្ថុ

១៤. ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ

## សម្តែងកាមាវចរកុសលចិត្ត ៨

- កាមាវចរកុសលចិត្ត ៨
  - សោមនស្ស
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - ឧបេក្ខា
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១

**ចប់ មហាកុសល ៨**

## កាមាវចរវិបាកចិត្ត ៨

មហាកុសល ៨ ជាបច្ច័យឱ្យផលជាសហេតុកវិបាកចិត្ត ៨ ហើយឱ្យផលជាអហេតុកកុសលវិបាកចិត្ត ៨ ទៀត រួមជាកុសលវិបាក ១៦ តែការឱ្យផលរបស់វិបាកទាំង ២ ប្រភេទនេះ ផ្សេងគ្នា គឺ ៖

បណ្តាអហេតុកកុសលវិបាក មានអហេតុកកុសលវិបាក ឧបេក្ខាអហេតុកវិបាកមនោវិញ្ញាណធាតុ ១ ធ្វើបដិសន្ធិកិច្ចក្នុងមនុស្សភូមិ ១ ក្នុងចាតុម្មហារាជិកាភូមិ ១ ក្នុងបវត្តិកាលអហេតុកកុសលវិបាក ៨ កើតឡើងទទួលផលរបស់កុសលកម្ម ក្នុងកាមភូមិ ១១ ក្នុងរូបភូមិ ១៥ (វៀរអសញ្ញសត្តាភូមិ) តាមសមគួរដល់ទ្វារនិងអារម្មណ៍ ។

ចំណែកសហេតុកមហាវិបាកទាំង ៨ នោះ ឱ្យផលកើតបានក្នុងសុគតិភូមិ ៧ ជាន់ប៉ុណ្ណោះ គឺ ឱ្យផលបដិសន្ធិក្នុងបដិសន្ធិកាល, ក្នុងបវត្តិកាលជាភវង្គកិច្ច និង

តទាលម្ពណកិច្ច ។

**វិបាក** មានវិគ្រោះថា **អញ្ញមញ្ញវិសុដ្ឋានំ កុសលា កុសលានំ បាកាតិ = វិបាកា** ធម៌ដែលជាផលរបស់កុសល និងអកុសល វិសេសជាងគ្នានិងគ្នា ឈ្មោះថា វិបាក ។

ផលវិសេសជាងគ្នានិងគ្នា សំដៅដល់ ផលរបស់កុសល និងអកុសលនោះ មិនប្រកបនូវគ្នានិងគ្នា ធ្ងន់ស្រាល ក៏មិនប៉ុនគ្នា ផលរបស់កុសលជាឥដ្ឋារម្មណ៍ ផលរបស់អកុសលជាអនិដ្ឋារម្មណ៍ ។

**ក្នុងអដ្ឋសាលិនី** សម្ដែងផល ២ យ៉ាង គឺ ៖

១. មុខផល ផលដោយត្រង់ បានដល់ ធម៌ដែលជាវិបាក គឺ ចិត្តនិងចេតសិក កើតឡើងទទួលផលរបស់កម្មដែលធ្វើទុកហើយ ។

២. សាមញ្ញផល បានដល់ ផលដែលស្មើគ្នា ដែលជាផលដោយអប បានដល់ កម្មជរូប មានហទយរូបជាដើម

ដែលកើតព្រមនឹងចិត្តក្នុងបដិសន្ធិកាល ។

ក្នុងទីនេះ លោកប្រាថ្នាយកមុខផល ដោយត្រង់ បានដល់ មហាវិបាកចិត្ត ៨ នុ៎ះឯង

មហាវិបាកចិត្តនេះ កាលពោលដោយវេទនាក្តី សម្បយោគ គឺ ការប្រកបក្តី និងសង្ខារក្តី មានលក្ខណៈដូចគ្នានឹងមហាកុសលទាំង ៨ គ្រប់ប្រការ ។

## កាមាវចរវិបាកចិត្ត ៨ គឺ

**១, សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** : មហាវិបាកចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ

**២, សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** : មហាវិបាកចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ

**៣, សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** : មហាវិបាកចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ

**៤, សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** : មហាវិបាកចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ

**៥, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** : មហាវិបាកចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ

**៦, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** : មហាវិបាកចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ

**៧, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** : មហាវិបាកចិត្តកើតឡើង ព្រមដោយឧបេក្ខា

*វេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ*

***៨, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ*** *: មហាវិបាកចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ*

***ឥមានិ អដ្ឋបិ សហេតុកកាមាវចរវិបាកចិត្តានិ នាម***

*ចិត្តទាំង ៨ នេះ ឈ្មោះថា សហេតុកកាមាវចរវិបាកចិត្ត ។*

## មហាវិបាកផ្សេងពីមហាកុសល

*មហាកុសលទាំងឡាយ មានច្រើនដោយកម្ម ៣ ដោយទ្វារ ៦ ដោយកម្មបថ ១០ ដោយបុញ្ញកិរិយាវត្ថុ ១០, ចំណែកមហាវិបាក ៨ មិនមានសេចក្តីផ្សេងគ្នា នៃកម្ម ទ្វារ កម្មបថ និងបុញ្ញកិរិយាវត្ថុទេ, សេចក្តីនេះ ព្រោះមហាវិបាកមិនអាចឱ្យវិញ្ញត្តិកើតបាន គឺ មហាវិបាកមិនធ្វើវិបាកឱ្យកើតទៀត និងព្រោះមហាវិបាកនោះ មិនប្រព្រឹត្តទៅដូចមហា*

កុសលចិត្ត ។

មួយទៀត ករុណា មុទិតា និង វិរតិ ៣ គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ រួមទាំង ៥ យ៉ាងនេះ ជាមហាកុសលប៉ុណ្ណោះ ចំណែកមហាវិបាកមិនមានករុណា មុទិតា វិរតិ ៣ ទេ សេចក្តីនេះ ព្រោះករុណា និងមុទិតា មានសត្វជាអារម្មណ៍របស់មហាកុសល និងជា មហគ្គតអប្បមញ្ញាឈាន. សូម្បីវិរតិ ៣ ក៏មិនមានក្នុងវិបាក ព្រោះក្នុងសិក្ខាបទវិភង្គ ព្រះមានព្រះភាគត្រាស់ថា "សិក្ខាបទទាំង ៥ ជាកុសលតែម្យ៉ាង"[១] ។

វិបាកធម៌ ជាអសង្ខារិក និងសសង្ខារិកនោះ ដូចគ្នានឹងមហាកុសល គឺ កុសលជាអសង្ខារិក វិបាកជាអសង្ខារិក, កុសលជាសសង្ខារិក វិបាកជាសសង្ខារិក ។

ចំណែកក្នុងសេចក្តីផ្សេងគ្នានៃកុសលចិត្ត ដែលទន់ទាប

១. អភិ. វិភ. សិក្ខាបទវិភង្គ. ៨២. ៩/១៧ ។

កណ្ដាល និងប្រណីតនោះ វិបាករបស់កុសលដែលទន់ទាប (វិបាកនោះ)ក៏ខ្សោយ, វិបាករបស់កុសលកណ្ដាល (វិបាកនោះ) ក៏កណ្ដាល, វិបាករបស់កុសលដែលប្រណីត (វិបាកនោះ) ក៏ប្រណីត, ក្នុងវិបាកទាំងនេះ សូម្បីធម៌ដែលជាអធិបតីទាំងឡាយ មិនមានទេ សេចក្ដីនេះ ព្រោះភាពនៃវិបាកទាំងនោះ មិនធ្វើឆន្ទៈជាដើមឱ្យជាធុរៈ ហើយកើតឡើង ។ ពាក្យដែលនៅសល់ដូចន័យដែលពោលហើយ ក្នុងមហាកុសល ៨ ទុំះឯង ។

## ឋានដែលឱ្យផលរបស់មហាវិបាក ៨ មាន ៤ ឋាន

**១, បដិសន្ធិស្ថាន** ដែលធ្វើកិច្ចបដិសន្ធិ

**២, ភវង្គស្ថាន** ដែលធ្វើកិច្ចរក្សាភពជាតិ

**៣, ចុតិស្ថាន** ដែលធ្វើកិច្ចឃ្លាតចាកភព

**៤, តទាលម្ពណស្ថាន** ដែលធ្វើកិច្ចទទួលអារម្មណ៍តពីជវន

សួរថា វិបាកទាំងនោះ ឱ្យផលយ៉ាងណា ?

ឆ្លើយថា វិបាកទាំងនោះ ឱ្យផលបដិសន្ធិស្ថានមុន គឺក្នុងវេលាចាប់បដិសន្ធិ របស់អ្នកមានបុណ្យទាំងឡាយ ដែលជាទុហេតុក និងតិហេតុក ឱ្យផលកើតក្នុងពួកមនុស្ស ឬពួកទេវតាជាន់កាមាវចរ, កាលបដិសន្ធិរលត់ទៅហើយ ក៏ឱ្យផលជាភវង្គស្ថាន ក្នុងបវត្តិកាលរហូតដល់អស់អាយុ ៦០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ ១ អសង្ខេយ្យឆ្នាំខ្លះ តាមសមគួរដល់អាយុរបស់សត្វដែលនៅក្នុងភពនោះ ៗ ឱ្យផលជាតទាលម្ពណស្ថាន ក្នុងអារម្មណ៍ដែលមានកម្លាំង ក្នុងទ្វារ ៦ គឺ ទទួលអារម្មណ៍ តពីជវនចិត្ត, តទាលម្ពណចិត្តនេះ កើតចំពោះតែក្នុងកាមសត្វដែលនៅក្នុងកាមភូមិប៉ុណ្ណោះ ។ ឱ្យផលជាចុតិស្ថាន ក្នុងមរណកាលនៃភពដែលរស់នៅនោះ គឺថា កាលមហាវិបាកចិត្តដែលប្រាកដគ្រាដំបូង (បដិសន្ធិ) ក្នុងភពនោះ តាំងនៅបន្តមក ដរាបដល់វារៈដែលនឹងត្រូវឃ្លាតចាកភពជាតិ ហើយ

មហាវិបាកចិត្តប្រភេទតែមួយដូចនឹងបដិសន្ធិនោះឯង ធ្វើចុតិកិច្ចឃ្លាតចាកភពនោះ មហាវិបាកចិត្ត ៨ នេះ ឱ្យផលក្នុងទី ៤ ស្ថាន ដោយប្រការយ៉ាងនេះ ។

## មហាវិបាកចែកសត្វឱ្យផ្សេងគ្នា

មហាវិបាក ៨ នេះ រមែងចែកសត្វឱ្យប្រព្រឹត្តទៅតាមកម្ម គឺ បដិសន្ធិក្នុងកាមសុគតិភូមិ ៧ តាមសមគួរដល់កម្លាំងរបស់មហាកុសលចិត្តនោះ និងធ្វើសត្វឱ្យផ្សេងគ្នា សូម្បីកើតក្នុងភូមិតែមួយក៏ដោយ ក៏ការដែលកម្មចែកសត្វឱ្យផ្សេងគ្នានោះ គឺ ព្រោះកិលេស និងកម្លាំងសទ្ធាជាដើមក្នុងអតីតកាល ។ សូម្បីក្នុងការឱ្យទានដូចគ្នា ក៏វិបាករបស់ទាននោះអាចញ៉ាំងសត្វឱ្យកើតក្នុងទីផ្សេង ៗគ្នា ដល់ ៧ កន្លែង គឺ ៖

១. អ្នកណាឱ្យទាន ដោយប្រាថ្នាផលតបមកវិញយ៉ាងណាមួយក្នុងភពខាងមុខ កាលស្លាប់ហើយ នឹងទៅកើតជាទេវតាជាន់ចាតុម្មហារាជិកា ។

២. អ្នកណាឱ្យទាន ដោយមិនប្រាថ្នាផលតបមកវិញក្នុងភពខាងមុខទេ គឺ ឱ្យដោយគិតថា ការឱ្យទានជាការល្អ កាលស្លាប់ហើយ នឹងទៅកើតជាទេវតាជាន់តាវត្តិង្ស ។

៣. អ្នកណាឱ្យទាន ដោយគិតថា មាតា បិតា យាយ តា ធ្លាប់ធ្វើមកហើយ គួរធ្វើតទៅ មិនឱ្យខូចប្រពៃណី កាលស្លាប់ហើយ នឹងទៅកើតជាទេវតាជាន់យាមា ។

៤. អ្នកណាឱ្យទាន ដោយមេត្តាប្រាថ្នានឹងឱ្យអ្នកទទួលទានមានសេចក្តីសុខ មិនមានសេចក្តីលំបាក កាលស្លាប់ហើយ នឹងទៅកើតជាទេវតាជាន់តុសិត ។

៥. អ្នកណាឱ្យទាន ដើម្បីបដិបត្តិតាមអ្នកប្រាជ្ញ អ្នកឱ្យទានកន្លងមកពីកាលមុន កាលស្លាប់ហើយ នឹងទៅកើតជាទេវតាជាន់និម្មានរតី ។

៦. អ្នកណាឱ្យទាន ដោយឃើញថា កាលឱ្យទានហើយ នឹងធ្វើចិត្តឱ្យរីករាយសោមនស្ស កើតសេចក្តីជ្រះថ្លា,

កាលស្លាប់ហើយ នឹងទៅកើតជាទេវតាជាន់បរនិម្មិតវសវត្តី ។

៧. អ្នកណាឱ្យទាន ដើម្បីជម្រះចិត្តឱ្យផូរផង់ បានឈាន កាលស្លាប់ហើយ នឹងទៅកើតក្នុងព្រហ្មលោក ។

## កុសលកម្មឱ្យផលផ្សេងគ្នា ៧ យ៉ាងទៀត

១. មានអាយុវែង ព្រោះមិនសម្លាប់សត្វ

២. មានរោគតិច ព្រោះមិនបៀតបៀនសត្វ

៣. មានសម្បុរល្អ ព្រោះមិនក្រោធ

៤. មានសក្តិធំ ព្រោះមិនច្រណែនក្នុងលាភជាដើមរបស់បុគ្គលដទៃ

៥. មានភោគច្រើន ព្រោះជាអ្នកឱ្យបាយទឹកជាដើមច្រើន

៦. កើតក្នុងត្រកូលខ្ពស់ ព្រោះជាអ្នកមិនរឹងត្អឹង ចេះគោរព

៧. មានបញ្ញាច្រើន ព្រោះសាកសួរ និងសិក្សាធម៌ ។[១]

---

១. មជ្ឈិ. ឧប. ចូឡកម្មវិភង្គសូត្រ ២៨. ៥៨/៥៧. ។

## បុព្វហេតុឱ្យសត្វផ្សេងគ្នា ៨ គឺ

*<u>ក្នុងវិសុទ្ធិមគ្គ</u> វិនិច្ឆ័យតាមមតិរបស់អដ្ឋកថាចារ្យទាំងឡាយ ក្នុងបញ្ហាថា ៖*

*ចរិតទាំងឡាយ មានអ្វីជាដើមហេតុនោះ ?*

*ក៏អាចារ្យទាំងនោះ បានពោលពាក្យនេះទុកថា ៖*

*សត្វទាំងនេះ បើនិយាយពីហេតុក្នុងកាលមុន ជាអ្នកក្រាស់ដោយលោភៈក៏មាន ក្រាស់ដោយទោសៈក៏មាន ក្រាស់ដោយមោហៈក៏មាន ជាអ្នកច្រើនដោយអលោភៈក៏មាន ច្រើនដោយអទោសៈក៏មាន ច្រើនដោយអមោហៈក៏មាន ។*

*១. ក្នុងខណៈព្យាយាមធ្វើកម្ម អ្នកណា មានលោភៈខ្លាំងក្លា អលោភៈទន់ខ្សោយ, អទោសៈ អមោហៈខ្លាំងក្លា ទោសៈ មោហៈទន់ខ្សោយ, អលោភៈទន់ខ្សោយរបស់បុគ្គលនោះ មិនអាចគ្របសង្កត់លោភៈ តែថា អទោសៈនិងអមោហៈ មានកម្លាំងខ្លាំងក្លា រមែងអាចគ្របសង្កត់ទោសៈ*

មោហៈបាន, ព្រោះហេតុនោះ បុគ្គលនោះ កើតមកដោយអំណាចកម្មនោះ ឱ្យផលហើយ រមែងជាមនុស្សល្មោភ មានសុខច្រើនជាប្រក្រតី មិនច្រើនដោយសេចក្តីក្រោធ មានបញ្ញា មានញាណ ប្រៀបដោយវជិរៈ ។

២. បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈ និងទោសៈខ្លាំងក្លា អលោភៈអទោសៈទន់ខ្សោយ, តែអមោហៈខ្លាំងក្លា មោហៈទន់ខ្សោយ, បុគ្គលនោះ កើតមកដោយកម្មនោះ ឱ្យផលហើយ រមែងជាមនុស្សល្មោភផង ឆាប់ខឹងផង តែជាមនុស្សមានបញ្ញា ។

៣. បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈ និងអទោសៈ មោហៈខ្លាំងក្លា ក្រៅពីនោះទន់ខ្សោយ, បុគ្គលនោះ បដិសន្ធិមកដោយកម្មនោះឱ្យផលហើយ រមែងជាមនុស្សល្មោភផង ជាមនុស្សល្ងង់ផង តែជាមនុស្សចិត្តត្រជាក់ មិនច្រើនដោយក្រោធ ។

៤. បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្មមាន លោភៈ ទោសៈ មោហៈ ទាំង ៣ មានកម្លាំងខ្លាំងក្លា មាន អលោភៈជាដើមទន់ខ្សោយ, បុគ្គលនោះ បដិសន្ធិមកដោយ កម្មនោះឱ្យផលហើយ រមែងជាមនុស្សល្មោភផង ឆាប់ខឹងផង ល្ងង់ខ្លៅផង ។

៥. បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មាន អលោភៈ ទោសៈ មោហៈខ្លាំងក្លា ក្រៅពីនោះទន់ខ្សោយ, បុគ្គលនោះ បដិសន្ធិមកដោយកម្មនោះឱ្យផលហើយ រមែងជា មនុស្សមិនមានលោភៈ និងមានកិលេសតិច សូម្បីឃើញ អារម្មណ៍ជាទិព្វ ឬល្អវិសេស ក៏មិនញាប់ញ័រ តែជាមនុស្ស ឆាប់ខឹង មានបញ្ញាតិច ។

៦. បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈ អទោសៈ មោហៈខ្លាំងក្លា ក្រៅពីនោះទន់ខ្សោយ, បុគ្គលនោះ បដិសន្ធិមកដោយកម្មនោះឱ្យផល រមែងជាមនុស្សមិនមាន លោភៈផង មានចិត្តត្រជាក់ផង តែជាមនុស្សល្ងង់ខ្លៅ ។

៧. បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មាន អលោភៈ ទោសៈ អមោហៈខ្លាំងក្លា ក្រៅពីនោះទន់ខ្សោយ, បុគ្គលនោះ បដិសន្ធិមកដោយកម្មនោះ ឱ្យផលហើយ រមែងជាមនុស្សមិនមានលោភៈផង មានបញ្ញាផង តែជាមនុស្សឆាប់ឆេវឆាវ ។

៨. បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មាន អលោភៈជាដើម មានកម្លាំងខ្លាំងក្លា អកុសលមានលោភៈជាដើមទន់ខ្សោយ, បុគ្គលនោះ កាលបដិសន្ធិមកដោយកម្មនោះ ឱ្យផល រមែងជាមនុស្សមិនមានលោភៈ មិនឆេវឆាវ ហើយ មានបញ្ញា ដូចព្រះមហាសង្ឃរក្ខិតត្ថេរ ដូច្នោះ ។

បុព្វហេតុ ( ហេតុខាងដើម ) តាមដែលពោលមកនេះ រមែងកំណត់ផលឱ្យប្រាកដឡើង ដើម្បីជាឧបការៈដល់អ្នកធ្វើ, ផលវិបាក ទើបមានសេចក្តីផ្សេងគ្នាជាច្រើន ដែលបុគ្គលធម្មតា លំបាកនឹងយល់ច្បាស់ទៅថា កម្មនេះ រមែងឱ្យផល យ៉ាងនេះ ឬផលយ៉ាងនេះ កើតព្រោះកម្មយ៉ាងនោះ ផលនៃ

កម្មនេះ ព្រះមានព្រះភាគត្រាស់ថា "ជាអចិន្តេយ្យ" ។

**អចិន្តេយ្យមាន ៤ គឺ**

១. ***ពុទ្ធវិសយោ*** ពុទ្ធវិស័យ គឺ ការប្រព្រឹត្តិទៅនៃសព្វញ្ញុតញ្ញាណជាដើម ។

២. ***ឈានវិសយោ*** ឈានវិស័យ គឺ ឈាន អភិញ្ញារបស់អ្នកមានឈាន

៣. ***កម្មវិបាកោ*** កម្មវិបាក គឺ ផលនៃកម្ម

៤. ***លោកចិន្តា***ការគិតរឿងក្នុងលោក ដូចគិតថា អ្នកណាហ្ន៎សាងព្រះចន្ទ ព្រះអាទិត្យ អ្នកណាសាងផែនដីធំ អ្នកណាសាងមហាសមុទ្រ អ្នកណាសាងសត្វឱ្យកើត អ្នកណាសាងភ្នំ អ្នកណាសាងដើមឈើទាំងឡាយ មានដើមស្វាយជាដើម ។[១]

ការដែលកម្មវិបាក គឺ ផលរបស់កម្មដែលនឹងឱ្យផល

១. អង្គុ. ចតុ. អបណ្ណកវគ្គ. ៤២. ៧៨/១៩៧ ។

នោះ ព្រោះសត្វបានធ្វើកម្មទុកហើយ មិនមានអ្នកណា នឹងហាមការឱ្យផលរបស់កម្មនោះបាន កម្មនោះឯង រមែងឱ្យផលតាមសមគួរដល់ចេតនាដែលធ្វើ សមដូចដែលទ្រង់ត្រាស់ទុកថា "**ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ចេតយិត្វា កម្មំ ករោតិ កាយេន វាចាយ មនសា :** ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនាថា ជាកម្ម ព្រោះបុគ្គលគិតហើយ ទើបធ្វើកម្មដោយកាយ វាចា ចិត្ត"[១] ។

<u>ក្នុងញាណវិភង្គអដ្ឋកថា</u> ពោលសភាពរបស់កម្ម ដោយសមង្គិតាទុក ៥ ប្រការ គឺ ៖

**១. អាយូហនសមង្គិតា** សេចក្តីប្រកបព្រមក្នុងការធ្វើកម្មល្អ និងកម្មអាក្រក់

**២. ចេតនាសមង្គិតា** សេចក្តីប្រកបព្រមដោយ

---

១. អង្គុ. ឆក្ក. មហាវគ្គ. ៤៦. ៦៣/២៧២ ។

ចេតនា ៣

៣. **កម្មសមង្គិតា** សេចក្ដីប្រកបព្រមនៃកម្ម ដែលគួរដល់វិបាក

៤. **វិបាកសមង្គិតា** សេចក្ដីប្រកបព្រមនៃវិបាក ដែលទឹងឱ្យផល

៥. **ឧបដ្ឋានសមង្គិតា** សេចក្ដីព្រមប្រកបនៃការប្រាកដ គឺ ដោយកម្មារម្មណ៍ កម្មនិមិត្តារម្មណ៍ និង គតិនិមិត្តារម្មណ៍ យ៉ាងណាមួយក្នុងវេលាជិតស្លាប់ ។

**ចែកមហាវិបាក ៨ ដោយន័យផ្សេង ៗ គឺ**

១. **ដោយជាតិ** ជាវិបាកជាតិ

២. **ដោយភូមិ** ជាកាមាវចរភូមិ (ក្នុងកាមសុគតិ ៧)

៣. **ដោយវេទនា** ជាសោមនស្ស ៤ ជាឧបេក្ខា ៤

៤. **ដោយហេតុ** ជានហេតុ និងជាសហេតុកចិត្ត

៦. **ដោយសម្បយុត្ត** ជាញាណសម្បយុត្ត៤ ជាញាណ

វិប្បយុត្ត ៤

៦. ដោយសង្ខារ ជាអសង្ខារិក ៤ ជាសសង្ខារិក ៤

៧. ដោយសោភណៈ ជាសោភណចិត្ត

៨. ដោយឈាន ជាអឈានចិត្ត

៩. ដោយលោក ជាលោកិយចិត្ត

១០. ដោយកិច្ច ធ្វើកិច្ច៤ គឺ បដិសន្ធិកិច្ច១ ភវង្គកិច្ច១
តទាលម្ពណកិច្ច១ ចុតិកិច្ច១

១១. ដោយអារម្មណ៍ ជាចិត្តមានអារម្មណ៍ ៦

១២. ដោយទ្វារ ជាចិត្តកើតតាមទ្វារ ៦ និងទ្វារវិមុត្ត

១៣. ដោយវត្ថុ ជាចិត្តកើតត្រង់ហទយវត្ថុ

១៤. ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុទាំង ៨

## កាមាវចរវិបាកចិត្ត មាន ២៣ គឺ

១. អកុសលវិបាកចិត្ត ៧
២. អហេតុកកុសលវិបាកចិត្ត ៨
៣. សហេតុកកាមាវចរវិបាកចិត្ត ៨
រួមជាវិបាកចិត្ត ២៣

## សម្ដែងមហាវិបាកចិត្ត ៨

- កាមាវចរវិបាកចិត្ត ៨
  - សោមនស្ស
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - ឧបេក្ខា
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១

**កាមាវចរវិបាកចិត្ត ៨ ចប់**

# មហាកិរិយា ៨

មហាកិរិយាចិត្ត ឬកាមាវចរកិរិយាចិត្តនេះ មិនមែនជាកុសលចិត្ត មិនមែនជាអកុសលចិត្ត មិនមែនជាវិបាកចិត្ត ជាចិត្តអព្យាកត គឺ ត្រឹមតែការធ្វើប៉ុណ្ណោះ មាន ២ ប្រភេទ គឺ

១. អហេតុកកិរិយាចិត្ត៣ ២.សហេតុកកិរិយាចិត្ត៨

បណ្ដាអព្យាកតចិត្តទាំង ១១ នោះ ពាក្យថា កិរិយា បានដល់ ត្រឹមតែការធ្វើ ពិតមែន ក្នុងកិរិយាចិត្តទាំងនោះ កិរិយាចិត្តណា មិនដល់ភាពជាជវនៈ កិរិយាចិត្តនោះ រមែងមិនមានផល ដូចផ្កាឈើខ្យល់ (**វាតបុប្ផំ វិយ**), កិរិយាចិត្តណា ដល់ភាពជាជវនៈ កិរិយាចិត្តនោះ ក៏មិនមានផល ដូចផ្កាឈើ(គឺ ផ្កាដែលត្រូវមានផ្លែ នៅជាប់ដើម) ដែលមានឫសដាច់ហើយ កិរិយាចិត្តទាំងនេះ គឺ ត្រឹមតែជាការធ្វើប៉ុណ្ណោះ ព្រោះប្រព្រឹត្តទៅដោយអំណាចការញុំាងកិច្ចនោះ ៗ ឱ្យសម្រេច ដូច្នោះ ។

ព្រះមានព្រះភាគ ទើបត្រាស់ថា កិរិយា (គ្រាន់តែជាការធ្វើ) ។

ក្នុងអហេតុកកិរិយាចិត្ត ៣ និងសហេតុកកិរិយាចិត្ត ៨ នោះ អហេតុកកិរិយាចិត្ត បានពោលមកហើយ ក្នុងអហេតុកចិត្ត ១៨, តទៅនេះ នឹងពោលសហេតុកកិរិយាចិត្ត ៨, ចិត្ត ៨ នេះ ជាចិត្តឱ្យសម្រេចការធ្វើការនិយាយ ការគិតរបស់ព្រះអរហន្ត ជាកិរិយាចិត្តដែលចូលដល់ភាពជាជវ័ន សោយអារម្មណ៍ដែលជាសោមនស្ស ឬឧបេក្ខា មិនជាហេតុនៃតណ្ហា និងឧបាទាន មិនអាចឱ្យកើតផល ក្នុងអនាគតកាល ដូច្នោះ ទើបលោកប្រៀបធៀប ដូចផ្កាឈើ (អាចនឹងមានគ្រាប់) ដែលមានឫសដាច់ហើយ សហេតុកចិត្ត ឬហៅថា មហាកិរិយាចិត្តនេះ ជាចិត្តមានហេតុប្រកបកើតឡើង ទទួលកាមារម្មណ៍ ជាចំណែកច្រើន និងកើតបាន ២៦ ភូមិ (វៀរអបាយភូមិ និងអសញ្ញសត្តាភូមិ) មហាកិរិយាចិត្តនេះ មាន

សភាពដូចមហាកុសលចិត្ត គឺ ចិត្តទាំង ៨ នេះ បើមិនកើតជាមួយព្រះអរហន្ត ក៏ជាចិត្តមហាកុសលទុំះឯង ។

## មហាកិរិយាចិត្ត ៨ គឺ

**១, សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** : មហាកិរិយាចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ

**២, សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** : មហាកិរិយាចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ

**៣, សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** : មហាកិរិយាចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ

**៤, សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ**

**មហាកិរិយាចិត្តំ** : មហាកិរិយាចិត្តកើតឡើង ព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ

**៥, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** : មហាកិរិយាចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ

**៦, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** : មហាកិរិយាចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ

**៧, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** : មហាកិរិយាចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ

**៨, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** : មហាកិរិយាចិត្តកើតឡើង ព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ

## ឥមានិ អដ្ឋបិ សហេតុកកាមាវចរក្រិយាចិត្តានិ នាម

ចិត្តទាំង ៨ នេះ ឈ្មោះថា សហេតុកកាមាវចរកិរិយា ។

មហាកិរិយាចិត្តរបស់ព្រះអរហន្ត ដែលកើតព្រមដោយសោមនស្សវេទនា រមែងកើតក្នុងទ្វារទាំង ៦ ។ ពិតមែន ក្នុងចក្ខុទ្វារព្រះខីណាស្រព ឃើញស្ថានដែលគួរបំពេញសេចក្តីព្យាយាមហើយ រមែងដល់ភាពជាសោមនស្ស ដោយមហាកិរិយាចិត្តនេះ, ក្នុងសោតទ្វារកាលដល់វារៈដែលលោកគួរចែកនូវចំណែកភណ្ឌៈ កាលអ្នកល្មោភធ្វើសំឡេងខ្លាំងកាន់យក លោកក៏កើតសោមនស្ស ដោយចិត្តនេះថា "តណ្ហាជាហេតុឱ្យញាប់ញ័របែបនេះ យើងលះបានហើយ", ក្នុងឃានទ្វារ កាលព្រះខីណាស្រពបូជាព្រះចេតិយ ដោយគ្រឿងក្រអូបឬដោយផ្កាឈើ លោកក៏កើតសោមនស្សដោយចិត្តនេះ, ក្នុងជិវ្ហាទ្វារ ព្រះខីណាស្រពបែងចែកបិណ្ឌបាត ដែលមានរស

ឆ្ងាញ់ដែលបានមកឆាន់ ក៏ដល់ភាពជាសោមនស្ស ដោយចិត្តនេះថា "សារាណីយធម៌ យើងបំពេញហើយហ្ន៎"[១] ដូច្នេះ, ក្នុងកាយទ្វារ ព្រះខីណាស្រពបំពេញអភិសមាចារិកវត្ត ក៏ដល់ភាពសោមនស្សដោយចិត្តនេះថា "វត្តរបស់យើងពេញគ្រប់ហើយ" ដូច្នេះ, ព្រះខីណាស្រព រមែងមានសោមនស្ស ក្នុងបញ្ចទ្វារយ៉ាងនេះ ។

តែក្នុងមនោទ្វារ ចិត្តសោមនស្សរបស់ព្រះខីណាស្រព រមែងកើតឡើងព្រោះប្រារព្ធអតីត និងអនាគត, ពិតមែន ព្រះតថាគតទ្រង់រលឹកដល់ហេតុដែលទ្រង់ធ្វើហើយ ក្នុងកាលដែលព្រះអង្គសោយជាតិ ជាជោតិបាល ជាស្តេចមឃទេវរាជ និងជាកណ្ហតាបសជាដើម ទើបទ្រង់ធ្វើការញញឹមឱ្យប្រាកដ តែការរលឹកនោះ ជាកិច្ចរបស់បុព្វេនិវាសញ្ញាណ និង

---

១. អង្គុ. ឆក្ក. សារាណីយាទិវគ្គ. ៤៦. ១១/២០ សម្តែងសារាណីយធម៌ ៦ ។

សព្វញ្ញុតញ្ញាណ ក្នុងវេលាចុងបំផុតនៃញាណទាំង ២ នោះ ចិត្តនេះ រមែងកើតវិកការ, ក្នុងអនាគត ព្រះអង្គទ្រង់បាន ធ្វើការញញឹមឱ្យប្រាកដថា នឹងមានព្រះបច្ចេកពុទ្ធ មានសំឡេង ដូចពិណ មានសំឡេងដូចសម្ភោរ ដូច្នេះ ។ ការរលឹកនោះ ជាកិច្ចរបស់អនាគតំសញ្ញាណ និងសព្វញ្ញុតញ្ញាណ ក្នុង វេលាចុងបំផុតនៃញាណទាំងពីរនោះ ចិត្តនេះ រមែងកើត វិកការ ។

មហាកិរិយាចិត្ត ដែលកើតព្រមនឹងឧបេក្ខាវេទនានោះ រមែងប្រាកដក្នុងខណៈដែលលោកពិចារណាអារម្មណ៍ ដែល មកប៉ះខ្ទប់ក្នុងទ្វារទាំង ៦ ដោយឆឡង្គុបេក្ខា មិនមានសេចក្ដី ញាប់ញ័រយ៉ាងណាទេ ។ មួយទៀត មហាកិរិយាចិត្តរបស់ ព្រះខីណាស្រពនោះ គ្រាខ្លះក៏ប្រកបដោយញាណ គ្រាខ្លះក៏មិន ប្រកបដោយញាណ, ដែលមិនប្រកបដោយញាណ ដូចខណៈ ឈរ ដើរជាដើម មិនបាច់មានបញ្ញា ក៏ឈរ ដើរ អង្គុយ

សរុបបាន ។

## ចែកមហាកិរិយា ៨ ដោយន័យផ្សេង ៗ គឺ

១. ដោយជាតិ ជាកិរិយាជាតិ

២. ដោយភូមិ ជាកាមភូមិ ( កើតបាន ២៦ ភូមិ )

៣. ដោយវេទនា ជាសោមនស្ស ៤ ជាឧបេក្ខា ៤

៤. ដោយហេតុ ជានហេតុ និងជាសហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាញាណសម្បយុត្ត ៤ ជាញាណវិប្បយុត្ត ៤

៦. ដោយសង្ខារ ជាអសង្ខារិក ៤ ជាសសង្ខារិក ៤

៧. ដោយសោភណៈ ជាកាមាវចរសោភណចិត្ត

៨. ដោយឈាន ជាអឈានចិត្ត

៩. ដោយលោក ជាលោកិយចិត្ត

១០. ដោយកិច្ច ធ្វើជវនកិច្ច

១១. ដោយអារម្មណ៍ មានអារម្មណ៍ ៦

១២. *ដោយទ្វារ* កើតតាមទ្វារ ៦

១៣. *ដោយវត្ថុ* កើតត្រង់ហទយវត្ថុ ( ២២ ភូមិ )

១៤. *ដោយវិញ្ញាណធាតុ* ជាមនោវិញ្ញាណធាតុ

## សម្ដែងកាមាវចរកិរិយាចិត្ត ៨

- កាមាវចរកិរិយាចិត្ត ៨
  - សោមនស្ស
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - ឧបេក្ខា
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១

**ចប់ មហាកិរិយាចិត្ត ៨**

## បាលីពាក្យនិគម

ឥច្ចេវំ សព្វថាបិ ចតុវីសតិ សហេតុកកាមាវចរកុសលវិបាកក្រិយា ចិត្តានិ សមត្តានិ : កុសលចិត្ត វិបាកចិត្ត និងកិរិយាចិត្ត ដែលជាកាមាវចរសហេតុកចិត្ត ២៤ ចប់បរិបូណ៌ហើយ ដោយប្រការទាំងពួង ដោយប្រការដូច្នេះ ។

## សរុបកាមាវចរសោភណចិត្ត ២៤

- កាមាវចរសោភណចិត្ត ២៤
  - សោមនស្ស
    - ញាណសម្បយុត្ត
      - អសង្ខារិក ៣
      - សសង្ខារិក ៣
    - ញាណវិប្បយុត្ត
      - អសង្ខារិក ៣
      - សសង្ខារិក ៣
  - ឧបេក្ខា
    - ញាណសម្បយុត្ត
      - អសង្ខារិក ៣
      - សសង្ខារិក ៣
    - ញាណវិប្បយុត្ត
      - អសង្ខារិក ៣
      - សសង្ខារិក ៣

**ចប់ កាមាវចរសហេតុកចិត្ត ២៤**

## សង្គហគាថា

៧. កាមេ តេវីស បាកានិ បុញ្ញាបុញ្ញានិ វីសតិ
ឯកាទស ក្រិយា ចេតិ ចតុបញ្ញាស សព្វថា ។

***កាមាវចរចិត្តនោះ រាប់ជាវិបាក ២៣. កុសលចិត្ត និងអកុសលចិត្ត ២០ និងកិរិយាចិត្ត ១១ រួបរួម កាមាវចរចិត្ត ទាំងអស់ត្រូវជា ៥៤ ដូច្នេះ ។***

*ឥឡូវនេះ ដើម្បីនឹងប្រមូលមកសម្តែងកាមាវចរចិត្តទាំងអស់ ទើបលោកពោលសង្គហគាថាទី ៧ ថា "**កាមេ តេវីស**"ជាដើម អធិប្បាយថា សូម្បីចិត្តក្នុងកាមភូមិ ដោយប្រការទាំងពួង ដែលមានប្រភេទច្រើន ដោយសេចក្តីផ្សេងគ្នានៃបកិណ្ណកៈ មានកាល ទ្វារ និងសន្តានជាដើម ក៏មានត្រឹមតែ ៥៤ ប៉ុណ្ណោះ ដោយសេចក្តីផ្សេងគ្នា តាំងចុះក្នុងកុសល អកុសល វិបាក និងកិរិយា គឺ ៖*

*អកុសលវិបាកចិត្ត ៧ = ៧*

| | | |
|---|---|---|
| កុសលវិបាកសហេតុកចិត្ត ៨ | អហេតុកវិបាកចិត្ត ៨ | = ១៦ |
| អកុសលចិត្ត ១២ | មហាកុសលចិត្ត ៨ | = ២០ |
| អហេតុកកិរិយាចិត្ត ៣ | សហេតុកកិរិយាចិត្ត ៨ | = ១១ |
| រួមកាមាវចរចិត្ត (៧ + ១៦ + ២០ + ១១) | | = ៥៤ |

## សម្តែងសរុប កាមាវចរចិត្ត ៥៤

- កាមាវចរចិត្ត៥៤
  - អសោភណចិត្ត ៣០
    - លោភមូលចិត្ត ៨
    - ទោសមូលចិត្ត ២
    - មោហមូលចិត្ត ២
    - អហេតុកចិត្ត១៨
      - អកុសលវិបាកចិត្ត ៧
      - អហេតុកកុសលវិបាកចិត្ត៨
      - អហេតុកកិរិយាចិត្ត ៣
  - កាមាវចរសោភណចិត្ត២៤
    - មហាកុសលចិត្ត ៨
    - មហាវិបាកចិត្ត ៨
    - មហាកិរិយាចិត្ត ៨

**ចប់ កាមាវចរសហេតុកចិត្ត ២៤**

## សំនួរ-ចំលើយ

១- កាមាវចរសោភណចិត្ត២៤ មានប៉ុន្មានជាតិ ?

+ កាមាវចរសោភណចិត្ត មាន ៣ ជាតិ គឺ មហាកុសលចិត្ត៨ ជាកុសលជាតិ, មហាវិបាកចិត្ត៨ ជាវិបាកជាតិ, មហាកិរិយាចិត្ត៨ ជាកិរិយាជាតិ ។

២- ពាក្យថា សោមនស្សសហគត កើតព្រមនឹងសោមនស្សក្តី និងឧបេក្ខាសហគត កើតព្រមនឹងឧបេក្ខាក្តី ក្នុងមហាកុសលចិត្តនេះ និងក្នុងលោភមូលចិត្ត ដែលពោលរួចហើយនោះ ផ្សេងគ្នាយ៉ាងណា ?

+ ផ្សេងគ្នាយ៉ាងនេះ គឺ ក្នុងលោភមូលចិត្ត ជាចិត្តមានលោភជាមូល ជាអកុសលឱ្យផលជាទុក្ខ ចំណែកមហាកុសលចិត្ត៨ នេះ ជាចិត្តដែលប្រកបដោយកុសលហេតុ គឺអលោភៈ អទោសៈ និងអមោហៈ ឱ្យផលជាសុខ ។

៣- តើការផ្សេងគ្នានៃមហាកុសលញាណសម្បយុត្ត និងញាណវិប្បយុត្ត យ៉ាងណា ?

+ មហាកុសលញាណសម្បយុត្ត និងញាណវិប្បយុត្ត

មានសេចក្ដីផ្សេងគ្នាយ៉ាងនេះ គឺ

កុសលចិត្ត ដែលប្រកបដោយញាណនោះ ដូចបុគ្គលឱ្យទានមានការយល់ឃើញថា ផលរបស់ទានមាន (សម្មាទិដ្ឋិ ១០ យ៉ាង មាន) ហើយឱ្យទានក្ដី ឬកាលណាបុគ្គលបានផ្កាឈើយ៉ាងណាមួយ មានពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហមនិងពណ៌សជាដើម រលឹកដល់ពណ៌នោះ ហើយបូជា ព្រះរតនត្រ័យជាដើម ដោយគិតថា បើយើងថ្វាយពណ៌ជាទានក្ដី ទាននេះនឹងប្រកបដោយញាណ ។

**<u>ក្នុងអដ្ឋសាលិនី</u>** ពោលរឿងទុកមកថា ៖

បានឮថា អ្នករក្សាឃ្លាំងម្នាក់ឈ្មោះ សង្ឃមិត្ត បានសំពត់ ឱនមាស(វិចិត្រដោយមាស)មួយផ្ទាំង គិតថា "សំពត់នេះ មានពណ៌ដូចមាស សូម្បីព្រះសម្មាសម្ពុទ្ធ ក៏មានព្រះឆវីវណ្ណដូចមាស សំពត់ពណ៌មាស សមគួរដល់ព្រះពុទ្ធ ដែលមានពណ៌ដូចមាសប៉ុណ្ណោះ និងការឱ្យ(ថ្វាយ)ពណ៌ នឹងមានដល់ពួកយើង" ដូច្នេះ. ទើបយកសំពត់នោះ ទៅរុំចេតិយ

កុសលទានដែលប្រកបដោយញាណបែបនេះ គប្បីជ្រាបថា ជាមហាកុសលញាណសម្បយុត្ត ។

ចំណែកកុសល ដែលមិនប្រកបដោយញាណ មានន័យផ្ទុយគ្នានឹងកុសល ដែលប្រកបដោយញាណ គឺ មិនប្រើបញ្ញាពិចារណា ឬមិនមានការយល់យ៉ាងត្រឹមត្រូវ តាមន័យដែលពោលទុកក្នុងសម្មាទិដ្ឋិ ១០ ប្រការ ដូចការធ្វើកុសលរបស់ពួកក្មេង ៗ ដែលគេធ្លាប់ឃើញញាតិថ្វាយអាហារបិណ្ឌបាតជាទានដល់សង្ឃ កាលពួកក្មេងទាំងនោះ ឃើញភិក្ខុនិមន្តមក ក៏ឱ្យរបស់ដែលខ្លួនមាន ឬលើកដៃសំពះ ការធ្វើកុសល បែបនេះ មិនប្រកបដោយញាណ ហៅថា ញាណវិប្បយុត្ត ។

៤- ការចម្រើនភាវនាយ៉ាងណា ទើបជាញាណសម្បយុត្ត ?

\+ ការចម្រើនកុសលដោយមានរូបជាត្រៃលក្ខណ៍

**ក្នុងអដ្ឋសាលិនី** ពោលទុកថា ៖

"កាលណា បុគ្គលធ្វើការបូជាព្រះរតនត្រ័យ ដោយវត្ថុ (វណ្ណទានំ )ដូច្នេះ ហើយផ្តើមតាំងសេចក្តីអស់ទៅ សាប

សូន្យទៅរបស់ពណ៌នោះ ដោយមនសិការៈប្រពៃថា ពណ៌នេះនឹង ដល់ការអស់ទៅ នឹងដល់ការសាបសូន្យទៅ” ដូច្នេះ កាលនោះ កុសលរមែងជាភាវនាមយៈ ដែលជាញាណសម្បយុត្ត

៥- តើសេចក្តីផ្សេងគ្នារបស់កុសល ដែលជាអសង្ខារិកចិត្ត និងសសង្ខារិកចិត្ត យ៉ាងណា ?

\+ កុសលដែលជាអសង្ខារិកចិត្តនោះ កើតឡើងដោយមិនមានការបបួលដឹកនាំ កាលវេលាឱ្យផល រមែងឱ្យផលខ្លាំងជាងផលរបស់កុសល ដែលជាសសង្ខារិកចិត្ត និងក្នុងចិត្តសន្តានរបស់បុគ្គល ដែលមានចិត្តជាអសង្ខារិកចិត្តនោះ រមែងជាបច្ច័យឱ្យអសង្ខារិកចិត្តកើតបានងាយក្នុងភពតទៅ, ចំណែកកុសលដែលជាសសង្ខារិកចិត្តនោះ កើតឡើងដោយមានការបបួលដឹកនាំ កាលវេលាឱ្យផល រមែងឱ្យផលខ្សោយ ជាងផលរបស់កុសល ដែលជាកុសលអសង្ខារិកចិត្ត ។

៦- តើមហាកុសលចិត្ត ក្នុងការធ្វើទានដែលប្រព្រឹត្តទៅក្នុង

កម្មទាំង ៣ យ៉ាងណា ?

+ ក្នុងកាលណា បុគ្គលថ្វាយទានចំពោះព្រះរតនត្រ័យ ដោយដៃរបស់ខ្លួន ក្នុងកាលនោះ ក៏ជាមហាកុសល ប្រកប ដោយកាយកម្ម, ក្នុងកាលណា ប្រើបុត្រ ភរិយាជាដើម ឱ្យ ថ្វាយទានក្នុងកាលនោះ ក៏ជាវចីកម្ម, ក្នុងកាលណា បុគ្គល ប្រារព្ធវត្ថុទានដែលខ្លួនមាន ហើយគិតថា "យើងនឹងឱ្យទាន" ក្នុងកាលនោះ ក៏ជាមនោកម្ម ។

៧- តើការឱ្យសំឡេង ឱ្យក្លិន ឱ្យរស ឱ្យផោដ្ឋព្វៈ ជាទាន នោះ ធ្វើយ៉ាងណា ?

+ ធម្មតាសំឡេងមិនមានអ្នកណា អាចចាប់មកដាក់ក្នុងដៃ ដូចជារបស់ផ្សេង ៗ មានបាយ ទឹកជាដើមបានទេ តែក៏អាចឱ្យ សំឡេងបាន ដោយគិតថា "យើងនឹងថ្វាយទាន ដោយ សំឡេងរបស់យើង ទើបបញ្ចេញវាចាក្នុងការថ្វាយភេសជ្ជៈ មានទឹកឃ្មុំ ទឹកអំពៅ"ជាដើម ឬរមែងឃោសនានូវការស្ដាប់ធម៌ ឬពោលធម្មកថា ក្នុងកាលនោះ ក៏ជាការឱ្យសំឡេងជា ទាន

( សទ្ទទានំ ) ។ ក្នុងកាលណា បុគ្គលធ្វើក្លិនឱ្យជាទីពេញចិត្ត ហើយឱ្យក្លិននោះជាទាន ដោយការបូជាព្រះរតនត្រ័យជាដើម ក្នុងកាលនោះ ក៏ជាការឱ្យក្លិនជាទាន( គន្ធទានំ ) ។ ក្នុងកាលណា បុគ្គលធ្វើរសឱ្យជាទីពេញចិត្ត ហើយឱ្យរសនោះជាទាន ឬ បូជាព្រះរតនត្រ័យជាដើម ក្នុងកាលនោះ ក៏ជាការឱ្យរសជាទាន ( រសទានំ ) ។ ក្នុងអដ្ឋកថាពោលរឿងព្រះបាទទុដ្ឋគាមិនីអភ័យថា ព្រះបាទទុដ្ឋគាមិនីអភ័យរាជាអង្គនេះ ទ្រង់ត្រិះរិះថា "ធម្មតា ការមិនថ្វាយសង្ឃទានហើយបរិភោគ យើងមិនធ្លាប់ប្រព្រឹត្ត"ដូច្នេះ ទើបថ្វាយទានដល់ភិក្ខុទាំងឡាយ ហើយសោយព្រះក្រយាហារមានរសល្អ ជាខាងក្រោយ ។ ក្នុងកាលណា បុគ្គលបានវត្ថុដែលគួរពាល់ត្រូវ គួរប្រាថ្នា យ៉ាងណាមួយ មានគ្រែ តាំងជាដើម ហើយនឹកដល់ការពាល់ត្រូវ( សម្ផស្ស ) រមែងឱ្យ រមែងបរិច្ចាគដោយគិតថា "យើងឱ្យសម្ផស្សជាទាន" ( ផោដ្ឋព្វទានំ ) ក្នុងកាលនោះ ក៏ជាការឱ្យផោដ្ឋព្វៈជាទាន ។

៨- ការឱ្យធម៌ ដែលជាអារម្មណ៍ ( ធម្មារម្មណ៍ ) ជាទាន

នោះ ធ្វើបានយ៉ាងណា ?

+ ធម្មារម្មណ៍នោះ បានដល់ ចិត្ត ចេតសិក រូប និព្វាន និងបញ្ញត្តិ តែក្នុងឋាននេះ បណ្ឌិតមិនធ្វើការប្រកបទុក ដោយអំណាចនៃធម៌ទាំងនោះ គប្បីប្រកបទុកដោយការឱ្យឱជា ( អាហារ ) ការឱ្យបានៈ( ទឹកដែលគួរផឹក ) និងការឱ្យជីវិតជាទាន ។ ពិតមែន ក្នុងធម្មារម្មណ៍នោះ កាលណា បុគ្គលថ្វាយទឹកដោះថ្លា ខ្លាញ់ជាដើម ដោយគិតថា "យើងថ្វាយ ឱជាជាទាន" ដូច្នេះ រមែងថ្វាយទឹកបានៈ ដោយគិតថា "យើងថ្វាយទឹកបានៈឱ្យជាទាន" ដូច្នេះ រមែងថ្វាយសលាកភត្តជាដើម ដោយគិតថា "យើងថ្វាយជីវិតជាទាន" ដូច្នេះ ឬរមែងថ្វាយភេសជ្ជៈ ដល់ភិក្ខុអាពាធទាំងឡាយ ឱ្យពេទ្យមកព្យាបាល ឱ្យដុតសំណាញ់ ឱ្យទំលាយទ្រុងបក្សី ឱ្យផុតចាកទ្រុង ឱ្យប្រកាសហាមសម្លាប់សត្វ កាលធ្វើបែបនេះ សូម្បីដទៃ ៗ ដើម្បីរក្សាជីវិត ក្នុងកាលនោះកុសលចិត្ត ក៏ជាទានមយៈ ជាធម្មារម្មណ៍ ប្រព្រឹត្តទៅតាមផ្លូវមនោទ្វារ ។

៩- កាមាវចរកុសល ប្រកបដោយធម៌អ្វី ហេតុអ្វី ទើបហៅថា មហាកុសល ?

+ កាមាវចរកុសល ៨ ប្រកបដោយសោភណចេតសិកធម៌ ៣ គឺ វេទនា១ បញ្ញា១ និងសង្ខារ១ ដែលហៅថា មហាកុសលនោះ ព្រោះជាចិត្តកើតបានក្នុងភូមិផ្សេងៗដល់៣០ ភូមិ (វៀរតែអសញ្ញសត្តាភូមិ) និងកើតបានក្នុងសន្តានរបស់បុគ្គលទូទៅ វៀរតែក្នុងសន្តានមគ្គបុគ្គល អរហត្តផលបុគ្គល និងអសញ្ញសត្តបុគ្គល, ក្រៅពីនេះហើយ កាមាវចរកុសល អាចជាបាទឱ្យកើតឈានចិត្ត អភិញ្ញាចិត្ត មគ្គចិត្ត ផលចិត្ត ដោយហេតុនេះ ទើបហៅថា មហាកុសល ។

១០- មហាកុសលចិត្តកើតបាន ៣០ភូមិ សេចក្តីថា ចិត្តប្រភេទនេះ កើតបានក្នុងសន្តានរបស់កាមបុគ្គល រូបបុគ្គល អរូបបុគ្គល ចុះហេតុអ្វី បានជាហៅថា កាមាវចរចិត្តទៀត ?

+ មហាកុសលចិត្ត កើតក្នុងសន្តានរបស់បុគ្គលក្នុងភូមិផ្សេងៗ បានក៏ពិត តែលក្ខណៈការកើតរបស់ចិត្តប្រភេទនេះ

កើតឡើង ដោយមានកាមារម្មណ៍មកប្រាកដ និងចិត្តនេះ ក៏ដឹងកាមារម្មណ៍ដោយច្រើន (វៀរតែខណៈធ្វើគោត្រភូកិច្ច និងវោទាន ឬបច្ចវេក្ខណញាណ ចំណែកខ្លះប៉ុណ្ណោះ) ដូច្នោះសូម្បីថា កើតបានដល់បុគ្គលដទៃ ៗ ដែលមិនមែនកាមបុគ្គល ក៏ឈ្មោះថា កាមាវចរចិត្ត ។

១១- ព្រោះហេតុអ្វី មហាកុសលចិត្ត ទើបមិនកើតក្នុងសន្តានរបស់មគ្គបុគ្គល និងអសញ្ញសត្តបុគ្គល ?

+ ព្រោះឋានរបស់មគ្គបុគ្គលនោះ ជាលោកុត្តរកុសល មិនមែនកាមាវចរកុសល ចំណែកអសញ្ញសត្តបុគ្គល ក្នុងអសញ្ញសត្តាភូមិនោះ ជាបុគ្គលមានតែរូប មិនមានចិត្ត និងចេតសិក ។

១២- មហាកុសលចិត្ត ៨នោះ ចិត្តណាឱ្យផលខ្ពស់ ?

+ មហាកុសលចិត្ត ដែលកើតព្រមទឹងសោមនស្ស ឱ្យផលខ្ពស់ជាងឧបេក្ខា, ដែលសម្បយុត្តដោយញាណ ឱ្យផលខ្ពស់ជាងញាណវិប្បយុត្ត, ដែលជាអសង្ខារិក ឱ្យផលខ្ពស់

ជាផសសង្ខារិក ។

១៣- អានិសង្សគឺ វិបាកដែលជាផលរបស់មហាកុសលចិត្ត ៨ នោះ ចំពោះមហាកុសលញាណសម្បយុត្ត ៤ ឱ្យផលយ៉ាងណាខ្លះ ?

+ ចំពោះមហាកុសលញាណសម្បយុត្ត ៤ នោះ ឱ្យផលជា ៤ ន័យ គឺ

១. មហាកុសលញាណសម្បយុត្តចិត្ត ជាន់ល្អកំពូលដែលហៅថា តិហេតុកឧក្កដ្ឋុក្កដ្ឋ (តិហេតុក+ឧក្កដ្ឋ+ឧក្កដ្ឋ) ឱ្យវិបាក ១៦ គឺ មហាវិបាកចិត្ត ៨ និងអហេតុកកុសលវិបាក ៨ គឺ ចក្ខុវិញ្ញាណ១ សោតវិញ្ញាណ១ ឃានវិញ្ញាណ១ ជិវ្ហាវិញ្ញាណ១ កាយវិញ្ញាណ១ មនោធាតុ១ មនោវិញ្ញាណធាតុ២ និងកើតក្នុងសុគតិភូមិ ៧ បរិបូណ៌ដល់ព្រមដោយមនុស្សសម្បត្តិ សួគ៌សម្បត្តិ ប្រកបដោយបញ្ញា អាចសម្រេចមគ្គផល និព្វាន និងឈានអភិញ្ញា ចាត់ជាបុគ្គល ជាន់ប្រណីតខ្ពង់ខ្ពស់ មានសម្បត្តិបរិបូណ៌ តាំងពីកើតរហូតដល់ស្លាប់ ។

២. មហាកុសលញាណសម្បយុត្តចិត្ត ជាន់ល្អកំពូលទី២ (រង) ដែលហៅថា តិហេតុកឧក្កដ្ឋោមកៈ (តិហេតុក + ឧក្កដ្ឋ+ឱមកៈ) ឱ្យវិបាក ១៦ ដូចគ្នានឹងន័យទី១ គឺ មហាវិបាកចិត្ត ៨ និងអហេតុកកុសលវិបាក ៨ ទៀត អាចកើតក្នុងមនុស្សភូមិ និងទេវភូមិ តែមិនល្អរហូត គឺ ផ្នែកខាងចុងមិនល្អ និងមានសតិបញ្ញា ។

៣. មហាកុសលញាណសម្បយុត្តចិត្ត យ៉ាងល្អជាន់ទី ៣ ដែលហៅថា តិហេតុកឱមកុក្កដ្ឋ (តិហេតុក+ឱមកៈ +ឧក្កដ្ឋ) ឱ្យវិបាក ១២ គឺ មហាវិបាកញាណសម្បយុត្តចិត្ត ៤ និងអហេតុកកុសលវិបាក៨ អាចកើតបានក្នុងមនុស្សភូមិ និងទេវភូមិ សេចក្តីសុខក្នុងកាមគុណ មិនបរិបូណ៌ ទាបខ្ពស់ ៗ គឺ វ័យក្មេងមិនល្អ វ័យកំលោះក្រមុំល្អ វ័យ កណ្តាលល្អ វ័យចាស់មិនល្អ

៤. មហាកុសលញាណសម្បយុត្តចិត្ត យ៉ាងទាបជាន់ទី ៤ ដែលហៅថា តិហេតុកឱមកោមកៈ (តិហេតុក +

ឱមកៈ + ឱមកៈ) ឱ្យវិបាក ១២ គឺ ដូចនឹងន័យទី៣ គឺ មហាវិបាកញាណសម្បយុត្តចិត្ត ៤ និងអហេតុកកុសលវិបាក ៨ អាចកើតបានក្នុងមនុស្សភូមិ និងទេវភូមិ សេចក្ដីសុខ និងសម្បត្តិតិចជាងន័យទី៣ មានសេចក្ដីសុខមិនស្មើ គឺ វ័យដើមមិនល្អ វ័យកំលោះក្រមុំល្អ វ័យកណ្ដាលមិនល្អ វ័យចាស់ មិនល្អ ដូច្នេះជាដើម ។

១៤- អានិសង្សរបស់មហាកុសលញាណសម្បយុត្តចិត្ត មានសេចក្ដីផ្សេងគ្នា ៤ ន័យ តើព្រោះអ្វី ?

+ គឺ ព្រោះចេតនាក្នុងការធ្វើកុសលនោះផ្សេងគ្នា ដោយអំណាចចេតនា ៤ កាល គឺ បុព្វចេតនា១ មុញ្ចនចេតនា១ អបរចេតនា១ អបរាបរចេតនា១ ។

១៥- ចេតនារបស់មហាកុសលញាណសម្បយុត្តចិត្ត ៤ ន័យនោះ មានអ្វីខ្លះ ? និងក្នុងសង្គហៈ ពោលអំពីការឱ្យផលក្នុងបដិសន្ធិកាល និងបវត្តិកាលយ៉ាងណា ?

+ មានអធិប្បាយទុកថា ចេតនាក្នុងការធ្វើកុសលញាណ

សម្បយុត្តនោះ កុសលក្នុងកាលទាំង ៤ (តិហេតុកឧក្កដ្ឋកដ្ឋ) រមែងឱ្យវិបាកល្អ ក៏រិតទី១ ។ បើចេតនាល្អក្នុងកាលទាំង ៣ តែអបរាបរចេតនាមិនល្អ (តិហេតុកឧក្កដ្ឋោមក) ជាកុសលឱ្យវិបាកល្អ ក៏រិតទី២ ។ បើបុព្វចេតនាមិនល្អ មុញ្ចនចេតនាល្អ អបរចេតនាល្អ តែអបរាបរចេតនាមិនល្អ (តិហេតុកឱមក្កដ្ឋ) ជាកុសលល្អក៏រិតទី៣ រមែងឱ្យផលល្អក៏រិតទី៣ បើមុញ្ចនចេតនាល្អ ចេតនាដែលនៅសល់ ៣ ទៀត មិនល្អ (តិហេតុកឱមកោមក) រមែងឱ្យផលល្អក៏រិតទី៤ ។

ការឱ្យផលក្នុងបដិសន្ធិកាល និងបវត្តិកាល របស់កុសលដែលជាឧក្កដ្ឋ(យ៉ាងខ្ពស់) និងឱមកៈ(ជាន់រង) ពោលទុកថា ?

**១. តិហេតុកឧក្កដ្ឋំ កុសលំ តិហេតុកំ បដិសន្ធឹ ធត្វា បវត្តេ សោឡសវិបាកានិ វិបច្ចតិ** តិហេតុកឧក្កដ្ឋកុសល (តិហេតុកយ៉ាងខ្ពង់ខ្ពស់) ឱ្យបដិសន្ធិជាតិហេតុក ហើយ ក្នុងបវត្តិកាល រមែងឱ្យ(បញ្ចេញ) វិបាក ១៦ យ៉ាង

២. តិហេតុកឧមកំ ទ្វិហេតុកឧក្កដ្ឋញ្ច កុសលំ ទ្វិហេតុកំ បដិសន្ធឹ ទត្វា បវត្តេ តិហេតុករហិតានិ ទ្វាទសវិបាកានិ វិបច្ចតិ តិហេតុកឱមកកុសល (តិហេតុកកុសលយ៉ាងថោកទាប) និងទ្វិហេតុកឧក្កដ្ឋកុសល (ទ្វិហេតុកយ៉ាងខ្ពង់ខ្ពស់) ឱ្យបដិសន្ធិជាទ្វិហេតុកហើយ ក្នុងបវត្តិកាលរមែងឱ្យ(បញ្ចេញ) វិបាក ១២ វៀរតិហេតុកវិបាក

៣. ទ្វិហេតុកឱមកំ បន កុសលំ អហេតុកមេវ បដិសន្ធឹ ទេតិ បវត្តេ អហេតុកវិបាកានេវ វិបច្ចតិ ចំណែកទ្វិហេតុកកុសលថោកទាប ឱ្យបដិសន្ធិ ជាអហេតុកវិបាកប៉ុណ្ណោះ និងក្នុងបវត្តិកាល រមែង(បញ្ចេញ)ឱ្យវិបាកជាអហេតុក ៨ នោះឯង ។

១៦- អានិសង្សរបស់មហាកុសលញាណវិប្បយុត្តចិត្ត មានន័យយ៉ាងណាខ្លះ ?

+ មាន ៤ ន័យ គឺ

<u>ន័យទី១.</u> មហាកុសលញាណវិប្បយុត្តចិត្ត (ទ្វិហេតុកឧក្កដ្ឋកុក្កដ្ឋ)

ជាមហាកុសលញាណវិប្បយុត្តចិត្តជាន់ទី១ រមែងឱ្យកើតវិបាក ១២ គឺ មហាវិបាកញាណវិប្បយុត្ត ៤ និងអហេតុកកុសលវិបាក ៨ គឺ កើតក្នុងសុគតិភូមិ ៧ គឺ ក្នុងភូមិមនុស្សនិងទេវតា រមែងបរិបូណ៌ដល់ព្រមដោយមនុស្សសម្បត្តិ សួគ៌សម្បត្តិ មានសម្បត្តិបរិបូណ៌ តាំង ពីកើតរហូត ដល់ស្លាប់ តែមិនអាចសម្រេចមគ្គ ផល និព្វាន ឈាន អភិញ្ញា ព្រោះមិនប្រកបដោយញាណ ។

<u>ន័យទី២.</u> មហាកុសលញាណវិប្បយុត្តចិត្ត (ទ្វិហេតុកឧក្កដ្ឋោ-មក:) ជាមហាកុសលញាណវិប្បយុត្តចិត្ត ជាន់ទី២ ឱ្យកើតវិបាក១២ ដូចគ្នានឹងន័យទី១ តែលំដាប់ទាបជាងអាចកើតក្នុងមនុស្សភូមិ និងទេវភូមិ បានទទួលសេចក្តីសុខក្នុង សម្បត្តិ តែមានល្អតិចជាងទី១ ដូចវ័យក្មេងល្អ វ័យកំលោះ ក្រមុំល្អ វ័យកណ្តាលល្អ វ័យចាស់មិនល្អ ដូច្នេះជាដើម និង មិនអាចសម្រេចមគ្គ ផល និព្វាន ឈាន អភិញ្ញា ។

<u>ន័យទី៣.</u> មហាកុសលញាណវិប្បយុត្តចិត្ត (ទ្វិហេតុកឧមកុក្កដ្ឋ) ជាមហាកុសលញាណវិប្បយុត្តចិត្ត ល្អជាន់ទី៣ ឱ្យកើតអហេតុកកុសលវិបាកចិត្ត ៨ ប៉ុណ្ណោះ អាចកើតបានក្នុងសុគតិភូមិ ៧ គឺ ក្នុងមនុស្សភូមិ និងទេវភូមិ បានសេចក្ដីសុខតិចជាងន័យទី២ និងមិនអាចសម្រេចមគ្គ ផល និព្វាន ឈានអភិញ្ញា ។

<u>ន័យទ៤.</u> មហាកុសលញាណវិប្បយុត្តចិត្ត (ទ្វិហេតុកឧមកោមកៈ) ជាមហាកុសលញាណវិប្បយុត្តចិត្ត ល្អយ៉ាងទាបបំផុត ឱ្យអហេតុកកុសលវិបាក ៨ អាចកើតបាន ក្នុងសុគតិភូមិ៧ គឺ មនុស្សភូមិ និងទេវភូមិជាន់ទាប ជាបុគ្គលជាន់ទាបជាងន័យទី៣ និងមិនអាចចម្រើនសមថៈ វិបស្សនាបានដូចគ្នា ។

១៧- មហាកុសលញាណវិប្បយុត្តចិត្តនេះ ឱ្យផលផ្សេងគ្នា ជា ៤ ន័យ តើព្រោះអ្វី ?

\+ គឺ ព្រោះចេតនាក្នុងការធ្វើកុសលនោះ មានសេចក្ដី

ប្លែកផ្សេងគ្នា ៤ យ៉ាង ទំនងដូចមហាកុសលញាណសម្បយុត្តចិត្តនោះឯង (ក្នុងសំនួរទី១៤) ។

១៨- បុគ្គលម្នាក់ ៗ សុទ្ធតែធ្វើកម្មមកច្រើន ជាកុសលក៏មាន អកុសលក៏មាន បើកុសលកម្មបានឱកាសធ្វើបដិសន្ធិហើយ ផលរបស់អកុសលកម្ម រមែងមិនបានឱកាសឬ ?

+ កាលផលរបស់កុសលកម្ម បានឱកាសធ្វើបដិសន្ធិ(នាំឱ្យកើត) ផលរបស់អកុសលកម្ម រមែងមិនបានឱកាសធ្វើបដិសន្ធិកិច្ច តែក៏បានឱកាសឱ្យផល ក្នុងបវត្តិកាល ដូចឱ្យឃើញ ក្នុងវត្ថុដែលមិនស្អាត បានស្ដាប់សំឡេងមិនពិរោះ ជាដើម យ៉ាងធ្ងន់អាចធ្វើការកាត់ផ្ដាច់ជីវិត ក៏មាន

១៩- ចូរសម្ដែងមហាកុសល ៨ ដោយន័យផ្សេង ៗ មានដោយជាតិជាដើម

+ មហាកុសល ៨ ដោយន័យផ្សេង ៗ ដូច្នេះ គឺ

១. ដោយជាតិ ជាកុសលជាតិ

២. ដោយភូមិ ជាកាមភូមិ(កើតបាន៣០ភូមិ)

| | |
|---|---|
| ៣. ដោយវេទនា | ជាសោមនស្ស៤ ជាឧបេក្ខា៤ |
| ៤. ដោយហេតុ | ជានហេតុ និងជាសហេតុកចិត្ត |
| ៥. ដោយសម្បយុត្ត | ជាញាណសម្បយុត្ត៤ ជាញាណវិប្បយុត្ត ៤ |
| ៦. ដោយសង្ខារ | ជាអសង្ខារិក៤ ជាសសង្ខារិក ៤ |
| ៧. ដោយសោភណ | ជាកាមសោភណចិត្ត |
| ៨. ដោយឈាន | ជាអឈានចិត្ត |
| ៩. ដោយលោក | ជាលោកិយចិត្ត |
| ១០. ដោយកិច្ច | ធ្វើជវនកិច្ច |
| ១១. ដោយអារម្មណ៍ | ជាចិត្តមានអារម្មណ៍៦ |
| ១២. ដោយទ្វារ | ជាចិត្តកើតតាមទ្វារ៦ |
| ១៣. ដោយវត្ថុ | កើតត្រង់ហទយវត្ថុ |
| ១៤. ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ |

២០- ក្នុងអហេតុកចិត្ត ក៏មានវិបាក ក្នុងកាមាវចរសោភណចិត្ត ក៏មានវិបាក, វិបាកទាំង ២ នេះ ផ្សេងគ្នាយ៉ាងណា ?

+ វិបាកក្នុងអហេតុកចិត្ត ជាចិត្តមិនមានសម្បយុត្តហេតុ វិបាកក្នុងកាមាវចរសោភណចិត្ត ជាវិបាក មានសម្បយុត្តហេតុ, វិបាកទាំង ២ នេះ មានសេចក្ដីខុសទាបជាងគ្នា ដូចដើមឈើមានឫសកែវ និងដើមឈើមិនមានឫសកែវ

២១- វិបាកចិត្តឱ្យផលផ្សេងគ្នានោះ មានអាស្រ័យអ្វីជាបុព្វហេតុ (ហេតុខាងដើម)? ចូរពន្យល់

+ អាស្រ័យចេតនា ដែលប្រកបដោយហេតុ ៦ គឺ អលោភៈ អទោសៈ អមោហៈ ឬលោភៈ ទោសៈ មោហៈ ជាបុព្វហេតុ គឺ ក្នុងខណៈធ្វើកុសលកម្មនោះ មានអលោភៈ អទោសៈ អមោហៈ ខ្លាំងឬខ្សោយ ឬមានលោភៈ ទោសៈ មោហៈ ខ្លាំងឬខ្សោយ បុព្វហេតុប៉ុណ្ណេះឯង ជាគ្រឿងចែកឱ្យមានវិបាកផ្សេង ៗគ្នា ។

២២- បុព្វហេតុ ដែលឱ្យវិបាកផ្សេង ៗគ្នានោះ មានប៉ុន្មាន? សូមលើកមកបញ្ជាក់មួយខផង

+ បុព្វហេតុ ដែលឱ្យវិបាកផ្សេង ៗគ្នា មាន ៨ យ៉ាង

ទី១ លោកពោលទុកដូច្នេះ ៖

ក្នុងខណៈដែលប្រកបកុសលកម្ម បុគ្គលណា មានលោភៈខ្លាំង ឯអលោភៈមានកម្លាំងខ្សោយ អលោភៈរបស់គេមិនអាចគ្របសង្កត់លោភៈ ដែលមានកម្លាំងខ្លាំងបាន អទោសៈ អមោហៈខ្លាំង ឯទោសៈ មោហៈមានកម្លាំងខ្សោយ អទោសៈ អមោហៈ របស់គេ អាចគ្របសង្កត់ទោសៈ និងមោហៈបាន ព្រោះដូច្នោះ បុគ្គលនោះ កាលបដិសន្ធិ ដោយកម្មនោះឱ្យផលហើយ រមែងឱ្យវិបាក ឬជាឧបនិស្ស័យឱ្យជាមនុស្ស ប្រាថ្នាច្រើន មានសេចក្តីសុខជាប្រក្រតី មិនច្រើនដោយ សេចក្តីក្រោធ និងមានបញ្ញាច្រើន ។

២៣- ក្នុងអបាយភូមិ៤ មានតទាលម្ពណកិច្ច ឬទេ ? ចូរពន្យល់

\+ ក្នុងអបាយភូមិ៤ មានតទាលម្ពណកិច្ច តែចិត្តដែលធ្វើកិច្ច នេះជាអហេតុកវិបាកចិត្តប៉ុណ្ណោះ

២៤- មហាវិបាកចិត្ត៨ កើតបានក្នុងភូមិណាខ្លះ ?

+ កើតបានក្នុងកាមភូមិ ៧ ប៉ុណ្ណោះ

២៥- អហេតុកវិបាកចិត្ត កើតបានក្នុងភូមិណាខ្លះ ?

+ កើតបានក្នុងអបាយភូមិ៤ កាមសុគតិ ៧ និងក្នុងរូបព្រហ្មភូមិ តាមសមគួរ

៦- ហេតុអ្វី បានជាមហាវិបាកចិត្ត៨ មិនធ្វើតទាលម្ពណកិច្ច តអំពីរូបាវចរកុសលចិត្ត និងអរូបាវចរកុសលចិត្ត ?

+ ព្រោះមិនមែនជាចិត្តប្រភេទតែមួយជាមួយគ្នា

**<u>អដ្ឋកថា</u>** លោកអធិប្បាយថា ៖

តទាលម្ពណកិច្ច ប្រៀបដូចទារក រមែងស្គាល់បិតាតែងជាប់តាមបិតា ឬអ្នកធ្លាប់ជិតដិតគ្នាទៅ មិនអាចតាមអ្នកដទៃដែលមិនស្គាល់ទេ ព្រោះកាមចិត្ត និងរូបាវចរចិត្ត អរូបាវចរចិត្តនោះ មិនមែនជាចិត្ត តែមួយជាមួយនឹងខ្លួន ។

២៧- ចូរចែកមហាវិបាក ៨ ដោយន័យផ្សេង ៗ មានដោយជាតិជាដើម

+ ចែកមហាវិបាក ៨ ដោយន័យផ្សេង ៗ គឺ

១. ដោយជាតិ ជាវិបាកជាតិ

២. ដោយភូមិ ជាកាមភូមិ ( សុគតិ៧ )

៣. ដោយវេទនា ជាសោមនស្ស៤ ជាឧបេក្ខា៤

៤. ដោយហេតុ ជានហេតុ និងជាសហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាញាណសម្បយុត្ត៤ ជាញាណវិប្បយុត្ត ៤

៦. ដោយសង្ខារ ជាអសង្ខារិក៤ ជាសសង្ខារិក ៤

៧. ដោយសោភណ ជាកាមាវចរសោភណចិត្ត

៨. ដោយឈាន ជាអឈានចិត្ត

៩. ដោយលោក ជាលោកិយចិត្ត

១០. ដោយកិច្ច ធ្វើកិច្ច៤ គឺ បដិសន្ធិកិច្ច១ ភវង្គកិច្ច១ តទាលម្ពណកិច្ច១ ចុតិកិច្ច១

១១. ដោយអារម្មណ៍ មានអារម្មណ៍៦

១២. ដោយទ្វារ កើតតាមទ្វារ៦ និងទ្វារវិមុត្ត

១៣. ដោយវត្ថុ កើតត្រង់ហទយវត្ថុ

១៤. ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ

២៨- អហេតុកកិរិយាចិត្ត ផ្សេងពីមហាកិរិយាចិត្តយ៉ាងណា ?

+ អហេតុកកិរិយាចិត្ត ជាកិរិយា ដែលមិនប្រកបដោយហេតុ ៦ ចំណែកមហាកិរិយាចិត្ត ជាកិរិយាចិត្ត ដែលប្រកបដោយហេតុ៣ និងហេតុ២

២៩- កិរិយា (អហេតុក. សហេតុក) ទាំង ២ ប្រភេទនោះ កើតក្នុងភូមិណាខ្លះ ?

+ អហេតុកកិរិយាចិត្ត កើតបាន ៣០ ភូមិ (វៀរអសញ្ញសត្តភូមិ) ចំណែកមហាកិរិយាចិត្ត ជាចិត្តរបស់ព្រះអរហន្តកើតបាន ២៦ភូមិ គឺ កាមសុគតិភូមិ៧ ក្នុងរូបាវចរភូមិ១៥ កើតត្រង់ហទយវត្ថុ ក្នុងអរូបាវចរភូមិ៤ កើតបានដោយមិនត្រូវមានហទយវត្ថុ (វៀរអបាយភូមិ៤ អសញ្ញសត្តភូមិ១)

៣០- ចូរចែកមហាកិរិយា ៨ ដោយន័យផ្សេង ៗ មានជាតិជាដើម

+ ចែកមហាកិរិយា ៨ ដោយន័យផ្សេង ៗ គឺ

១. ដោយជាតិ ជាកិរិយាជាតិ

២. ដោយភូមិ ជាកាមភូមិ (កើតបាន២៦ភូមិ)

| | |
|---|---|
| ៣. ដោយវេទនា | ជាសោមនស្ស៤ ជាឧបេក្ខា ៤ |
| ៤. ដោយហេតុ | ជានហេតុ និងជាសហេតុកចិត្ត |
| ៥. ដោយសម្បយុត្ត | ជាញាណសម្បយុត្ត ៤ |
| | ជាញាណវិប្បយុត្ត ៤ |
| ៦. ដោយសង្ខារ | ជាអសង្ខារិក៤ ជាសសង្ខារិក ៤ |
| ៧. ដោយសោភណៈ | ជាកាមាវចរសោភណចិត្ត |
| ៨. ដោយឈាន | ជាអឈានចិត្ត |
| ៩. ដោយលោក | ជាលោកិយចិត្ត |
| ១០. ដោយកិច្ច | ធ្វើជវនកិច្ច |
| ១១. ដោយអារម្មណ៍ | មានអារម្មណ៍ ៦ |
| ១២. ដោយទ្វារ | កើតតាមទ្វារ ៦ |
| ១៣. ដោយវត្ថុ | កើតត្រង់ហទយវត្ថុ (២២ភូមិ) |
| ១៤. ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ |

**សំនួរ-ចម្លើយក្នុងកាមាវចរសោភណចិត្ត ចប់**

# រូបាវចរសោភណចិត្ត ១៥

ពាក្យថា ***រូបាវចរសោភណចិត្តំ*** គឺ ***រូប*** + ***អវចរ*** + ***សោភណ*** + ***ចិត្តំ***

*សោភណចិត្តដែលត្រាច់ទៅក្នុងរូប បានដល់ រូបជ្ឈាន ដែលជាកុសល ហៅថា រូបាវចរកុសលចិត្ត, ដែលជាវិបាក ហៅថា រូបាវចរវិបាកចិត្ត, ដែលជាកិរិយា ហៅថា រូបាវចរកិរិយាចិត្តទាំង ៣ ប្រភេទនេះ ព្រះមានព្រះភាគទ្រង់សរសើរ, តែមានឈានមួយប្រភេទទៀត ព្រះមានព្រះភាគទ្រង់មិនសរសើរ គឺ អកុសលឈាន ។ អកុសលឈាននេះ ឃើញថា សមគួរនាំមកពោលទុកក្នុងទីនេះផង ។*

***ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ*** មានសម្តែងអំពីអកុសល ឈាននេះ ដោយសេចក្តីថា ៖

*គ្រានោះវស្សការព្រាហ្មណ៍ ជាមហាអាមាត្យក្នុងដែនមគធរដ្ឋ ក៏សួរព្រះអានន្ទមានអាយុ ដូច្នេះថា ចុះព្រះអាន*

នុនៅក្នុងទីណា ឥឡូវនេះ ។ ព្រះអានន្ទ ឆ្លើយថា ម្នាល ព្រាហ្មណ៍ ឥឡូវនេះ អាត្មាភាពនៅក្នុងវត្តវេឡុវ័ន ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះវត្តវេឡុវ័ន ជាទីគួរត្រេកអរផង មានសំឡេងតិចផង មានសេចក្តីគឹកកងតិចផង មានខ្យល់រំភើយ ៗ (ដែលផ្សាយចេញអំពីសរីរៈនៃមនុស្ស) ជាទីគួរធ្វើការសម្ងាត់របស់មនុស្ស ជាទីសមគួរនឹងពួនសម្ងំដែរឬ ។ អើ ព្រាហ្មណ៍ វត្តវេឡុវ័ន ជាទីគួរត្រេកអរផង មានសំឡេងតិចផង មានសេចក្តីគឹកកងតិចផង មានខ្យល់រំភើយ ៗ ជាទីគួរធ្វើការសម្ងាត់របស់មនុស្ស ជាទីសមគួរដល់ការពួនសម្ងំ ថែមទាំងមានបុគ្គលទាំងឡាយ ប្រហែលនឹងអ្នក ជាអ្នករក្សាគ្រប់គ្រង ដោយពិត ។

អើ ព្រះអានន្ទដ៏ចម្រើន វត្តវេឡុវ័ន ជាទីគួរត្រេកអរផង មានសំឡេងតិចផង មានសេចក្តីគឹកកងតិចផង មានខ្យល់រំភើយ ៗ ជាទីគួរធ្វើការសម្ងាត់របស់មនុស្ស ជាទី

សមគួរដល់ការពួនសម្ងំ ថែមទាំងមានលោកដ៏ចម្រើនទាំងឡាយ ជាអ្នកប្រកបដោយឈាន មានឈានជាប្រក្រតីដោយពិត ព្រោះលោកដ៏ចម្រើនទាំងឡាយ ជាអ្នកប្រកបដោយឈានផង មានឈានជាប្រក្រតីផង បពិត្រព្រះអានន្ទដ៏ចម្រើន សម័យមួយ ខ្ញុំមកក្នុងទីនេះ ព្រះគោតមដ៏ចម្រើនអង្គនោះ គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី បពិត្រព្រះអានន្ទដ៏ចម្រើន គ្រានោះឯង ខ្ញុំបានចូលទៅរកព្រះគោតមដ៏ចម្រើននោះ ក្នុងកូដាគារសាលា នាមហាវ័ន ព្រះគោតមដ៏ចម្រើននោះ ទ្រង់ពោលនូវឈានកថាជាអនេកបរិយាយ ក្នុងកូដាគារសាលានោះ ព្រះគោតមដ៏ចម្រើនអង្គនោះ ជាអ្នកប្រកបដោយឈានផង មានឈានជាប្រក្រតីផង មិនតែប៉ុណ្ណោះ ព្រះគោតមដ៏ចម្រើនអង្គនោះ ទ្រង់ក៏សរសើរនូវឈានទាំងអស់ផង ។

( ព្រះថេរៈគិតថា ឈានដែលព្រះសម្មាសម្ពុទ្ធទ្រង់

សរសើរក៏មាន ដែលទ្រង់មិនសរសើរក៏មាន តែព្រាហ្មណ៍នេះ សរសើរឈានទាំងអស់ ពោលបញ្ហាធ្វើឱ្យឃ្លៀងឃ្លាត យើងមិនអាចនឹងមើលមុខព្រាហ្មណ៍នេះបាន មិនអាចរក្សាបិណ្ឌបាត យើងនឹងពោលបញ្ហាឱ្យត្រង់ ដូច្នេះ ទើបផ្ដើមពោលពាក្យនេះថា )

ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ មិនទ្រង់សរសើរនូវឈានទាំងអស់ទេ ព្រះមានព្រះភាគអង្គនោះ មិនមែនជាមិនទ្រង់សរសើរនូវឈានទាំងអស់ឡើយ ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ មិនទ្រង់សរសើរនូវឈានមានសភាពដូចម្ដេច ។ ម្នាលព្រាហ្មណ៍ ក្នុងលោកនេះ បុគ្គលពួកខ្លះ មានចិត្តត្រូវកាមរាគៈរួបរឹតហើយ ត្រូវកាមរាគៈគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមសេចក្ដីពិត នូវធម៌ជាគ្រឿងរលាស់ចោលនូវកាមរាគៈ ដែលកើតឡើង បុគ្គលនោះធ្វើនូវកាមរាគៈឱ្យឋិតនៅក្នុងចិត្ត ហើយក៏សួតស្ងប់ ជ្រប់សញ្ជប់សញ្ជឹង ។ មានចិត្តត្រូវព្យាបាទៈរួបរឹតហើយ ត្រូវ

ព្យាបាទៈគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមសេចក្តីពិត នូវធម៌ជាគ្រឿងរលាស់បោលនូវព្យាបាទៈដែលកើតឡើង បុគ្គលនោះធ្វើនូវព្យាបាទៈឱ្យឋិតនៅក្នុងចិត្ត ហើយក៏ស្ងួតស្ងប់ ជ្រប់សញ្ជប់សញ្ជឹង ។ មានចិត្តត្រូវថីនមិទ្ធៈរួបរឹតហើយ ត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមសេចក្តីពិត នូវធម៌ជាគ្រឿងរលាស់បោលនូវថីនមិទ្ធៈ ដែលកើតឡើង បុគ្គលនោះធ្វើនូវថីនមិទ្ធៈឱ្យឋិតនៅក្នុងចិត្ត ហើយក៏ស្ងួតស្ងប់ ជ្រប់សញ្ជប់សញ្ជឹង ។ មានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈរួបរឹតហើយ ត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមសេចក្តីពិត នូវធម៌ជាគ្រឿងរលាស់បោលនូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើង បុគ្គលនោះធ្វើនូវឧទ្ធច្ចកុក្កុច្ចៈឱ្យឋិតនៅក្នុងចិត្ត ហើយក៏ស្ងួតស្ងប់ ជ្រប់ សញ្ជប់សញ្ជឹង ។ មានចិត្តត្រូវវិចិកិច្ឆារួបរឹតហើយ ត្រូវវិចិកិច្ឆាគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមសេចក្តីពិត នូវធម៌ជាគ្រឿងរលាស់បោលនូវវិចិកិច្ឆាដែលកើតឡើង បុគ្គលនោះ ធ្វើនូវវិចិកិច្ឆាឱ្យឋិតនៅក្នុងចិត្ត ហើយ

ក៏ស្ងួតស្ងប់ ជ្រប់ សញ្ជប់សញ្ជឹង ។ ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ ទ្រង់មិនសរសើរនូវឈានមានសភាពដូច្នេះទេ ។ ម្នាលព្រាហ្មណ៍ ចុះព្រះមានព្រះភាគអង្គនោះ ទ្រង់សរសើរនូវឈានមានសភាពដូចម្តេចវិញ ។ ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិ និងសុខៈ កើតអំពីសេចក្តីស្ងប់ស្ងាត់ ហើយសម្រាន្តនៅដោយឥរិយាបថទាំង ៤ (បានដល់) នូវទុតិយជ្ឈានជាធម្មជាតិកើតមានក្នុងសន្តានខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺ សទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ កើតអំពីសមាធិ គឺ បឋមជ្ឈាន ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈ បានដល់នូវតតិយជ្ឈាន ... បានដល់នូវចតុត្ថជ្ឈាន ហើយសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ ទ្រង់សរសើរនូវឈានមានសភាពដូច្នេះ

ឯង ។

បពិត្រព្រះអានន្ទដ៏ចម្រើន បានឮថា ព្រះគោតមដ៏ចម្រើនអង្គនោះ ទ្រង់តិះដៀលនូវឈានដែលគួរតិះដៀល ទ្រង់សរសើរនូវឈានដែលគួរសរសើរ, បពិត្រព្រះអានន្ទដ៏ចម្រើន ណ្ហើយចុះ នឹងសុំលាទៅ ក្នុងកាលឥឡូវនេះ ព្រោះយើងខ្ញុំមានកិច្ចច្រើន មានការងារច្រើន ។ ម្នាលព្រាហ្មណ៍ អ្នកចូរសំគាល់នូវកាលដែលគួរនឹងអញ្ជើញទៅ ឥឡូវនេះចុះ ។ គ្រានោះវស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈ ត្រេកអររីករាយនឹងភាសិតរបស់ព្រះអានន្ទមានអាយុ ហើយក៏ក្រោកចាកអាសនៈចៀសចេញទៅ ។[១]

អកុសលឈាន តាមដែលព្រះអានន្ទត្រាស់ សម្ដែងដល់ព្រាហ្មណ៍ ក៏គឺ នីវរណៈ ៥ ដែលបិទបាំងរារាំងចិត្ត មិនឱ្យសម្រេចសេចក្ដីល្អនោះឯង ។

១. មជ្ឈិ. ឧប. គោបកមោគ្គល្លានសូត្រ. ២៦. ១១៥/១៨៤ ។

ក្នុងសំយុត្តនិកាយ មហាវារវគ្គ មានព្រះតម្រាស់ដែលត្រាស់ប្រៀបធៀបនីវរណៈ ៥ ទុកដោយសង្ខេបដូច្នេះ ៖

១. កាមច្ឆន្ទៈ ដូចភាជន៍ ដាក់ទឹកដែលលាយដោយពណ៌
២. ព្យាបាទ ដូចភាជន៍ ដាក់ទឹកដែលក្តៅ
៣. ថីនមិទ្ធៈ ដូចភាជន៍ ដាក់ទឹកដែលសារាយនិងចកគ្របបិទ
៤. ឧទ្ធច្ចកុក្កុច្ចៈ ដូចភាជន៍ ដាក់ទឹកដែលខ្យល់បក់ ធ្វើឱ្យញ័ររញ្ជួយ ។
៥. វិចិកិច្ឆា ដូចភាជន៍ ដាក់ទឹកល្អក់ដោយភក់

**ចប់ អកុសលឈាន**

## សង្គហគាថា

៨. បញ្ចធា ឈានភេទេន រូបាវចរមានសំ
បុញ្ញបាកក្រិយាភេទា តំ បញ្ចទសធា ភវេ ។

រូបាវចរចិត្ត ១៥ ចែកដោយឈាន មាន ៥ គឺ កុសលចិត្ត៥ វិបាកចិត្ត៥ កិរិយាចិត្ត៥ រួមជា ១៥ ។

## រូបាវចរសោភណ ១៥ គឺ

-រូបាវចរកុសលចិត្ត ៥ -រូបាវចរវិបាកចិត្ត ៥
-រូបាវចរកិរិយាចិត្ត ៥

## រូបាវចរកុសលចិត្ត ៥ គឺ

១, វិតក្កវិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ បឋមជ្ឈានកុសលចិត្តំ : បឋមជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

២, វិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ ទុតិយជ្ឈាន

**កុសលចិត្តំ :** ទុតិយជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ៤ គឺ វិចារៈ បីតិ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**៣, បីតិសុខេកគ្គតាសហិតំ សសង្ខារិកំ តតិយជ្ឈានកុសលចិត្តំ :** តតិយជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ៣ គឺ បីតិ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**៤, សុខេកគ្គតាសហិតំ សសង្ខារិកំ ចតុត្ថជ្ឈានកុសលចិត្តំ :** ចតុត្ថជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ២ គឺ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**៥, ឧបេក្ខេកគ្គតាសហិតំ សសង្ខារិកំ បញ្ចមជ្ឈានកុសលចិត្តំ :** បញ្ចមជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា មានការបបួលដឹកនាំ

ចិត្ត ៥ នេះ ឈ្មោះថា រូបាវចរកុសលចិត្ត ។

## អធិប្បាយ រូបាវចរកុសលចិត្ត

ឥឡូវនេះ ដល់លំដាប់និទ្ទេសនៃរូបាវចរចិត្ត ដែលលោកលើកឡើង សម្តែងទុកក្នុងលំដាប់នៃកាមាវចរចិត្តនោះជា ៥ យ៉ាងដោយសេចក្តីផ្សេងគ្នានៃការប្រកបដោយអង្គឈាន ទើបពោលពាក្យថា "វិតក្ក ។បេ ។ សហិតំ" ប្រែថា បឋមជ្ឈានកុសលចិត្ត ប្រកបដោយវិតក្កៈជាដើម ។

ចិត្តប្រព្រឹត្តទៅជាមួយធម៌ទាំងនេះ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ឈ្មោះថា ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតា ។

## អង្គ ៥ នៃបឋមជ្ឈាន

<u>អដ្ឋសាលិនី</u> ពោលថា ៖

**១. វិតក្កោ** ការត្រិះរិះ

***វិតក្ក*** មានវចនត្ថៈថា ***វិតក្កេតីតិ*** = ***វិតក្កោ.*** ធម៌ដែលឈ្មោះថា វិតក្កៈ ព្រោះអត្ថថា ត្រិះរិះ(នឹក) ***វិតក្កនំ វា*** =

**វិតក្កោ** ម្យ៉ាងទៀត ការត្រិះរិះ (គឺ ការផ្តោតអារម្មណ៍) ឈ្មោះថា វិតក្កៈ ។

<u>**ក្នុងអភិធម្មត្ថវិភាវិនី**</u> ពោលថា ៖

**អារម្មណំ វិតក្កេតិ សម្បយុត្តធម្មេ អភិនិរោបេតីតិ** = **វិតក្កោ** : ធម៌ដែលឈ្មោះថា វិតក្កៈ ព្រោះអត្ថថា ត្រិះរិះ គឺ លើកសម្បយុត្តធម៌ឡើងកាន់អារម្មណ៍

ប្រៀបដូចអ្នកខ្លះ អាស្រ័យរាជវល្លភៈ ឬ មិត្រអ្នកមានការជាប់ទាក់ទងនឹងព្រះរាជា រមែងចូលទៅកាន់ព្រះរាជវាំងបានយ៉ាងណា ចិត្តអាស្រ័យវិតក្កៈ ក៏ឡើងកាន់អារម្មណ៍បាន យ៉ាងនោះដូចគ្នា ។

សួរថា បើយ៉ាងនោះ ឈានចិត្តដែលមិនមានវិតក្កៈ នឹងឡើងកាន់អារម្មណ៍មិនបានឬ ?

ឆ្លើយថា សូម្បីឈានចិត្តដែលមិនមានវិតក្កៈ ក៏ឡើងកាន់អារម្មណ៍បាន ដោយកម្លាំងនៃវិតក្កៈនុ៎ះឯង ប្រៀបដូច

បុរស ( ដែលធ្លាប់ចូល ) នោះ សូម្បីវៀរាជវល្លភៈ ឬមិត្រនោះ ជាអ្នកមិនមានសេចក្ដីសង្ស័យ រមែងចូលទៅកាន់ព្រះរាជវាំងបាន ព្រោះសេចក្ដីជិតជិត យ៉ាងណា ឈានចិត្តដែលមិនមានវិតក្កៈ ក៏ឡើងកាន់អារម្មណ៍បានយ៉ាងនោះ ។

ដែលឈ្មោះថា សេចក្ដីជិតជិតក្នុងទីនេះ បានដល់ ការអប់រំចិត្តឱ្យកើតឡើង ដោយអំណាចនៃការប្រព្រឹត្តិទៅរឿយ ៗ ក្នុងសន្តាននៃចិត្តដែលមានវិតក្កៈ ។ ម្យ៉ាងទៀត ចិត្តដែលមិនមានវិតក្កៈទាំងនេះ បញ្ចវិញ្ញាណ សូម្បីមិនមានវិតក្កៈ ក៏ឡើងកាន់អារម្មណ៍បាន ដោយកម្លាំងនៃវត្ថុ និងអារម្មណ៍ប៉ះខ្ទប់គ្នា និងឈាន មានទុតិយជ្ឈានជាដើម រមែងឡើងកាន់អារម្មណ៍បាន ដោយកម្លាំងនៃការចម្រើនឈានជាន់ទាប ។

វិតក្កៈក្នុងអង្គឈាននេះ ប្រហារថីនមិទ្ធនីវរណៈ ( ដោយវិក្ខម្ភនប្បហាន )

## លក្ខណាទិចតុក្កៈរបស់វិតក្កៈនៃអង្គឈាន

១- **អារម្មណេ ចិត្តស្ស អភិនិរោបនលក្ខណោ** មានការលើកចិត្តឡើងកាន់អារម្មណ៍ ជាលក្ខណៈ

២- **អាហននបរិយាហននរសោ** មានការផ្គោត និងផ្គោតដោយជុំវិញ ( អារម្មណ៍ ) ជាកិច្ច

៣- **អារម្មណេ ចិត្តស្ស អានយនបច្ចុប្បដ្ឋានោ** មានការនាំចិត្តមកក្នុងអារម្មណ៍ ជាបច្ចុប្បដ្ឋាន

៤- **អាបាថវិសយបទដ្ឋានោ** មានអារម្មណ៍ក្នុងវិថី ជាហេតុជិត ។

**២. វិចារោ** ការពិចារណា

**វិចារ** មានវចនត្ថៈថា **អារម្មណេ តេន ចិត្តំ វិចរតីតិ = វិចារោ** ធម៌ដែលឈ្មោះថា វិចារៈ ព្រោះអត្ថថា ជាហេតុពិចារណាអារម្មណ៍នៃចិត្ត ។

វិចារៈនោះ មានលក្ខណៈ ពិចារណារិះគិតអារម្មណ៍ពិតមែន វិចារៈនេះ លោកអធិប្បាយថា ជាការបន្ត

(**អនុសន្ធានតា**) បណ្ដាធម៌ទាំងពីរនេះ វិតក្កៈ ជាការធ្លាក់ចុះគ្រាដំបូងនៃចិត្ត ប្រៀបដូចការគោះរគាំងដំបូង ដោយអត្ថថាគ្រោតគ្រាតជាងវិចារៈ និងដោយអត្ថថា ជាធម៌ទៅមុនវិចារៈនោះឯង ចំណែកវិចារៈជាការរិះរក ប្រៀបដូចសំឡេងខ្ទ័រនៃរគាំងនោះ ។

ម្យ៉ាងទៀត វិតក្កៈជាការផ្សាយទៅ គឺ ជាការកម្រើកចេញនៃចិត្ត ប្រៀបដូចការទទះស្លាបនៃសត្វបក្សីដែលត្រូវហើរឡើងទៅក្នុងអាកាស និងប្រៀបដូចការបែរមុខឆ្ពោះទៅកាន់ផ្កាបទុមនៃសត្វភមរ ដែលមានចិត្តជាប់ជំពាក់ក្លិន ចំណែកវិចារៈ មានការប្រព្រឹត្តិទៅស្ងប់ មានការមិនកម្រើកចេញច្រើនហួសនៃចិត្ត ប្រៀបដូចការត្រដាងស្លាបនៃសត្វបក្សីដែលហើរឡើងទៅកាន់អាកាស និងប្រៀបដូចការហើរវិលជុំវិញខាងលើផ្កាបទុមរបស់ភមរ(កន្លង់ ឃ្មុំ ...) បែរមុខឆ្ពោះទៅរក ផ្កាបទុម ដូច្នោះ វិចារៈ ក្នុងអដ្ឋកថានេះប្រហារវិចិកិច្ឆានីវរណៈ ។

## លក្ខណាទិចតុក្កៈរបស់វិចារៈនៃអង្គឈាន

១- **អារម្មណានុមជ្ជនលក្ខណោ** មានការស្ទាបអង្អែល (ពិចារណា) អារម្មណ៍ ជាលក្ខណៈ

២- **តត្ថ សហជាតានុយោជនរសោ** មានការតាមប្រកប សហជាតធម៌ក្នុងអារម្មណ៍នោះ ជាកិច្ច

៣- **ចិត្តស្ស អនុប្បពន្ធនបច្ចុប្បដ្ឋានោ** មានការតាមចងចិត្តទុកក្នុងអារម្មណ៍ ជាបច្ចុប្បដ្ឋាន

៤- **អារម្មណបទដ្ឋានោ** មានអារម្មណ៍ ជាហេតុជិត ។

### ៣. **បីតិ** ការឆ្អែត (កាយនិងចិត្ត)

**បីតិ** មានវចនត្ថៈថា **បិនយតិ កាយចិត្តំ តប្បេតិ វឌ្ឍេតីតិ វា = បីតិ** ធម្មជាតិ ដែលឈ្មោះថា បីតិ ព្រោះអត្ថថា ញ៉ាំងកាយនិងចិត្តឱ្យឆ្អែត ឱ្យពោរពេញ ឬថា ញ៉ាំងកាយនិងចិត្តឱ្យចម្រើន ។

ពិតមែន បីតិនោះ មានការឆ្អែតជាលក្ខណៈ បានដល់ មានការទទួលអារម្មណ៍ដោយសមគួរ (ដល់កាយនិងចិត្ត) ជាលក្ខណៈ គឺ ធ្វើកាយនិងចិត្តឱ្យរីករាយ ។

**បីតិ ៥ យ៉ាង**

១, **ខុទ្ទកាបីតិ** សេចក្ដីត្រេកអរតិច ត្រឹមព្រឺរោម ព្រឺស្បែក

២, **ខណិកាបីតិ** សេចក្ដីត្រេកអរមួយខណៈ ៗ ប្រាកដដូចជាផ្លេកបន្ទោរ

៣, **ឱក្កន្តកាបីតិ** សេចក្ដីត្រេកអររឿយ ៗ មានអាការប្រាកដ ដូចជាទឹករលកបោកខ្ទប់មកត្រូវ

៤, **ឧព្វេង្គាបីតិ** សេចក្ដីត្រេកអរខ្លាំង អាចញ៉ាំងកាយឱ្យអណ្តែតឡើង

៥, **ផរណាបីតិ** សេចក្ដីត្រេកអរធ្វើឱ្យផ្សព្វផ្សាយជ្រួតជ្រាបទូទៅក្នុងកាយ ។

# អធិប្បាយ

ខុទ្ទកាបីតិកើតឡើងហើយ អាចធ្វើត្រឹមតែរោមក្នុងរាងកាយឱ្យបះឡើងប៉ុណ្ណោះ ។ ខណិកាបីតិកើតឡើង រមែងដូចជាផ្លេកបន្ទោរ ក្នុងមួយខណៈៗ ។ ឱក្កន្តិកាបីតិកើតឡើងឈានចុះកាន់កាយហើយក៏រីករាយ រហូតដល់កាយកម្រើកហើយក៏រលត់ទៅ ដូចទឹករលកត្រង់ច្រាំងសមុទ្រ ។ ឧព្វេង្គាបីតិ ជាបីតិដែលមានកម្លាំង អាចធ្វើកាយឱ្យអណ្តែតឱ្យហោះឡើងទៅក្នុងអាកាសបាន ។ ពិតមែន ព្រះមហាតិស្សត្ថេរអ្នកនៅក្នុងបុណ្ណវល្លិកវិហារ ក្នុងថ្ងៃបុណ្ណមី( ព្រះចន្ទពេញវង់ ) ក្នុងវេលាល្ងាចលោកទៅកាន់លានព្រះចេតិយ ឃើញពន្លឺនៃព្រះចន្ទ ទើបបែរមុខទៅចំព្រះមហាចេតិយ ហើយរំពឹងថា "ថ្ងៃនេះ ពួកបរិស័ទទាំង ៤ កំពុងថ្វាយបង្គំព្រះមហាចេតិយហ្ន៎" ដូច្នេះ ញុំាងឧព្វេង្គាបីតិ មានព្រះពុទ្ធជាអារម្មណ៍ ឱ្យកើតឡើងហើយ ដោយអំណាចដែលបានឃើញតាមប្រក្រតី

អណ្តែតឡើងទៅកាន់អាកាសហើយ ឈរនៅក្នុងទីលានព្រះមហាចេតិយនោះឯង ។

( ក្នុងអដ្ឋសាលិនី បានពោលដល់រឿងកុលធីតាក្នុងស្រុកឈ្មោះវត្តកាលកៈ មានទំនងដូចគ្នានេះឯង ) ។

ចំណែកផរណាបីតិ កើតឡើងផ្សាយទៅកាន់សរីរៈទាំងអស់ ដូចស្បោងដែលពេញដោយខ្យល់ និងដូចប្រឡាយដែលទឹកជន់ជំហូរទៅពេញហើយ បីតីដែលជាអប្បនាឈាន ក៏គឺផរណាបីតិ, បីតិនេះអាចប្រហារព្យាបាទនីវរណៈបានដោយវិក្ខម្ភនប្បហានៈ ចំណែកបីតិ ៤ យ៉ាង ដែលនៅសល់ មិនរាប់ថា ជាអប្បនាឈាន ព្រោះមានកម្លាំងតិច ។

## លក្ខណាទិចតុក្កៈរបស់បីតិនៃអប្បនាឈាន

**១- សម្បិយាយនលក្ខណា** មានការឆ្អែត ជាលក្ខណៈ

**២- កាយចិត្តបីននរសា** មានការធ្វើកាយនិងចិត្តឱ្យឆ្អែតជាកិច្ច,

**ផរណរសោ វា** ឬ មានសេចក្តីផ្សាយទៅ ជាកិច្ច
៣- **ឱទគ្យបច្ចុប្បដ្ឋានា** មានការរីកសាយចិត្ត ជាបច្ចុប្បដ្ឋាន
៤- **បស្សទ្ធិបទដ្ឋានា** មានការស្ងប់កាយនិងចិត្ត ជាហេតុជិត ។

៤. **សុខៈ** ( សោមនស្សវេទនា )

សុខ មានវចនត្ថៈថា **សម្បយុត្តធម្មេ សុខយតីតិ = សុខំ** ធម្មជាត ដែលឈ្មោះថា សុខៈ ព្រោះអត្ថថា ញ៉ាំងសម្បយុត្តធម៌ឱ្យសប្បាយ ។ ម្យ៉ាងទៀត ធម្មជាតិណា រមែងសេពសោយសប្បាយ និងរមែងជីក( ទម្លាយ )រោគតាមផ្លូវចិត្ត ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សុខ ។

ពាក្យថា "សុខ" នេះជាឈ្មោះរបស់សោមនស្សវេទនា គប្បីឃើញអត្ថ ៤ មានលក្ខណៈជាដើមរបស់សុខនោះ ដោយន័យដែលពោលទុកក្នុងសោមនស្សវេទនាថា សោមនស្សមានការសោយអារម្មណ៍ដែលល្អ ជាលក្ខណៈ ។ សុខ គឺ

សោមនស្សវេទនា ក្នុងអដ្ឋឈាននេះ ប្រហារឧទ្ធច្ចកុក្កុច្ចនីវរណៈ ។ ម្យ៉ាងទៀត បីតិនិងសុខនេះ មានសភាពស្រដៀងគ្នាច្រើន គប្បីកំណត់ដឹងសេចក្ដីផ្សេងគ្នាយ៉ាងនេះ គឺ ៖

**បីតិ** បានដល់ សេចក្ដីត្រេកអរ ក្នុងឥដ្ឋារម្មណ៍

**សុខៈ** បានដល់ ការសោយរសនៃឥដ្ឋារម្មណ៍ដែលបានហើយ

**បីតិ** មានក្នុងទីណា សុខក៏មានក្នុងទីនោះ

**សុខៈ** មានក្នុងទីណា ក្នុងទីនោះ មិនមែនសុទ្ធតែមានបីតិទេ

**បីតិ** សង្គ្រោះចូលក្នុងសង្ខារក្ខន្ធ

**សុខៈ** សង្គ្រោះចូលក្នុងវេទនាខន្ធ

## ឧបមាបីតិ និង សុខ

បីតិ ប្រៀបដូចក្នុងករណីដែលបុគ្គលនឿយហត់ក្នុងផ្លូវកន្ដារៈ បានឃើញ បានឮសំឡេងទឹកហូរក្នុងព្រៃ (នៅមិនទាន់បានផឹកជាដើម) ក៏កើតបីតិសប្បាយខ្លាំងក្នុងចិត្តថា យើងនឹងបានផឹក បានងូតទឹក ជម្រះរាងកាយឱ្យសប្បាយ

ចំណែកសុខនោះ ប្រៀបដូចបុគ្គលចូលទៅកាន់ម្លប់ក្នុងព្រៃបាន ផឹកនិងប្រើប្រាស់ទឹកតាមសប្បាយ ។

## លក្ខណាទិចតុក្កៈរបស់សុខនៃអង្គឈាន

**១. សាតលក្ខណំ** មានសេចក្តីសប្បាយ ជាលក្ខណៈ

**២. សម្បយុត្តកានំ ឧបព្រូហនរសំ** មានការចូលទៅចម្រើននូវសម្បយុត្តធម៌ ជាកិច្ច

**៣. អនុគ្គហបច្ចុប្បដ្ឋានំ** មានសេចក្តីអនុគ្រោះ ជាគ្រឿងប្រាកដ

**៤. សេសខន្ធត្តយបទដ្ឋានំ** មាននាមខន្ធ ៣ ដែលនៅសល់ជាហេតុជិត ។

**៥. ឯកគ្គតា** ឯកគ្គតានៃចិត្ត

ឯកគ្គតា មានវចនត្ថៈថា **នានាលម្ពណវិក្ខេបាភាវេន ឯកំ អារម្មណំ អគ្គំ ឥមស្សាតិ = ឯកគ្គំ ចិត្តំ** : ចិត្តដែលឈ្មោះថា ឯកគ្គៈ ដោយអត្ថថា មានអារម្មណ៍តែមួយ ព្រោះមិនមានសេចក្តីរវើរវាយទៅក្នុងអារម្មណ៍ផ្សេង ៗ ។ **តស្ស**

**ភាវោ = ឯកគ្គតា សមាធិ :** ភាវៈនៃចិត្ត មានអារម្មណ៍តែមួយនោះ ឈ្មោះថា ឯកគ្គតា គឺ សមាធិ ។

សមាធិឈ្មោះថា មានសេចក្តីមិនរវើរវាយ ជាលក្ខណៈ ព្រោះមិនឱ្យសហជាតធម៌ទាំងឡាយ រវើរវាយ ខ្ចាត់ខ្ចាយ ។ ដូចព្រះរាជាស្តេចទ័ព ស្តេចចូលទៅកាន់ទីទាហានចម្បាំង ទាហានទាំងនោះ រមែងប្រជុំគ្នាកកកុញ ក្នុងទីដែលស្តេចទៅនោះ ៗ ទាហានរមែងព្រមព្រៀងទម្លាយពួកសត្រូវ និងរមែងធ្វើតាមព្រះរាជា ។

ន័យមួយទៀត ឈ្មោះថា សមាធិ គឺ ឯកគ្គតានៃចិត្តនេះ មានការមិនខ្ចាត់ខ្ចាយទៅ ជាលក្ខណៈ ឬ មានការមិនអណ្តែតអណ្តូង ជាលក្ខណៈ ។ មានការប្រមូលមកនូវសហធម៌ទាំងឡាយចូលគ្នា ជារស ( កិច្ច ) ដូចទឹកធ្វើកម្មេចល្អិត ៗ ឱ្យជាប់គ្នាជាដុំ ៗ មានការចូលទៅស្ងប់ជាបច្ចុប្បដ្ឋាន ឬមានញាណ ជាបច្ចុប្បដ្ឋាន គឺ មានចិត្តតាំង

មាំហើយ រមែងជ្រាបច្បាស់ រមែងឃើញសភាពពិត ពោល ដោយពិសេសហើយ សមាធិមានសុខជាបទដ្ឋាន បណ្ឌិតគប្បី ជ្រាបការតាំងនៅនៃចិត្ត ដូចអណ្តាតប្រទីបដែលប្រាសចាក ខ្យល់ ដូច្នោះ ។

## សមាធិ មាន ៣ យ៉ាង គឺ

១. ខណិកសមាធិ បានដល់ ចិត្តតាំងមាំក្នុងអារម្មណ៍ បានមួយខណៈ ៗ

២. ឧបចារសមាធិ បានដល់ ចិត្តតាំងមាំនៅក្នុង អារម្មណ៍ជិតឈានចិត្ត

៣. អប្បនាសមាធិ បានដល់ ចិត្តតាំងមាំស៊ប់នៅ ក្នុងអារម្មណ៍ដែលកំណត់ទុក កិលេសមិនអាចរុកកួនបាន ឈានចិត្តនោះ រមែងកើតឡើង ដោយអប្បនាសមាធិនេះ ។

## លក្ខណាទិចតុក្កៈរបស់ឯកគ្គតានៃអង្គឈាន

**១, អវិក្ខេបលក្ខណា** មានការមិនរវើរវាយ ជាលក្ខណៈ

**២, សហជាតានំ សម្បិណ្ឌនរសា** មានការប្រមូលសហជាតធម៌មក ជាកិច្ច

**៣, ឧបសមបច្ចុប្បដ្ឋានា** មានការចូលទៅស្ងប់ ជាផល

**៤, សុខបទដ្ឋានា** មានសុខវេទនា ជាហេតុជិត ។

## ប្រភេទនៃឈានចិត្ត

ន័យនៃអភិធម្មចែកឈានទុក៥ ហៅថា បញ្ចកន័យ[១] គឺ

១-បឋមជ្ឈាន មានអង្គ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា

២-ទុតិយជ្ឈាន មានអង្គ ៤ គឺ វិចារៈ បីតិ សុខៈ ឯកគ្គតា

---

១. មនុស្សបុគ្គលដែលមានបញ្ញាត្រាស់ដឹងយឺត មិនអាចពិចារណាឃើញទោសរបស់វិតក្កៈនិងវិចារៈ ទាំង២ នេះក្នុងខណៈតែមួយបាន ។ ឈានទី ៥ ដែលលះសុខជាឧបេក្ខានោះ សូម្បីឧបេក្ខា ក៏គឺ សុខនោះឯង ព្រោះប្រព្រឹត្តទៅសប្បាយ ។

៣-តតិយជ្ឈាន មានអង្គ ៣ គឺ បីតិ សុខៈ ឯកគ្គតា

៤-ចតុត្ថជ្ឈាន មានអង្គ ២ គឺ សុខៈ ឯកគ្គតា

៥-បញ្ចមជ្ឈាន មានអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា

## អធិប្បាយពាក្យ បឋមជ្ឈាន

ឈ្មោះថា ឈាន ព្រោះចូលទៅសម្លឹងអារម្មណ៍ និង ព្រោះដុតធម៌ដែលជាសត្រូវ ដែលឈ្មោះថា បឋម (ទី ១) ព្រោះជាខាងដើម ដោយលំដាប់នៃទេសនា និងលំដាប់នៃការកើតឡើង ព្រោះហេតុនោះ ទើបឈ្មោះថា **បឋមជ្ឈាន** បាន ដល់ ការប្រជុំនៃអង្គឈាន៥ មានវិតក្កៈ និងវិចារៈជាដើម ។

ពិតណាស់ កាលប្រជុំអង្គ ៥ ទើបហៅថា ឈាន ដូចការប្រជុំនៃចំណែកមានកង់រថជាដើម ទើបហៅថា រថ ។

<u>**ក្នុងវិភង្គបករណ៍**</u> ទ្រង់ត្រាស់ទុកថា "ត្រង់ពាក្យថា ឈាន គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតានៃចិត្ត"[១] ។

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៤០២/២៧៦ ។

## បឋមជ្ឈានកុសលចិត្ត

កុសលចិត្តសម្បយុត្តដោយបឋមជ្ឈាន ឈ្មោះថា បឋមជ្ឈានកុសលចិត្ត ។

សួរថា សម្បយុត្តធម៌ពួកដទៃ ដូចជាផស្សៈជាដើម មានចុះហេតុអ្វី ទើបត្រាស់ធម៌ ៥ នេះប៉ុណ្ណោះថា ជាអង្គឈាន ?

ឆ្លើយថា ព្រោះធម៌ទាំង ៥ នេះ មានកិច្ច (គឺនាទី) សម្លឹងអារម្មណ៍ និងជាបដិបក្ខដោយត្រង់ចំពោះកាមឆន្ទនីវរណៈជាដើម ពិតណាស់ វិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតានេះ សុទ្ធតែធ្វើនាទីសម្លឹងអារម្មណ៍ មានបឋវីកសិណជាដើម ។ ដែលថា ជាបដិបក្ខចំពោះកាមឆន្ទៈជាដើមនោះ គឺ

១. សមាធិ ជាបដិបក្ខចំពោះកាមឆន្ទៈ
២. បីតិ ជាបដិបក្ខចំពោះព្យាបាទៈ
៣. វិតក្កៈ ជាបដិបក្ខចំពោះថីនមិទ្ធៈ

៤. សុខៈ ជាបដិបក្ខចំពោះឧទ្ធច្ចកុក្កុច្ចៈ

៥. វិចារៈ ជាបដិបក្ខចំពោះវិចិកិច្ឆា

ដូចពាក្យដែលព្រះបូរាណាចារ្យទាំងឡាយ ពោលទុកថា ៖

**ឧបនិជ្ឈានកិច្ចត្តា កាមាទិបដិបក្ខតោ**

**សន្តេសុបិ ច អញ្ញេសុ បញ្ចេវជ្ឈានសញ្ញិតា ។**

សូម្បីកាលធម៌ដទៃ ដូចជាផស្សៈជាដើមមាន តែធម៌ ៥ ប៉ុណ្ណោះ លោកហៅថា ឈាន ព្រោះមានកិច្ច គឺ ការសម្លឹងអារម្មណ៍ និង ព្រោះជាបដិបក្ខ ចំពោះ នីវរណៈ មានកាមច្ឆន្ទនីវរណៈជាដើម ។

<u>ក្នុងសារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ មហាវារវគ្គ</u> ពោលការលះបង់នីវរណៈទាំង ៥ នេះ ទុកថា ៖

១. កាមច្ឆន្ទៈ លះបង់ចេញដោយធម៌ ៣ គឺ

១. ដោយតទង្គនិស្សរណៈ ( គឺ វិបស្សនា )

២. ដោយវិក្ខម្ភននិស្សរណៈ ( គឺ អសុភឈាន )

៣. ដោយសមុច្ឆេទនិស្សរណៈ ( គឺ អរហត្តមគ្គ )

២. ព្យាបាទ លះបង់ចេញដោយធម៌ ២ គឺ

១. ដោយវិក្ខម្ភននិស្សរណៈ ( គឺ មេត្តាឈាន )

២. ដោយសមុច្ឆេទនិស្សរណៈ ( គឺ អនាគាមិមគ្គ )

៣. ថីនមិទ្ធៈ លះបង់ចេញដោយធម៌ ២ គឺ

១. ដោយវិក្ខម្ភននិស្សរណៈ ( គឺ អលោកសញ្ញា )

២. ដោយសមុច្ឆេទនិស្សរណៈ ( គឺ អរហត្តមគ្គ )

៤. ឧទ្ធច្ចកុក្កុច្ចៈ លះបង់ចេញដោយវិក្ខម្ភននិស្សរណៈ ដោយសមថកម្មដ្ឋានយ៉ាងណាមួយ ។

កុក្កុច្ចៈ លះបង់ចេញដោយសមុច្ឆេទនិស្សរណៈ គឺ ដោយអនាគាមិមគ្គ,

ឧទ្ធច្ចៈ លះបង់ចេញដោយសមុច្ឆេទនិស្សរណៈ គឺ ដោយអរហត្តមគ្គ ។

៥. វិចិកិច្ឆា លះបង់ចេញដោយធម៌ ២ គឺ

១. ដោយវិក្ខម្ភននិស្សរណៈ គឺ ឈានយ៉ាងណាមួយ
២. ដោយសមុច្ឆេទនិស្សរណៈ គឺ បឋមមគ្គ ។

## សង្ខារប្បភេទរបស់អប្បនាឈាន

ក្នុងកុសលឈាន គឺ រូបាវចរកុសលនេះ លោកមិនកាន់សេចក្តីផ្សេងគ្នានៃឈាន ដោយអសង្ខារិក និងសសង្ខារិកដូចក្នុងកាមាវចរកុសល ។

**ក្នុងអភិធម្មត្ថវិភាវិនីបាលី** ពោលទុកថា ៖

សួរថា ក្នុងរូបាវចរកុសលនេះ ហេតុអ្វី ទើបលោកមិនកាន់យកសេចក្តីផ្សេងគ្នានៃសង្ខារ ដូចក្នុងកាមាវចរកុសលដោយថា សូម្បីរូបាវចរកុសលនេះ ដែលព្រះយោគាវចរសម្រេចហើយ ដោយប្រាថ្នាការប្រកបក្នុងសមថៈតែម្យ៉ាង ក៏អាចហៅថា សសង្ខារិក និងដែលបានដោយអំណាចការសម្រេចមគ្គ ក៏អាចហៅថា អសង្ខារិក មិនមែនឬ ?

ឆ្លើយថា រូបាវចរកុសលនេះ មិនអាចហៅយ៉ាងនោះបាន

ទេ ព្រោះឈាន សូម្បីដែលបានដោយកម្លាំងមគ្គ ដោយអំណាចការសម្រេចមគ្គ កើតឡើងដោយអំណាចបរិកម្មតែម្យ៉ាង ក្នុងកាលតមក ព្រោះដូច្នោះ ទើបមិនអាចហៅថាអសង្ខារិក ព្រោះឈានទាំងអស់ វៀរចាកការតាក់តែងពីខាងដើម ពោលគឺ បរិកម្ម រមែងកើតឡើងដោយអំណាចការតាំងចិត្ត ខាងដើម ( អធិការ ) តែម្យ៉ាងមិនបាន. និងមិនហៅថាសសង្ខារិក ព្រោះវៀរចាកការតាំងចិត្តខាងដើមហើយ កើតឡើងដោយអំណាចតាក់តែង គឺ បរិកម្មតែម្យ៉ាងប៉ុណ្ណោះ ក៏មិនបាន ។

ម្យ៉ាងទៀត ឆ្លើយថា ដែលលោកមិនហៅថា អសង្ខារិក ព្រោះឈានកើតឡើង ដោយអំណាចការតាក់តែងពីខាងដើម ( គឺ បរិកម្ម ) ប៉ុណ្ណោះ មិនសម្រេចជាអសង្ខារិក ក្នុងកាលណា ៗ និងមិនហៅថា សសង្ខារិក ព្រោះមិនមានការប្រព្រឹត្តិទៅដោយអាការផ្សេង ៗ ។

អាចារ្យខាងក្រោយសង្គ្រោះជាសសង្ខារិក ។

## ឈាន ២ យ៉ាង គឺ

១. អារម្មណូបនិជ្ឈាន បានដល់ សមាបត្តិ ៨

២. លក្ខណូបនិជ្ឈាន បានដល់ វិបស្សនាមគ្គនិងផល

បណ្តាឈានទាំង២នោះ សមាបត្តិ៨ ព្រះយោគាវចរ រមែងសម្លឹងអារម្មណ៍ដែលជាកសិណ មានបឋវីកសិណជាដើម ព្រោះហេតុនោះ ឈាននោះ ទើបហៅថា អារម្មណូបនិជ្ឈាន ។

ចំណែកវិបស្សនា ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះការសម្លឹងពិនិត្យលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។ មគ្គចិត្ត ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះកិលេសដែលវិបស្សនាកំចាត់ហើយ រមែងសម្រេចដោយមគ្គ, ចំណែកផលចិត្ត ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះសម្លឹងលក្ខណៈដែលជាសច្ចៈ គឺ និរោធសច្ចៈ ។

ឈានក្នុងទីនេះ លោកប្រាថ្នាយកអារម្មណូបនិជ្ឈាន ព្រោះហេតុនោះ ឈាននោះ គប្បីជ្រាបថា ឈ្មោះថា ឈាន

ព្រោះចូលទៅសម្លឹងអារម្មណ៍ ឬចូលទៅដុតបំផ្លាញបដិបក្ខធម៌ (ធម៌ដែលជាសត្រូវគ្នា)

ម្យ៉ាងទៀត អារម្មណ៍ដែលគួរចូលទៅសម្លឹង ដើម្បីធ្វើចិត្តឱ្យស្ងប់ចាកនីវរណៈ ៥ ហៅថា សមថកម្មដ្ឋាន មាន ៤០ យ៉ាង ។

## សមថកម្មដ្ឋាន ៤០ យ៉ាង

កសិណ១០ អសុភៈ១០ អនុស្សតិ១០ ព្រហ្មវិហារធម៌៤ អរូបជ្ឈាន៤ អាហារេបដិកូលសញ្ញា១ ចតុធាតុវវត្ថាន ១ ។ ក្នុងអារម្មណ៍កម្មដ្ឋាន៤០ នេះ អារម្មណ៍ដែលនឹងធ្វើឱ្យសម្រេចដល់អប្បនាសមាធិបាន មានត្រឹមតែ៣០ យ៉ាងប៉ុណ្ណោះ ។ ព្រោះដូច្នោះ ដោយពិស្តារ គប្បីជ្រាបសមថកម្មដ្ឋាន៤០ យ៉ាង ដែលពោលអធិប្បាយទុកក្នុងវិសុទ្ធិមគ្គ បឋមភាគ ដោយអាការ ១០ យ៉ាង គឺ

១. **ដោយសម្តែងចំនួន** បានដល់ សមថកម្មដ្ឋាន ៤០ គឺ

កសិណ ១០ អសុភៈ ១០ អនុស្សតិ ១០ ព្រហ្មវិហារ

ធម៌ ៤ អរូបជ្ឈាន ៤ អាហារេបដិកូលសញ្ញា ១ ចតុធាតុវវត្ថាន ១

២. **ដោយនាំមកនូវឧបចារ និងអប្បនា** គឺ ក្នុងកម្មដ្ឋាន ៤០ នោះ អនុស្សតិ ៨ (វៀរកាយគតាសតិ និងអានាបានស្សតិ) អាហារេបដិកូលសញ្ញា ១ ចតុធាតុវវត្ថាន ១ រួមជា ១០ នេះ ជាកម្មដ្ឋាននាំមកបានត្រឹមឧបចារឈាន (ឧបចារសមាធិ) ក្រៅពីនេះ នាំមកដល់អប្បនាឈាន (អប្បនាសមាធិ)

៣. **ដោយប្រភេទនៃឈាន** បានដល់ ដោយឧបចារឈាន និងអប្បនាឈាន ក្នុង ២ យ៉ាងនេះ កសិណ ១០ អានាបានស្សតិ ១ (ឈានដោយចតុក្កន័យ) ចម្រើនបានដល់ឈានទី ៤ ។ អសុភៈ ១០ កាយគតាសតិ ១ (ចតុក្កន័យ) ចម្រើនបានត្រឹមបឋមជ្ឈាន ។

ព្រហ្មវិហារ ៣ ខាងដើម ចម្រើនបានដល់ឈានទី ៣ (ចតុក្កន័យ) ព្រហ្មវិហារទី ៤ និងអរូបជ្ឈាន ៤

ប្រព្រឹត្តទៅក្នុងឈានទី ៤ ។

៤. **ដោយការឈានកន្លង** បានដល់ ការឈានកន្លង២ យ៉ាង គឺ ឈានកន្លងអង្គឈាន និងឈានកន្លងអារម្មណ៍ ។ ការឈានកន្លងអង្គឈាន ដូចទុតិយជ្ឈាន (ចតុក្កន័យ) ឈានកន្លងវិតក្កៈ វិចារៈជាដើម ក្នុងព្រហ្មវិហារ ៤ ក៏ដូច្នោះ ព្រោះសូម្បីព្រហ្មវិហារទី ៤ នោះ ក៏គប្បីឈានកន្លងសោមនស្ស ។ ចំណែកការឈានកន្លងអារម្មណ៍ រមែងមានក្នុងអរូបជ្ឈាន ៤ គឺ អាកាសានញ្ចាយតនៈ ឈានកន្លងអារម្មណ៍ក្នុងកសិណ ៩ ខាងដើមហើយ ទើបសម្រេចបាន, អរូបជ្ឈានខាងលើ ក៏ឈានកន្លងអារម្មណ៍ខាងក្រោម ប្រព្រឹត្តទៅដោយលំដាប់ ។

៥. **ដោយគួរពង្រីក ឬមិនគួរពង្រីក** គឺ កសិណ១០ គួរពង្រីក (និមិត្ត), អានាបានស្សតិ១ កាយគតាសតិ១ អសុភ១០ ព្រហ្មវិហារ៤ អរូបជ្ឈាន៤ មិនគួរពង្រីក ព្រោះមិនកើតប្រយោជន៍ ។

៦. **ដោយអារម្មណ៍** ក្នុងបណ្តាកម្មដ្ឋានទាំង ៤០ នេះ កម្មដ្ឋាន ២២ គឺ កសិណ១០ អសុភ១០ អានាបានស្សតិ១ កាយគតាសតិ១ មានអារម្មណ៍ ជាបដិភាគនិមិត្ត កម្មដ្ឋានដែលនៅសល់១៨ មិនមានអារម្មណ៍ ជាបដិភាគនិមិត្ត ។

៧. **ដោយភូមិ** បានដល់ កម្មដ្ឋាន ១២ គឺ អសុភ១០ កាយគតាសតិ១ អាហារេ បដិកូលសញ្ញា១ រមែងមិនប្រព្រឹត្តទៅក្នុងពួកទេវតា ។ កម្មដ្ឋាន១៣ មិនប្រព្រឹត្តទៅក្នុងព្រហ្មលោក គឺ កម្មដ្ឋាន១២ ខាងដើមនោះ និងអានាបានស្សតិ១ ។ ក្នុងអរូបភព មានតែអរូបកម្មដ្ឋាន៤ ប៉ុណ្ណោះ ។ ក្នុងពួកមនុស្ស រមែងចម្រើនកម្មដ្ឋានបានទាំងអស់ ។

៨. **ដោយការកាន់យក** បានដល់ ការកាន់យកដោយភ្នែកមើល ដោយការប៉ះខ្ទប់ និងដោយការស្តាប់ ក្នុងការកាន់យក ៣ យ៉ាងនោះ កម្មដ្ឋាន ១៩ គឺ កសិណ៩ ( វៀរ

វាយោកសិណ) និងអសុភ:១០ គឺ កាន់យកដោយការមើល ទើបធ្វើឱ្យកើតនិមិត្ត៣ បាន ។ កាយគតាសតិ កាន់យកបានដោយភ្នែកមើល និងដោយការស្ដាប់ គឺ តចបញ្ចកកម្មដ្ឋាន កាន់យកបានដោយភ្នែកមើល ចំណែក ដែលនៅសល់ កាន់យកដោយការស្ដាប់ ។ អានាបានស្សតិ កាន់យកដោយការប៉ះខ្ទប់ ។ វាយោកសិណ កាន់ យកដោយការមើល និងការប៉ះខ្ទប់ ។ ដែលនៅសល់ ១៨ ទៀត កាន់យកដោយការស្ដាប់ ។ ក្នុងបណ្ដាកម្មដ្ឋាន៤០ នោះ ឧបេក្ខាព្រហ្មវិហារ និងអរូបកម្មដ្ឋាន៤ ព្រះយោគាវចរ ជាអាទិកម្មិក (ដែលមិនទាន់ជំនាញ) មិនគួរកាន់យក, កម្មដ្ឋានដែលនៅសល់ ៣៥ គួរកាន់ យក ។

៩. **ដោយបច្ច័យ** បានដល់ កសិណ៩ (វៀរអាកាសកសិណ) ជាបច្ច័យដល់រូបជ្ឈាន ។ កសិណ១០ ជាបច្ច័យ ដល់អភិញ្ញា ។ ព្រហ្មវិហារ៣ ជាបច្ច័យដល់

ព្រហ្មវិហារទី៤ ។ អរូបជ្ឈានទាប ៗ ជាបច្ច័យដល់អរូបជ្ឈានខ្ពស់ ៗ នេវសញ្ញានាសញ្ញាយតនៈជាបច្ច័យដល់និរោធសមាបត្តិ ។ កម្មដ្ឋានទាំងអស់ ជាបច្ច័យដល់សុខវិហារ និងភពសម្បត្តិ ។

**១០. ដោយសមគួរដល់ចរិត** មានអធិប្បាយថា ក្នុងកម្មដ្ឋាន ៤០ នោះ កម្មដ្ឋាន១១ គឺ អសុភៈ១០ កាយគតាសតិ១ សមគួរដល់មនុស្សរាគចរិត ។ កម្មដ្ឋាន៨ គឺ ព្រហ្មវិហារ៤ វណ្ណកសិណ៤ សមគួរដល់មនុស្សទោសចរិត ។ អានាបានស្សតិប៉ុណ្ណោះ សមគួរដល់មនុស្សមោហចរិត និងមនុស្សវិតក្កចរិត ។ អនុស្សតិ ៦ ខាងដើម សមគួរដល់មនុស្សសទ្ធាចរិត ។ កម្មដ្ឋាន ៤ គឺ មរណស្សតិ ឧបសមានុស្សតិ ចតុធាតុវវត្ថាន និងអាហារេបដិកូលសញ្ញាសមគួរដល់មនុស្សពុទ្ធិចរិត ។ កសិណដែលនៅសល់ គឺ កសិណ៦ (វៀរវណ្ណកសិណ ៤) និងអរូបជ្ឈាន ៤ សមគួរដល់មនុស្សគ្រប់ចរិត ។ មួយ

ទៀត ក្នុងកសិណទាំងឡាយ កសិណយ៉ាងណាមួយដែលជាបរិត្តារម្មណ៍ សមគួរដល់មនុស្សវិតក្កចរិត ។ ដែលជាអប្បមាណារម្មណ៍ សមគួរដល់មនុស្សមោហចរិត ។

ការចម្រើនសមថភាវនា គឺ ចម្រើនរូបជ្ឈាន ប្រកបដោយអង្គឈាន ៥ មានវិតក្កជាដើមនោះ អាចញ៉ាំញីនូវនីវរណៈ ៥ មិនឱ្យកើតឡើង ព្រោះចិត្តមូលនៅក្នុងអារម្មណ៍តែមួយ ដរាបដល់ឈានចិត្តកើត កាលឈានចិត្តកើតហើយអង្គឈាននោះឯង រមែងប្រហារនីវរណធម៌ ៥ ដោយវិក្ខម្ភនប្បហាន ។

មួយទៀត កាលឈានចិត្តនឹងកើតឡើង សមាធិរមែងកើតឡើងតាមលំដាប់ គឺ ខណិកសមាធិ ឧបចារសមាធិ និងអប្បនាសមាធិ ឈានចិត្តកើតឡើងគ្រាដំបូង ត្រឹមខណៈចិត្តមួយប៉ុណ្ណោះ ហើយក៏ជាភវង្គ បើនឹងមិនឱ្យចិត្តជាភវង្គ ត្រូវហ្វឹកហាត់ ដរាបដល់ជំនាញ (ដែលហៅថា វសី ៥ យ៉ាង) ។ ឈាន គឺ រូបាវចរកុសលចិត្ត នឹងកើតនោះ

វិថីចិត្ត ត្រូវកើតឡើង ដោយលំដាប់ ។

វិថីរបស់រូបាវចរកុសលចិត្ត គឺ ៖

១. ភវង្គចលនៈ

២. ភវង្គុបច្ឆេទ

៣. មនោទ្វារាវជ្ជនៈ

៤. បរិកម្ម
៥. ឧបចារ
៦. អនុលោម
៧. គោត្រភូ
} មហាកុសលញ្ញាណសម្បយុត្ត

៨. ឈាន គឺ រូបាវចរកុសលចិត្ត

ភវង្គបាត ចិត្តជាភវង្គ

## អធិប្បាយ អប្បនាវិថី

កាលភវង្គចលនៈ គឺ ការញ័ររបស់ភវង្គរលត់ទៅ ភវង្គុបច្ឆេទ ក៏កើតនិងរលត់ទៅ. តពីនោះ មនោទ្វារាវជ្ជនៈ គឺ

អហេតុកកិរិយាចិត្ត ក៏កើតឡើងធ្វើកិច្ចពិចារណាអារម្មណ៍តាមមនោទ្វារ កាលមនោទ្វារាវជ្ជនចិត្តរលត់ហើយ មហាកុសលញាណសម្បយុត្ត ៤ ណាមួយ ក៏ធ្វើបរិកម្ម ឧបចារ អនុលោម គោត្រភូ កាលគោត្រភូចិត្តរលត់ហើយ ឈានចិត្តក៏កើតមួយខណៈចិត្តប៉ុណ្ណោះ ហើយចិត្តក៏ជាភវង្គតទៅ ។

## ទុតិយជ្ឈាន

កាលព្រះយោគាវចរហ្វឹកហាត់ព្យាយាម ចូលបឋមជ្ឈានដរាបដល់ជំនាញល្អ ព្រមដោយវសី ៥ គឺ

**១. អាវជ្ជនវសី** ជំនាញក្នុងការនឹក

**២. សមាបជ្ជនវសី** ជំនាញក្នុងការចូលឈាន

**៣. អធិដ្ឋានវសី** ជំនាញក្នុងការតាំងមាំ

**៤. វុដ្ឋានវសី** ជំនាញក្នុងការចេញចាកឈាន

**៥. បច្ចវេក្ខណវសី** ជំនាញក្នុងការពិចារណាអង្គឈាន

ព្រះយោគាវចរចូលឈាន ចេញចាកឈានដរាបជំនាញ

ហើយ ហ្វឹកហាត់ដោយពិចារណាថា ទឹកយ៉ាងណា ឈាន ទើបនឹងកើតបានរហ័ស ហ្វឹកហាត់ដោយវិធីនោះរឿយ ៗ រហូត ដល់ជំនាញល្អ ហៅថា **អាវជ្ជនវសី** ( ជំនាញក្នុងការនឹក ) ។

**សមាបជ្ជនវសី** ( ជំនាញក្នុងការចូលឈាន ) គឺ ចូលឈានរឿយ ៗ ដែលជំនាញដូចការលេងកីឡា ឬលោក ហៅថា កីឡាឈាន ។

**អធិដ្ឋានវសី** ជំនាញក្នុងការឱ្យឈានកើតរលត់បន្ត ដោយមិនជាភវង្គ គឺ នឹងឱ្យឈានតាំងនៅតាមត្រូវការ ។

**វុដ្ឋានវសី** ជំនាញក្នុងការចេញចាកឈាន ដោយតាំង ចិត្ត និងចេញចាកឈានវេលាណា ក៏ចេញបានមិនយឺតយូរ ។

**បច្ចវេក្ខណវសី** ជំនាញក្នុងការពិចារណាអង្គឈាន គឺ កាលចេញចាកឈានហើយ ពិចារណា ដើម្បីលះអង្គឈាន ដែលគ្រោតគ្រាតចេញ ដើម្បីធ្វើឱ្យអប្បនាសមាធិរឹងមាំ ក្រៃលែងឡើង រមែងពិចារណាឃើញថា វិតក្កៈនេះ ជាអង្គ

ឈានដែលគ្រោតគ្រាតជាងវិចារៈ ព្រោះជិតនឹងកាមារម្មណ៍ ដូច្នោះ កាលនឹងឈានឡើងកាន់ទុតិយជ្ឈាន ទើបលោកសម្លឹងបដិភាគនិមិត្ត ដើម្បីឱ្យចិត្តជាអប្បនាសមាធិ ដោយមិនមានវិតក្កៈតទៅ ព្យាយាមរហូតដល់ឈានចិត្ត មិនមានវិតក្កៈកើតឡើង មានត្រឹមតែវិចារៈ បីតិ សុខៈ ឯកគ្គតាប៉ុណ្ណោះ ។ កាលទុតិយជ្ឈាននឹងកើតនោះ ក៏នឹងមានវិថីចិត្តដែលកើតមុនទុតិយជ្ឈាន គឺ មហាកុសលញាណសម្បយុត្តចិត្តដែលជាបរិកម្ម ឧបចារ អនុលោម និងគោត្រភូដូចគ្នានឹងបឋមជ្ឈានដែលបានពោលហើយ ។

## តតិយជ្ឈាន

កាលព្រះយោគាវចរ ជំនាញក្នុងទុតិយជ្ឈានល្អប្រកបដោយវសី ៥ ហើយ ក៏នឹងសម្លឹងបដិភាគនិមិត្តឡើងកាន់ឈានទី ៣ ដោយពិចារណាឃើញវិចារៈ ជាអង្គឈានគ្រោតគ្រាតជិតនឹងវិតក្កៈ ដែលធ្វើឱ្យសាបសូន្យបានងាយ

កាលឃើញទោសរបស់វិចារៈហើយ ក៏ចូលឈាន សម្លឹងបដិភាគនិមិត្ត ដើម្បីឱ្យអប្បនាសមាធិកើតឡើង ដោយមិនមានវិចារៈដរាបដល់តតិយជ្ឈានកើតឡើង ដោយទំនងដូចនឹងឈានដែលពោលហើយ ។

## ចតុត្ថជ្ឈាន

កាលចម្រើនតតិយជ្ឈានជំនាញល្អ ព្រមទាំងវសី ៥ ហើយ ក៏នឹងព្យាយាមឡើងកាន់ឈានទី ៤ ដោយពិចារណាឃើញបីតិដែលកើតក្នុងតតិយជ្ឈាននោះ ជាសេចក្តីត្រេកអររីករាយរីកពោរពេញទូទាំងកាយចិត្ត មានអាការបង្អោនទៅក្នុងការកម្រើកឡើងនៃចិត្ត ដែលរាប់ថា ជាសភាពដែលនៅគ្រោតគ្រាត ដើម្បីឱ្យចិត្តប្រណីតក្រៃលែងឡើង ទើបសម្លឹងបដិភាគនិមិត្ត ដើម្បីចម្រើនអប្បនាសមាធិ ដរាបដល់មិនមានបីតិកើតរួមផង វិថីចិត្តដែលកើតមុនចតុត្ថជ្ឈាន មានទំនងដូចនឹងឈានដែលពោលហើយ ។

## បញ្ចមជ្ឈាន

កាលព្រះយោគាវចរឈានឡើងកាន់ឈានទី ៥ ក៏ត្រូវធ្វើវសី ៥ យ៉ាង របស់ចតុត្ថជ្ឈាន រហូតដល់ជំនាញល្អ ព្រមទាំងវសី ៥ ហើយ ក៏ចូលឈានចេញចាកឈានហើយពិចារណាឃើញទោសរបស់សុខៈ ថា ជាសភាពដែលគ្រោតគ្រាតជាងឧបេក្ខា ព្រោះសុខនោះ នៅញាប់ញ័រ មិនមាំទាំដូចឧបេក្ខាវេទនា ទើបសម្លឹងបដិភាគនិមិត្តចម្រើនអប្បនាសមាធិដើម្បីលះសុខ រហូតដល់បញ្ចមជ្ឈានកើត ប្រកបដោយអង្គ ២ គឺ ឧបេក្ខា និងឯកគ្គតា ។

### លក្ខណាទិចតុក្កៈរបស់ឧបេក្ខានៃអង្គឈាន

**១- មជ្ឈត្តលក្ខណា** មានសេចក្តីមធ្យ័ត (ភាពជាកណ្តាល) ជាលក្ខណៈ

**២- អនាភោគរសា** មានការមិនទឹកដល់ ជាកិច្ច

**៣- អព្យាបារប្បច្ចុបដ្ឋានា** មានការមិនខ្វល់ខ្វាយ

ជាបច្ចុប្បដ្ឋាន

៤- **បីតិវិរាគប្បទដ្ឋានា** មានសេចក្តីបន្ទោបង់បីតិ ជាបទដ្ឋាន ។

**លក្ខណាទិចតុក្កៈរបស់ឧបេក្ខានៃអង្គឈាន ( ន័យមួយទៀត )**

១- **ឥដ្ឋានិដ្ឋវិបរីតានុភវនលក្ខណា** មានការសោយអារម្មណ៍ ដែលខុសប្លែកអំពី អារម្មណ៍ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ជាលក្ខណៈ

២- **មជ្ឈត្តរសា** មានភាពជាកណ្តាល ជាកិច្ច

៣- **អវិភូតបច្ចុប្បដ្ឋានា** មានអារម្មណ៍មិនជាក់ច្បាស់ ជាអាការប្រាកដ

៤- **សុខនិរោធបទដ្ឋានា** មានការរលត់សុខ ជាបទដ្ឋាន ។

មហាកុសលញាណសម្បយុត្តដែលធ្វើបរិកម្ម ឧបចារ អនុលោម និងគោត្រភូ ដែលកើតមុនបញ្ចមជ្ឈាននោះ កើតព្រមជាមួយឧបេក្ខាវេទនា ព្រោះឈានទី ៥ នេះ មានឧបេក្ខា និងឯកគ្គតា ជាអង្គឈាន ចំណែកឈាន ៤ ក្រៅអំពីនេះ

មហាកុសលនោះ កើតឡើងព្រមជាមួយសោមនស្សវេទនា ។

មួយទៀត មហាកុសលញាណសម្បយុត្តចិត្តដែលកើតឡើងក្នុងវេលាងការចម្រើនសមថភាវនានោះ គ្រាខ្លះក៏កើតព្រមជាមួយសោមនស្សវេទនា គ្រាខ្លះក៏កើតព្រមជាមួយឧបេក្ខាវេទនា ។

**បែករូបាវចរកុសលចិត្ត ៥ ដោយន័យផ្សេង ៗ គឺ**

**១. ដោយជាតិ** ជាកុសលជាតិ

**២. ដោយភូមិ** ជារូបាវចរភូមិ (បាន ២២ ភូមិ វៀរ អបាយនិងអសញ្ញី)

**៣. ដោយវេទនា** ជាសោមនស្ស ៤ គឺ ឈាន ៤ ខាងដើម ជាឧបេក្ខា ១ គឺ ឈានទី ៥

**៤. ដោយហេតុ** ជានហេតុ និងជា តិហេតុកចិត្ត

**៥. ដោយសម្បយុត្ត** ជាញាណសម្បយុត្ត

**៦. ដោយសង្ខារ** ជាសសង្ខារិក(ដោយមនោបយោគ)

៧. ដោយសោភណ ជារូបាវចរសោភណចិត្ត

៨. ដោយឈាន ជារូបជ្ឈានចិត្ត

៩. ដោយលោក ជាលោកិយចិត្ត

១០. ដោយកិច្ច ធ្វើជវនកិច្ច

១១. ដោយអារម្មណ៍ មានធម្មារម្មណ៍ជាអារម្មណ៍

១២. ដោយទ្វារ ដឹងអារម្មណ៍តាមមនោទ្វារ

១៣. ដោយវត្ថុ កើតត្រង់ហទយវត្ថុ

១៤. ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ

**រូបាវចរកុសលចិត្ត ៥ ចប់**

# រូបាវចរវិបាកចិត្ត ៥ គឺ

**១, វិតក្កវិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ បឋមជ្ឈានវិបាកចិត្តំ** : បឋមជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**២, វិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ ទុតិយជ្ឈានវិបាកចិត្តំ** : ទុតិយជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ៤ គឺ វិចារៈ បីតិ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**៣, បីតិសុខេកគ្គតាសហិតំ សសង្ខារិកំ តតិយជ្ឈានវិបាកចិត្តំ** : តតិយជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ៣ គឺ បីតិ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**៤, សុខេកគ្គតាសហិតំ សសង្ខារិកំ ចតុត្ថជ្ឈានវិបាកចិត្តំ** : ចតុត្ថជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ២ គឺ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**៥, ឧបេក្ខេកគ្គតាសហិតំ សសង្ខារិកំ បញ្ចមជ្ឈានវិបាកចិត្តំ**

: បញ្ចមជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា មានការបបួលដឹកនាំ

ចិត្ត ៥ នេះ ឈ្មោះថា រូបាវចរវិបាកចិត្ត ។

## អធិប្បាយ រូបាវចរវិបាកចិត្ត

រូបាវចរកុសលចិត្ត ជាហេតុឱ្យកើត រូបាវចរវិបាកចិត្ត ដែលធ្វើបដិសន្ធិ ជារូបភូមិ(រូបាវចរភូមិ)ផ្សេង ៗគ្នា ដូច្នេះ គឺ

| ឈានកុសល | ឱ្យផលជា | បដិសន្ធិក្នុងភូមិ | មានអាយុ |
|---|---|---|---|
| បឋមជ្ឈានកុសល | បឋមជ្ឈានវិបាក | បឋមជ្ឈានភូមិ | ១ កប្បតូច |
| ទុតិយជ្ឈានកុសល | ទុតិយជ្ឈានវិបាក | ទុតិយជ្ឈានភូមិ | ៨ មហាកប្ប |
| តតិយជ្ឈានកុសល | តតិយជ្ឈានវិបាក | | |
|ចតុត្ថជ្ឈានកុសល | ចតុត្ថជ្ឈានវិបាក | តតិយជ្ឈានភូមិ | ៦៤ មហាកប្ប |
| បញ្ចមជ្ឈានកុសល | បញ្ចមជ្ឈានវិបាក | ចតុត្ថជ្ឈានភូមិ | ៥០០មហាកប្ប |

កាមាវចរវិបាក រមែងដូចគ្នាខ្លះ មិនដូចគ្នាខ្លះ ជាមួយនឹងកុសលចិត្តរបស់ខ្លួន ព្រោះដូច្នោះ វិបាករបស់កាមាវចរ

កុសលនោះ ទើបលោកមិនបានចែកឱ្យវិបាកស្របតាមកុសល ចំណែករូបាវចរវិបាកចិត្តនេះ រមែងដូចគ្នានឹងកុសលរបស់ខ្លួន ប្រៀបដូចស្រមោលទាំងឡាយ មានប្រមោយដំរី សេះ និង ដើមឈើជាដើម រមែងដូចគ្នានឹងដំរី សេះ និងដើមឈើជាដើម ព្រោះដូច្នោះ រូបាវចរវិបាកចិត្តនេះ ទើបលោកចែកធ្វើឱ្យស្របតាមកុសលរបស់ខ្លួន ។ មួយទៀត កាមាវចរកុសល រមែងឱ្យវិបាកក្នុងកាលខ្លះ គ្រាខ្លះក៏បាន ចំណែករូបាវចរកុសល រមែងឱ្យវិបាកក្នុងភពទី ២ តែម្តង ព្រោះហេតុនេះ រូបាវចរវិបាកចិត្ត ទើបលោកចែកឱ្យដូចគ្នានឹងកុសលរបស់ខ្លួន ។

បុគ្គលដែលបដិសន្ធិក្នុងរូបាវចរភូមិ ដោយរូបាវចរវិបាកចិត្ត ជារូបព្រហ្ម បុគ្គលនោះ រមែងមានចក្ខុប្រសាទ និង សោតប្រសាទល្អ តែមិនមានឃានប្រសាទ ជិវ្ហាប្រសាទ និង កាយប្រសាទ ខណៈដែលចក្ខុវិញ្ញាណ ឬសោតវិញ្ញាណរបស់ព្រហ្មនោះកើត គប្បីជ្រាបថា ចក្ខុវិញ្ញាណក្តី សោតវិញ្ញាណក្តី

មិនមែនជាវិបាក (ផល) របស់រូបាវចរកុសល ៥ នោះទេ គឺ ជាវិបាករបស់កាមាវចរកុសលចិត្ត ។ រូបាវចរវិបាកចិត្ត ៥ ប៉ុណ្ណោះ ដែលធ្វើបដិសន្ធិក្នុងរូបភូមិ ១៥ (វៀរ អសញ្ញសត្តាភូមិ) គឺ

| | |
|---|---|
| ១. បារិសជ្ជាភូមិ<br>២. បុរោហិតាភូមិ<br>៣. មហាព្រហ្មាភូមិ | បដិសន្ធិដោយបឋមជ្ឈានវិបាកចិត្ត |
| ៤. បរិត្តាភាភូមិ<br>៥. អប្បមាណាភាភូមិ<br>៦. អាភស្សរាភូមិ | បដិសន្ធិដោយទុតិយជ្ឈានវិបាកចិត្ត (ចតុក្កន័យ) ឬទុតិយជ្ឈានវិបាក និង តតិយជ្ឈានវិបាក (បញ្ចកន័យ) |
| ៧. បរិត្តសុភាភូមិ<br>៨. អប្បមាណាសុភាភូមិ<br>៩. សុភកិណ្ហាភូមិ | បដិសន្ធិដោយតតិយជ្ឈានវិបាកចិត្ត (ចតុក្កន័យ) ឬចតុត្ថជ្ឈានវិបាកចិត្ត (បញ្ចកន័យ) |

១០. វេហប្ផលាភូមិ - បដិសន្ធិដោយចតុត្ថជ្ឈានវិបាកចិត្ត (ចតុក្កន័យ) ឬបញ្ចមជ្ឈានវិបាកចិត្ត (បញ្ចកន័យ)

១១. អវិហាភូមិ
១២. អតប្បាភូមិ
១៣. សុទស្សាភូមិ
១៤. សុទស្សីភូមិ
១៥. អកនិដ្ឋាភូមិ

៥ ភូមិនេះ ជាព្រហ្មជាន់សុទ្ធាវាស របស់ព្រះអនាគាមិបដិសន្ធិ ដោយចតុត្ថជ្ឈានដោយចតុក្កន័យ ឬបញ្ចមជ្ឈានវិបាកចិត្ត ដោយបញ្ចកន័យ

## អធិប្បាយ ព្រហ្មក្នុងព្រហ្មភូមិ

អ្នកកើតជាព្រហ្ម រមែងមានសេចក្ដីសុខប្រណីត (ជាងសុខក្នុងសួគ៌) មានកាយល្អស្អាត មានសំឡេងពីរោះ ។

### សំឡេងរបស់ព្រហ្មប្រកបដោយអង្គ ៨ គឺ

១. **វិសដ្ឋោ** ក្បោះក្បាយ ២. **វិញ្ញេយ្យោ** ងាយយល់
៣. **មញ្ជូ** ទន់ពីរោះ ៤. **សវនីយោ** គួរស្ដាប់
៥. **ពិន្ទុ** មូល ៦. **អវិសារី** មិនគ្រាវ

**៧. គម្ពីរោ** ក្រអួន **៨. និន្នាទី** លាន់រំពង ៗ[១]

បណ្តាព្រហ្មដែលកើតក្នុងបឋមជ្ឈានភូមិនេះ មានមហាព្រហ្មជាធំ អាចផ្សាយរស្មីទៅឆ្ងាយ ពួកខ្លះផ្សាយទៅដល់ ១.០០០ ចក្រវាឡ ពួកខ្លះផ្សាយទៅដល់ ២.០០០ ចក្រវាឡ ពួកខ្លះផ្សាយទៅដល់ ៣.០០០ ចក្រវាឡ ព្រោះកើតឡើងដោយអំណាចវិបាករបស់ឈានដែលប្រណីត មានអាយុ ១ កប្ប ៗ បើកើតដោយវិបាកឈានថ្នាក់កណ្តាល ក៏ឈ្មោះថា ព្រហ្មបុរោហិតា (ព្រហ្មអ្នកជាទីប្រឹក្សា) មានអាយុកន្លះកប្ប ៗ បើកើតដោយវិបាកឈានថ្នាក់ខ្សោយ ក៏ឈ្មោះថា ព្រហ្មបារិសជ្ជា (ព្រហ្មអ្នកជាបរិវាររបស់មហាព្រហ្ម) មានអាយុ មួយភាគបីនៃកប្ប ៗ ព្រហ្មទាំង ៣ នេះ មានកាយផ្សេងគ្នា មានសញ្ញាបដិសន្ធិតែមួយដូចគ្នា (នានត្តកាយ ឯកត្តសញ្ញិនោ) ដូចសត្វដែលកើតក្នុងអបាយភូមិ ៤ ៗ

១. ទីឃ. មហា. មហាគោវិន្ទសូត្រ. ១៧. ៥៦/១១៩ ៗ

ព្រហ្មដែលកើតក្នុងទុតិយជ្ឈានភូមិ មានអាភស្សរាព្រហ្មជាប្រធាន បដិសន្ធិដោយទុតិយជ្ឈានវិបាក ឬតតិយជ្ឈានវិបាកដែលប្រណីត មានរស្មីផ្សាយចេញពីសរីរៈ ដូចដាច់ធ្លាក់ចុះក្នុងគប់ភ្លើង មានអាយុ ៨ កប្ប ។ វិបាកយ៉ាងកណ្តាល រមែងកើតជាព្រហ្ម ឈ្មោះថា អប្បមាណាភាព្រហ្មមានអាយុ ៤ កប្ប (មានតំណែងដូចបុរោហិតាព្រហ្ម) ។ វិបាកយ៉ាងខ្សោយ រមែងកើតជាព្រហ្ម ឈ្មោះថា បរិត្តាភាព្រហ្ម មានអាយុ ២ កប្ប (មានតំណែងដូចព្រហ្មបារិសជ្ជា) ។ ព្រហ្មទាំង ៣ នេះ មានកាយដូចគ្នា មានសញ្ញាបដិសន្ធិផ្សេងគ្នា ព្រោះសញ្ញាមិនមានវិតក្កៈមានវិចារៈខ្លះ មិនមានវិតក្កៈមិនមានវិចារៈខ្លះ ។

ព្រហ្មដែលកើតក្នុងតតិយជ្ឈានភូមិ មានព្រហ្មឈ្មោះថាសុភកិណ្ហាព្រហ្មជាធំ កើតឡើងដោយវិបាករបស់ចតុត្ថជ្ឈានដែលប្រណីត មានរស្មីល្អស្អាត ដូចរស្មីរបស់ព្រះចន្ទគឺ រស្មី

ចាកសរីរៈ មានអាយុ ៦៤ កប្ប ។ វិបាកយ៉ាងកណ្ដាល កើតជាព្រហ្មឈ្មោះថា អប្បមាណសុភាព្រហ្ម (មានតំណែងដូចបុរោហិតាព្រហ្ម) ។ វិបាកយ៉ាងខ្សោយ រមែងកើតជាព្រហ្មឈ្មោះថា បរិត្តសុភាព្រហ្ម មានអាយុ ១៦ កប្ប (មានតំណែងដូចព្រហ្មបារិសជ្ជា) ។ ព្រហ្មទាំង ៣ នេះ មានកាយដូចគ្នា មានសញ្ញាបដិសន្ធិតែមួយដូចគ្នា ។

ព្រហ្មដែលកើតនៅក្នុងចតុត្ថជ្ឈានភូមិ មានឈ្មោះថា វេហប្ផលាព្រហ្ម កើតឡើងដោយវិបាករបស់បញ្ចមជ្ឈានដែលមានឧបេក្ខា និងឯកគ្គតាជាអង្គឈាន ជាឈានដែលរឹងមាំមានផលបរិបូណ៌ មិនញាប់ញ័រ រមែងប្រព្រឹត្តទៅតាមឈានមិនដូចបឋមជ្ឈានភូមិ ៣ ទុតិយជ្ឈានភូមិ ៣ និងតតិយជ្ឈានភូមិ ៣ ដែលប្រកបដោយសោមនស្ស ព្រហ្មជាន់នេះ មិនអាចវិនាសដោយភ្លើង ទឹក ខ្យល់ទេ មានអាយុពេញ ៥០០ កប្ប ។

ព្រហ្មដែលតាំងនៅក្នុងភូមិទាំង ៤ តាមដែលពោលមកនេះ ជាវដ្តៈ ។

ចំណែកសុទ្ធាវាសភូមិ ៥ ដែលកើតដោយចតុត្ថជ្ឈានវិបាក គឺ អវិហា អតប្បា សុទស្សា សុទស្សី និងអកនិដ្ឋា នេះ តាំងនៅក្នុងផ្នែកវិវដ្តៈ ជាទីសម្រាប់រស់នៅរបស់ព្រះអនាគាមី តាំងនៅជាជាន់ ៗ ឡើងទៅតាមលំដាប់របស់ភូមិ មិនដូចភូមិដទៃ ៗ មានបឋមជ្ឈានភូមិជាដើមតាមដែលពោលហើយទេ ។

**អវិហា** ប្រែថា មិនសាបសូន្យបាកសម្បត្តិ

**អតប្បា** ប្រែថា មិនក្តៅក្រហាយ (មានភាពស្ងប់ត្រជាក់) ។

**សុទស្សា** ប្រែថា ឃើញវត្ថុផ្សេង ៗបានល្អ (ព្រោះបរិបូណ៌ ដោយចក្ខុប្រសាទ ទិព្វចក្ខុ ធម្មចក្ខុ បញ្ញាចក្ខុ) ។

**សុទស្សីភូមិ** ប្រែថា ឃើញវត្ថុផ្សេង ៗបានល្អជាង

សុទស្សា

**អកនិដ្ឋា** ប្រែថា មិនមានសុខតិចតួច (គឺ សុខច្រើនសន្ធឹក) ជាព្រហ្មដែលមានគុណសម្បត្តិជាងព្រហ្មជាន់ទី ១. ២. ៣. ៤ របស់សុទ្ធាវាសភូមិ ។

សុទ្ធាវាសភូមិទាំង ៥ នេះ មិនមានរហូតទេ ក្នុងវេលាដែលមិនមានព្រះពុទ្ធ រហូតមួយសែនកប្បខ្លះ មួយអសង្ខេយ្យកប្បខ្លះ រមែងមិនមានក្នុងលោក កាលព្រះពុទ្ធទ្រង់ឧប្បត្តិឡើងហើយនោះឯង សុទ្ធាវាសភូមិទាំង ៥ នេះ ទើបកើតឡើងក្នុងវាងវេលា ១៦.០០០ កប្ប (ឬ ៣១.០០០ កប្ប ក្នុងកាលដែលមានឧទ្ធំសោតោអកនិដ្ឋគាមី) ។

## ចែករូបាវចរវិបាកចិត្ត ៥ ដោយន័យផ្សេង ៗ គឺ

១. ដោយជាតិ ជាវិបាកជាតិ

២. ដោយភូមិ ជារូបាវចរភូមិ ( រូបព្រហ្មភូមិ ១៥ )

៣. ដោយវេទនា ជាសោមនស្ស ៤ គឺ ឈាន៤ ខាងដើម;

ជាឧបេក្ខា ១ គឺ ឈានទី ៥

៤. ដោយហេតុ ជានហេតុ និងជា តិហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាញាណសម្បយុត្ត

៦. ដោយសង្ខារ ជាសសង្ខារិក

៧. ដោយសោភណ ជារូបាវចរសោភណចិត្ត

៨. ដោយឈាន ជាផលរបស់ឈានចិត្ត

៩. ដោយលោក ជាលោកិយចិត្ត

១០. ដោយកិច្ច មាន៣ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច

១១. ដោយអារម្មណ៍ កុសលមានអារម្មណ៍ណា ជាកម្មដ្ឋាន

វិបាកចិត្ត ក៏មានអារម្មណ៍នោះ

**១២. ដោយទ្វារ** ដឹងអារម្មណ៍ដោយមិនអាស្រ័យទ្វារ (ទ្វារវិមុត្ត)

**១៣. ដោយវត្ថុ** កើតត្រង់ហទយវត្ថុ

**១៤. ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ

**រូបាវចរវិបាកចិត្ត ចប់**

## រូបាវចរកិរិយាចិត្ត ៥

**១, វិតក្កវិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ បឋមជ្ឈានកិរិយាចិត្តំ** : បឋមជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**២, វិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ ទុតិយជ្ឈានកិរិយាចិត្តំ** : ទុតិយជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ៤ គឺ វិចារៈ បីតិ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**៣, បីតិសុខេកគ្គតាសហិតំ សសង្ខារិកំ តតិយជ្ឈានកិរិយា**

**ចិត្តំ** : តតិយជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ៣ គឺ បីតិ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**៤, សុខេកគ្គតាសហិតំ សសង្ខារិកំ ចតុត្ថជ្ឈានកិរិយាចិត្តំ** : ចតុត្ថជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ២ គឺ សុខៈ ឯកគ្គតា មានការបបួលដឹកនាំ

**៥, ឧបេក្ខេកគ្គតាសហិតំ សសង្ខារិកំ បញ្ចមជ្ឈានកិរិយាចិត្តំ** : បញ្ចមជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា មានការបបួលដឹកនាំ

ចិត្ត ៥ នេះ ឈ្មោះថា រូបាវចរកិរិយាចិត្ត ។

រូបាវចរកិរិយាចិត្ត ជារូបជ្ឈានចិត្តរបស់ព្រះខីណាស្រព គឺ រូបាវចរឈានរបស់ព្រះខីណាស្រព ជាកិរិយាចិត្ត មិនមែនកុសល មិនមែនអកុសល មិនមែនវិបាក ជាទិដ្ឋធម្មសុខវិហារធម៌ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្នប៉ុណ្ណោះ ។

ក្នុងសមាបត្តិទាំងនោះ សមាបត្តិដែលព្រះខីណាស្រពឱ្យ

កើតឡើងក្នុងវេលាដែលលោកនៅជាបុថុជ្ជន កាលលោកសម្រេចព្រះអរហត្ត និងចូលសមាបត្តិនោះហើយ សមាបត្តិនោះ ក៏ជាកិរិយាចិត្ត ។

## ចែករូបាវចរកិរិយាចិត្ត ៥ ដោយន័យផ្សេង ៗ គឺ

១. ដោយជាតិ ជាកិរិយាជាតិ

២. ដោយភូមិ ជារូបាវចរភូមិ ( កើតបាន ២២ ភូមិ )

៣. ដោយវេទនា ជាសោមនស្ស ៤ ជាឧបេក្ខា ១

៤. ដោយហេតុ ជាទហេតុ និងជាតិហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាញាណសម្បយុត្ត

៦. ដោយសង្ខារ ជាសសង្ខារិក

៧. ដោយសោភណៈ ជារូបាវចរសោភណចិត្ត

៨. ដោយឈាន ជារូបាវចរកិរិយាឈានចិត្ត

៩. ដោយលោក ជាលោកិយចិត្ត ព្រោះមិនមាននិព្វាន ជាអារម្មណ៍

១០. ដោយកិច្ច ធ្វើជវនកិច្ច

១១. ដោយអារម្មណ៍ មានធម្មារម្មណ៍ ជាអារម្មណ៍

១២. ដោយទ្វារ ដឹងអារម្មណ៍តាមមនោទ្វារ

១៣. ដោយវត្ថុ កើតត្រង់ហទយវត្ថុ

១៤. ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ

**រូបាវចរកិរិយាចិត្ត ចប់**

## ពាក្យនិគម

ឥច្ចេវំ សព្វថាបិ បណ្ណរស រូបាវចរកុសលវិបាកកិរិយាចិត្តានិ សមត្តានិ : រូបាវចរកុសល វិបាក កិរិយាចិត្ត ចប់បរិបូរណ៍ហើយ ដោយប្រការទាំងពួង ។

## សរុបរូបាវចរសោភណចិត្ត ១៥

- រូបាវចរសោភណចិត្ត ១៥
  - រូបាវចរកុសលចិត្ត ៥
    - បឋមជ្ឈានកុសលចិត្ត ១
    - ទុតិយជ្ឈានកុសលចិត្ត ១
    - តតិយជ្ឈានកុសលចិត្ត ១
    - ចតុត្ថជ្ឈានកុសលចិត្ត ១
    - បញ្ចមជ្ឈានកុសលចិត្ត ១
  - រូបាវចរវិបាកចិត្ត ៥
    - បឋមជ្ឈានវិបាកចិត្ត ១
    - ទុតិយជ្ឈានវិបាកចិត្ត ១
    - តតិយជ្ឈានវិបាកចិត្ត ១
    - ចតុត្ថជ្ឈានវិបាកចិត្ត ១
    - បញ្ចមជ្ឈានវិបាកចិត្ត ១
  - រូបាវចរកិរិយាចិត្ត ៥
    - បឋមជ្ឈានកិរិយាចិត្ត ១
    - ទុតិយជ្ឈានកិរិយាចិត្ត ១
    - តតិយជ្ឈានកិរិយាចិត្ត ១
    - ចតុត្ថជ្ឈានកិរិយាចិត្ត ១
    - បញ្ចមជ្ឈានកិរិយាចិត្ត ១

**រូបាវចរសោភណចិត្ត ១៥ ចប់**

# អរូបាវចរសោភណចិត្ត ១២

## សង្គហគាថា

៩. អាលម្ពនប្បភេទេន ចតុធារុប្បមានសំ
បុញ្ញបាកក្រិយាភេទា បុន ទ្វាទសធា ឋិតំ ។
*អរូបាវចរចិត្ត ចាត់តាមអារម្មណ៍ មាន ៤ ប្រការ*
*ចាត់តាមកុសល វិបាក កិរិយា មាន១២ ប្រការ ។*

## អធិប្បាយសង្គហគាថា

*<u>ក្នុងដីកា</u> លោកអធិប្បាយថា ៖*

*អរូបាវចរចិត្តមាន ៤ ដោយប្រភេទនៃអារម្មណ៍ ៤ មាន អាកាសជាដើម ដែលគប្បីឈានកន្លង និងគប្បីគោរយក គឺ អាកាសវិញ្ញាណ និងសេចក្តីមិនមាននៃអារម្មណ៍ទាំង ៣ នោះ ។*

*ពិតមែន អរូបាវចរចិត្តនោះ រមែងឈានកន្លង*

កសិណនិមិត្ត ដែលជាអារម្មណ៍នៃបញ្ចមជ្ឈានហើយ តោង យកអាកាសដែលបើកកសិណនិមិត្ត (កសិណុគ្ឃាដិមាកាស) នោះ ឈានកន្លងសូម្បីអាកាសនោះ ដោយតោងយកវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាសនោះ ឈានកន្លងសូម្បីវិញ្ញាណ នោះ តោងយកសភាពមិនមានអ្វីតិចតួច ដែលជាការមិនមាន នៃអរូបវិញ្ញាណទី ១ នោះ ឈានកន្លងសូម្បីសភាពមិនមានអ្វី តិចតួចនោះ ហើយតោងយកអរូបវិញ្ញាណទី ៣ ដែលប្រព្រឹត្ត ទៅក្នុងសភាពមិនមានអ្វីតិចតួចនោះ ប្រព្រឹត្តទៅតាមលំដាប់ តែមិនបានកាន់យកអារម្មណ៍នៃឈានដើម ៗ ដែលប្រព្រឹត្តទៅ ដោយអំណាចឈានកន្លងអង្គដើម ៗ ដូចរូបាវចរកុសលចិត្ត ទេ ដោយហេតុនោះ ទើបព្រះបូរាណាចារ្យពោលថា ៖

អារម្មណាតិក្កមតោ ចតស្សោបិ ភវន្តិមា
អង្គាតិក្កមមេតាសំ ន ឥច្ឆន្តិ វិភាវិនោតិ

*សមាបត្តិទាំង ៤ នេះ រមែងមានដោយការឈាន*

កន្លងអារម្មណ៍ បណ្ឌិតទាំងឡាយ រមែងមិនប្រាថ្នា យកការឈានកន្លងអង្គនៃសមាបត្តិទាំងនេះឯង ។

**អរូបាវចរកុសលចិត្ត ៤**

១, អាកាសានញ្ចាយតនកុសលចិត្តំ

២, វិញ្ញាណញ្ចាយតនកុសលចិត្តំ

៣, អាកិញ្ចញ្ញាយតនកុសលចិត្តំ

៤, នេវសញ្ញានាសញ្ញាយតនកុសលចិត្តំ

ឥមានិ ចត្តារិបិ អរូបាវចរកុសលចិត្តំ ចិត្ត ៤ នេះ ឈ្មោះថា អរូបាវចរកុសលចិត្ត

## អធិប្បាយ

### ១-អាកាសានញ្ចាយតនកុសលចិត្ត

មានវិគ្រោះថា ដែលឈ្មោះថា **អនន្ត** ព្រោះអត្ថថា អាកាសនោះ មិនមានទីបំផុត ដោយវៀរចាកទីបំផុត មានការ

កើតជាដើម ។ អាកាសនោះ មិនមានទីបំផុត ទើបឈ្មោះថា **អាកាសានន្តៈ** បានដល់ អាកាសដែលបើកកសិណ ។ ត្រូវពោលថា **អនន្តាកាសៈ** តែលោកពោលថា អាកាសានន្តៈវិញដោយរៀងបទវិសេសន ទុកខាងក្រោយ ដូចក្នុងពាក្យថា **អគ្យាហិតោ** ( **អគ្គិ** + **អាហិតោ** ) ប្រែថា ភ្លើងដែលបុគ្គលបូជាហើយជាដើម ។ អាកាសានន្តៈនោះ ជាអាកាសានញ្ចៈដោយអំណាចការបច្ច័យដែលចុះក្នុងអត្ថនៃខ្លួន ។

អាកាសានញ្ចៈនុ៎ះឯង ជាអាយតនៈ( ជាទីកើត ) នៃឈាននោះ ព្រមដោយសម្បយុត្តធម៌ ដោយអត្ថថា ជាទីតាំងនៅ ដូចទេវាយតនៈ ( ទីនៅនៃទេវតា )របស់ពួកទេវតា ព្រោះហេតុនោះ ឈាននោះ ទើបឈ្មោះថា អាកាសានញ្ចាយតនៈ( អាកាសានញ្ច + អាយតនៈ ) ។

មួយទៀតថា **អាកាសានញ្ចំ អាយតនំ អស្សាតិ** = **អាកាសានញ្ចាយតនំ ឈានំ** : ឈាន ឈ្មោះថា អាកាសាន

ញ្ចាយតនៈ[១] ព្រោះអត្ថថា មានអាកាសមិនមានទីបំផុត ជាទីកើតនៃកុសលចិត្ត ដែលសម្បយុត្តដោយអាកាសានញ្ចាយតនៈនោះ ឈ្មោះថា អាកាសានញ្ចាយតនកុសលចិត្ត ។

## វិធីចម្រើនអរូបជ្ឈានទី ១

ព្រះយោគាវចរ អ្នកចម្រើនអរូបជ្ឈានកម្មដ្ឋាន ឱ្យឈានកន្លងរូបជ្ឈាននោះ ខាងដើម ត្រូវតែបានរូបាវចរបញ្ចមជ្ឈានព្រមទាំងវសី ៥ មានភាពជំនាញហើយ ឃើញទោសរបស់រូបជ្ឈានផ្សេង ៗ ដោយប្រការទាំងពួង មិនមែនឃើញតែទោសរបស់រូបជ្ឈានប៉ុណ្ណោះទេ ត្រូវឃើញទោសរបស់រូបរាងកាយផងថា មានរូបក៏ត្រូវមានទុក្ខច្រើន

---

១. ក្នុងសទ្ទនីតិ. អាកាសានញ្ច គឺ ស័ព្ទដើមជា អាកាសានន្ត, ចុះណ្យ ជា អាកាសានន្ត្យ , ន > ០ = អាកាសានំត្យ , ត្យ > ច = អាកាសានំ ច , ០ > ញ = អាកាសានញ្ច ។

លំបាកកាយ មានការត្រូវទោសអាជ្ញា និងប្រកបដោយរោគផ្សេង ៗ មានរោគភ្នែករោគត្រចៀកជាដើម បើមិនមានរូបរាងកាយទោសផ្សេង ៗ និងរោគផ្សេង ៗ ក៏មិនមានការផុតអំពីរូបកាយទៅបាន ក៏ត្រូវអាស្រ័យការចម្រើនឈាន មិនមានរូប (អរូបជ្ឈាន) ជាអារម្មណ៍ ។

កាលព្រះយោគាវចរឃើញទោសរបស់រូប និងឃើញវិធីនាំឱ្យរូបផុតពីរូបនោះ ហើយក៏ចូលរូបជ្ឈានទី ៥ ធ្វើឱ្យកើតឡើងមុន ចេញពីឈានហើយ ពិចារណាឃើញទោសរបស់រូបកម្មដ្ឋានដែលជាអារម្មណ៍ ហើយចូលឈាននោះពង្រីកនិមិត្ត (រូបកម្មដ្ឋាន) ឱ្យមិនមានទីបំផុត គឺ ផ្សាយទៅដល់ ១ ចក្រវាឡ កាលពង្រីកឱ្យធំក្រៃលែងទៅនិមិត្តរបស់រូបកម្មដ្ឋាន ដែលជាអារម្មណ៍រីកចេញទៅ ដោយមិនមានទីបំផុត ច្រើនប៉ុនណា ក៏ឃើញក្រៃលែងថា ផ្សាយនិមិត្តចេញទៅបានប៉ុណ្ណោះ ក៏ព្រោះអាកាសមិនមានទីបំផុត

អាកាសដែលទទេនោះ មិនមានការកើតឡើង មិនមានការសាបសូន្យ មិនមានទីបំផុត កាលឃើញភាពមិនមានទីបំផុតរបស់អាកាស ក៏បើកសញ្ញា គឺ មិនដាក់ចិត្តក្នុងរូបនិមិត្តដែលជាអារម្មណ៍នោះ ដាក់ចិត្តនៅក្នុងតែសភាពរបស់អាកាសដែលមិនមានទីបំផុត ( **អាកាសោ អនន្តោ** ) ក្នុងខណៈដែលចិត្តត្រិះរិះដល់អាកាស ដែលមិនមានទីបំផុតនេះ វេលានោះចិត្តនៅមានរូបនិមិត្តដែលផ្សាយចេញទៅ ទាំងឧបចារសមាធិក៏កើតឡើងតាមលំដាប់, កាលដាក់ចិត្តដល់អាកាស ដែលមិនមានទីបំផុតនោះរឿយ ៗ ក្នុងទីបំផុត អប្បនាសមាធិក៏កើតដោយមានអាកាសមិនមានទីបំផុតនោះជាអារម្មណ៍ អាកាសមិនមានទីបំផុតនេះ ជាទីតាំងឱ្យកើតអរូបជ្ឈានទី ១ ហៅថាអាកាសានញ្ចាយតនកុសលចិត្ត ជាកសិណុគ្ឃាដិមាកាសបញ្ញត្តិដែលបើករូបកសិណចេញហើយ ជាអារម្មណ៍ ។

កាលអប្បនាវិថីដែលជាអាទិកម្មិក អរូបជ្ឈានរបស់

មន្ទបុគ្គល( អ្នកដឹងយឺត ) នឹងកើតនោះ វិថីចិត្តរមែងកើតតាម លំដាប់យ៉ាងនេះ គឺ ៖

១. ភវង្គចលនៈ } ចិត្តផុតវិថី
២. ភវង្គុបច្ឆេទ }

៣. មនោទ្វារាវជ្ជនៈ

៤. បរិកម្ម }
៥. ឧបចារ } មហាកុសលឧបេក្ខា
៦. អនុលោម } ញាណសម្បយុត្តចិត្ត ២
៧. គោត្រភូ }

៨. បឋមារូបជ្ឈាន  អាកាសានញ្ចាយតនកុសលចិត្ត

ភវង្គបាត  ចិត្តជាភវង្គ

## អាទិកម្មិកអរូបជ្ឈានវិថីរបស់តិក្ខបុគ្គល

១. ភវង្គចលនៈ } ចិត្តផុតវិថី
២. ភវង្គុបច្ឆេទ
៣. មនោទ្វារាវជ្ជនៈ
៤. ឧបចារ } មហាកុសលឧបេក្ខា
៥. អនុលោម } ញាណសម្បយុត្តចិត្ត ២
៦. គោត្រភូ
៧. បឋមារូបជ្ឈាន អាកាសានញ្ចាយតនកុសល
ភវង្គបាត ចិត្តជាភវង្គ

## អធិប្បាយអប្បនាវិថី

ទី១. ភវង្គចលនៈ ទី២. ភវង្គុបច្ឆេទ , ចិត្ត ២ នេះ ផុតវិថី បានដល់ វិបាកដែលសម្បយុត្តដោយញាណ ជាតិហេតុកវិបាកចិត្ត មានអារម្មណ៍ដើម គឺ អារម្មណ៍មុនចុតិ របស់ជាតិមុន ៗ ទី៣. មនោទ្វារាវជ្ជនៈ ជាអហេតុកកិរិយា

ចិត្ត ។ ទី៤. បរិកម្ម, ទី៥. ឧបចារ, ទី៦. អនុលោម, ទី៧. គោត្រភូ បានដល់ មហាកុសលឧបេក្ខាញាណសម្បយុត្តចិត្ត ២ ណាមួយ, ទី ៨. បឋមារូបជ្ឈាន បានដល់ អាកាសានញ្ចាយតនកុសលចិត្ត ឈាននេះ មានអាកាសបញ្ញត្តិដែលបើកចេញ ពីរូបាវចរបញ្ចមជ្ឈានជាអារម្មណ៍ ហៅថា កសិណុគ្ឃាដិមាកាសបញ្ញត្តិ ។

## ២, វិញ្ញាណញ្ចាយតនជ្ឈាន

ព្រះយោគាវចរបុគ្គល អ្នកជំនាញអាកាសានញ្ចាយតនជ្ឈានហើយ ប្រាថ្នានឹងចម្រើនអរូបជ្ឈានទី ២ ត្រូវធ្វើវសី ៥ ឱ្យជំនាញ ហើយពិចារណាឃើញទោសរបស់អាកាសានញ្ចាយតនជ្ឈាន ឃើញសេចក្តីស្ងប់ប្រណីតរបស់វិញ្ញាណញ្ចាយតនជ្ឈាន ហើយចូលឈាន នឹកយកបឋមារូបជ្ឈានជាអារម្មណ៍ ដោយបង្អោនដល់សភាពរបស់វិញ្ញាណដែលមានអាកាសមិនមានទីបំផុត ជាអារម្មណ៍ថា **"វិញ្ញាណំ**

**អនន្តំ : វិញ្ញាណ មិនមានទីបំផុត**” ដរាបដល់ឈានចិត្តកើតឡើង, អរូបជ្ឈានទី ២ ដែលនឹងកើតឡើង មានអាកាសានញ្ចាយតនចិត្តជាអារម្មណ៍ ឈ្មោះថា វិញ្ញាណញ្ចាយតនចិត្ត ឬហៅថា ទុតិយារូបជ្ឈាន ។ វិថីចិត្តដែលកើតមុនទុតិយារូបជ្ឈានចិត្តនោះ ដូចគ្នានឹងបឋមារូបជ្ឈានចិត្តនោះឯង ផ្សេងគ្នាត្រង់ពាក្យថា **វិញ្ញាណញ្ចាយតនកុសលចិត្ត** ប៉ុណ្ណោះ ។

## អធិប្បាយវិញ្ញាណញ្ចាយតនកុសលចិត្ត

**វិញ្ញាណញ្ចាយតន** មានវចនត្ថៈថា ៖

**វិញ្ញាណមេវ អនន្តំ វិញ្ញាណានន្តំ បឋមវិញ្ញាណំ** វិញ្ញាណនុ៎ះឯង មិនមានទីបំផុត ឈ្មោះថា **វិញ្ញាណានន្តំ** បានដល់ អរូបជ្ឈានទី ១ ។ ពិតមែន អរូបជ្ឈានទី ១ (អាកាសានញ្ចាយតនចិត្ត)នោះ សូម្បីមានទីបំផុតមានឧប្បាទៈជាដើម លោកក៏ពោលថា **អនន្តំ** (មិនមានទីបំផុត) ព្រោះ

ប្រព្រឹត្តទៅក្នុងអាកាសដែលមិនមានទីបំផុត និងព្រោះភាវនាដែលប្រារព្ធវិញ្ញាណប្រព្រឹត្តទៅ មិនបានកាន់យកទីបំផុតមានឧប្បាទជាដើមទេ ប្រព្រឹត្តទៅដោយអំណាចផ្សាយដោយមិនមានទីបំផុត ។

ម្យ៉ាងទៀត ឈ្មោះថា **វិញ្ញាណញ្ចំ**[1] ព្រោះអត្ថថា ដែលអរូបជ្ឈានទី ២ គប្បីដល់ គឺ គប្បីសម្រេច ។ ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ព្រោះអត្ថថា វិញ្ញាណញ្ចៈនុ៎ះឯងជាអាយតនៈ ព្រោះជាទីតាំងនៃអរូបជ្ឈានទី ២ ។

ពាក្យដែលនៅសល់ ដូចនឹងពាក្យមុន ។

---

១. វិញ្ញាណានន្តំ នុ៎ះឯង ជាវិញ្ញាណញ្ចំ គឺ វិញ្ញាណានន្តំ ចុះ ណ្យ បច្ច័យក្នុងភាវទ្ធិត = វិញ្ញាណានន្ត្យំ ; រស្សៈ អា ជា អ = វិញ្ញាណនន្ត្យំ, លុប ន = វិញ្ញាណនត្យំ ; ហើយផ្លាស់ ត្យ > ច = វិញ្ញាណន្ចំ, ផ្លាស់ ន > 0 ហើយផ្លាស់ 0 > ញ សម្រេចរូបជា វិញ្ញាណញ្ចំ ។

## ៣, អាកិញ្ចញ្ញាយតនជ្ឈាន

ព្រះយោគាវចរ អ្នកប្រាថ្នានឹងធ្វើសមាធិឱ្យរឹងមាំ ប្រណីតក្រៃលែងឡើង ដោយការចូលអាកិញ្ចញ្ញាយតនជ្ឈាន នោះ ត្រូវចូលវិញ្ញាណញ្ចាយតនជ្ឈាន ដរាបជំនាញជាវសី កាលចេញចាកឈានហើយ ពិចារណាឃើញទោសរបស់ វិញ្ញាណញ្ចាយតនជ្ឈានថា បើដាច់(មិនបានធ្វើ)ការចូល ឈាននេះជានិច្ចហើយ ឈាននេះអាចសាបសូន្យ ត្រឡប់ទៅ តាំងនៅក្នុងអាកាសានញ្ចាយតនជ្ឈាន និងសមាធិដែលកើតអំពី វិញ្ញាណញ្ចាយតនជ្ឈាននេះ ក៏នៅគ្រោតគ្រាត មិនប្រណីតស្មើ អាកិញ្ចញ្ញាយតនជ្ឈានទេ ទើបដាក់ចិត្តដល់សភាពមិនមានអ្វី របស់អរូបជ្ឈានទី ១ ជាអារម្មណ៍ ។ ប្រៀបដូចសាលាធ ម្មសភាជាទីប្រជុំរបស់ព្រះសង្ឃធ្វើសង្ឃកម្ម ជាអារម្មណ៍របស់ អរូបជ្ឈានទី ២ នោះ ឥឡូវនេះ សង្ឃធ្វើកិច្ចស្រេចហើយ ក៏ចេញទៅពីសាលានោះទាល់តែអស់មិនមានសល់ ចិត្តដែល

បង្អោនទៅក្នុងសភាព ដែលមិនមានអ្វីទៀតនោះថា **នត្ថិ កិញ្ចិ** (មិនមានអ្វីណា ៗ) ដរាបដល់អរូបជ្ឈានចិត្ត ដែលកើតដោយមាននត្ថិភាវបញ្ញត្តិ ជាអារម្មណ៍កើតឡើងនេះ ឈ្មោះថា អាកិញ្ចញ្ញាយតនជ្ឈាន ឬតតិយអរូបជ្ឈាន (អាកិញ្ចញ្ញាយតនកុសលចិត្ត) ។ វិថីចិត្តដែលកើតឡើងមុន អរូបជ្ឈាននេះ ដូចដែលពោលហើយ ។

### ៤, នេវសញ្ញានាសញ្ញាយតន

ព្រះយោគាវចរ អ្នកចម្រើនអរូបជ្ឈានទី ៤ នឹងត្រូវធ្វើអរូបជ្ឈានទី ៣ ដរាបដល់ជាវសី ហើយចម្រើនអរូបជ្ឈានទី ៤ ដែលប្រណីតជាទីបំផុតដូច្នោះ ដើម្បីចម្រើនអរូបជ្ឈានទី ៤ ទើបចូលអរូបជ្ឈានទី ៣ ចេញហើយដាក់ចិត្តពិចារណាសេចក្ដីស្ងប់ប្រណីត **ឯតំ សន្តំ ឯតំ បណីតំ** របស់សញ្ញាក្នុងអាកិញ្ចញ្ញាយតនជ្ឈាន មិនមែនសញ្ញាដទៃ ៗ (វេទនាជា

ដើមក្នុងទីនេះ ក៏ស្ងប់ប្រណីតដូចគ្នា ការប្រើសញ្ញាស័ព្ទ ព្រោះសញ្ញាចេតសិកនេះ ចងចាំនិមិត្តតាំងពីផ្ដើមចម្រើនរូបជ្ឈាន) ចម្រើនដរាបដល់អរូបជ្ឈានទី ៤ នឹងកើត កាលឈានេះកើត ក៏ឈ្មោះថា នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ។

លោកដីកាចារ្យ ពោលអរូបជ្ឈានទី ៤ នេះ ទុក ២ ន័យ គឺ

ន័យទី ១ អរូបជ្ឈានទី ៤ នេះ ព្រមទាំងសម្បយុត្តធម៌ ឈ្មោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ព្រោះមិនមានសញ្ញាគ្រោតគ្រាត មានតែសញ្ញាល្អិត ។ នេវសញ្ញានាសញ្ញានុ៎ះឯង ជាអាយតនៈ ព្រោះរាប់បញ្ចូលក្នុងមនាយតនៈ និងធម្មាយតនៈ ព្រោះហេតុនោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញាយតនៈ ។

ន័យទី ២ សញ្ញានុ៎ះឯង ឈ្មោះថា សញ្ញា ក៏មិន

មែន ព្រោះមិនមានកិច្ចនៃសញ្ញាដែលច្បាស់លាស់ ពោលគឺឱ្យកើតនិព្វេធបញ្ញា កុសលចិត្ត និងឈ្មោះថា មិនជាសញ្ញាក៏មិនមែន ព្រោះនៅមានដោយសភាពជាធម៌ល្អិត ប្រៀបដូចតេជោធាតុ ក្នុងទឹកក្តៅដូច្នោះ[1] ព្រោះហេតុនោះ ទើបលោកពោលថា នេវសញ្ញានាសញ្ញា ។ នេវសញ្ញានាសញ្ញានុ៎ះឯងជាអាយតនៈនៃឈាន ព្រមទាំងសម្បយុត្តធម៌ ដោយនិស្សយប្បច្ច័យជាដើម ដូច្នោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ វិថីចិត្តដែលកើតឡើងមុនអរូបជ្ឈានទី ៤ នេះ ដូចដែលពោលហើយ ។

## ចប់ អរូបាវចរកុសលចិត្ត

១. ទឹកនោះថា មានភ្លើងក៏បានព្រោះអាចរលាក, ថា មិនមានក៏បានព្រោះមិនអាចដុតអ្វីឱ្យឆេះបាន ។

## អរូបាវចរវិបាកចិត្ត ៤

អរូបាវចរវិបាកចិត្ត ជាផលរបស់អរូបាវចរកុសលចិត្ត គឺ អាកាសានញ្ចាយតនកុសលចិត្ត មានអាកាសមិនមានទីបំផុតជាអារម្មណ៍ អាកាសានញ្ចាយតនវិបាកចិត្ត ក៏មានអាកាសមិនមានទីបំផុតជាអារម្មណ៍ដូចគ្នា សូម្បីអរូបជ្ឈានទី ២ ជាដើម ក៏ន័យនេះឯង ។

## អរូបាវចរវិបាកចិត្ត ៤ គឺ

១-អាកាសានញ្ចាយតនវិបាកចិត្តំ

២-វិញ្ញាណញ្ចាយតនវិបាកចិត្តំ

៣-អាកិញ្ចញ្ញាយតនវិបាកចិត្តំ

៤-នេវសញ្ញានាសញ្ញាយតនវិបាកចិត្តំ

កាលអរូបាវចរវិបាកចិត្តណាមួយ ដែលនឹងត្រូវកើតនោះ មិនបានកើតជាវិថីដូចអរូបាវចរកុសលចិត្ត គឺ មុននឹង

ចុតិចិត្តកើតឡើងនោះ អរូបាវចរកុសលចិត្តណាមួយកើតឡើងមុនហើយ ទើបចុតិ កាលចុតិរលត់ហើយ អរូបាវចរវិបាកចិត្តណាមួយ ក៏កើតឡើងធ្វើកិច្ចបដិសន្ធិ បន្ទាប់ពីចុតិនោះភ្លាម អរូបាវចរកុសលចិត្ត មុនចុតិមានអារម្មណ៍អ្វី អរូបាវចរវិបាកចិត្តដែលកើតតពីចុតិចិត្តនោះ ក៏មានអារម្មណ៍ដូចកុសលរបស់ខ្លួន ដោយន័យនោះឯងទាំង ៤ ។

បណ្តាអរូបភូមិទាំង ៤ នេះ អរូបព្រហ្មបុគ្គលក្នុងអាកាសានញ្ចាយតនភូមិ មានអាយុ ២០.០០០ មហាកប្បក្នុងវិញ្ញាណញ្ចាយតនភូមិ មានអាយុ ៤០.០០០ មហាកប្បក្នុងអាកិញ្ចញ្ញាយតនភូមិ មានអាយុ ៦០.០០០ មហាកប្បក្នុងនេវសញ្ញានាសញ្ញាយតនភូមិ មានអាយុ ៨៤.០០០ មហាកប្ប ។

**ចប់ អរូបាវចរវិបាកចិត្ត**

## អរូបាវចរកិរិយាចិត្ត ៤

១-អាកាសានញ្ចាយតនកិរិយាចិត្តំ

២-វិញ្ញាណញ្ចាយតនកិរិយាចិត្តំ

៣-អាកិញ្ចញ្ញាយតនកិរិយាចិត្តំ

៤-នេវសញ្ញានាសញ្ញាយតនកិរិយាចិត្តំ

អរូបាវចរកិរិយាចិត្ត ៤ នេះ កើតដល់ព្រះអរហន្ត ប៉ុណ្ណោះ បុថុជ្ជនក្តី ព្រះសេក្ខបុគ្គល ៧ ក្តី ចម្រើនអរូបជ្ឈាន ៤ អរូបជ្ឈានចិត្តនេះ រមែងជាកុសល មិនជាអរូបាវចរកិរិយាចិត្ត ចំណែកព្រះអរហន្តចម្រើន ទើបហៅថា អរូបាវចរកិរិយាចិត្តផ្សេងគ្នាដោយបុគ្គល សូម្បីអារម្មណ៍ក៏ប្រព្រឹត្តទៅដូចនឹងអរូបាវចរកុសលចិត្ត កាលអរូបាវចរចិត្តរបស់ព្រះអរហន្តកើត វិថីចិត្តដែលកើតឡើងមុនមានសភាពដូច្នេះ ៖

១. ភវង្គចលនៈ ⎫
២. ភវង្គុបច្ឆេទ ⎭ ចិត្តផុតវិថី

៣. មនោទ្វារាវជ្ជនៈ

៤. បរិកម្ម
៥. ឧបចារ មហាកិរិយាឧបេក្ខា
៦. អនុលោម ញាណសម្បយុត្តចិត្ត ២
៧. គោត្រភូ

៨. អរូបាវចរកិរិយាចិត្ត

ភវង្គបាត ចិត្តជាភវង្គ

វិថីចិត្តនេះសម្រាប់មនុស្សបុគ្គល ឯតិក្ខបុគ្គលមិនមាន បរិកម្ម ។

## ចែកអរូបាវចរចិត្ត ១២ ដោយន័យផ្សេង ៗ គឺ

១. ដោយជាតិ ជាកុសលជាតិ ៤ ជាវិបាកជាតិ ៤ ជាកិរិយាជាតិ ៤

២. ដោយភូមិ ជាអរូបាវចរភូមិ (កុសល កិរិយា បាន ២៦ ភូមិ)

៣. ដោយវេទនា ជាឧបេក្ខាវេទនា

៤. ដោយហេតុ ជាទហេតុ និងជាតិហេតុកចិត្ត

៥. ដោយសម្បយុត្ត ជាញាណសម្បយុត្ត

៦. ដោយសង្ខារ ជាសសង្ខារិក

៧. ដោយសោភណ ជាអរូបាវចរសោភណចិត្ត

៨. ដោយឈាន ជាបញ្ចមជ្ឈានចិត្ត (បញ្ចកន័យ)

៩. ដោយលោក ជាលោកិយចិត្ត

១០. ដោយកិច្ច អរូបាវចរកុសល ៤ កិរិយា ៤ ធ្វើជវនកិច្ច, អរូបាវចរវិបាក ធ្វើកិច្ច ៣ គឺ

បដិសន្ធិ ភវង្គ ចុតិ

១១. **ដោយអារម្មណ៍** មានធម្មារម្មណ៍ជាអារម្មណ៍

១២. **ដោយទ្វារ** អរូបាវចរកុសល៤ កិរិយា៤ ដឹងអារម្មណ៍ តាមមនោទ្វារ, អរូបាវចរវិបាក ៤ មិនអាស្រ័យទ្វារ

១៣. **ដោយវត្ថុ** អរូបាវចរកុសល ៤ កិរិយា ៤ ដែលកើតក្នុងបញ្ចវោការភូមិអាស្រ័យហទយវត្ថុ, បើកើតក្នុងអរូបព្រហ្មបុគ្គល មិនមានវត្ថុអាស្រ័យ, អរូបាវចរវិបាក ៤ មិនអាស្រ័យវត្ថុ

១៤. **ដោយវិញ្ញាណធាតុ** ជាមនោវិញ្ញាណធាតុ

## បាលីពាក្យនិគម

ឥច្ចេវំ សព្វថាបិ ទ្វាទស អរូបាវចរកុសលវិបាកក្រិយាចិត្តានិ សមត្តានិ ៖ អរូបាវចរកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត រួម ១២ សូម្បីដោយប្រការទាំងពួង ចប់បរិបូរណ៍ហើយ ដោយប្រការដូច្នេះ ។

## សរុបមហគ្គតចិត្ត ២៧

- មហគ្គតចិត្ត ២៧
  - រូបាវចរចិត្ត ១៥
    - រូបាវចរកុសល ៥
    - រូបាវចរវិបាក ៥
    - រូបាវចរកិរិយា ៥
  - អរូបាវចរចិត្ត ១២
    - អរូបាវចរកុសល៤
    - អរូបាវចរវិបាក ៤
    - អរូបាវចរកិរិយា៤

**អរូបាវចរចិត្ត ១២ ចប់**

# លោកុត្តរសោភណចិត្ត

ពាក្យថា *លោកុត្តរៈ* គឺ លោក + ឧត្តរ ប្រែថា លើលោក ឬផុតលោក ។ **លោកុត្តរ** + **កុសល** + **ចិត្តំ** ជា **លោកុត្តរកុសលចិត្តំ** ប្រែថា កុសលដែលលើលោក ឬផុតចាកលោក មានព្រះនិព្វានជាអារម្មណ៍ បរមត្ថធម៌ដទៃ ៗ ក្រៅអំពីព្រះនិព្វាន រមែងកើតរលត់ ចំណែកព្រះនិព្វានជាធម៌ដែលមិនកើតរលត់ ចិត្តទាំងឡាយ សូម្បីជាលោកុត្តរកុសលចិត្ត ក៏ត្រូវកើតរលត់ ព្រោះសភាពរបស់ចិត្តទាំងអស់ ជាសង្ខតធម៌ (ធម៌ដែលមានបច្ច័យតាក់តែង) និព្វានជាអសង្ខធម៌ (ធម៌មិនមានបច្ច័យតាក់តែង) និងជាអសង្ខតធាតុ (ធាតុដែលមិនមានបច្ច័យតាក់តែង) ដូច្នោះ និព្វានទើបមិនកើតរលត់ ។

## សង្គហគាថា លោកុត្តរចិត្ត ៨

១០ ចតុមគ្គប្បភេទេន ចតុធា កុសលន្តថា
បាកន្តស្ស ផលត្តាតិ អដ្ឋធានុត្តរំ មតំ ។

*អនុត្តរចិត្ត ( លោកុត្តរចិត្ត ) បណ្ឌិតពោលទុក ៨ ប្រភេទ គឺ កុសលចិត្ត ៤ យ៉ាង ដោយប្រភេទនៃមគ្គ. វិបាកចិត្តក៏មាន ៤ យ៉ាង ព្រោះជាផលរបស់កុសលនោះ ។*

### លោកុត្តរសោភណចិត្ត ៨ មាន ២ ប្រភេទ គឺ

*លោកុត្តរកុសលចិត្ត ៤ លោកុត្តរវិបាកចិត្ត ៤*

### លោកុត្តរកុសលចិត្ត ៤

១- *សោតាបត្តិមគ្គចិត្តំ* សោតាបត្តិមគ្គចិត្ត
២- *សកទាគាមិមគ្គចិត្តំ* សកទាគាមិមគ្គចិត្ត
៣- *អនាគាមិមគ្គចិត្តំ* អនាគាមិមគ្គចិត្ត

៤- **អរហត្តមគ្គចិត្តំ** អរហត្តមគ្គចិត្ត

**ឥមានិ ចត្តារិបិ លោកុត្តរកុសលចិត្តានិ នាម**

ចិត្តទាំង ៤ នេះ ឈ្មោះថា លោកុត្តរកុសលចិត្ត ។

## អធិប្បាយ

### ១-សោតាបត្តិមគ្គចិត្ត

ពាក្យថា សោតាបត្តិមគ្គចិត្ត គឺ **សោត** + **អាបត្តិ** + **មគ្គ** + **ចិត្ត** ។

**សោត** : ក្រសែ, **អាបត្តិ** : ការសម្រេចដល់,

**មគ្គ** : មគ្គ (ស្វែងរកព្រះនិព្វាន), **ចិត្ត** : ចិត្ត ។

**សោតាបត្តិមគ្គចិត្ត** មាន ២ ន័យ

ន័យទី ១ មានវចនត្ថៈថា ៖

**និព្វានម្បត្តិសវនតោ ឧបគមនតោ និព្វានមហាសមុទ្ទនិន្នតាយ សោតសទិសត្តា វា សោតោតិ វុច្ចតិ = អរិយោ អដ្ឋង្គិកោ មគ្គោ** អរិយមគ្គប្រកបដោយអង្គ ៨

បណ្ឌិតហៅថា សោតៈ(ក្រសែ) ព្រោះហូរតម្រង់ទៅ គឺចូលដល់ ព្រះនិព្វាន ឬដូចក្រសែទឹក ព្រោះការហូរទៅកាន់មហាសមុទ្រ គឺ ព្រះនិព្វាន ។

ពាក្យថា អាបត្តិ ប្រែថា ការដល់ គឺ សម្រេចតាំងពីខាងដើម ជាការសមាគមដំបូងនូវសោតៈនោះ ព្រោះដូច្នោះទើបឈ្មោះថា សោតាបត្តិ ព្រោះឧបសគ្គប្រព្រឹត្តទៅក្នុងកម្មជាដើម ។ ឈ្មោះថា មគ្គ ព្រោះអត្ថថា ស្វែងរកព្រះនិព្វាន ឬអ្នកត្រូវការព្រះនិព្វាន ស្វែងរកហើយ ឬព្រោះអត្ថថា សម្លាប់កិលេសទាំងឡាយទៅ ។ ចិត្តដែលសម្បយុត្តដោយមគ្គនោះ ឈ្មោះថា មគ្គចិត្ត ។ មគ្គចិត្តដែលសម្រេចក្រសែគ្រាដំបូង ឈ្មោះថា សោតាបត្តិមគ្គចិត្ត ។

មួយទៀត បុគ្គលឈ្មោះថា សោតាបត្តិ ព្រោះអត្ថថា មានការដល់ក្រសែគ្រាដំបូង ។ មគ្គរបស់បុគ្គលដែលដល់ក្រសែគ្រាដំបូងនោះ ឈ្មោះថា សោតាបត្តិមគ្គ ។ ចិត្តដែលសម្បយុត្តដោយមគ្គនោះ ឈ្មោះថា សោតាបត្តិមគ្គចិត្ត ។

### ២-សកទាគាមិមគ្គចិត្ត

ពាក្យថា **សកទាគាមិមគ្គចិត្ត** គឺ **សកឹ** + **អាគាមី** + **មគ្គ** + **ចិត្តំ** ។ **សកឹ** : មួយគ្រា មួយដង, **អាគាមី** : ត្រឡប់មក, **មគ្គ** : មគ្គ, **ចិត្តំ** : ចិត្ត ។

បានដល់ ចិត្តដែលត្រឡប់មកបដិសន្ធិក្នុងមនុស្សភូមិម្តងទៀត ឈ្មោះថា សកទាគាមី ។

<u>ក្នុងដីកា</u> ពោលទុកថា ៖

**សកឹ ឯកវារំ បដិសន្ធិវសេន ឥមំ មនុស្សលោកំ អាគច្ឆតីតិ** = **សកទាគាមី** ឈ្មោះថា សកទាគាមី ព្រោះអត្ថថា មកកាន់មនុស្សលោកនេះ ដោយអំណាចបដិសន្ធិម្តងទៀត គឺ តែមួយវារៈ ។ មគ្គរបស់សកទាគាមីនោះ ឈ្មោះថា សកទាគាមិមគ្គ ។ ចិត្តដែលសម្បយុត្តដោយសកទាគាមិមគ្គនោះ ឈ្មោះថា សកទាគាមិមគ្គចិត្ត ។

ក្នុងទីនេះ លោកប្រាថ្នាយកសកទាគាមី ប្រភេទទី ៥

ដែលសម្រេចជាសកទាគាមីក្នុងមនុស្សលោកហើយ កើតក្នុងទេវលោក ចុតិចាកទេវលោកហើយ មកកើតក្នុងមនុស្សលោកនេះ ទើបសម្រេចជាព្រះអរហត្ត បរិនិព្វានក្នុងមនុស្សលោកនេះ ។

### ៣-អនាគាមិមគ្គចិត្ត

ពាក្យថា អនាគាមិមគ្គចិត្ត គឺ **ន** + **អាគាមិ** + **មគ្គ** + **ចិត្ត** ; **ន** ប្រែថា មិន, **អាគាមិ** ប្រែថា ត្រឡប់មក, បានដល់ ចិត្តដែលមិនត្រឡប់មកកាន់កាមធាតុ ដោយអំណាចបដិសន្ធិ ។

មានវចនត្ថៈថា **បដិសន្ធិវសេន ឥមំ កាមធាតុំ ន អាគច្ឆតីតិ = អនាគាមី** ឈ្មោះថា អនាគាមី ព្រោះអត្ថថា មិនមកកាន់កាមធាតុ ដោយអំណាចបដិសន្ធិ ។ មគ្គរបស់ព្រះអនាគាមីនោះ ឈ្មោះថា អនាគាមិមគ្គ ។ ចិត្តដែលសម្បយុត្តដោយអនាគាមិមគ្គនោះ ឈ្មោះថា អនាគាមិមគ្គចិត្ត ។

### ៤-អរហត្តមគ្គចិត្ត

ពាក្យថា អរហត្តមគ្គចិត្ត គឺ អរហត្ត + មគ្គ + ចិត្ត មានវិគ្រោះថា **អគ្គទក្ខិណេយ្យភាវេន បូជាវិសេសំ អរហតីតិ = អរហា** ឈ្មោះថា ព្រះអរហន្ត ព្រោះអត្ថថា គួរដល់ការបូជាពិសេស ព្រោះជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ។ ម្យ៉ាងទៀត ឈ្មោះថា អរហន្ត ព្រោះអត្ថថា កាំ គឺ កិលេស ឬកិលេសដែលជាកាំនៃសង្សារចក្រ ត្រូវលោកកាច់ចេញហើយ ។ ម្យ៉ាងទៀត ឈ្មោះថា អរហន្ត ព្រោះមិនមានការបិទបាំងក្នុងការធ្វើបាប បានដល់ ព្រះអរិយបុគ្គលទី ៨ ។ ភាវៈនៃបុគ្គលទី ៨ នោះ ឈ្មោះថា អរហត្ត ។ ពាក្យថា អរហត្តនោះ ជាឈ្មោះនៃផលទី ៤ ។ មគ្គដែលជាហេតុនៃព្រះអរហត្តនោះ ឈ្មោះថា អរហត្តមគ្គ ។ ចិត្តដែលសម្បយុត្តដោយអរហត្តមគ្គនោះ ឈ្មោះថា អរហត្តមគ្គចិត្ត (មានពិស្តារក្នុងសច្ចវិភង្គ) ។

## សម្ដែងលោកុត្តរកុសលចិត្ត ៤ ឬ ២០

១. សោតាបត្តិមគ្គចិត្ត ៥
- បឋមជ្ឈានសោតាបត្តិមគ្គចិត្ត១
- ទុតិយជ្ឈានសោតាបត្តិមគ្គចិត្ត១
- តតិយជ្ឈានសោតាបត្តិមគ្គចិត្ត១
- ចតុត្ថជ្ឈានសោតាបត្តិមគ្គចិត្ត១
- បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្ត១

២. សកទាគាមិមគ្គចិត្ត ៥
- បឋមជ្ឈានសកទាគាមិមគ្គចិត្ត១
- ទុតិយជ្ឈានសកទាគាមិមគ្គចិត្ត១
- តតិយជ្ឈានសកទាគាមិមគ្គចិត្ត១
- ចតុត្ថជ្ឈានសកទាគាមិមគ្គចិត្ត១
- បញ្ចមជ្ឈានសកទាគាមិមគ្គចិត្ត១

៣. អនាគាមិមគ្គចិត្ត ៥
- បឋមជ្ឈានអនាគាមិមគ្គចិត្ត១
- ទុតិយជ្ឈានអនាគាមិមគ្គចិត្ត១
- តតិយជ្ឈានអនាគាមិមគ្គចិត្ត១
- ចតុត្ថជ្ឈានអនាគាមិមគ្គចិត្ត១
- បញ្ចមជ្ឈានអនាគាមិមគ្គចិត្ត១

៤. អរហត្តមគ្គចិត្ត ៥
- បឋមជ្ឈានអរហត្តមគ្គចិត្ត១
- ទុតិយជ្ឈានអរហត្តមគ្គចិត្ត១
- តតិយជ្ឈានអរហត្តមគ្គចិត្ត១
- ចតុត្ថជ្ឈានអរហត្តមគ្គចិត្ត១
- បញ្ចមជ្ឈានអរហត្តមគ្គចិត្ត១

**លោកុត្តរកុសលចិត្ត ចប់**

## លោកុត្តរវិបាកចិត្ត ៤

១, សោតាបត្តិផលចិត្តំ សោតាបត្តិផលចិត្ត

២, សកទាគាមិផលចិត្តំ សកទាគាមិផលចិត្ត

៣, អនាគាមិផលចិត្តំ អនាគាមិផលចិត្ត

៤, អរហត្តផលចិត្តំ អរហត្តផលចិត្ត

ឥមានិ ចត្តារិបិ លោកុត្តរវិបាកចិត្តានិ នាម

ចិត្តទាំង ៤ នេះ ឈ្មោះថា លោកុត្តរវិបាកចិត្ត ។

## សម្តែងលោកុត្តរវិបាកចិត្ត ៤ ឬ ២០

១. សោតាបត្តិផលចិត្ត ៥
- បឋមជ្ឈានសោតាបត្តិផលចិត្ត១
- ទុតិយជ្ឈានសោតាបត្តិផលចិត្ត១
- តតិយជ្ឈានសោតាបត្តិផលចិត្ត១
- ចតុត្ថជ្ឈានសោតាបត្តិផលចិត្ត១
- បញ្ចមជ្ឈានសោតាបត្តិផលចិត្ត១

២. សកទាគាមិផលចិត្ត ៥
- បឋមជ្ឈានសកទាគាមិផលចិត្ត១
- ទុតិយជ្ឈានសកទាគាមិផលចិត្ត១
- តតិយជ្ឈានសកទាគាមិផលចិត្ត១
- ចតុត្ថជ្ឈានសកទាគាមិផលចិត្ត១
- បញ្ចមជ្ឈានសកទាគាមិផលចិត្ត១

៣. អនាគាមិផលចិត្ត ៥
- បឋមជ្ឈានអនាគាមិផលចិត្ត១
- ទុតិយជ្ឈានអនាគាមិផលចិត្ត១
- តតិយជ្ឈានអនាគាមិផលចិត្ត១
- ចតុត្ថជ្ឈានអនាគាមិផលចិត្ត១
- បញ្ចមជ្ឈានអនាគាមិផលចិត្ត១

៤. អរហត្តផលចិត្ត ៥
- បឋមជ្ឈានអរហត្តផលចិត្ត១
- ទុតិយជ្ឈានអរហត្តផលចិត្ត១
- តតិយជ្ឈានអរហត្តផលចិត្ត១
- ចតុត្ថជ្ឈានអរហត្តផលចិត្ត១
- បញ្ចមជ្ឈានអរហត្តផលចិត្ត១

**លោកុត្តរវិបាកចិត្ត ចប់**

## បាលីពាក្យនិគម

***ឥច្ចេវំ សព្វថាបិ អដ្ឋ លោកុត្តរកុសលវិបាកចិត្តានិ សមត្តានិ*** **:** លោកុត្តរកុសលចិត្ត និងលោកុត្តរវិបាកចិត្ត ចប់បរិបូណ៌ហើយ សូម្បីដោយប្រការទាំងពួង យ៉ាងដូច្នេះ ។

ក្នុងគាថាទី១០នេះ ព្រះដីកាចារ្យអធិប្បាយថា ៖

ពាក្យថា **ចតុមគ្គប្បភេទេន** ( ដោយប្រភេទនៃមគ្គ ៤ )

អធិប្បាយ លោកុត្តរចិត្ត ដែលឈ្មោះថា អនុត្តរចិត្ត ព្រោះមិនមានចិត្តដទៃក្រៃលែងជាង លោកពោលទុក ៨ ប្រការ គឺលោកុត្តរកុសល ពោលគឺ មគ្គចិត្ត ៤ ដោយសេចក្តីផ្សេងគ្នានៃការប្រកបរបស់អដ្ឋង្គិកមគ្គ មានសោតាបត្តិមគ្គជាដើម ដោយអំណាចការលះសញ្ញោជនៈបានយ៉ាងនេះ គឺ ៖

សោតាបត្តិមគ្គ លះសញ្ញោជនៈ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាស ដោយសមុច្ឆេទប្បហានៈ ។

សកទាគាមិមគ្គ លះសញ្ញោជនៈដោយតនុកប្បហានៈ គឺ ធ្វើកាមរាគៈ និងព្យាបាទៈ ឱ្យស្រាលចុះ ។

អនាគាមិមគ្គ លះសញ្ញោជនៈ បាន ២ គឺ កាមរាគៈ និងព្យាបាទៈ ដោយសមុច្ឆេទប្បហានៈ ។

អរហត្តមគ្គ លះសញ្ញោជនៈដែលនៅសល់ពីមគ្គខាងក្រោមបានលះហើយ គឺ រូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ និងអវិជ្ជា ដោយសមុច្ឆេទប្បហានៈ ។

ការដែលមគ្គទាំង ៤ លះសញ្ញោជនៈ បានផ្សេងគ្នា

ព្រោះឥន្ទ្រិយ ៥ មានសទ្ធាជាដើម មានកម្លាំងផ្សេងគ្នា គឺ ឥន្ទ្រិយ ៥ របស់សោតាបត្តិមគ្គ មិនទាន់ចាស់ក្លារបស់ សកទាគាមិមគ្គចាស់ក្លា របស់អនាគាមិមគ្គចាស់ក្លាជាង របស់ អរហត្តមគ្គចាស់ក្លាបំផុត ។

មួយទៀត លោកុត្តរវិបាក ក៏មាន ៤ ប្រការ ព្រោះជា ផលរបស់កុសលនោះ ៗ ។

លោកុត្តរចិត្តនោះ មិនមានកិរិយាចិត្តទាំងនេះ ព្រោះមគ្គចិត្ត កើតឡើងម្តង ក៏ប្រហារកិលេសបានដាច់អស់ ប្រៀបដូច អសនីបាត(រន្ទះ)កំចាត់រុក្ខជាតិព្រមទាំងឫស ដូច្នោះ មគ្គចិត្ត ដែលកើតឡើងប្រហារកិលេសហើយនេះ នឹងមិនកើតឡើងជា លើកទី ២ ទៀតទេ ចំណែកផលចិត្តអាចកើតបានច្រើនដង គឺ ជាផលសម្បត្តិដែលមានព្រះនិព្វានជាអារម្មណ៍ ក៏ដើម្បី ការនៅជាសុខក្នុងភពបច្ចុប្បន្ន ព្រោះដូច្នោះ លោកុត្តរចិត្តដែល ជាកិរិយាមិនមាន សូម្បីដោយប្រការទាំងពួង ។

## អកុសលធម៌ ៩ កង

អកុសលធម៌ គឺ ធម៌ដែលជាអកុសល ដែលព្រះអរិយបុគ្គលគប្បីលះ (ប្រហារ)ដោយផ្ដាច់អស់ មាន ៩ ប្រភេទ គឺ ៖

១. **អាសវៈ** ធម៌ដែលដេកត្រាំនៅក្នុងសន្ដាន មាន៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ និងអវិជ្ជាសវៈ

២. **ឱឃៈ** ធម៌ដែលប្រៀបដូចអន្លង់ទឹកញ៉ាំងសត្វឱ្យលិចចុះក្នុងវដ្ដៈ មាន ៤ គឺ កាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ និងអវិជ្ជោឃៈ

៣. **យោគៈ** ធម៌ដែលប្រកបសត្វទុកក្នុងភូមិភព មាន ៤ គឺ កាមយោគៈ ភវយោគៈ ទិដ្ឋិយោគៈ និងអវិជ្ជាយោគៈ

៤. **គន្ថៈ** ធម៌ជាគ្រឿងចងសត្វទុកមាន ៤ គឺ អភិជ្ឈាកាយគន្ថៈ ព្យាបាទកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ និង

ឥទំសច្ចាភិនិវេសកាយគន្ថៈ

៥. **ឧបាទាន** ធម៌ជាគ្រឿងប្រកាន់មាំ មាន ៤ គឺ កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន និងអត្តវាទុបាទាន

៦. **នីវរណៈ** ធម៌ជាគ្រឿងរាំងអំពើល្អ មាន ៦ យ៉ាង គឺ កាមឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា និង អវិជ្ជា ។

៧. **អនុសយៈ** ធម៌ដែលដេកសម្ងំនៅក្នុងសន្តាន មាន ៧ គឺ កាមរាគានុស័យ ភវរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ និងអវិជ្ជានុស័យ

៨. **សញ្ញោជនៈ** ធម៌ជាគ្រឿងរួបរឹតសត្វទុក មាន ១០ គឺ កាមរាគៈ ភវរាគៈ មានះ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ឥស្សា មច្ឆរិយៈ បដិឃៈ និងអវិជ្ជា

៩. **កិលេស** ធម៌ជាគ្រឿងសៅហ្មង មាន ១០ គឺ

លោភៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ

## មគ្គចិត្តទម្លាយអកុសលធម៌ ៩ កង

១. *សោតាបត្តិមគ្គចិត្ត* ទម្លាយនូវទិដ្ឋាសវៈ, ទិដ្ឋោឃៈ, ទិដ្ឋិយោគៈ, សីលព្វតបរាមាសកាយគន្ថៈ និង ឥទំសច្ចាភិនិវេសកាយគន្ថៈ, ទិដ្ឋុបាទាន សីលព្វតុបាទាន និង អត្តវាទុបាទាន, វិចិកិច្ឆានីវរណៈ កុក្កុច្ចនីវរណៈ(យ៉ាងគ្រោតគ្រាត), ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ, ទិដ្ឋិសញ្ញោជនៈ វិចិកិច្ឆាសញ្ញោជនៈ សីលព្វតបរាមាសសញ្ញោជនៈ ឥស្សាសញ្ញោជនៈ មច្ឆរិយសញ្ញោជនៈ, មិច្ឆាទិដ្ឋិកិលេស និងវិចិកិច្ឆាកិលេស ។

២. ***សកទាគាមិមគ្គចិត្ត*** ទម្លាយនូវអកុសលធម៌យ៉ាងគ្រោតគ្រាត ដែលនៅសល់អំពីបឋមមគ្គទម្លាយហើយនោះឱ្យស្រាលចុះ (តនុកប្បហាន) ។

៣. ***អនាគាមិមគ្គចិត្ត*** ទម្លាយនូវកាមាសវៈ កាមោឃៈ កាមយោគៈ ព្យាបាទកាយគន្ថៈ កាមច្ឆន្ទនីវរណៈ កាមរាគា

នុស័យ បដិឃានុស័យ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ ទោសកិលេស ។

៤. **អរហត្តមគ្គចិត្ត** ទម្លាយអកុសលធម៌ដែលនៅសល់ពីមគ្គខាងក្រោម៣ ដែលមិនទាន់បានលះនោះ ឱ្យអស់ទៅ ។

## មគ្គចិត្តលះអកុសលកម្មបថ១០

១. **សោតាបត្តិមគ្គចិត្ត** លះបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារៈ មុសាវាទ មិច្ឆាទិដ្ឋិ

២. **សកទាគាមិមគ្គចិត្ត** លះអកុសលកម្មបថគ្រោតគ្រាតដែលនៅសល់អំពីបឋមមគ្គលះហើយ ដោយតនុកប្បហាន

៣. **អនាគាមិមគ្គចិត្ត** លះបិសុណាវាទ ផរុសវាទ និងព្យាបាទៈ

៤. **អរហត្តមគ្គចិត្ត** លះសម្ផប្បលាបៈ និងអភិជ្ឈា

## សោតាបន្ន ៣ ប្រភេទ

**១. ឯកពីជីសោតាបន្ន** គឺ ព្រះសោតាបន្នដែលមានពូជកំណើតមួយជាតិទៀត គឺ កើតឡើងម្តងទៀត ក៏សម្រេចអរហត្តហើយបរិនិព្វាន ។

មានវចនត្ថៈថា **ឯកំ ពីជំ អស្សាតិ = ឯកពីជី** ឈ្មោះថា ឯកពីជី ព្រោះអត្ថថា មានពីជៈ (កំណើត)ការកើតតែមួយជាតិទៀត ។

**២. កោលង្កោលសោតាបន្ន** គឺ ព្រះសោតាបន្នដែលត្រូវកើត ២-៦ ជាតិទៀត ទើបបរិនិព្វាន ។

មានវចនត្ថៈថា ៖ **កុលតោ កុលំ គច្ឆតីតិ កោលង្កោលោ** ឈ្មោះថា កោលង្កោល ព្រោះអត្ថថា ទៅកាន់ត្រកូលចាកត្រកូល

**៣. សត្តក្ខត្តុបរមសោតាបន្ន** គឺ ព្រះសោតាបន្នដែលត្រូវកើតទៀតមិនលើសពី ៧ ជាតិ ហើយបរិនិព្វាន ។

មានវចនត្ថៈថា **សត្តក្ខត្តុបរមំ អស្សាតិ = សត្តក្ខត្តុបរមោ** ដែលឈ្មោះថា សត្តក្ខត្តុបរមៈ ព្រោះអត្ថថា មាន ៧ ជាតិ ជាយ៉ាងក្រៃលែង ។

<u>**ក្នុងអដ្ឋកថានៃបុគ្គលប្បញ្ញត្តិ**</u> ពោលថា ៖

ព្រះសោតាបន្ន មានអធ្យាស្រ័យត្រេកអរ ពេញចិត្តក្នុងវដ្តៈ នឹងកើតក្នុងទេវលោក ហើយនឹងតាំងនៅក្នុងអកនិដ្ឋភព បរិនិព្វានក្នុងភពនោះ ។

**សត្តក្ខត្តុបរមបុគ្គល មាន ៧ អង្គ គឺ**

១. អនាថបិណ្ឌិកសេដ្ឋី ២. ឧបាសិកាវិសាខា

៣. ចូឡរថទេវបុត្រ ៤. មហារថទេវបុត្រ

៥. អនេកវណ្ណទេវបុត្រ ៦. សក្កទេវរាជ

៧. នាគទត្តទេវបុត្រ

<u>**គាថាធម្មបទ**</u> សរសើរព្រះសោតាបន្នថា ៖

បថព្យា ឯករជ្ជេន សគ្គស្ស គមនេន វា

**សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។**

*សោតាបត្តិផល ជាគុណជាតដ៏ប្រសើរជាងភាពនៃឯករាជ្យលើផែនដីផង ជាងដំណើរទៅកាន់ស្ថានសួគ៌ផង ជាងភាពជាធំក្នុងលោកទាំងមូលផង ។*[1]

## សកទាគាមី មាន ៥ ប្រភេទ

១. **ឥធ បត្វា ឥធ បរិនិព្វាយី** *ព្រះសកទាគាមីដែលសម្រេចក្នុងមនុស្សនេះ ហើយបរិនិព្វានក្នុងមនុស្សលោកនេះ*

២. **តត្ថ បត្វា តត្ថ បរិនិព្វាយី** *ព្រះសកទាគាមីដែលសម្រេចក្នុងទេវលោកនោះ ហើយបរិនិព្វានក្នុងទេវលោកនោះ*

៣. **ឥធ បត្វា តត្ថ បរិនិព្វាយី** *ព្រះសកទាគាមីដែលសម្រេចក្នុងមនុស្សលោកនេះ ហើយបរិនិព្វានក្នុងទេវលោកនោះ*

៤. **តត្ថ បត្វា ឥធ បរិនិព្វាយី** *ព្រះសកទាគាមីដែលសម្រេច*

---

១. ខុទ្ទ. ធម្ម. លោកវគ្គ. ៥២. ២៣/៥៩ ។

ក្នុងទេវលោកនោះ ហើយមកបរិនិព្វានក្នុងមនុស្សលោកនេះ

៥. **ឥធ បត្វា តត្ថ និព្វត្តិត្វា ឥធ បរិនិព្វាយី** ព្រះសកទាគាមី ដែលសម្រេចក្នុងមនុស្សលោកនេះ ទៅកើតក្នុងទេវលោកនោះហើយ ចុតិចាកទេវលោកហើយ មកកើតក្នុងមនុស្សលោកនេះ ទើបបរិនិព្វានក្នុងលោកនេះ ។

## ព្រះអនាគាមី ៥ ប្រភេទ

១. ***អន្តរាបរិនិព្វាយី*** បានដល់ ព្រះអនាគាមីដែលបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយ ហើយបរិនិព្វានក្នុងរវាងពាក់កណ្តាល ដំបូងនៃអាយុរបស់ភូមិនោះ ។

២. ***ឧបហច្ចបរិនិព្វាយី*** បានដល់ ព្រះអនាគាមីដែលបដិសន្ធិក្នុងសុទ្ធាវាសភូមិ ណាមួយ ហើយបរិនិព្វានក្នុងកាលក្រោយពីពាក់កណ្តាលនៃអាយុក្ខ័យរបស់ភូមិនោះ ។

៣. ***អសង្ខារបរិនិព្វាយី*** បានដល់ ព្រះអនាគាមីដែលបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយ ហើយសម្រេចអរហត្ត

បរិនិព្វានដោយសប្បាយ មិនត្រូវព្យាយាមច្រើន ។

៤. **សសង្ខារបរិនិព្វាយី** បានដល់ ព្រះអនាគាមីដែលបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយ ហើយសម្រេចអរហត្តបានដោយលំបាក ត្រូវព្យាយាមច្រើន ទើបបរិនិព្វានក្នុងទីនោះ ។

៥. **ឧទ្ធំសោតោអកនិដ្ឋគាមី** បានដល់ ព្រះអនាគាមីដែលបដិសន្ធិតាំងពីសុទ្ធាវាសភូមិជាន់ទាប គឺ អវិហា (មានអាយុក្ខ័យ ១.០០០ មហាកប្ប) ចុតិហើយបដិសន្ធិក្នុងអតប្បា (មានអាយុក្ខ័យ២.០០០មហាកប្ប) ចុតិហើយបដិសន្ធិក្នុងសុទស្សាភូមិ (មានអាយុក្ខ័យ ៤.០០០ មហាកប្ប) ចុតិហើយ បដិសន្ធិក្នុងសុទស្សីភូមិ (មានអាយុក្ខ័យ ៨.០០០ មហាកប្ប) ចុតិហើយបដិសន្ធិក្នុងអកនិដ្ឋភូមិ (មានអាយុក្ខ័យ ១៦.០០០ មហាកប្ប) គ្រប់ ៣១.០០០ មហាកប្បទើបបរិនិព្វាន ។

## ព្រះអរហន្ត ២ ប្រភេទ

១. ព្រះអរហន្តដែលសម្រេចដោយបញ្ញាវិមុត្ត

២. ព្រះអរហន្តដែលសម្រេចដោយចេតោវិមុត្ត

ព្រះអរហន្តដែលជាបញ្ញាវិមុត្ត មិនមានឈាន ចំណែកព្រះអរហន្ត ដែលជាចេតោវិមុត្ត មានឈាន, ពួកខ្លះបានវិជ្ជា ៣ គឺ បុព្វេនិវាសញ្ញាណ ចុតូបបាតញ្ញាណ និងអាសវក្ខយញ្ញាណ, ពួកខ្លះបានអភិញ្ញា ៦ គឺ ឥទ្ធិវិធ (សម្ដែងឫទ្ធិបាន) ទិព្វសោត(ត្រចៀកទិព្វ) ចេតោបរិយញ្ញាណ(កំណត់ដឹងចិត្តអ្នកដទៃបាន) និងវិជ្ជា ៣ មានបុព្វេនិវាសញ្ញាណជាដើម ។ មួយប្រភេទទៀត លោកដែលបានបដិសម្ភិទា ៤ ហៅថា បដិសម្ភិទប្បត្តោ, លោកដែលមិនបានបដិសម្ភិទា ៤ ហៅថា អប្បដិសម្ភិទប្បត្តោ ។

**លោកុត្តរចិត្ត ចប់**

## សង្គហគាថា

១១. ទ្វាទសាកុសលានេវ កុសលានេកវីសតិ
ឆត្តឹសេវ វិបាកានិ ក្រិយាចិត្តានិ វីសតិ ។

*អកុសលចិត្ត ១២ កុសលចិត្ត ២១ វិបាកចិត្ត ៣៦ និងកិរិយា ២០ ។*

### គាថានេះ សម្តែងដោយជាតិ ៤ គឺ

| | | | |
|---|---|---|---|
| ១. | អកុសលចិត្ត | ១២ | ជាអកុសលជាតិ |
| ២. | កុសលចិត្ត | ២១ ឬ ៣៧ | ជាកុសលជាតិ |
| ៣. | វិបាកចិត្ត | ៣៦ ឬ ៥២ | ជាវិបាកជាតិ |
| ៤. | កិរិយាចិត្ត | ២០ | ជាកិរិយាជាតិ |

## សង្គហគាថា

១២. ចតុបញ្ញាសធា កាមេ រូបេ បណ្ណរសីរិយេ
ចិត្តានិ ទ្វាទសារូបេ អដ្ឋធានុត្តរេ តថា ។

*បណ្ឌិតពោលចិត្តក្នុងកាមភូមិ ៥៤ ចិត្តក្នុងរូបភូមិ*

១៥ ចិត្តក្នុងអរូបភូមិ ១២ និងអនុត្តរចិត្ត ៨ ។

គាថានេះ សម្តែងដោយភូមិ ៤ គឺ

១. កាមាវចរ ៥៤ ជាកាមភូមិ

២. រូបាវចរចិត្ត ១៥ ជារូបាវចរភូមិ

៣. អរូបាវចរចិត្ត ១២ ជាអរូបាវចរភូមិ

៤. លោកុត្តរចិត្ត ៨ ឬ ៤០ ជាលោកុត្តរចិត្តភូមិ

## សង្គហគាថា

១៣. ឥត្ថមេកូននវុតិ ប្បភេទំ បន មានសំ

ឯកវីសសតំ វាថ វិភជ្ជន្តិ វិចក្ខណា ។

បណ្ឌិតដែលមានបញ្ញា ឃើញច្បាស់ រមែងចែកមានសៈ (ចិត្ត) ក្នុងទីនេះ ចេញជាចិត្ត ៨៩ ឬ ១២១ ។

គាថានេះ សម្តែងចិត្តទាំងអស់ ដោយសោភណន័យ

ដោយលោកភេទន័យ ដោយហេតុភេទន័យ និងដោយឈាន ភេទន័យ ។

១. **ដោយសោភណន័យ** គឺ អកុសលចិត្ត ១២ អហេតុកចិត្ត ១៨ រួម ៣០ ជាអសោភណចិត្ត, កាមាវចរ សោភណចិត្ត ២៤ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨ រួម ជា ៥៩ ជាសោភណចិត្ត ។

២. **ដោយលោកភេទន័យ** គឺ កាមាវចរ ៥៤ រូបាវចរ ចិត្ត ១៥ អរូបាវចរចិត្ត ១២ រួម ៨១ ជាលោកិយចិត្ត, ចិត្ត ៨ ជាលោកុត្តរចិត្ត ។

៣. **ដោយហេតុភេទន័យ** គឺ ចិត្តទាំងអស់ ជានហេតុ ម្យ៉ាងទៀត ដោយជាអហេតុកចិត្ត១៨ និងសហេតុកចិត្ត៧១ ។

ចិត្តដែលមិនមានហេតុប្រកប ១៨ ហៅថា អហេតុក ចិត្ត, សហេតុកចិត្ត ៧១ មាន ៣ ប្រភេទ គឺ

**ឯកហេតុកចិត្ត** ចិត្តដែលមានហេតុមួយប្រកប មាន ២

គឺ មោហមូលចិត្ត ២

**ទ្វិហេតុកចិត្ត** ចិត្តដែលមានហេតុពីរប្រកប មាន ២២ គឺ លោភមូលចិត្ត ៨ ទោសមូលចិត្ត ២ មហាកុសលចិត្ត មហាវិបាកចិត្ត មហាកិរិយាចិត្ត ជាញាណវិប្បយុត្ត ១២ ។

តិហេតុកចិត្ត ចិត្តដែលមានហេតុបីប្រកប មាន ៤៧ គឺ មហាកុសល. មហាវិបាក. មហាកិរិយាជាញាណសម្បយុត្ត ១២ រូបាវចរចិត្ត១៥ អរូបាវចរចិត្ត១២ លោកុត្តរចិត្ត៨ ។

**៤. ដោយឈានភេទន័យ** គឺ រូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ រួម ២៧ ហៅថា ឈានចិត្ត, អកុសលចិត្ត ១២ អហេតុកចិត្ត ១៨ កាមាវចរសោភណចិត្ត ២៤ លោកុត្តរចិត្ត ៨ ហៅថា អឈានចិត្ត ។

**<u>ក្នុងដីកាវិភាវិនី</u>** លោកពោលចិត្ត ១២១ ទុកថា **កថមេកូនវុតិវិធំ ចិត្តំ ឯកវីសតំ ហោតិ ។ បេ ។ លោកុត្តរចិត្តានិ ភវន្តិ** ចិត្ត ៨៩ ជាចិត្ត ១២១ យ៉ាងនេះគឺ

-បឋមជ្ឈាន សោតាបត្តិមគ្គចិត្ត ១

-ទុតិយជ្ឈាន សោតាបត្តិមគ្គចិត្ត ១

-តតិយជ្ឈាន សោតាបត្តិមគ្គចិត្ត ១

-ចតុត្ថជ្ឈាន សោតាបត្តិមគ្គចិត្ត ១

-បញ្ចមជ្ឈាន សោតាបត្តិមគ្គចិត្ត ១

សកទាគាមិមគ្គចិត្ត អនាគាមិមគ្គចិត្ត អរហត្តមគ្គចិត្ត ក៏មាន ៥ ៗ ដូចគ្នា ។ មគ្គចិត្ត ២០ និងផលចិត្ត ២០ រួមជា ៤០ ( លោកុត្តរចិត្ត ៤០ + លោកិយចិត្ត ៨១ = ចិត្ត ១២១ )

## សង្គហគាថា

## សម្តែងលោកុត្តរចិត្ត ៤០ ដោយអង្គឈាន

១៤. ឈានង្គយោគភេទេន កត្វេកេកន្តុ បញ្ចធា
វុច្ចតានុត្តរំ ចិត្តំ ចត្តាឡីសវិធន្តិ ច ។

បណ្ឌិតធ្វើលោកុត្តរចិត្តមួយ ៗ ជា ៥ យ៉ាង ដោយសេចក្តីផ្សេងគ្នា នៃការប្រកបដោយអង្គឈានហើយ ពោលថា លោកុត្តរចិត្ត ៤០ ។

## សង្គហគាថា

### សម្តែងលោកុត្តរចិត្ត ដោយរូបជ្ឈាន និងអរូបជ្ឈាន

១៥. យថា ច រូបាវចរំ    គយ្ហតានុត្តរំ តថា
បឋមាទិជ្ឈានភេទេ    អារុប្បញ្ចាបិ បញ្ចមេ ។

រូបាវចរចិត្ត ក្នុងប្រភេទនៃឈាន មានបឋមជ្ឈានជាដើម យ៉ាងណា លោកុត្តរចិត្ត ក៏យ៉ាងនោះ សូម្បីអរូបជ្ឈាន ក៏សង្គ្រោះចូលក្នុងបញ្ចមជ្ឈាន ។

## សង្គហគាថា

### សម្តែងឈានចិត្ត រួមនឹងលោកុត្តរចិត្ត

១៦. ឯកាទសវិធំ តស្មា    បឋមាទិកមីរិតំ
ឈានមេកេកមន្តេ តុ    តេវីសតិវិធំ ភវេ ។

ព្រោះហេតុនោះ ឈានចិត្តមួយ ៗ ដែលលោកហៅថា បឋមជ្ឈានជាដើម ទើបមាន១១ ចំណែកឈានចិត្ត ខាងចុង(បញ្ចមជ្ឈាន) មានចិត្ត ២៣ ។

**ឈានចិត្ត ៦៧ គឺ**

-បឋមជ្ឈានចិត្ត១១ គឺ លោកិយចិត្ត៣ លោកុត្តរចិត្ត៨
-ទុតិយជ្ឈានចិត្ត១១ គឺ លោកិយចិត្ត៣ លោកុត្តរចិត្ត៨
-តតិយជ្ឈានចិត្ត១១ គឺ លោកិយចិត្ត៣ លោកុត្តរចិត្ត៨
-ចតុត្ថជ្ឈានចិត្ត១១ គឺ លោកិយចិត្ត៣ លោកុត្តរចិត្ត៨
-បញ្ចមជ្ឈានចិត្ត២៣ គឺ លោកិយចិត្ត១៥ លោកុត្តរចិត្ត៨

**សង្គហគាថា**

*ចែកចិត្ត ដោយពិស្តារ ១២១*

១៧. សត្តតឹសវិធំ បុញ្ញំ ទ្វិបញ្ញាសវិធន្តថា
ធាកមិច្ចាហុ ចិត្តានិ ឯកវីសសតម្ពុធា ។

*កុសលចិត្ត ៣៧ វិបាកចិត្ត ៥២ (រួមនឹងអកុសល*

**ចិត្ត ១២ កិរិយាចិត្ត ២០) បណ្ឌិតគប្បីពោល ដោយពិស្តារថា មាន ១២១ ។**

គាថានេះសម្តែងចិត្តដោយពិស្តារ ចំណែកក្នុងគាថាទី ១១ លោកសម្តែងកុសលចិត្ត ២១ វិបាកចិត្ត ៣៦ ជាការសម្តែងចិត្ត ៨៩ ដោយសង្ខេប, តែក្នុងគាថាទី ១៧ នេះ ជាការសម្តែងចំនួនចិត្ត ១២១ ដោយពិស្តារ ។

## កុសលចិត្តដោយពិស្តារ ៣៧

កាមាវចរកុសលចិត្ត ៨ មហគ្គតកុសលចិត្ត ៩ លោកុត្តរកុសលចិត្ត ២០ រួមជាកុសលចិត្ត ៣៧ ។

## វិបាកចិត្តដោយពិស្តារ មាន ៥២

អកុសលវិបាកចិត្ត ៧ អហេតុកកុសលវិបាកចិត្ត ៨ មហាវិបាកចិត្ត ៨ មហគ្គតវិបាកចិត្ត ៩ លោកុត្តរវិបាកចិត្ត ២០ រួមជាវិបាកចិត្ត ៥២ ។

## ចែកចិត្ត ១២១ ដោយន័យផ្សេង ៗ គឺ

១. ដោយជាតិ អកុសលចិត្ត ១២ ជាអកុសលជាតិ
កុសលចិត្ត ៣៧ ជាកុសលជាតិ
វិបាកចិត្ត ៥២ ជាវិបាកជាតិ
កិរិយាចិត្ត ២០ ជាកិរិយាជាតិ

២. ដោយភូមិ កាមាវចរចិត្ត ៥៤ ជាកាមភូមិ
រូបាវចរចិត្ត ១៥ ជារូបាវចរភូមិ
អរូបាវចរចិត្ត ១២ ជាអរូបាវចរភូមិ
លោកុត្តរចិត្ត ៤០ ជាលោកុត្តរភូមិ

៣. ដោយវេទនា សុខសហគតចិត្ត ១ ជាសុខវេទនា,
ទុក្ខសហគតចិត្ត ១ ជាទុក្ខវេទនា
សោមនស្សសហគតចិត្ត ៦២ ជាសោមនស្សវេទនា
ទោមនស្សសហគតចិត្ត ២ ជាទោមនស្សវេទនា
ឧបេក្ខាសហគតចិត្ត ៥៥ ជាឧបេក្ខាវេទនា

៤. **ដោយហេតុ** ជានហេតុ ចិត្តដែលអត់ហេតុ ១៨ ជាអហេតុកចិត្ត

ចិត្តដែលមានហេតុប្រកប ១០៣ ជាសហេតុកចិត្ត

៥. **ដោយសម្បយុត្ត** សម្បយុត្តចិត្ត ៨៧ គឺ ជាញាណសម្បយុត្ត៧៩ ជាអកុសលសម្បយុត្ត៨;

វិប្បយុត្តចិត្ត៣៤ គឺ ជាទិដ្ឋិវិប្បយុត្ត៤ អហេតុក១៨ និងញាណវិប្បយុត្ត ១២

៦. **ដោយសង្ខារ** ជាអសង្ខារិក ៣៧ ជាសសង្ខារិក ៨៤

៧. **ដោយសោភណៈ** ជាអសោភណ៣០ ជាសោភណ៩១

៨. **ដោយឈាន** ចិត្តដែលមិនមែនជាមហគ្គត (កាមចិត្ត) ៥៤ ជាអឈានចិត្ត, ចិត្តដែលជាមហគ្គត ៦៧ ជាឈានចិត្ត

៩. **ដោយលោក** ជាលោកិយចិត្ត៨១ ជាលោកុត្តរចិត្ត៤០

១០. **ដោយកិច្ច** ធ្វើកិច្ចបាន ១៤ កិច្ច

១១. **ដោយអារម្មណ៍** មានអារម្មណ៍ ៦

១២. **ដោយទ្វារ** អាស្រ័យទ្វារ៦ និងទ្វារវិមុត្តិ (កាលជា ចិត្ត បដិសន្ធិ ភវង្គ ចុតិ)

១៣. **ដោយវត្ថុ** កើតត្រង់វត្ថុទាំង ៦

១៤. **ដោយវិញ្ញាណធាតុ** ជាវិញ្ញាណធាតុ ៧ ។

## សេចក្ដីសំដៅរបស់ភូមិ ២ ន័យ

ពាក្យថា ភូមិ សំដៅដល់ ថ្នាក់របស់ចិត្ត១ ស្ថានទី១

១. ភូមិដែលសំដៅដល់ជាន់ ឬថ្នាក់ មាន ៤ គឺ

កាមាវចរភូមិ ឬហៅថា កាមាវចរចិត្ត

រូបាវចរភូមិ ឬហៅថា រូបាវចរចិត្ត

អរូបាវចរភូមិ ឬហៅថា អរូបាវចរចិត្ត

លោកុត្តរភូមិ ឬហៅថា លោកុត្តរចិត្ត

២. ភូមិដែលសំដៅដល់ស្ថានទីកើត មាន៣១ភូមិ គឺ

កាមភូមិ១១ ស្ថាន រូបភូមិ១៦ ស្ថាន អរូបភូមិ ៤ ស្ថាន

រួមចិត្តទាំងអស់ដែលជាភូមិទាំង២ន័យ បាន៣ប្រភេទ ហៅថា វត្ថានភូមិ១ អវត្ថានភូមិ១ វត្ថានាវត្ថានភូមិ១ ។

**វត្ថានភូមិ** បានដល់ ចិត្តដែលកើតជាប្រចាំតាមភូមិរបស់ខ្លួន មិនកើតក្នុងភូមិដទៃ

**អវត្ថានភូមិ** បានដល់ ចិត្តដែលកើតឡើង ដោយមិនមានភូមិរបស់ខ្លួន ។

**វត្ថានាវត្ថានភូមិ** បានដល់ ចិត្តដែលកើតឡើងក្នុងភូមិរបស់ខ្លួន និងកើតក្នុងភូមិដទៃទៀត

១. វត្ថានភូមិ បានចិត្ត ២៥ គឺ

| | | | |
|---|---|---|---|
| -ឃានវិញ្ញាណ | ២ | កើតក្នុងកាមភូមិ | ធ្វើឃាយនកិច្ច |
| -ជិវ្ហាវិញ្ញាណ | ២ | កើតក្នុងកាមភូមិ | ធ្វើសាយនកិច្ច |
| -កាយវិញ្ញាណ | ២ | កើតក្នុងកាមភូមិ | ធ្វើផុស្សនកិច្ច |
| -ទោសមូលចិត្ត | ២ | កើតក្នុងកាមភូមិ | ធ្វើជវនកិច្ច |
| -មហាវិបាកចិត្ត | ៨ | កើតក្នុងកាមភូមិ | ធ្វើកិច្ច ៤ យ៉ាង |

-រូបាវចរវិបាកចិត្ត ៥ កើតក្នុងរូបភូមិ ធ្វើកិច្ច ៣ យ៉ាង

-អរូបាវចរវិបាកចិត្ត ៤ កើតក្នុងអរូបភូមិ ធ្វើកិច្ច ៣ យ៉ាង

២. អវត្ថានភូមិ ចិត្តដែលមិនមានភូមិរបស់ខ្លួន គឺ លោកុត្តរចិត្ត ៨ ព្រោះជាចិត្តដែលផុតចាកលោក

៣. វត្ថានាវត្ថានភូមិ ចិត្តដែលមានភូមិច្រើន គឺ

| | | |
|---|---|---|
| -ចក្ខុវិញ្ញាណ | ២ | កើតក្នុងកាមភូមិ និង រូបភូមិ |
| -សោតវិញ្ញាណ | ២ | |
| -វិបាកមនោធាតុ | ២ | |
| -អហេតុកវិបាកមនោវិញ្ញាណធាតុ | ៣ | |
| -បញ្ចទ្វារាវជ្ជនចិត្ត | ១ | |
| -ហសិតុប្បាទចិត្ត | ១ | |
| -រូបាវចរកុសលចិត្ត | ៥ | |
| -រូបាវចរកិរិយាចិត្ត | ៥ | |

| | | |
|---|---|---|
| -លោភមូលចិត្ត | ៨ | កើតក្នុងកាមភូមិ រូបភូមិ អរូបភូមិ |
| -មោហមូលចិត្ត | ២ | |
| -មនោទ្វារាវជ្ជនចិត្ត | ១ | |
| -មហាកុសលចិត្ត | ៨ | |
| -មហាកិរិយាចិត្ត | ៨ | |
| -អរូបាវចរកុសលចិត្ត | ៤ | |
| -អរូបាវចរកិរិយាចិត្ត | ៤ | |

ចិត្ត ៨៩ ឬ ១២១ នេះ ដែលចែកដោយន័យផ្សេង ៗ មានដោយជាតិជាដើម តាមដែលបានចែកទុកហើយនោះ ដើម្បីសម្តែងឱ្យដឹងចិត្តមួយប្រភេទ ៗ ដោយជាអកុសលចិត្តខ្លះ អហេតុកចិត្តខ្លះ មហាកុសលចិត្តខ្លះ មហាវិបាកចិត្តខ្លះ មហាកិរិយាចិត្តខ្លះ មហគ្គតចិត្តខ្លះ លោកុត្តរចិត្តខ្លះ ក្នុងទីនេះ សំដៅដល់ស្ថានទី គឺ រូបជាទីធ្លាក់ចុះរបស់ចិត្ត ៣ ប្រភេទ ដែលហៅថា វត្ថានភូមិ អវត្ថានភូមិ និងវត្ថានាវត្ថានភូមិ ដើម្បីឱ្យជ្រាបថា ចិត្តបរមត្ថនេះ មានសេចក្តីវិចិត្រក្រៃលែងណាស់ ។

## សម្តែងសរុប ចិត្តបរមត្ថ ១២១

- កាមាវចរចិត្ត៥៤
  - អសោភណចិត្ត ៣០
    - អកុសលចិត្ត១២
      - លោភមូលចិត្ត ៨
      - ទោសមូលចិត្ត ២
      - មោហមូលចិត្ត ២
    - អហេតុកចិត្ត១៨
      - អកុសលវិបាកចិត្ត ៧
      - អហេតុកកុសលវិបាកចិត្ត៨
      - អហេតុកកិរិយាចិត្ត ៣
  - កាមាវចរសោភណចិត្ត២៤
    - មហាកុសលចិត្ត ៨
    - មហាវិបាកចិត្ត ៨
    - មហាកិរិយាចិត្ត ៨

- រូបាវចរសោភណចិត្ត ១៥
  - រូបាវចរកុសលចិត្ត ៥
  - រូបាវចរវិបាកចិត្ត ៥
  - រូបាវចរកិរិយាចិត្ត ៥

អរូបាវចរសោភណចិត្ត ១២
- អរូបាវចរកុសលចិត្ត ៤
- អរូបាវចរវិបាកចិត្ត ៤
- អរូបាវចរកិរិយាចិត្ត ៤

លោកុត្តរសោភណចិត្ត ៤០
- មគ្គចិត្ត ២០
  - សោតាបត្តិមគ្គចិត្ត ៥
  - សកទាគាមិមគ្គចិត្ត ៥
  - អនាគាមិមគ្គចិត្ត ៥
  - អរហត្តមគ្គចិត្ត ៥
- ផលចិត្ត ២០
  - សោតាបត្តិផលចិត្ត ៥
  - សកទាគាមិផលចិត្ត ៥
  - អនាគាមិផលចិត្ត ៥
  - អរហត្តផលចិត្ត ៥

## អវសានគាថា

ឥច្ចានុរុទ្ធរចិតេ អភិធម្មត្ថសង្គហេ
បឋមោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ ។

*បរិច្ឆេទទី ១ ឈ្មោះថា ចិត្តសង្គហវិភាគ ក្នុងបករណ៍ រួបរួមអត្ថនៃព្រះអភិធម្ម (អភិធម្មត្ថសង្គហៈ) ដែលព្រះអនុរុទ្ធាចារ្យ រចនាទុកដោយសង្ខេប ចប់ហើយ ដោយប្រការដូច្នេះឯង ។*

**បរិច្ឆេទទី ១ ចិត្តសង្គហវិភាគ ចប់**

យំ ឯត្ថ វុឌ្ឍិមន្តោ សលក្ខណា បូជិតា បរិច្ឆិន្នា
វុត្តាធិកា ច ធម្មា អភិធម្មោ តេន អក្ខាតោ ។
ព្រោះហេតុដែលធម៌ទាំងឡាយ មានសេចក្ដីចម្រើន
មានការកំណត់ ជាធម៌ដែលបុគ្គលបូជាហើយ ជាធម៌
ដែលបណ្ឌិតកាត់ជាចំណែកៗ និងជាធម៌ដ៏ក្រៃលែង
ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ក្នុងព្រះ
អភិធម្មនេះ ដូច្នោះ ទើបលោកពោលថា អភិធម្ម ។



**ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**